**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royal de Droit et des Sciences Economiques

Royal University of Law and Economics


## សារណាបញ្ចប់ការសិក្សា

# សិទ្ធិលើការបញ្ចាំ

ស្រាវជ្រាវពីថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០២១ ដល់ ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០២១


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **យុន ចាន់នឿន**

**ក. លឹម សូនី**

សាស្ត្រាចារ្យណែនាំ

**បណ្ឌិត ញឹក ខុឆ្ធី**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំទាំងពីរនាក់ដែលមានឈ្មោះ **ឃុន ចាន់ធឿន** និងឈ្មោះ **លឹម សូនី** ជានិស្សិតបរិញ្ញាបត្រនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

សូមគោរពថ្លែងអំណរគុណ និងការដឹងគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ៖

**លោកឪពុក និងអ្នកម្តាយ**៖ ដែលលោកអ្នកមានគុណទាំងពីរបានផ្តល់កំណើតដល់យើងខ្ញុំទាំងពីរ ព្រមទាំងខិតខំចិញ្ចឹមបីបាច់ថែរក្សាកូនតាំងពីតូចរហូតដល់ធំដឹងក្តី ហើយថែមទាំងបានផ្គត់ផ្គង់ទំនុកបម្រុងកូនៗសព្វបែបយ៉ាង ដោយលោកហ៊ានតស៊ូពុះពារគ្រប់ការលំបាកទាំងឡាយ ហាលភ្លៀង ហាលក្តៅដោយមិនពោលពាក្យថា នឿយហត់ លំបាកមកកាន់កូនៗ ក្នុងគោលបំណងដើម្បីរកប្រាក់ឲ្យកូនៗបានសិក្សារៀនសូត្រចេះដឹង ស្គាល់អ្វីដែលជាគុណ ជាទោស ស្គាល់ពីតម្លៃនៃគុណធម៌ សីលធម៌ ជាពិសេស គឺស្គាល់ពីអ្វីដែលជាតម្លៃនៃការសិក្សានេះ ដើម្បីឲ្យកូនៗបានក្លាយជាបុគ្គលដែលពោរពេញទៅដោយព្រហ្មវិហារធម៌នៅក្នុងគ្រួសារ សាលារៀន និងនៅក្នុងសង្គម។

**ថ្នាក់ដឹកនាំសាកលវិទ្យាល័យ ព្រមទាំងលោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យទាំងអស់**៖ ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ដោយបានខិតខំយកចិត្តទុកដាក់ក្នុងការបណ្តុះបណ្តាល ដើម្បីផ្តល់នូវចំណេះដឹងដែលជាពុទ្ធិថ្មីៗ ក៏ដូចជាបទពិសោធន៍នានា ដើម្បីឲ្យសិស្សនិស្សិតអាចយកមកធ្វើជាគុណប្រយោជន៍ដល់ការប្រកបកិច្ចទាំងឡាយនាថ្ងៃមុខបាន។

**លោកសាស្ត្រាចារ្យ បណ្ឌិត ញឹក ឧត្តី** ៖ ដែលលោកបានចំណាយពេលវេលាដ៏មានតម្លៃរបស់លោក ដោយបានខិតខំបង្រៀនយ៉ាងយកចិត្តទុកដាក់ អស់ពីកម្លាំងកាយ ចិត្ត ព្រមទាំងធ្វើការណែនាំ និងចង្អុលបង្ហាញផ្លូវដែលជាគន្លឹះដ៏សំខាន់ក្នុងការទទួលបានភាពជោគជ័យទាំងក្នុងការសិក្សា និងក្នុងការបំពេញកិច្ចការសំខាន់ៗផ្សេងទៀត។ អ្វីដែលពិសេសទៀតនោះគឺ លោកបានបង្រៀនណែនាំដល់យើងខ្ញុំទាំងពីរ ក្នុងការសរសេរតាក់តែងនូវកម្រងស្នាដៃជាសារណាមួយនេះឡើង ក្នុងគោលដៅបង្កើតបានជាសមិទ្ធិផលមួយដ៏ល្អប្រសើរជាទីបំផុត ពោលគឺ ជាសមិទ្ធិផលដែលប្រកបទៅដោយគុណភាពពេញលេញ និងភាពជោគជ័យ។

**ជាចុងក្រោយយើងខ្ញុំ** សូមគោរពជូនពរដល់ លោកអ្នកមានគុណទាំងពីរ គឺលោកឪពុក និងអ្នកម្តាយ លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ លោកសាកលវិទ្យាធិការ លោក លោកស្រី រួមទាំងមិត្តនិស្សិតរួមសាលាទាំងអស់ សូមជួបប្រទះតែសំណាងល្អ ទទួលបានជោគជ័យគ្រប់ភារកិច្ចទាំងឡាយ និងជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈកុំបីឃ្លៀងឃ្លាតឡើយ។

# **អារម្ភកថា**

សារណាដែលត្រូវបានរៀបចំតាក់តែងឡើងស្តីពី **សិទ្ធិលើការបញ្ចាំ** គឺជាអត្ថបទមួយដែលក្រុមរបស់យើងខ្ញុំ បានចងក្រងឡើងចេញពីការខិតខំប្រឹងប្រែងសិក្សារៀនសូត្រ បន្ទាប់ពីបានសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្រ្តរយៈពេល ៤ឆ្នាំ កន្លងមកនេះ ព្រមទាំងការបង្ហាត់បង្រៀន និងការពន្យល់ណែនាំពីសំណាក់លោកលោកស្រីសាស្រ្តាចារ្យទាំងអស់ផងដែរ។ មូលហេតុដែលយើងខ្ញុំទាំងពីរនាក់បានសម្រេចចិត្តជ្រើសរើសយកប្រធានបទនេះ មកសរសេរតាក់តែងឡើង ដោយសារតែយើងខ្ញុំមានការចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើមុខវិជ្ជានីតិរដ្ឋប្បវេណី ចាប់តាំងតែពីបានសិក្សាឆ្នាំទី២មកម្ល៉េះ។ លើសពីនេះទៅទៀត សិទ្ធិលើការបញ្ចាំ គឺពិតជាមានសារៈសំខាន់ និងមានអត្ថប្រយោជន៍សម្រាប់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងសកម្មភាពជំនួញនានាយ៉ាងខ្លាំង ដែលជាមូលហេតុមួយនៃការពន្លឿនដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ចគ្រួសារ និងសេដ្ឋកិច្ចជាតិឱ្យមានភាពរីកចម្រើនផងដែរ។

**សិទ្ធិលើការបញ្ចាំ** គឺស្ថិតនៅក្នុង ប្រាតិភោគប្រត្យក្សមួយប្រភេទ នៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាយើង ហើយសិទ្ធិលើការបញ្ចាំនេះទៀតសោត បានផ្តល់អត្ថប្រយោជន៍ជាច្រើនទៅដល់ម្ចាស់បំណុល និងកូនបំណុលផងដែរ។ ទោះបីជាសិទ្ធិលើការបញ្ចាំ ត្រូវបានចែងកំណត់នៅក្នុងក្រមរដ្ឋប្បវេណី និងបទដ្ឋានគតិយុត្តនានាយ៉ាងជាក់ច្បាស់ក្តី ក៏ឥទ្ធិពលនៃការយល់ដឹងទាក់ទងនឹងសិទ្ធិលើការបញ្ចាំនេះហាក់បីដូចជា មិនទាន់បានជ្រួតជ្រាបទៅដល់មជ្ឈដ្ឋានប្រជាពលរដ្ឋបានពេញលក្ខណៈ និងទូលំទូលាយនៅឡើយទេ។ កត្តាទាំងអស់នេះហើយ ដែលធ្វើឲ្យក្រុមយើងខ្ញុំមានការចាប់អារម្មណ៍ទៅលើចំណុចដែលជាបញ្ហាចោទខាងលើយ៉ាងខ្លាំង រហូតដល់ក្រុមយើងខ្ញុំបានសម្រេចចិត្តថានឹងធ្វើការជ្រើសរើសយកប្រធានបទមួយនេះ យកមករៀបរៀងចងក្រងជាសារណាឡើង។ ហើយក្រុមយើងខ្ញុំសង្ឃឹម និងជឿជាក់យ៉ាងមុតមាំថា ឯកសារដែលក្រុមយើងខ្ញុំបានស្រាវជ្រាវនេះនឹងអាចឲ្យគ្រប់បុគ្គលទាំងអស់អាចយកទៅប្រើប្រាស់តាមតម្រូវការបាន ដើម្បីជាគុណប្រយោជន៍ ដែលអាចជួយឈានទៅបំពេញកង្វះខ្វះចន្លោះរបស់បុគ្គលដែលពាក់ព័ន្ធនឹងចំណុចទាំងអស់នោះផងដែរ។

ជាទីបញ្ចប់ ក្រុមយើងខ្ញុំក៏សូមខន្តីអភ័យទោសជាមុននូវរាល់កំហុសឆ្គងដែលកើតមានឡើងដោយអចេតនាទាំងកំហុសផ្នែកអក្ខរាវិរុទ្ធក្តី ក៏ដូចជាខ្លឹមសារដែលមានចំណុចខ្វះខាតដោយប្រការណាមួយដែលកើតមាននៅក្នុងការតាក់តែងនូវសារណានេះក្តី។ ហើយក្រុមយើងខ្ញុំ សូមទទួលយកនូវគ្រប់មតិរិះគន់ទាំងឡាយ ក្នុងអត្ថន័យស្ថាបនាកែលម្អទៅលើកិច្ចការសារណាមួយនេះដោយក្តីសោមនស្សរីករាយជាទីបំផុត។

**សូមអរគុណ**!

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ........ ១

១. បុព្វហេតុនៃការស្រាវជ្រាវ ........ ១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ២

៣. គោលបំណងនៃការស្រាវជ្រាវ ........ ៣

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ........ ៣

៥. សារៈសំខាន់នៃការស្រាវជ្រាវ ........ ៤

៦. វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ៥

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៦

## ជំពូកទី ១
## សញ្ញាណទូទៅនៃសិទ្ធិលើការបញ្ចាំ

**១. អត្ថន័យនៃសិទ្ធិលើការបញ្ចាំ** ........ ១

**២. ប្រភេទកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ** ........ ១

២.១ ចលនវត្ថុ ........ ២

២.២ អចលនវត្ថុ ........ ២

២.៣ សិទ្ធិលើបំណុល ........ ២

**៣. គោលការណ៍ទូទៅនៃការបង្កើតសិទ្ធិលើការបញ្ចាំ** ........ ២

៣.១.១ លក្ខខណ្ឌគ្រឹះ ........ ៣

៣.១.១.១ ការព្រមព្រៀងរបស់គូភាគី ........ ៤

៣.១.១.២ សមត្ថភាពរបស់គូភាគី ........ ៤

៣.១.១.៣ កម្មវត្ថុនៃកិច្ចសន្យា ........ ៥

៣.១.១.៣.១ កម្មវត្ថុមានពេលបច្ចុប្បន្ន ........ ៦

៣.១.១.៣.២ កម្មវត្ថុមាននៅពេលអនាគត ........ ៦

៣.១.១.៣.៣ កម្មវត្ថុដែលអាចធ្វើកើត ........ ៦

៣.១.២ លក្ខខណ្ឌទម្រង់ ........ ៦

**៤. អានុភាពនៃកិច្ចសន្យាបញ្ចាំ** ........ ៧

៤.១ កាតព្វកិច្ចក្នុងការអនុវត្តកិច្ចសន្យាបញ្ចាំ ........ ៧

៤.២ ទណ្ឌកម្មនៃការបំពានកិច្ចសន្យាបញ្ចាំ ........ ៨

**៥. សិទ្ធិរបស់ម្ចាស់បំណុលនៃកិច្ចសន្យាបញ្ចាំ** ........ ៨

៥.១ សិទ្ធិកាន់កាប់វត្ថុបញ្ចាំ ........ ៨

៥.២ សិទ្ធិឃាត់ទុកវត្ថុបញ្ចាំ ........ ៨

៥.៣ សិទ្ធិទាមទារឲ្យសងសោហ៊ុយរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ ........ ៨

៥.៤ សិទ្ធិទាមទារសំណងរបស់អ្នកធានាដោយវត្ថុ ........ ៩

៥.៥ សិទ្ធិហាមឃាត់ការកាន់កាប់ដោយផ្ទាល់ ចំពោះអ្នកបង្កើតសិទ្ធិលើការបញ្ចាំ ........ ៩

**៦. ឧបាទេសកម្មលើវត្ថុ** ........ ៩

**៧. ការហាមឃាត់ចំពោះការបញ្ចាំផ្តាច់** ........ ១០


## ជំពូកទី ២
## ការបញ្ចាំចលនវត្ថុ


**១. អត្ថន័យនៃការបញ្ចាំចលនវត្ថុ** ........ ១១

**២. ការបង្កើតលក្ខខណ្ឌអានុភាពនៃសិទ្ធិលើការបញ្ចាំចលនវត្ថុ** ........ ១១

២.១ លក្ខខណ្ឌទម្រង់នៃការបង្កើតកិច្ចសន្យាបញ្ចាំចលនវត្ថុ ........ ១១

២.១.១ លិខិតឯកជន ........ ១១

២.១.២ ការផ្ទេរសិទ្ធិកាន់កាប់ចលនវត្ថុ ........ ១២

២.២ អានុភាពនៃការបញ្ចាំចលលនវត្ថុ ........ ១៣

២.៣ សិទ្ធិរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ ........ ១៣

**៣. ការបញ្ចាំបន្ត** ........ ១៤

**៤. ការហាមឃាត់ការបញ្ចាំផ្តាច់** ........ ១៤

**៥. ការអនុវត្តសិទ្ធិលើការបញ្ចាំចលនវត្ថុ** ........ ១៤

៥.១ ការលក់ដោយបង្ខំ ........ ១៤

៥.២ ការអនុវត្តសិទ្ធិលើការបញ្ចាំដោយសង្ខេប ........ ១៥


## ជំពូកទី ៣
## ការបញ្ចាំអចលនវត្ថុ


**១. អត្ថន័យនៃការបញ្ចាំអចលនវត្ថុ** ........ ១៦

**២. ការបង្កើតលក្ខខណ្ឌអានុភាពនៃសិទ្ធិលើកិច្ចសន្យាបញ្ចាំអចលនវត្ថុ** .... ១៦

២.១ លិខិតយថាភូត ........ ១៧

២.២ ការផ្ទេរសិទ្ធិកាន់កាប់អចលនវត្ថុ ........ ១៧

**៣. ការមិនអនុញ្ញាតឲ្យបញ្ចាំផ្តាច់** ........ ១៩

**៤. ការកំណត់រយៈពេលនៃការបញ្ចាំ**.......... ១៩
**៥. អានុភាពនៃសិទ្ធិលើកិច្ចសន្យាបញ្ចាំអចលនវត្ថុ**.......... ១៩
៥.១ ទំហំអានុភាពនៃសិទ្ធិលើការបញ្ចាំអចលនវត្ថុ.......... ១៩
៥.២ សិទ្ធិទាមទារសំណងរបស់អ្នកធានាដោយវត្ថុ..........២០
៥.៣ លំដាប់នៃការបញ្ចាំអចលនវត្ថុ..........២០
៥.៤ ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា..........២២
**៦. ការអនុវត្តកិច្ចសន្យាបញ្ចាំអចលវត្ថុ**..........២២
៦.១ សិទ្ធិ និងកាតព្វកិច្ចរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ..........២២
**៦.១.១ សិទ្ធិនៃម្ចាស់សិទ្ធិលើការបញ្ចាំ**..........២២
៦.១.១.១ សិទ្ធិប្រើប្រាស់ និងអាស្រ័យផល..........២២
៦.១.១.២ ការសន្យាពិសេសនៅក្នុងកិច្ចសន្យាបញ្ចាំអចលនវត្ថុ.......... ២៣
៦.១.១.៣ បទបញ្ញត្តិពិសេស ស្តីពីការធ្វើកសិកម្ម.......... ២៣
៦.១.១.៣.១ សិទ្ធិលើបំណុលដែលគ្មានកំណត់ពេល.......... ២៣
៦.១.១.៣.២ សិទ្ធិលើបំណុលដែលមានកំណត់ពេល.......... ២៣
៦.១.១.៤ សិទ្ធិបញ្ចាំបន្ត..........២៤
៦.១.១.៥ សិទ្ធិឃាត់ទុកអចលនវត្ថុបញ្ចាំ..........២៤
៦.១.១.៦ សិទ្ធិប្តឹងឲ្យលក់ដោយបង្ខំ..........២៤
**៦.១.២ កាតព្វកិច្ច**..........២៥
៦.១.២.១ ប្រគល់វត្ថុបញ្ចាំ..........២៥
៦.១.២.២ ថែរក្សា ឬចេញសោហ៊ុយ..........២៥
៦.២ សិទ្ធិ និងកាតព្វកិច្ចរបស់អ្នកបង្កើតសិទ្ធិលើការបញ្ចាំ..........២៦
**៦.២.១ សិទ្ធិទាមទារវត្ថុបញ្ចាំ និងសំណងខូចខាត**..........២៦
**៦.២.២ កាតព្វកិច្ចសងសំណង**..........២៦
**៧. ការរលត់សិទ្ធិនៃការបញ្ចាំអចលនវត្ថុ**..........២៦
៧.១ ការរលត់ដោយការទាមទារ..........២៦
៧.២ ការរលត់ដោយអាជ្ញាយុកាល.......... ២៧
៧.៣ ការរលត់ការបញ្ចាំអចលនវត្ថុដោយលទ្ធកម្មនូវការបញ្ចាំអចលនវត្ថុដោយអាជ្ញាយុ-កាល.......... ២៧
**៨. ការអនុវត្តដូចគ្នាតាមបទបញ្ញត្តិស្តីពីហ៊ីប៉ូតែក**..........២៨

# ជំពូកទី ៤
# ការបញ្ចាំសិទ្ធិ

**១. អត្ថន័យនៃការបញ្ចាំសិទ្ធិ** ........ ២៩
**២. ការបង្កើតសិទ្ធិលើការបញ្ចាំសិទ្ធិ** ........ ២៩
២.១ លក្ខខណ្ឌបង្កើតអានុភាពចំពោះកិច្ចសន្យាបញ្ចាំសិទ្ធិ ........ ២៩
២.១.១ ការព្រមព្រៀង........ ២៩
២.១.២ លក្ខខណ្ឌតតាំង........ ៣០
២.២ ការអនុវត្តនៃការបញ្ចាំសិទ្ធិ ........ ៣០
**៣. ការប្រៀបធៀប ការបញ្ចាំចលនវត្ថុ ការបញ្ចាំអចលនវត្ថុ និងការបញ្ចាំសិទ្ធិលើបំណុល** ........ ៣១
**សេចក្តីសន្និដ្ឋាន** ........ ៣២
**អនុសាសន៍** ........ ៣៣
**ឯកសារយោង** ........ ៣៧
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## ១. មូលហេតុនៃការស្រាវជ្រាវ

ការរស់នៅក្នុងសង្គមមួយតែងតែមានទំនាក់ទំនងរវាងគ្នា និងគ្នាជានិច្ច ដែលទំនាក់ទំនងនេះ មានលក្ខណៈជាទំនាក់ទំនងបុគ្គល និងទំនាក់ទំនងទ្រព្យសម្បត្តិ។ ទំនាក់ទំនងទ្រព្យសម្បត្តិ ត្រូវបានច្បាប់ទទួលស្គាល់យ៉ាងទូលំទូលាយ ក្រោមរូបភាពជាទំនាក់ទំនងដែលមានការធានា និងទំនាក់ទំនងដែលគ្មានការធានា ហើយសិទ្ធិដែលមានការធានាគេហៅថា **សិទ្ធិប្រាតិភោគប្រត្យក្ស** ដែលជាប្រភេទមួយនៃសិទ្ធិប្រត្យក្ស[1]។ សិទ្ធិប្រាតិភោគប្រត្យក្សនេះ ត្រូវបានគ្រប់គ្រងដោយនីតិប្រាតិភោគ ដែលជាយន្តការគតិយុត្តគ្រប់គ្រងទំនាក់ទំនងនៃសិទ្ធិប្រាតិភោគប្រត្យក្ស។ នៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានកំណត់ថា ជនណាក៏ដោយ ទោះជាបុគ្គលក្តី ជាសមូហភាពក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ ហើយកម្មសិទ្ធិឯកជនត្រូវស្ថិតក្រោមការគាំពារនៃច្បាប់[2]។ បញ្ញត្តិនេះ គឺជារបបគំហើញគតិយុត្តដែលទទួលស្គាល់លើទ្រព្យសម្បត្តិរបស់ឯកជនដែលធ្វើឲ្យមានទំនាក់ទំនងទ្រព្យសម្បត្តិនៅក្នុងសង្គម។

នៅពេលដែលបុគ្គលម្នាក់ ឬច្រើននាក់ ចង់ធានាកាតព្វកិច្ចទៅលើអ្វីមួយ បុគ្គលដែលបានបង្កើតសិទ្ធិប្រាតិភោគប្រត្យក្សលើទ្រព្យសម្បត្តិរបស់ខ្លួនដើម្បីធានាកាតព្វកិច្ចរបស់អ្នកដទៃ គេហៅថា អ្នកធានាដោយវត្ថុ ចំណែកឯបុគ្គលដែលបានធ្វើនូវលទ្ធកម្មនូវវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគប្រត្យក្ស ដែលបង្កើតឡើងដោយកូនបំណុល ដើម្បីធានាកាតព្វកិច្ចរបស់ខ្លួន ហៅថាតតិយជនដែលបានធ្វើលទ្ធកម្ម។ ជាគោលការណ៍ សិទ្ធិប្រាតិភោគប្រត្យក្សមិនអាចយកវត្ថុ ឬសិទ្ធិណាមួយដែលមិនអាចធ្វើអនុប្បទានបាន មកធ្វើជាកម្មវត្ថុបានឡើយ។ ប៉ុន្តែគោលការណ៍នេះ មិនប៉ះពាល់ដល់សិទ្ធិឃាត់ទុកលើវត្ថុដែលមិនអាចធ្វើអនុប្បទាននោះទេ។ ម្យ៉ាងវិញទៀត សិទ្ធិប្រាតិភោគប្រត្យក្ស ត្រូវបានបង្កើតឡើង ដើម្បីធានាកាតព្វកិច្ចដែលមានអត្ថិភាព ហើយទោះបីជាកាតព្វកិច្ចដែលនឹងកើតឡើងនាពេលអនាគតក៏ដោយ ក្នុងករណីដែលអាចកំណត់កាតព្វកិច្ចបាន ក៏សិទ្ធិប្រាតិភោគប្រត្យក្សនៅតែមានអត្ថិភាព ដោយយកកាតព្វកិច្ចនោះ មកធ្វើជាកាតព្វកិច្ចដែលត្រូវធានា។ ប៉ុន្តែប្រសិនបើខ្វះលក្ខខណ្ឌគតិយុត្ត សិទ្ធិប្រតិភោគប្រត្យក្សក៏មិនអាចកើតមានឡើងបានដែរ ឬនៅក្នុងករណីដែលសិទ្ធិលើបំណុលដែលត្រូវបានធានា ត្រូវបានចាត់ទុកជាមោឃៈ ដោយសារមានវិការៈក្នុងការបង្ហាញឆន្ទៈ ឬហេតុផ្សេងៗទៀតនោះ សិទ្ធិលើបំណុលដែលត្រូវបានធានាត្រូវបានលុបចោល នាំឲ្យសិទ្ធិប្រាតិភោគប្រត្យក្សមិនមានអានុភាព។ លើសពីនេះទៅទៀត ប្រសិនបើសិទ្ធិលើបំណុលដែលត្រូវបានធានាបានរលត់ដោយសារការសង ឬអាជ្ញាយុកាលនៃការរំលត់សិទ្ធិ ឬហេតុផ្សេងៗទៀត សិទ្ធិប្រាតិភោគប្រត្យក្សក៏ត្រូវបានរលត់ផងដែរ។

លើសពីនេះទៅទៀត សិទ្ធិលើការបញ្ចាំ គឺជាស្ថានភាពមួយដែលម្ចាស់បំណុលមានសិទ្ធិក្នុងការកាន់កាប់វត្ថុរបស់កូនបំណុល ឬតតិយជន ដោយរាប់បញ្ចូលទាំងសិទ្ធិ (ការបញ្ចាំសិទ្ធិ) ដើម្បីធានាសិទ្ធិលើបំណុលរបស់ខ្លួន និងទទួលបានការសងពីវត្ថុនោះដោយមានអត្ថិភាពជាងម្ចាស់បំណុលផ្សេងទៀត ដោយម្ចាស់សិទ្ធិលើការបញ្ចាំអាចធ្វើការឃាត់ទុកវត្ថុបញ្ចាំនោះបាន រហូតដល់ពេលទទួលបានការសង ដែលជាទូទៅត្រូវធានានូវ

[1] មាត្រា ១៣០ និង មាត្រា ១៣១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[2] មាត្រា ៤៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

ប្រាក់ដើម ការប្រាក់ ប្រាក់ធានាសងក្នុងករណីមិនអនុវត្តកាតព្វកិច្ច រីឯសោហ៊ុយដើម្បីអនុវត្តសិទ្ធិលើការបញ្ចាំ សោហ៊ុយដើម្បីថែរក្សាវត្ថុបញ្ចាំ ដោយរាប់បញ្ចូលទាំងសំណងខូចខាតដែលកើតឡើងដោយសារការមិនអនុវត្ត កាតព្វកិច្ច ឬវិការៈកំបាំងនៃវត្ថុបញ្ចាំ លើកលែងតែមានកំណត់ផ្សេងនៅក្នុងកិច្ចព្រមព្រៀងបង្កើតសិទ្ធិលើការបញ្ចាំ ហើយម្ចាស់សិទ្ធិលើការបញ្ចាំអាចទទួលផលពីវត្ថុបញ្ចាំ និងយកផលនោះមកកាត់សិទ្ធិលើបំណុលរបស់ខ្លួន បានដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀត។ ប៉ុន្តែម្ចាស់សិទ្ធិលើការបញ្ចាំមិនអាចយកវត្ថុបញ្ចាំទៅធ្វើ ការដាក់បញ្ចាំបន្តបានទេ លុះត្រាតែមានការយល់ព្រមពីកម្មសិទ្ធិករនៃវត្ថុបញ្ចាំ។ ចំពោះការយកវត្ថុបញ្ចាំទៅបញ្ចាំ បន្តនេះ ម្ចាស់បំណុលត្រូវទទួលសងនៅការខូចខាតទាំងឡាយដែលកើតមានលើវត្ថុបញ្ចាំ ទោះបីជាមានករណី ប្រធានសក្តិកើតឡើងក៏ដោយ។ យ៉ាងណាមិញ ម្ចាស់បំណុលមិនអាចធ្វើការបញ្ចាំផ្តាច់បានឡើយ ហើយនៅ ពេលដែលអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល នោះនាំឲ្យរលត់នូវសិទ្ធិលើការបញ្ចាំផងដែរ មានន័យថា ប្រសិនបើគ្មានសិទ្ធិលើបំណុល ក៏គ្មានសិទ្ធិលើការបញ្ចាំដែរ។

ដោយឡែក សម្រាប់សិទ្ធិលើការបញ្ចាំដែលជាប្រភេទមួយនៃសិទ្ធិប្រត្យក្សនេះ ក៏ជាយន្តការដែលត្រូវ បានគេនិយមប្រើជាញឹកញាប់នៅក្នុងសង្គមកម្ពុជាបច្ចុប្បន្ននេះ។ ប៉ុន្តែការអនុវត្តជាក់ស្តែង ហាក់មិនទាន់មាន ភាពត្រឹមត្រូវ និងច្បាស់លាស់ទៅតាមក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ ដែលជាបទដ្ឋានគតិយុត្តជាតិ ដែលបានចែង កំណត់នូវសិទ្ធិលើការបញ្ចាំនេះនៅឡើយទេ។

ដូច្នេះបុព្វហេតុដែលនាំឲ្យយើងខ្ញុំ ជ្រើសរើសនូវប្រធានបទមួយនេះមកធ្វើការសិក្សាស្រាវជ្រាវ គឺដើម្បី ទទួលបាននូវចំណេះដឹងបន្ថែមទៀត ដើម្បីអាចយកមកជាប្រយោជន៍ក្នុងការជួយបំពេញនៅចំណុចខ្វះចន្លោះ របស់គ្រប់បុគ្គលដែលជាអ្នកអនុវត្តនូវកិច្ចប្រភេទនេះ ហើយជាពិសេសដើម្បីស្វែងយល់អំពីសិទ្ធិ និងកាតព្វកិច្ច របស់គូភាគីនៅក្នុងកិច្ចសន្យាបញ្ចាំឲ្យកាន់តែច្បាស់លាស់ ព្រមទាំងអាចទទួលយកនូវពុទ្ធិដែលអាចផ្តល់ជាបទ ពិសោធន៍ល្អៗប្រៀបបានជាប្រទីបដែលអាចដឹកនាំយើងឲ្យក្លាយទៅជាបុគ្គលដែលមានភាពថ្លៃថ្នូរ អព្យាក្រឹត្យ មានសុចរិតភាព និងមានសមត្ថភាពក្នុងការអនុវត្តទៅតាមច្បាប់បានត្រឹមត្រូវនាពេលអនាគត។ កត្តាទាំងអស់ នេះហើយ ដែលញ៉ាំងឲ្យយើងខ្ញុំធ្វើការសម្រេចជ្រើសរើសយកប្រធានបទនេះឡើងមកបកស្រាយ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

យើងបានដឹងងហើយថា ចំពោះក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ដែលត្រូវបានគេកំណត់ហៅជាទូទៅថា ជា ច្បាប់សារធាតុនោះ គឺបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការការពារនូវផលប្រយោជន៍របស់បុគ្គលឯកជនទាំង អស់។ បើយើងនិយាយពី ការបង្កើតទំនាក់ទំនងសិទ្ធិ និងកាតព្វកិច្ចរបស់បុគ្គលដែលជាគូភាគី មិនថានៅពេល បង្កើតបានជាកិច្ចសន្យាបញ្ចាំដែលមានអានុភាពអនុវត្ត ឬ ពេលមានវិវាទកើតឡើងក្តី គឺច្បាប់សារធាតុ បានចែង កំណត់យ៉ាងច្បាស់លាស់ ដោយបានកំណត់ពីកិច្ចសំខាន់ៗរបស់គូភាគីដែលចាំបាច់ត្រូវតែអនុវត្តតាមនោះ។

ដូច្នេះ យើងគួរតែស្វែងយល់ថា៖

- តើសញ្ញាណទូទៅនៃសិទ្ធិលើការបញ្ចាំមានលក្ខណៈយ៉ាងដូចម្តេចខ្លះ?
- តើបង្កើតកិច្ចសន្យាបញ្ចាំត្រូវអនុលោមដោយគោរពទៅតាមលលក្ខខណ្ឌសំខាន់ៗអ្វីខ្លះ ទើបភាគីនៃកិច្ច សន្យាបញ្ចាំនេះ មានអានុភាពក្នុងការអនុវត្ត ក៏ដូចជាក្នុងការបង្កើតឲ្យមានសិទ្ធិ និងកាតព្វកិច្ចរបស់ពួក

ពួកគេកើតឡើងបាននោះ?

- តើច្បាប់សារធាតុបានចែងការពារផលប្រយោជន៍ដល់គូភាគីយ៉ាងណាខ្លះ នៅពេលមិនមានការអនុវត្ត កាតព្វកិច្ចរបស់កូនបំណុល ឬម្ចាស់បំណុលនៅក្នុងកិច្ចសន្យាបញ្ចាំ?
- តើច្បាប់សារធាតុបានផ្តល់នូវសិទ្ធិដែលមានលក្ខណៈពិសេសអ្វីខ្លះទៅដល់ម្ចាស់បំណុលក្រៅពីឯកសិទ្ធិ និងសិទ្ធិបុរិមា?

## ៣. គោលបំណងនៃការស្រាវជ្រាវ

រាល់ការសិក្សាស្រាវជ្រាវទាំងអស់ គឺសុទ្ធតែមានសារៈសំខាន់ទាំងអស់ ពោលគឺ បានផ្តល់ផលប្រយោជន៍តបមកវិញទៅតាមកិច្ចការដែលយើងបានធ្វើការស្រាវជ្រាវនោះ។ គោលបំណងនៃការសិក្សាស្រាវជ្រាវនេះនឹងឆ្លើយតបយ៉ាងជាក់លាក់មកវិញ ចំពោះការយកមកអនុវត្តជាក់ស្តែងផងដែរ។ យ៉ាងណាមិញ គោលបំណងសំខាន់ និងជាចម្បងដែលយើងខ្ញុំធ្វើការស្រាវជ្រាវទៅលើប្រធានបទមួយនេះ គឺដើម្បីទទួលបាននូវពុទ្ធិថ្មីៗ និងដើម្បីពង្រីកចំណេះដឹងដែលពាក់ព័ន្ធនឹងនីតិកិច្ចសន្យា ពិសេសគឺ កិច្ចសន្យាបញ្ចាំនេះឲ្យកាន់តែយល់ច្បាស់បន្ថែម ម៉្យាងវិញទៀតដើម្បីអាចយកទៅអនុវត្តក្នុងកិច្ចការប្រចាំថ្ងៃរបស់យើងខ្ញុំបានដោយមានប្រសិទ្ធិភាព និងសក្តានុពលបាន។

គោលបំណងសំខាន់ៗនៃការស្រាវជ្រាវដែលទាក់ទងនឹងប្រធានបទស្តីពី "**សិទ្ធិលើការបញ្ចាំ**" មានដូចខាងក្រោមនេះ៖

- ស្វែងយល់ពីគោលការណ៍នៃការបង្កើតនូវសិទ្ធិលើកិច្ចសន្យាបញ្ចាំ ដោយស្របតាមច្បាប់
- ស្វែងយល់ពីលក្ខណៈខុសគ្នាពីទម្រង់នៃការបង្កើតកិច្ចសន្យាបញ្ចាំ និងកិច្ចសន្យាទូទៅដោយផ្អែកសំខាន់ទៅលើកម្មវត្ថុនៃកិច្ចសន្យា៖
    - ➢ កិច្ចសន្យាបញ្ចាំ៖ មានការបញ្ចាំចលនវត្ថុ និងការបញ្ចាំអចលនវត្ថុ
        - ❖ បើកម្មវត្ថុនៃកិច្ចសន្យាបញ្ចាំជាចលនវត្ថុ៖ ត្រូវធ្វើជាលិខិតឯកជន
        - ❖ បើកម្មវត្ថុនៃកិច្ចសន្យាបញ្ចាំជាអចលនវត្ថុ៖ ត្រូវធ្វើជាលិខិតយថាភូត
    - ➢ កិច្ចសន្យាទូទៅ៖ ទម្រង់នៃកិច្ចសន្យាមិនផ្តោតសំខាន់លើកម្មវត្ថុ ដែលជាចលនវត្ថុ ឬអចលនវត្ថុឡើយ កិច្ចសន្យាអាចធ្វើបានពីរទម្រង់គឺ
        - ❖ លាយល័ក្ខណ៍អក្សរ ឬ
        - ❖ ដោយផ្ទាល់មាត់ ទៅតាមការកំណត់របស់គូភាគី។
- ស្វែងយល់ពីដំណើរការនៃការអនុវត្តកិច្ចសន្យាបញ្ចាំ
- ស្វែងយល់ពីបញ្ហាប្រឈម និងដំណោះស្រាយក្រោយពេលអនុវត្តកិច្ចសន្យាបញ្ចាំ។

## ៤. ទំហំ និងដែនកំណត់នៃការសិក្សាស្រាវជ្រាវ

ដោយសារតែនៅប្រទេសកម្ពុជាយើង ជាប្រទេសដែលបាន និងស្ថិតក្នុងស្ថានភាពជាប្រទេសដែលកំពុងអភិវឌ្ឍនៅឡើយ នាំឲ្យបញ្ហាសេដ្ឋកិច្ចកម្ពុជាមានការរីកចម្រើនក្នុងកម្រិតមួយដែលនៅទាបជាងបណ្តាប្រទេសដទៃ ដូចនេះស្ថានភាពជីវភាពប្រជាជនក៏មានការរីកចម្រើនជាសន្សឹមៗទៅតាមនោះផងដែរ។ តាមរយៈកត្តាទាំង

នេះហើយបានជាប្រជាជនភាគច្រើននៅកម្ពុជា និយមនូវការខ្ចីបុលនានា ដោយយករបស់ទ្រព្យដែលខ្លួនមានមកធ្វើការដាក់បញ្ចាំជាមួយម្ចាស់បំណុល ដើម្បីជាការធានាបំណុលនេះឯង។ ប៉ុន្តែការបង្កើតនូវកិច្ចសន្យាខ្ចីបុលប្រាក់ខ្លះហាក់មិនមានភាពត្រឹមត្រូវស្រប ទៅតាមគោលការណ៍ដែលច្បាប់បានចែងឲ្យគូភាគីធ្វើការអនុវត្តនោះឡើយទេ។ ពេលខ្លះយើងសង្កេតឃើញថា តាមរយៈការបង្កើតសិទ្ធិ និងកាតព្វកិច្ចរបស់ម្ចាស់បំណុលទៅឲ្យកូនបំណុលហាក់មិនមានភាពស៊ីមេទ្រីគ្នា ឯពេលខ្លះទៀតកូនបំណុលខ្លួនឯងផ្ទាល់បែរជាបំពានកិច្ចសន្យាជាដើម។ ដោយសារតែការបង្កើតនូវកិច្ចសន្យាប្រភេទនេះរបស់គូភាគីហាក់មានភាពមិនត្រឹមត្រូវច្បាស់លាស់ ដោយការបង្កើតទៅតាមអ្វីដែលខ្លួនគិតថានឹងមានទំនោរផលប្រយោជន៍ច្រើនមកដល់ខ្លួនតែប៉ុណ្ណោះ។ ដោយសង្កេតឃើញពីកត្តាទាំងអស់នេះហើយ យើងខ្ញុំក៏បានសម្រេចចិត្តធ្វើការសិក្សាស្រាវជ្រាវចំពោះប្រធានបទស្តីពី **"សិទ្ធិលើការបញ្ចាំ"** នេះ។ ហើយការសិក្សាស្រាវជ្រាវនេះដែរ គឺផ្តោតសំខាន់ទៅលើខ្លឹមសារសំខាន់នៃសិទ្ធិលើការបញ្ចាំដែលរួមមានដូចជា៖ សញ្ញាណទូទៅ លក្ខខណ្ឌក្នុងការបង្កើតកិច្ចសន្យាបញ្ចាំ (ទាំងចលនវត្ថុ និងអចលនវត្ថុ) ការបញ្ចាំសិទ្ធិរបស់ម្ចាស់បំណុលដែលមានអាទិភាពជាងគេ រួមទាំងលំហូរនីតិវិធីក្នុងការអនុវត្តចំពោះសិទ្ធិលើការបញ្ចាំនេះផងដែរ។ មួយវិញទៀត យើងខ្ញុំធ្វើការស្រាវជ្រាវដោយផ្អែកទៅលើច្បាប់ រួមទាំងបទដ្ឋានគតិយុត្តនានានៃព្រះរាជាណាចក្រកម្ពុជាដែលមានចែងកំណត់ជាធរមាន ដែលជាពិសេស គឺក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ជាមូលដ្ឋានគ្រឹះផងដែរ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ចំពោះសារៈសំខាន់នៃការស្រាវជ្រាវនេះ យើងខ្ញុំនឹងធ្វើការផ្តោតសំខាន់ទៅលើអត្ថប្រយោជន៍ដែលនឹងទទួលបានជា ៣ (បី) ផ្នែកសំខាន់ៗដែលមានដូចជា៖

- **ចំពោះគូភាគីនៃកិច្ចសន្យាបញ្ចាំ៖**
  - ដើម្បីឲ្យដឹងពីរបៀបក៏ដូចជាលក្ខខណ្ឌក្នុងការបង្កើតនូវកិច្ចសន្យាបញ្ចាំមួយដែលមានអានុភាពស្របតាមច្បាប់ ជាពិសេសដែលអាចយកទៅតតាំងជាមួយតតិយជនបាន
  - ដើម្បីឲ្យដឹងកាន់តែច្បាស់ថែមទៀតថា ខ្លួនមានសិទ្ធិ និងកាតព្វកិច្ចយ៉ាងណាខ្លះនៅក្នុងកិច្ចសន្យានេះ(ទាំងកូនបំណុល និងម្ចាស់បំណុល)
  - យល់ដឹងពីអ្វីដែលច្បាប់បានហាមឃាត់មិនឲ្យអនុវត្ត ក៏ដូចជាអ្វីដែលច្បាប់ផ្តល់សិទ្ធិជាអាទិភាពក្នុងការអនុវត្តជាដើម
  - បានដឹងពីកិច្ចការពារដែលច្បាប់បានចែងកំណត់ជាមុន នៅពេលមានការរំលោភបំពានកិច្ចសន្យាបញ្ចាំ។
- **ចំពោះអ្នកសិក្សាស្រាវជ្រាវ៖**
  - ជាប្រភពឯកសារសម្រាប់សិស្ស និស្សិតដែលមានបំណងចង់ដឹង និងស្វែងយល់ឲ្យកាន់តែច្បាស់ទាក់ទងនឹងវិស័យនេះ ពោលគឺអាចយកមកធ្វើជាមូលដ្ឋានក្នុងស្រាវជ្រាវបន្ថែម
  - ដើម្បីបង្កើតបាននូវចំណេះ ជំនាញថ្មីៗដែលខ្លួនមិនធ្លាប់បានដឹងពីមុនមកអាចយកទៅអនុវត្តជាក់ស្តែងក្នុងជីវភាពរស់នៅបាន

   - អាចមានចំណេះ ក្នុងការប្រៀបធៀបនូវទិដ្ឋភាពច្បាប់ដែលបានចែងពីការអនុវត្តកិច្ចសន្យាបញ្ចាំជាមួយនឹងការអនុវត្តក្នុងសង្គមបច្ចុប្បន្នបានផងដែរ។
- **ចំពោះយើងខ្ញុំទាំងពីរ៖**
   - តាមរយៈការសិក្សាស្រាវជ្រាវនៃប្រធានបទនេះ គឺដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
   - ដើម្បីពង្រឹងនូវចំណេះដឹងរបស់យើងខ្ញុំឲ្យកាន់តែមានភាពល្អប្រសើរជាងមុន
   - ដើម្បីឈ្វេងយល់ឲ្យកាន់តែពិស្តារទាក់ទិននឹងនីតិកិច្ចសន្យាបន្ថែមបានមួយកម្រិតទៀត ដែលអាចផ្តល់នូវភាពងាយស្រួល នៅពេលដែលយើងខ្ញុំយកទៅអនុវត្តនៅថ្ងៃខាងមុខប្រកបដោយប្រសិទ្ធិភាពបាន
   - ជាពិសេសអាចយល់ច្បាស់ពីនីតិវិធីក្នុងការអនុវត្តរបស់ភាគីនៃកិច្ចសន្យាបញ្ចាំ
   - បន្ទាប់ពីធ្វើការស្រាវជ្រាវនៃប្រធានបទនេះចប់ យើងខ្ញុំអាចផ្តល់នូវការប្រឹក្សាទៅដល់បុគ្គលដែលមានចម្ងល់ពាក់ព័ន្ធនឹងការអនុវត្តនូវកិច្ចសន្យាប្រភេទនេះបានមួយចំណែកផងដែរ។

## ៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

- **តម្រូវការព័ត៌មាន៖** ដើម្បីឲ្យដំណើរការនៃការសិក្សាស្រាវជ្រាវប្រកបដោយភាពជោគជ័យ គឺត្រូវកំណត់ទិន្នន័យចំនួន ២ (ពីរ) សំខាន់ៗគឺ៖ ទិន្នន័យចម្បង និងទិន្នន័យបន្ទាប់បន្សំ។
- **ទិន្នន័យចម្បង៖** រាល់ឯកសារទាំងឡាយណាដែលជាបទដ្ឋានគតិយុត្ត ហើយដែលត្រូវបានប្រកាសចូលជាធរមានឲ្យអនុវត្ត ពោលគឺ ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ ដែលនៅតែមានអានុភាពអនុវត្តរហូតមកដល់ពេលបច្ចុប្បន្ននេះ។
- **ទិន្នន័យបន្ទាប់បន្សំ៖** គឺជាទិន្នន័យដែលបានមកពី៖
   - ឯកសារដែលបានតម្កល់ទុកនៅបណ្ណាល័យនីតិសាស្ត្រ និងបណ្ណាល័យអេឡិចត្រូនិចរបស់សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
   - សៀវភៅដែលបានចងក្រងឡើងដោយ លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
   - សារណាបញ្ចប់ការសិក្សារបស់និស្សិតគ្រប់ជំនាន់
   - តាមរយៈប្រព័ន្ធអ៊ីនធឺណែត (Internet)
   - និងតាមរយៈកម្មវិធីដែលពាក់ព័ន្ធនៅវិស័យច្បាប់ នៅក្នុងបណ្តាញសង្គមនានា។
- **វិធីសាស្ត្រវិភាគទិន្នន័យ៖** បើនិយាយពីវិធីសាស្ត្រនៃការវិភាគត្រូវបានគេបែងចែកជា ២ (ពីរ)ផ្នែកគឺ៖ វិភាគទិន្នន័យតាមបរិមាណ និងវិភាគទិន្នន័យបែបគុណភាព។
   - ការវិភាគទិន្នន័យតាមបែបបរិមាណ គឺជាការវិភាគមួយប្រភេទដែលមានប្រើនូវទិន្នន័យជាតួលេខច្បាស់លាស់។
   - រីឯការវិភាគទិន្នន័យតាមបែបគុណភាពវិញ គឺជាវិធីមួយដែលធ្វើការវិភាគទិន្នន័យដែលមាន ឬ

ទិន្នន័យដែលទទួលបានពីការចុះកម្មសិក្សា ឬ បានមកពីការសាកសួរដោយប្រើកម្រងសំណួរដើម្បីចេញជាលទ្ធផលណាមួយ។

ដោយឡែកសម្រាប់ការវិភាគទិន្នន័យរបស់ក្រុមយើងខ្ញុំ យើងខ្ញុំបានធ្វើការវិភាគដោយប្រមូលនូវទិន្នន័យ គឺ តាមរយៈ ការស្នើសុំការផ្តល់ការប្រឹក្សាពីលោកបណ្ឌិតសាស្ត្រាចារ្យណែនាំ លោកបេក្ខបណ្ឌិតច្បាប់ សិស្សច្បងរួមសាលា និងមិត្តនិស្សិតរួមជំនាន់ដែលមានបទពិសោធន៍ចំណេះដឹងទាក់ទងនឹងចំណុចនេះ រួចធ្វើការវិភាគឲ្យលេចចេញជាលទ្ធផលមួយដែលល្អប្រសើរ។

ជាដំបូងត្រូវធ្វើការប្រមូលប្រភពទិន្នន័យ និងទិន្នន័យឲ្យបានច្បាស់លាស់ និងគ្រប់គ្រាន់។ បន្ទាប់ពីទទួលបានគ្រប់អស់ហើយ យើងខ្ញុំនឹងធ្វើការវិភាគដោយធ្វើការប្រៀបធៀបជាមួយនឹង៖

- អត្ថបទច្បាប់ដែលមានជាធរមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា (ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ក៏ដូចជាបទដ្ឋានគតិយុត្តដទៃទៀតដូចជា ច្បាប់ភូមិបាល ឆ្នាំ ២០០១ ឬអនុក្រឹត្យនានាជាដើម)
- ទ្រឹស្តីនានាដែលបានសិក្សាកន្លងមកជាមួយលោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ ដែលពោរពេញទៅដោយសមត្ថភាព និងមានបទពិសោធន៍ជាច្រើនឆ្នាំក្នុងការបណ្តុះបណ្តាលសិស្សនិស្សិតខាងផ្នែកនីតិសាស្ត្រ និងការអនុវត្តជាក់ស្តែងដែលជាពិសេសខាងផ្នែកនីតិរដ្ឋប្បវេណី ដូចជានីតិកាតព្វកិច្ច នីតិកិច្ចសន្យាជាដើមនោះ
- និងឯកសារពាក់ព័ន្ធផ្សេងៗទៀត។

ចំពោះការវិភាគនូវទិន្នន័យនេះផងដែរ យើងខ្ញុំបានធ្វើការប្រៀបធៀបជាមួយនឹងការអនុវត្តជាក់ស្តែងនៅក្នុងសង្គមទៅនឹងបទបញ្ញត្តិច្បាប់ដែលបានចូលជាធរមានរួច ថាតើមានលក្ខណៈដូចគ្នា ឬខុសគ្នាយ៉ាងណាខ្លះ។

## ៧. រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ

### ក្របខណ្ឌនៃការសក្សាស្រាវជ្រាវ ៖

ការសិក្សាស្រាវជ្រាវនេះ គឺផ្តោតសំខាន់ទៅលើការអនុវត្តតាមគោលការណ៍របស់ក្រមរដ្ឋប្បវេណីដែលបានចែងទាក់ទងនឹងទ្រព្យសម្បត្តិ ដែលផ្តោតជាពិសេសទៅលើសិទ្ធិការបញ្ចាំ ដែលមានទំនាក់ទំនងនឹងផលប្រយោជន៍របស់បុគ្គល។

- **ដំណាក់កាលទី១៖** ការស្រាវជ្រាវរៀបចំបង្កើតគម្រោងផែនការស្រាវជ្រាវ ធ្វើការរៀបចំកំណត់គោលដៅដែលជាកម្មវត្ថុ ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ។ ការសិក្សាទៅលើទ្រឹស្តីដែលពាក់ព័ន្ធ ដើម្បីរកពាក្យគន្លឹះឆ្ពោះទៅរកដំណោះស្រាយនៃប្រធានបទ។
- **ដំណាក់កាលទី២៖** ធ្វើការសិក្សាទៅលើប្រភពនៃឯកសារសំខាន់ៗ ដោយធ្វើការវិភាគវាយតម្លៃទៅលើទិន្នន័យដែលទទួលបានបន្ទាប់ពីបានធ្វើការសិក្សារួច ព្រមទាំងរៀបចំលំដាប់នៃគំនិតដែលស្របទៅតាមខ្លឹមសារនៃប្រធានបទដែលខ្លួនបាននឹងកំពុងរៀបចំតាក់តែងឡើង។

ដើម្បីឲ្យមានភាពយល់ដឹងកាន់តែស៊ីជម្រៅ និងជ្រួតជ្រាបកាន់តែច្បាប់លាស់បន្ថែមទៀតនោះ ការសិក្សាស្រាវជ្រាវដែលបានចងក្រងជាសារណានេះ ត្រូវបានធ្វើការរៀបចំ និង ចងក្រងឡើងដោយធ្វើការបែងចែកជា ៤ (បួន) ជំពូកដែលមានខ្លឹមសារដូចតទៅនេះ៖

- **ជំពូកទី ១ ៖ សិក្សាពីសញ្ញាណទូទៅនៃសិទ្ធិលើការបញ្ចាំ**
  - ដែលនឹងលើកបង្ហាញពីទិដ្ឋភាពជាទូទៅដែលទាក់ទងនឹងអត្ថន័យនៃសិទ្ធិលើការបញ្ចាំការអនុវត្តសិទ្ធិលើការបញ្ចាំ ឧបាទេសកម្មលើវត្ថុ ក៏ដូចជាលក្ខខណ្ឌសុពលនៃការបង្កើតនូវកិច្ចសន្យាបញ្ចាំជាដើម។
- **ជំពូកទី២ ៖ ការបញ្ចាំចលនវត្ថុ**
  - បង្ហាញពីលក្ខខណ្ឌក្នុងការបង្កើតកិច្ចសន្យាបញ្ចាំចលនវត្ថុ លក្ខខណ្ឌតតាំង អំពីសិទ្ធិ និងកាតព្វកិច្ចរបស់គូភាគីជាដើម។
- **ជំពូកទី ៣ ៖ ការបញ្ចាំអចលនវត្ថុ**
  - បង្ហាញពីអត្ថន័យនៃការបញ្ចាំអចលនវត្ថុ លក្ខខណ្ឌទម្រង់ក្នុងបង្កើតកិច្ចសន្យាបញ្ចាំអចលនវត្ថុ ដែលមានភាពផ្ទុយពីលក្ខខណ្ឌបង្កើតកិច្ចសន្យា អាជ្ញាយុកាលនៃការកាន់កាប់ សិទ្ធិ និងកាតព្វកិច្ចរបស់កូនបំណុល និង ម្ចាស់បំណុលជាដើម។
- **ជំពូកទី ៤ ៖ ការបញ្ចាំសិទ្ធិ**
  - បង្ហាញពីលក្ខណៈពិសេសដែលច្បាប់បានការពារនូវផលប្រយោជន៍របស់ម្ចាស់បំណុល តាមរយៈការបានផ្តល់នូវសិទ្ធិពិសេសជាអាទិភាពមួយទៅដល់ម្ចាស់បំណុលដែលមានអត្ថិភាពនៃសិទ្ធិលើការបញ្ចាំនោះ។

# ជំពូកទី១
# សញ្ញាណទូទៅនៃសិទ្ធិលើការបញ្ចាំ

មុននឹងឈានទៅដល់ការបកស្រាយពីការអនុវត្តសិទ្ធិលើការបញ្ចាំនៃជំពូកនេះ យើងនឹងធ្វើការពន្យល់បង្ហាញពីសញ្ញាណខ្លះៗដែលទាក់ទងនឹងខ្លឹមសារជាទូទៅនៃសិទ្ធិលើការបញ្ចាំដូចតទៅនេះ៖

## ១. អត្ថន័យនៃសិទ្ធិលើការបញ្ចាំ

សញ្ញាណជាទូទៅនៃសិទ្ធិលើការបញ្ចាំ បានបង្កប់នូវអត្ថន័យនៃពាក្យគន្លឹះមួយចំនួននៅក្នុងខ្លឹមសារនៃសិទ្ធិលើការបញ្ចាំនេះ ដែលយើងគប្បីស្វែងយល់ មុននឹងឈានទៅដល់និយមន័យដែលបានកំណត់ទុកជាស្រេចដោយបទដ្ឋានគតិយុត្តិជាតិនោះ ដែលរួមមានពាក្យថា ការបញ្ចាំ ដែលមានភ្ជាប់ទាំងអត្ថន័យនៃការធានាបំណុលរួមទាំងសញ្ញាណនៃសិទ្ធិលើការបញ្ចាំដូចខាងក្រោមនេះ។

ការបញ្ចាំ គឺសំដៅទៅលើការធានាកាព្វកិច្ចលើបំណុល ដោយដាក់ទ្រព្យធានា។ ប៉ុន្តែ ទ្រព្យធានា ដែលត្រូវអនុវត្តតាមច្បាប់ស្តីពី ប្រតិបត្តិការដែលមានកិច្ចធាននានេះ[3] គឺសំដៅតែទៅលើចលនវត្ថុតែប៉ុណ្ណោះ ដោយមិនរាប់បញ្ចូលការធានាលើអចលនវត្ថុទេ។

ការធានាបំណុល គឺមានចែងជារួមនៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាយើងដែលទើបតែចូលជាធរមានក្រោយច្បាប់ស្តីពី ប្រតិបត្តិការដែលមានកិច្ចធានា កាលពីឆ្នាំ ២០០៧ កន្លងទៅនេះ ដែលការធានាបំណុលនៅក្រមរដ្ឋប្បវេណីនេះ គឺមានទាំងការធានាបំណុលដោយបុគ្គល និងការធានាបំណុលដោយទ្រព្យ(ទាំងចលនទ្រព្យ និងអចលនទ្រព្យ)។

- ការធានាបំណុលដោយបុគ្គល (កិច្ចសន្យាធានា) គឺមានន័យថា បុគ្គលទី៣ណាមួយ ជាអ្នកចេញ មុខធានា ចំពោះម្ចាស់បំណុលថានឹងសងបំណុលជំនួសកូនបំណុល ក្នុងករណីកូនបំណុលមិន សង។
- ការធានាបំណុលដោយដាក់ទ្រព្យធានា គឺ ជាកិច្ចសន្យាមួយដែលកូនបំណុល ឬ ក៏បុគ្គលទី៣ ណាមួយផ្សេងទៀត ព្រមព្រៀងដាក់ទ្រព្យរបស់ខ្លួនជា កិច្ចធានា ដើម្បីឲ្យម្ចាស់បំណុលមានសិទ្ធិទាមទារលក់ទ្រព្យធានានេះ ដើម្បីអាចយកលុយមកសងបំណុលដោយមានអាទិភាពលើម្ចាស់បំណុលផ្សេងទៀត។ ប្រតិបត្តិការដាក់ទ្រព្យធានាបំណុលនេះអាចធ្វើចំពោះចលនទ្រព្យដូចជា ការបញ្ចាំ ចលនទ្រព្យ ជាដើម ឬ ក៏ចំពោះអចលនទ្រព្យដូចជា ការបញ្ចាំអចលនទ្រព្យ ឬ ក៏ហ៊ីប៉ូតែក។

ជារួម **សិទ្ធិលើការបញ្ចាំ** ត្រូវបានក្រមរដ្ឋប្បវេណីឲ្យនិយមន័យថា សំដៅទៅលើសិទ្ធិដែលម្ចាស់សិទ្ធិមានសិទ្ធិកាន់កាប់វត្ថុដែលទទួលបានពីកូនបំណុល ឬតតិយជន ដើម្បីធានាសិទ្ធិលើបំណុលរបស់ខ្លួន និងទទួលបានការសងចំពោះសិទ្ធិលើបំណុលរបស់ខ្លួនពីវត្ថុនោះ ដោយមានអាភិភាពជាងម្ចាស់បំណុលផ្សេងៗទៀត[4]។

## ២. ប្រភេទកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ

កម្មវត្ថុ គឺវត្ថុ ឬទ្រព្យទាំងឡាយណាដែលអាចជាទ្រព្យរូបី និងទ្រព្យអរូបី។ កម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ រួមមាន ៣ (បី) ប្រភេទសំខាន់គឺ៖ ចលនវត្ថុ ឬចលនទ្រព្យ អចលនវត្ថុ ឬអចលនទ្រព្យរួមទាំង សិទ្ធិលើការបញ្ចាំ

[3] មាត្រា ៦ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា, អនុម័តថ្ងៃទី ៦ ខែ មេសា ឆ្នាំ ២០០៧

[4] មាត្រា ៨១៦ និង មាត្រា ៨៤០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

សិទ្ធិដែលត្រូវបានគេចាត់ទុកថាជាកម្មវត្ថុពិសេសនៅក្នុងកិច្ចសន្យាបញ្ចាំនេះ។

### ២.១ ចលនវត្ថុ

ចលនវត្ថុ គឺជាវត្ថុ ឬទ្រព្យដែលអាចកម្រើកបាន ដែលអាចលើកដាក់ ឬដឹកនាំពីកន្លែងមួយទៅកន្លែងមួយទៀតបានមានដូចជា តុ ទូជាដើម[5]។

ចលនវត្ថុ គឺជាទ្រព្យសម្បត្តិ គ្រឿងចក្រ និងឧបករណ៍ទាំងអស់ដែលលើកលែងតែដី និងអគារ[6]។ ពោលគឺ សំដៅទៅលើវត្ថុក្រៅអចលនវត្ថុ[7]។

### ២.២ អចលនវត្ថុ

អចលនវត្ថុ សំដៅលើ ដីធ្លី និងវត្ថុជាប់នៅនឹងដី ហើយមិនអាចផ្លាស់ទីបាន ដូចជាអគារ សំណង់ ដំណាំរុក្ខជាតិជាអាទិ៍[8]។

អចលនវត្ថុ អាចជាអចលនវត្ថុពីកំណើត និងអាចជាអចលនវត្ថុតាមការកំណត់របស់ច្បាប់។

- អចលនវត្ថុពីកំណើត៖ សំដៅទៅដល់ ដីធម្មជាតិ ដូចជា ដីព្រៃឈើ ដីកាប់រាន ដីដាំដុះ ដីទុកទំនេរ ឬមិនអាចដាំដុះ ដីលិចទឹកដោយទឹកនៅនឹងដី ឬទឹកហូរ និងសំណង់ ឬការរៀបចំទាំងឡាយដែលស្ថិតនៅជាប់មួយកន្លែង កើតឡើងដោយអំពើរបស់មនុស្ស ហើយមិនអាចរំកិល ឬផ្លាស់ប្តូរកន្លែងបាន។
- អចលនវត្ថុតាមការកំណត់របស់ច្បាប់៖មានសិទ្ធិភណ្ឌិកទាំងឡាយលើអចលនវត្ថុ និងចលនវត្ថុទាំងទាំងឡាយដែលបានកំណត់ដោយច្បាប់ជាអចលនវត្ថុ[9]។

រីឯអចលនវត្ថុពីភ័ព្វវាសនាវិញ អាចចាត់បញ្ចូលទៅក្នុងសមាសភាគនៃអចលនវត្ថុ និងវត្ថុចំណុះបាន (ភ្ជាប់ទៅនឹងវត្ថុចម្បង) ហេតុដូច្នេះ អចលនវត្ថុនេះ អាចនឹងមិនត្រូវបានយកមកធ្វើជាកម្មវត្ថុនៃការបញ្ចាំអចលនវត្ថុបានឡើយ។

### ២.៣ សិទ្ធិលើបំណុល

ការបញ្ចាំសិទ្ធិ គឺសំដៅទៅលើសិទ្ធិលើការបញ្ចាំដែលអាចមានកម្មវត្ថុជាសិទ្ធិលើទ្រព្យសម្បត្តិ។ ការបញ្ចាំសិទ្ធិនេះ អាចបង្កើតបានមិនត្រឹមតែចំពោះសិទ្ធិលើវត្ថុតែមួយប៉ុណ្ណោះនោះទេ គឺសំដៅពិសេសទៅលើសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលទៅលើកូនបំណុល ដែលម្ចាស់បំណុលអាចប្រើសិទ្ធិលើបំណុលជាអាទិភាពក្នុងការយកទៅប្រតិបត្តិលើកិច្ចលើបំណុលចំពោះតតិយបានជាដើម។

## ៣. គោលការណ៍នៃការបង្កើតសិទ្ធិលើការបញ្ចាំ

សិទ្ធិលើការបញ្ចាំ ត្រូវបានកើតមានឡើងតាមរយៈការធ្វើនូវកិច្ចសន្យាបញ្ចាំ។

កិច្ចសន្យា គឺជាកិរិយារបស់បុគ្គលពីរនាក់ ឬច្រើននាក់មានឆន្ទៈត្រូវគ្នាព្រមបង្កើត កែប្រែ ឬរំលត់កាតព្វកិច្ច។ ជាគោលការណ៍ផងដែរ ការបង្កើតកិច្ចសន្យា គឺជាការព្រមព្រៀងរវាងបុគ្គលពីរនាក់ ឬច្រើននាក់ ដោយភាគី

[5] ដកស្រង់ចេញពីវចនានុក្រមខ្មែរ សម្តេចសង្ឃរាជ ជួន ណាត ( https://g.co/kgs/9fa1mR )
[6] វាក្យខណ្ឌទី៣ មាត្រា ៤ នៃច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ, អនុម័តថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០០៩
[7] វាក្យខណ្ឌទី៣ មាត្រា ១២០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧
[8] មាត្រា ១២០, ១២១ និងមាត្រា ១២២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧
[9] មាត្រា ២ នៃច្បាប់ភូមិបាលឆ្នាំ ២០០១

ម្ខាងបានបង្ហាញឆន្ទៈដោយសេរី ពិតប្រាកដ តាមរយៈការភ្ជាប់លក្ខខណ្ឌនូវសំណើរបស់ខ្លួនទៅកាន់ភាគីម្ខាងទៀត ហើយភាគីម្ខាងទៀតបានធ្វើស្វីការតបទទួលយកសំណើពីភាគីម្ខាងនៃដំណើរការដោយគ្មានវិការៈ ឬហៅម្យ៉ាងទៀតថា កិច្ចសន្យាបានបង្កើតឡើងតាមរយៈសំណើ និងស្វីការជួបគ្នា[10]។

សំណើ គឺជាការស្នើសុំដល់ភាគីម្ខាងទៀតនៃកិច្ចសន្យាឲ្យបានដឹង និងទទួលយកនូវលក្ខខណ្ឌដែលបានដាក់ស្នើសុំបង្កើតកិច្ចសន្យា ចំណែកឯស្វីការ គឺជាការឆ្លើយតបរបស់ភាគីម្ខាងទៀតដែលបានបង្ហាញឆន្ទៈព្រមទទួលយកសំណើពីភាគីម្ខាងនៃអ្នកធ្វើសំណើ[11]។

ម៉្យាងវិញទៀត កិច្ចសន្យានឹងត្រូវបានបង្កើតឡើងនៅពេលដែលដំណឹងអំពីស្វីការនោះត្រូវបានមកដល់អ្នកស្នើវិញ[12]។ ហើយអានុភាពដែលបានបង្កើតឡើងតាមកិច្ចសន្យានេះរួមមាន ការកើតឡើងវិញនៃសិទ្ធិលើបំណុល ឬកាតព្វកិច្ចជាដើម។

យ៉ាងណាមិញកិច្ចសន្យាបញ្ចាំ គឺជាសកម្មភាពមួយដែលកើតឡើងតាមរយៈការព្រមព្រៀងរវាងគូភាគីដោយគ្មានវត្តមាននៃវិការៈចូលរួមក្នុងការព្រមព្រៀងនោះ ដែលក្នុងនោះអ្នកបង្កើតសិទ្ធិលើការបញ្ចាំ (កូនបំណុល) ឬ តតិយជនដែលធានាដោយវត្ថុដែលបានបង្កើតសិទ្ធិលើការបញ្ចាំនោះ មានកាតព្វកិច្ចត្រូវធ្វើការប្រគល់វត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំទៅឲ្យម្ចាស់សិទ្ធិលើការបញ្ចាំ (ម្ចាស់បំណុល)។

ហេតុនេះ ការព្រមព្រៀងបង្កើតសិទ្ធិលើការបញ្ចាំដោយកូនបំណុលជាលក្ខខណ្ឌដាច់ខាត។ នេះមានន័យថា ម្ចាស់សិទ្ធិលើការបញ្ចាំ គឺជាអ្នកកាន់កាប់វត្ថុបញ្ចាំ រីឯអ្នកដែលបានបង្កើតសិទ្ធិលើការបញ្ចាំមិនអាចធ្វើការកាន់កាប់វត្ថុបញ្ចាំនោះបានទេ។ នៅក្នុងករណីនេះផងដែរ ម្ចាស់បំណុល គឺមានសិទ្ធិក្នុងការឃាត់ទុកវត្ថុបញ្ចាំ បើកូនបំណុលមិនបានអនុវត្តកាតព្វកិច្ចសងបំណុលមកម្ចាស់បំណុលវិញ នៅពេលដល់កំណត់សងនោះ។ ប៉ុន្តែសិទ្ធិនេះ មិនអាចយកមកធ្វើការតតាំងចំពោះម្ចាស់បំណុលដែលមានអាទិភាពជាងខ្លួនបានឡើយ[13]។

ថ្វីត្បិតតែការបង្កើតកិច្ចសន្យាមួយ ត្រូវបានធ្វើឡើងតាមគោលការណ៍ខាងលើដែលសំណើ និងស្វីការត្រូវបានជួបគ្នាក៏ដោយ ប៉ុន្តែដើម្បីឲ្យកិច្ចសន្យាមួយមានសុពលភាពពេញលេញដោយបង្កើតឲ្យមានសិទ្ធិ និងកាតព្វកិច្ចបាន និងស្របតាមការបង្ហាញឆន្ទៈរបស់ភាគីនៃកិច្ចសន្យា និងច្បាប់របស់ប្រទេសនោះ គឺភាគីទាំងសងខាងត្រូវតែបំពេញនូវលក្ខខណ្ឌចំនួន ២ (ពីរ) យ៉ាងដូចខាងក្រោមនេះ៖

### ៣.១ លក្ខខណ្ឌគ្រឹះ

កិច្ចសន្យា ត្រូវចាត់ទុកថាមានសុពលភាពអនុវត្តទៅបាន កាលណាកាតព្វកិច្ចដែលកើតពីកិច្ចសន្យានោះគឺ៖

- កើតចេញពីការព្រមព្រៀងដោយពិតប្រាកដ និងសេរី
- កើតចេញពីជនដែលមានសមត្ថភាពចុះកិច្ចសន្យា

[10] មាត្រា ៣៣៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[11] មាត្រា ៣៣៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[12] មាត្រា ៣៤០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[13] មាត្រា ៨២១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

➢ មានកម្មវត្ថុជាក់លាក់ដែលអាចធ្វើកើត ស្របច្បាប់ របៀបរៀបរយសាធារណៈ ឬ ទំនៀមទម្លាប់ល្អ[14]។

### ៣.១.១ ការព្រមព្រៀងរវាងគូភាគី

ការព្រមព្រៀង គឺជាឆន្ទៈរបស់គូភាគីក្នុងការបង្កើតកិច្ចសន្យាដោយពិតប្រាកដ និង ដោយសេរីគ្មានការគំរាមគំហែង ឆបោក ឬក្លែងបន្លំពីភាគីណាឡើយ ។

កិច្ចសន្យាបញ្ចាំ ត្រូវបានកើតមានឡើងនៅពេលដែលអ្នកបង្កើតសិទ្ធិលើការបញ្ចាំ(កូនបំណុល) ឬ តតិយជនបានព្រមព្រៀងប្រគល់វត្ថុបញ្ចាំនោះទៅឲ្យម្ចាស់សិទ្ធិលើការបញ្ចាំ។ ប៉ុន្តែកិច្ចសន្យានេះ មិនអាចកើតឡើងបានទេ បើការព្រមព្រៀងប្រគល់វត្ថុនោះកើតចេញពីការបង្ហាញឆន្ទៈដែលមានភ្ជាប់មកជាមួយនឹងវិការៈ[15] ដូចជា ការភាន់ច្រឡំ ការឆបោក ព័ត៌មានមិនពិត ការរំលោភលើស្ថានភាពបុគ្គល ការគំរាមគំហែង អំពើកេងចំណេញហួសហេតុជាដើម[16]។ សិទ្ធិលើការបញ្ចាំ ត្រូវកើតឡើងដោយកូនបំណុល ឬតតិយជនដែលបានបង្កើតសិទ្ធិលើការបញ្ចាំនោះ ប្រគល់នូវវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំទៅម្ចាស់សិទ្ធិលើការបញ្ចាំ[17]។ បានន័យថា សិទ្ធិលើការបញ្ចាំអាចកើតមានឡើងទៅបាន លុះត្រាតែមានការប្រគល់វត្ថុបញ្ចាំនោះ ទៅឲ្យម្ចាស់សិទ្ធិលើការបញ្ចាំធ្វើការកាន់កាប់ ។ ពោលគឺ ករណីនេះមិនអនុញ្ញាតឲ្យប្រគល់នូវវត្ថុបញ្ចាំនោះ តាមរយៈការប្តូរលក្ខន្តិកៈនៃការកាន់កាប់ទេ បានន័យថា អ្នកបង្កើតសិទ្ធិលើការបញ្ចាំមិនបានប្រគល់វត្ថុជាក់ស្តែងទេ ហើយម្ចាស់សិទ្ធិលើការបញ្ចាំទទួលការកាន់កាប់ដោយប្រយោលតែប៉ុណ្ណោះ គឺមិនត្រូវបានច្បាប់ហាមឃាត់ចំពោះករណីបែបនេះ[18]។

### ៣.១.២ សមត្ថភាពរបស់គូភាគី

សមត្ថភាព គឺជាលក្ខណៈសម្បត្តិរបស់បុគ្គលម្នាក់ៗ ដែលអាចក្លាយជាម្ចាស់សិទ្ធិ និងកាតព្វកិច្ចដែលអាចវិនិច្ឆ័យបានអំពីលទ្ធផលនៃសកម្មភាពរបស់ខ្លួន ដែលអាចធ្វើឲ្យសកម្មភាពរបស់ខ្លួនមានអានុភាពតាមផ្លូវច្បាប់ ។

សមត្ថភាពរបស់ភាគីត្រូវបានគេបែងចែកជា ៣ (បី) គឺ៖

➢ សមត្ថភាពទទួលសិទ្ធិ

➢ សមត្ថភាពខាងឆន្ទៈ

➢ និងសមត្ថភាពក្នុងការធ្វើសកម្មភាព។

ជាគោលការណ៍ បុគ្គលដែលមានសមត្ថភាពក្នុងការយល់ដឹង និងអាចវិនិច្ឆ័យបានអំពីលទ្ធផលតាមផ្លូវច្បាប់ ដែលកើតចេញពីសមត្ថភាព និងសកម្មភាពរបស់ខ្លួន អាចបង្កើតកិច្ចសន្យាបញ្ចាំអចលនវត្ថុបាន គឺសំដៅដល់នីតិជនដែលមានអាយុចាប់ពី ១៨(ដប់ប្រាំបី)ឆ្នាំឡើងទៅ លើកលែងតែនីតិជន ដែលជាជនគំហាត់ស៊ីវិលតែ

---

[14] មាត្រា ៣ នៃក្រឹត្យច្បាប់លេខ៣៨

[15] វិការៈ គឺសំដៅដល់ការប្រែប្រួលចាកពីភាពប្រក្រតី។ ដកស្រង់ចេញពី សទ្ទានុក្រមពាក្យច្បាប់ ខ្មែរអង់គ្លេស-បារាំង ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី បោះពុម្ពដោយទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ២០០៧។ ក្រឹត្យច្បាប់លេខ ៣៨ ៖ វិការៈនៃការព្រមព្រៀងមាន ៣ គឺ ការភាន់ច្រឡំ ការបន្លំបោកប្រាស់ និង ហិង្សា។

[16] មាត្រា ៣៤៥ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[17] កថាខណ្ឌទី១ មាត្រា ៨១៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[18] មាត្រា ៨២៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

ប៉ុណ្ណោះដែលតុលាការហាមឃាត់[19]។ ករណីនេះ ច្បាប់មិនបានកំហិតសិទ្ធិស៊ីវិល ឬហាមឃាត់ដោយប្រការណាមួយទេ ជាហេតុនាំឲ្យបុគ្គលនោះមានគុណសម្បត្តិអាចក្លាយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ចបាន។

ចំណែកឯក្រឹត្យច្បាប់លេខ ៣៨ ត្រង់មាត្រា ១៤ ក៏បានចែងទៀតថា *ជនទាំងឡាយដែលមានអាយុ ១៨ (ដប់ប្រាំបី)ឆ្នាំ អាចធ្វើកិច្ចសន្យាបានគ្រប់ពេលវេលាលើកលែងតែជនគំហាត់ដែលមានចែងក្នុងច្បាប់ផងដែរ។*

ប៉ុន្តែការបង្ហាញខាងលើនេះ មិនមែនមានន័យថា រាល់នីតិជនទាំងអស់សុទ្ធតែអាចធ្វើសកម្មភាពប្រកបដោយសុពលភាពនោះទេ ហើយរាល់សកម្មភាពរបស់អនីតិជនទាំងអស់ពុំមែនសុទ្ធតែចាត់ទុកថា គ្មានសុពលភាពពេញលេញនោះដែរ។ ករណីនេះ បានន័យថា ជនដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យនូវលទ្ធផលនានាដែលកើតចេញពីសកម្មភាពរបស់ខ្លួន ដោយសារតែមានវិបត្តិផ្នែកវិបល្លាសស្មារតី[20] (ប្រាជ្ញាស្មារតី) ទោះមួយផ្នែក ឬទាំងស្រុងក្តី ទោះជាបានដល់នីតិភាពក៏ដោយ ក៏ច្បាប់មិនអនុញ្ញាតឲ្យធ្វើសកម្មភាពបង្កើតកិច្ចសន្យាបានដែរ។ ជនទាំងនោះមាន ២(ពីរ) ប្រភេទគឺ ជននៅក្រោមអាណាព្យាបាលទូទៅ និងជននៅក្រោមហិតូបត្ថម្ភ[21]។

ម៉្យាងវិញទៀត អនីតិជនដែលមានគំនិតចាស់ទុំអាចប្រកបរបរ ឬធ្វើអាជីវកម្មបាន ឬអាចទ្រទ្រង់ជីវភាពខ្លួនឯងបានដោយឯករាជ្យ ត្រូវបានច្បាប់អនុញ្ញាតឲ្យធ្វើសកម្មភាព ឬកិច្ចទាំងពួងបានប្រកបដោយសុពលភាព ឬមានអានុភាពអនុវត្តបានតែម្តង។ ជនទាំងនោះរួមមាន៖ អនីតិជនដែលអនុញ្ញាតឲ្យចាត់ចែងទ្រព្យ អនីតិជនដែលអនុញ្ញាតឲ្យប្រកបអាជីវកម្មដោយអ្នកមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន និងអនីតិជនមានអាត្តាធីនភាព[22] ។ ជាលទ្ធផល យើងអាចធ្វើការសន្និដ្ឋានបានថា អនីតិជនដែលបានរៀបរាប់ខាងលើនេះ គឺមានសិទ្ធិគ្រប់គ្រាន់ និងពេញលេញស្របទៅតាមច្បាប់ក្នុងការបង្កើតកិច្ចសន្យាបញ្ជាំបានដោយមានអានុភាពក្នុងការអនុវត្តបានដោយមានសុពលភាពពេញលេញតែម្តង។

### ៣.១.៣ កម្មវត្ថុនៃកិច្ចសន្យា

កម្មវត្ថុ គឺជាខ្លឹមសារសំខាន់នៃកិច្ចសន្យាដែលកម្មវត្ថុនោះត្រូវតែ ជាក់លាក់ ដែលអាចធ្វើទៅបាន ឬបំពេញបាន និង ស្របច្បាប់ ហើយមិនប៉ះពាល់ដល់របៀបរៀបរយសាធារណៈ ឬទំនៀមទំលាប់ល្អរបស់ប្រពៃណីជាតិ[23]។

កិច្ចសន្យានឹងមិនមានសុពលភាពឡើយ ក្នុងករណីប្រសិនបើភាគីណាមួយមិនបានបំពេញតាវកាលិក ឬកាតព្វកិច្ចដែលមានចែងក្នុងកិច្ចសន្យា ភាគីផ្សេងៗទៀតអាចប្រើប្រាស់យន្តការតុលាការ ដើម្បីសុំរំលាយកិច្ចសន្យា ឬប្តឹងសុំរឹបអូសទ្រព្យសម្បត្តិយកមកលក់ឡៃឡុង ក្នុងករណីដែលភាគីនោះគ្មានប្រាក់សង ឬប្តឹងដាក់ពន្ធនាគារបង្ខំលើរូបកាយ ប្រសិនភាគីនោះមិនព្រមអនុវត្តកាតព្វកិច្ចទៀត។

កម្មវត្ថុនៃកិច្ចសន្យា សំដៅលើប្រតិបត្តិការគតិយុត្តដែលភាគីទាំងឡាយត្រូវបំពេញចំពោះគ្នាទៅវិញទៅ

[19] សៀវភៅនីតិរដ្ឋប្បវេណី, រៀបរៀងដោយសាស្ត្រាចារ្យ អម សុផាណារ៉ាត, ឆ្នាំសិក្សា ២០១៨-២០១៩,ទំព័រ ៣៨

[20] មាត្រា ៣១ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១១

[21] កថាភាគទី២ ទំព័រ៧,កថាភាគទី៣ ទំព័រ៨ ដល់១០ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ និងកថាភាគទី២ និងទី៣,ទំព័រ ៧,៨,៩នៃក្រមព្រហ្មទណ្ឌឆ្នាំ២០១១

[22] មាត្រា ១៩,២០ និងមាត្រា ២១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[23] វាក្យខណ្ឌទី៣ មាត្រា ៣ នៃក្រឹត្យច្បាប់លេខ ៣៨

មកដែលអាចសន្មត់បានថា វាជាកម្មវត្ថុនៃកាតព្វកិច្ចរបស់គូភាគីនៃកិច្ចសន្យាបញ្ចាំនេះ។ កម្មវត្ថុនៃកាតព្វកិច្ចនេះ សំដៅទៅលើតាវកាលិក ឬរបស់អ្វីមួយដែលគូភាគីត្រូវផ្តល់ឲ្យគូភាគីម្ខាងទៀតនៃកិច្ចសន្យាបញ្ចាំដែលខ្លួនបាន សន្យាចំពោះគ្នាដែលដូចទៅនឹងកិច្ចសន្យាលក់ទិញដែរ ដូចជាអ្នកទិញមានកាតព្វកិច្ចបង់ថ្លៃ ឯអ្នកលក់មាន កាតព្វកិច្ចប្រគល់វត្ថុជាដើម ។ល។

កម្មវត្ថុនៃកិច្ចសន្យាបញ្ចាំ ត្រូវតែជាកម្មវត្ថុដែលមានបច្ចុប្បន្ន កម្មវត្ថុដែលមាននៅពេលអនាគត និងកម្ម វត្ថុដែលអាចធ្វើបាន។

### ៣.១.៣.១ កម្មវត្ថុមានបច្ចុប្បន្ន

នៅពេលដែលមានការចុះកិច្ចសន្យាត្រូវមានវត្ថុមួយជាក់លាក់ និងមានតម្លៃជាពាណិជ្ជកម្ម អាចជួញដូរ បាន ហើយភាគីនៃកិច្ចសន្យាបានដឹងច្បាស់ថា កម្មវត្ថុនៃកិច្ចសន្យា ជាប្រភេទនៃវត្ថុអ្វីមួយពិតប្រាកដដែលមានរូប រាង បរិមាណ គុណភាព ពណ៌........នៅពេលចុះកិច្ចសន្យា និងជាវត្ថុមិនត្រូវបានហាមឃាត់ដោយច្បាប់នោះទេ ដែលជារួមភាគីអាចយកមកអនុវត្តបានចំពោះកិច្ចសន្យានោះ។

### ៣.១.៣.២ កម្មវត្ថុមាននៅពេលអនាគត

នៅក្នុងកិច្ចសន្យាបញ្ចាំនេះ កម្មវត្ថុដែលនឹងមាននៅពេលអនាគត គឺសំដៅលើកម្មវត្ថុនៃកិច្ចសន្យា ដែល ត្រូវបានគេសន្មត់ថា មានជាក់លាក់នៅពេលចុះកិច្ចសន្យាតែកត់សម្គាល់ឃើញជាវិជ្ជមាននៅពេលអនាគត។

### ៣.១.៣.៣ កម្មវត្ថុដែលអាចធ្វើកើត

ដូចដែលបានលើកឡើងខាងលើនេះ កម្មវត្ថុនៃកិច្ចសន្យាបញ្ចាំត្រូវតែជាវត្ថុដែលមានតម្លៃជាពាណិជ្ជកម្ម អាចធ្វើការជួញដូរ បម្លែងបាន ហើយមិនស្ថិតនៅក្រោមការហាមឃាត់ដោយច្បាប់ និងមិនផ្ទុយនឹងរបៀបរៀបរយ សាធារៈ ឬទំនៀមទំលាប់ល្អជាដើម។ ជាក់ស្តែង វត្ថុដែលច្បាប់មិនបានហាមឃាត់មានដូចជា កម្មវត្ថុនៃកិច្ច សន្យាត្រូវតែជាកម្មសិទ្ធិស្របច្បាប់របស់ភាគីម្ខាងទៀតដែលជាម្ចាស់កម្មសិទ្ធិដូចជា ផ្ទះ អគារ ឬថយន្ត ដែល ម្ចាស់កម្មសិទ្ធិបានទិញពីក្រុមហ៊ុនមានអាជ្ញាប័ណ្ណត្រឹមត្រូវជាដើម ផ្ទុយមកវិញបើក្រុមហ៊ុនពុំមានអាជ្ញាប័ណ្ណត្រឹម ត្រូវស្របតាមច្បាប់ទេ ឃើញថាក្រុមហ៊ុនបានធ្វើសកម្មភាពលក់ទិញរថយន្តដោយមិនស្របច្បាប់ ដែលជាហេតុ នាំឲ្យកិច្ចសន្យាអសុពលភាពក្នុងការអនុវត្តតែម្តង។

## ៣.២ លក្ខខណ្ឌទម្រង់

ជាគោលការណ៍ កិច្ចសន្យាមួយមានសុពលភាព និងមានអានុភាពអនុវត្តលើភាគីនៃកិច្ចសន្យាបាន ដោយផ្អែកលើលក្ខខណ្ឌសមត្ថភាព កម្មវត្ថុ និងស្វ័យភាពនៃការបង្ហាញឆន្ទៈដោយគ្មានវិការៈនៅពេលចុះកិច្ច សន្យាហើយនោះ វានឹងក្លាយទៅជាច្បាប់សម្រាប់គូភាគីនៃកិច្ចសន្យាក្នុងការអនុវត្ត គឺមិនផ្តោតតែទៅលើកិច្ច សន្យាដែលបានធ្វើជាទម្រង់លាយល័ក្ខណ៍អក្សរតែប៉ុណ្ណោះទេ (លិខិតឯកជន សំដៅលើលិខិតទាំងឡាយណា ដែលបង្កើតឡើងដោយបុគ្គលឯកជនមានចុះហត្ថលេខា និងស្នាមផ្តិតម្រាមដៃរបស់ភាគីនៃកិច្ចសន្យា) តែច្បាប់ក៏ បានទទួលស្គាល់ផងដែរនូវការសន្យា ឬការព្រមព្រៀងដោយផ្ទាល់មាត់សម្រាប់គូភាគីអនុវត្តបានដែរ គ្រាន់តែវា មានភាពលំបាកជាងការព្រមព្រៀងដែលធ្វើជាលាយល័ក្ខណ៍អក្សរ ឬជាឯកសារ ព្រោះពេលដែលមានវិវាទកើត ឡើង គឺភាគីអាចយកលិខិតដែលជាឯកសារនោះមកធ្វើជាភ័ស្តុតាងដើម្បីអះអាងបាន។

មាត្រា ៤ នៃក្រឹត្យច្បាប់លេខ ៣៨ ក្រ.ច ២៨/១០/១៩៨៨ បានបញ្ជាក់ថា កិច្ចសន្យាអាចធ្វើឡើងដោយ

ផ្ទាល់មាត់ ឬជាលាយល័ក្ខណ៍អក្សរ។ ច្បាប់អាចកំណត់ឲ្យមានទម្រង់ណាមួយជាក់លាក់ក្នុងកិច្ចសន្យាបាន។ ហើយកិច្ចសន្យាណាដែលមិនបានធ្វើឡើងតាមការកំណត់របស់ច្បាប់ត្រូវបានចាត់ទុកជាមោឃៈ។

ដោយអនុលោមតាមគោលការណ៍កិច្ចសន្យាតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាយើង កិច្ចសន្យាអាចធ្វើឡើងក្រោមទម្រង់២ (ពីរ) យ៉ាងគឺ៖

- ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ ដែលគេហៅថាជា លិខិតយថាភូត
- ឬធ្វើឡើងដោយផ្ទាល់មាត់ក៏បាន ដែលគេហៅថាជា លិខិតឯកជន ទើបមានអានុភាពអនុវត្តស្របតាមគោលការណ៍ច្បាប់កំណត់។

ដោយឡែក ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មិនបានតម្រូវឲ្យបង្កើតកិច្ចសន្យាបញ្ចាំទៅតាមទម្រង់លិខិតយថាភូត ឬលិខិតឯកជននោះ គឺគ្រាន់តែទាមទារឲ្យមានការព្រមព្រៀងរវាងគូភាគីជាចំណុចចាំបាច់តែប៉ុណ្ណោះ។

យ៉ាងណាមិញមាត្រា ៨៤៥ នៃក្រមដដែលនេះក៏បានចែង និងកំណត់ថា ម្ចាស់បំណុលហ៊ីប៉ូតែកមិនអាចយកហ៊ីប៉ូតែកនោះមកតតាំងចំពោះតតិយជនក្រៅពីអ្នកបង្កើតបានឡើយ ប្រសិនបើមិនបានធ្វើកិច្ចសន្យាបង្កើតហ៊ីប៉ូតែកនោះជាលិខិតយថាភូត និងមិនបានចុះបញ្ជីក្នុងសៀវភៅបញ្ជីដីធ្លីទេនោះ។

## ៤. អានុភាពនៃកិច្ចសន្យាបញ្ចាំ

កិច្ចសន្យាមានអានុភាពទៅបាន លុះត្រាតែធ្វើឡើងដោយគោរពទៅតាមលក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់ស្របតាមច្បាប់រដ្ឋដែលនឹងក្លាយជាច្បាប់របស់ភាគី ហើយមានអានុភាពទៅលើភាគី និងបង្កើតឲ្យមានសិទ្ធិ និងកាតព្វកិច្ចតែចំពោះភាគីនៃកិច្ចសន្យាតែប៉ុណ្ណោះ។

ដូច្នេះ នៅពេលដែលកិច្ចសន្យាបានក្លាយទៅជាច្បាប់របស់ភាគីហើយនោះ ភាគីនៃកិច្ចសន្យាត្រូវគោរពនៅគ្រប់លក្ខខណ្ឌទាំងឡាយដែលមានបញ្ញត្តិនៅក្នុងកិច្ចសន្យាបញ្ចាំ ដោយភាគីម្ខាងនៃកិច្ចសន្យានេះមិនអាចកែប្រែ ផ្លាស់ប្តូរ ឬរំលត់សិទ្ធិ និងកាតព្វកិច្ចបានទេ បើពុំមានការពិភាក្សា ឬការព្រមព្រៀងណាមួយជាលាយល័ក្ខណ៍អក្សរ ឬផ្ទាល់មាត់ជាមុនជាមួយភាគីម្ខាងនៃកិច្ចសន្យា ដោយហេតុថា កិច្ចសន្យាបញ្ចាំត្រូវយកទៅអនុវត្តដោយសុចរិត និង កើតចេញពីឆន្ទៈរបស់ភាគីនៃកិច្ចសន្យា តែបើសិនជាកិច្ចសន្យាមិនបានចែងឲ្យបានច្បាស់លាស់ ត្រង់ចំណុចណាមួយដែលនាំឲ្យមានការផលវិបាកនៅក្នុងការអនុវត្ត ភាគីនៃកិច្ចសន្យាបញ្ចាំមានសិទ្ធិលើកចំណុចដែលជាវិមតិសង្ស័យមកពិភាក្សា ចរចា សម្រេចសម្របសម្រួល និងកែតម្រូវ ឬបង្កើតកិច្ចព្រមព្រៀងបំពេញបន្ថែមទៅលើចំណុចណាដែលមិនច្បាស់លាស់នោះបាន។

### ៤.១ កាតព្វកិច្ចក្នុងការអនុវត្តកិច្ចសន្យាបញ្ចាំ

នៅពេលដែលកិច្ចសន្យាមួយមានសុពលភាពលើគូភាគីនៃកិច្ចសន្យាបញ្ចាំ នោះភាគីទាំងសងខាងត្រូវអនុវត្តតាមលក្ខខណ្ឌនៃកិច្ចសន្យាដោយសុចរិត និងស្មោះត្រង់ មានន័យថាភាគីម្ខាងៗត្រូវប្រកាន់យកនូវឥរិយាបទសមស្របត្រឹមត្រូវ ជៀសវាងក្នុងការបង្កផលវិបាកឲ្យគ្នាទៅវិញទៅមក ក្នុងន័យនេះផងដែរ គូភាគីនៃកិច្ចសន្យាបញ្ចាំដែលរួមមានអ្នកបង្កើតសិទ្ធិលើការបញ្ចាំ និងម្ចាស់សិទ្ធិលើការបញ្ចាំនោះ ត្រូវតែសហការគ្នាក្នុងការប្រើសិទ្ធិ និងអនុវត្តកាតព្វកិច្ចឲ្យបានល្អ មិនកេងចំណេញខុសច្បាប់ឡើយ។ ដូច្នេះ ភាគីនៃកិច្ចសន្យាប្រភេទនេះត្រូវតែគោរពទៅតាមលក្ខខណ្ឌនៃប្រការទាំងឡាយ ដែលមានចែងនៅក្នុងកិច្ចសន្យាបញ្ចាំនោះ។ ការដែលភាគី

មិនអនុវត្តកាតព្វកិច្ចទៅតាមកិច្ចសន្យាទេ វានឹងបង្កើតបានជាទណ្ឌកម្មនៃកិច្ចសន្យា ដែលឈានទៅរកការរំលាយនៃកិច្ចសន្យាបញ្ចាំ ក៏ដូចជាការសងសំណងខូចខាតចំពោះភាគីដែលរងការខូចខាតផលប្រយោជន៍ជាដើម។

### ៤.២ ទណ្ឌកម្មនៃការបំពានកិច្ចសន្យាបញ្ចាំ

កាលណាកិច្ចសន្យាមួយត្រូវបានបង្កើតឡើងដោយមានសុពលភាពតាមផ្លូវច្បាប់រួចហើយ ភាគីនៃកិច្ចសន្យាត្រូវតែគោរពឲ្យបានម៉ត់ចត់ និងម៉ឺងម៉ាត់ ដោយមូលហេតុកិច្ចសន្យាបញ្ចាំនេះ បានបង្កើតអានុភាពទៅដល់ភាគីនៃកិច្ចសន្យា។ ក្នុងករណី ភាគីណាមួយមិនអនុវត្តតាមត្រូវចាត់ទុកថា ជាការរំលោភ ឬបំពានកិច្ចសន្យាដែលនាំឲ្យភាគីដែលខូចខាតផលប្រយោជន៍ មានសិទ្ធិក្នុងការស្នើសុំឲ្យភាគីម្ខាងទៀតឲ្យធ្វើការពិនិត្យទៅលើខ្លឹមសារនៃកិច្ចសន្យាបញ្ចាំនោះឡើងវិញ និងត្រូវគោរពឲ្យបានត្រឹមត្រូវ ពោល គឺត្រូវធ្វើការអនុវត្តទៅតាមកាតព្វកិច្ចដែលមានចែង។ ប្រសិនបើភាគីនៅតែមិនអនុវត្តទៀត ត្រូវចាត់ទុកថា ជាការរំលោភបំពានកិច្ចសន្យា[24] ដែលបណ្តាលមកពីកំហុសធ្ងន់ធ្ងររបស់ភាគីម្ខាងទៀត។ ក្នុងករណីនេះដែរ ភាគីមានសិទ្ធិអាចរំលាយកិច្ចសន្យាបានភ្លាមៗតែម្តង[25]។

## ៥.សិទ្ធិរបស់ម្ចាស់បំណុលនៃកិច្ចសន្យាបញ្ចាំ

### ៥.១ សិទ្ធិកាន់កាប់វត្ថុបញ្ចាំ

ការបញ្ចាំត្រូវធ្វើឡើងដោយការព្រមព្រៀង និងត្រូវមានការប្រគល់វត្ថុបញ្ចាំរបស់អ្នកដែលបានបង្កើតសិទ្ធិលើការបញ្ចាំ ឬតតិយជនទៅឲ្យម្ចាស់សិទ្ធិលើការបញ្ចាំ។ ហេតុនេះ ម្ចាស់សិទ្ធិលើការបញ្ចាំត្រូវកាន់កាប់វត្ថុបញ្ចាំនោះ ដោយមានការប្រុងប្រយ័ត្នបំផុតក្នុងនាមជាអ្នកគ្រប់គ្រងដោយសុច្ចរិត។ ម្ចាស់សិទ្ធិលើការបញ្ចាំ មានសិទ្ធិទទួលបានផលដែលកើតចេញពីវត្ថុបញ្ចាំនោះបាន និងអាចយកផលនោះ មកកាត់សិទ្ធិលើបំណុលរបស់ខ្លួនបាន។ ផលនោះទៀតសោត ត្រូវយកមកកាត់ការប្រាក់នៃសិទ្ធិលើបំណុលជាមុនសិន ក្នុងករណីបើមានសំណល់ត្រូវយកទៅកាត់ជាមួយប្រាក់ដើម (យោងតាម មាត្រា ៨២២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧)។ ការប្រើប្រាស់ទ្រព្យដាក់បញ្ចាំ ដោយម្ចាស់បំណុលអាចជំនួសការសងបំណុលនេះជាការប្រាក់តែមួយមុខ ឬជាប្រាក់ដើម និងការប្រាក់ផងក៏បាន បើសិនមានចែងក្នុងកិច្ចសន្យាបញ្ចាំនោះបាន។

### ៥.២. សិទ្ធិឃាត់ទុកវត្ថុបញ្ចាំ

តាមរយៈការកាន់កាប់វត្ថុបញ្ចាំនេះ ម្ចាស់សិទ្ធិលើការបញ្ចាំ គឺមានសិទ្ធិជាអាទិភាពក្នុងការឃាត់ទុកនូវវត្ថុបញ្ចាំបាន។ ហើយម្ចាស់សិទ្ធិលើការបញ្ចាំអាចឃាត់ទុកវត្ថុបញ្ចាំបាន រហូតដល់ពេលដែលទទួលការសងចំពោះសិទ្ធិលើបំណុលដែលបានកំណត់។ ប៉ុន្តែសិទ្ធិនេះមិនអាចយកទៅតតាំងជាមួយនឹងម្ចាស់បំណុលដែលមានអាទិភាពជាងខ្លួនបានឡើយ[26]។

### ៥.៣ សិទ្ធិទាមទារឲ្យសងសោហ៊ុយរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ

ប្រសិនបើ ម្ចាស់សិទ្ធិលើការបញ្ចាំ បានចេញចំណាយជាចាំបាច់សម្រាប់គ្រប់គ្រង និងថែរក្សាវត្ថុបញ្ចាំ

---

[24] មាត្រា ៤០៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[25] មាត្រា ៤០៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[26] មាត្រា ៨២១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

ម្ចាស់សិទ្ធិលើការបញ្ចាំនោះអាចទាមទារឲ្យកម្មសិទ្ធិករនៃវត្ថុនោះសងនូវចំណាយនោះមកវិញបាន[27]។ ប្រសិនបើម្ចាស់សិទ្ធិលើការបញ្ចាំបានចេញចំណាយបង្កើនតម្លៃនៃវត្ថុបញ្ចាំ ម្ចាស់សិទ្ធិលើការបញ្ចាំនោះអាចទាមទារឲ្យកម្មសិទ្ធិករនៃវត្ថុបញ្ចាំនោះ សងនូវចំណាយទាំងអស់ដែលបានចេញ ឬសងនូវតម្លៃប្រាក់ដែលកើន នោះវិញតាមជម្រើសរបស់ខ្លួនបានក្នុងករណីដែលកំណើនតម្លៃនៅតែមាន។ ប៉ុន្តែតុលាការអាចកំណត់ពេលមួយដែលសមរម្យ ដើម្បីឲ្យភាគីម្ខាងទៀតអាចសងតាមការទាមទាររបស់កម្មសិទ្ធិករបាន (កថាខណ្ឌទី២ មាត្រា៨២៤នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧)។

### ៥.៤ សិទ្ធិទាមទារសំណងរបស់អ្នកធានាដោយវត្ថុ

ប្រសិនបើអ្នកដែលបានបង្កើតសិទ្ធិលើការបញ្ចាំ ដើម្បីធានាកាតព្វកិច្ចរបស់អ្នកដែលបានសងចំពោះកាតព្វកិច្ចនោះ ឬបានបាត់បង់នូវកម្មសិទ្ធិលើវត្ថុបញ្ចាំ ដោយសារការអនុវត្តសិទ្ធិលើការបញ្ចាំ អ្នកនោះ គឺមានសិទ្ធិក្នុងការទាមទារសំណងពីកូនបំណុលបាន ដោយយោងទៅតាមបទបញ្ញត្តិស្តីពីការធានា[28]។

### ៥.៥ សិទ្ធិហាមឃាត់ការកាន់កាប់ដោយផ្ទាល់ ចំពោះអ្នកបង្កើតសិទ្ធិលើការបញ្ចាំ

ម្ចាស់បំណុល ឬម្ចាស់សិទ្ធិលើការបញ្ចាំនេះ មានសិទ្ធិអាចធ្វើការហាមឃាត់មិនឲ្យកូនបំណុល ឬអ្នកដែលបានបង្កើតសិទ្ធិលើការបញ្ចាំនោះធ្វើការកាន់កាប់ដោយផ្ទាល់ទៅលើវត្ថុបញ្ចាំនោះបានឡើយ[29]។

## ៦. ឧបាទេសកម្មលើវត្ថុ

យោងតាមសន្ទានុក្រម ពាក្យច្បាប់ផ្នែករដ្ឋប្បវេណី ឆ្នាំ ២០០៧ បានផ្តល់និយមន័យនៃពាក្យ **ឧបាទេសកម្ម**ថា គឺជា ឋានៈមួយ ដែលបុគ្គលម្នាក់ ទទួលជំនួសបុគ្គលណាមួយតាមផ្លូវច្បាប់។

ចំពោះឧបាទេសកម្មលើវត្ថុនៃសិទ្ធិលើការបញ្ចាំនេះ គឺអាចអនុវត្តបានចំពោះទឹកប្រាក់ ឬវត្ថុផ្សេងៗទៀតដែលអ្នកបង្កើតត្រូវទទួល ដោយការលក់ ការបាត់បង់ ឬការខូចខាតនូវវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំ។ ប៉ុន្តែម្ចាស់សិទ្ធិលើការបញ្ចាំពុំអាចមានសិទ្ធិរបស់ខ្លួនបានឡើយ នៅក្រោយពេលដែលទឹកប្រាក់ត្រូវបានបង់ ឬវត្ថុផ្សេងត្រូវបានប្រគល់ ទៅឲ្យអ្នក បង្កើតសិទ្ធិលើការបញ្ចាំនោះ។ ករណីដែលតម្លៃថ្នូរនឹងសិទ្ធិប្រត្យក្សដែលបានបង្កើតឡើង ដោយអ្នកបង្កើតសិទ្ធិលើការបញ្ចាំ លើវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំនោះ ក៏ត្រូវបានយកមកអនុវត្តដូចគ្នាទៅនឹងចំណុចដែលបានលើកបង្ហាញខាងលើនេះផងដែរ[30]។

ប៉ុន្តែឧបាទេសកម្មលើវត្ថុនេះ ត្រូវបានធ្វើការបកស្រាយទៅតាមបទបញ្ញត្តិនៃមាត្រា៨៤៩ នៃក្រមរដ្ឋប្បវេ-ណីមកបកស្រាយទៅតាមហ៊ីប៉ូតែក ប្រសិនបើការបញ្ចាំនោះ គឺជាការបញ្ចាំអចលនវត្ថុ។ ហ៊ីប៉ូតែក គឺជាសិទ្ធិដើម្បីប្តូរនឹងតម្លៃនៃកម្មវត្ថុជាក់លាក់ណាមួយ។ ម្ចាស់សិទ្ធិហ៊ីប៉ូតែក (អ្នកទទួលការបញ្ចាំ) អាចអនុវត្តនូវសិទ្ធិលើការបញ្ចាំរបស់ខ្លួនបានចំពោះប្រាក់ ឬវត្ថុផ្សេងទៀត ដែលកើតចេញពីការលក់ ឬការបាត់បង់ កម្មវត្ថុនៃការបញ្ចាំនោះ ពីព្រោះថា ហេតុទាំងនេះ ត្រូវបានចាត់ទុកថា ជាការទទួលស្គាល់ ឬបំប្លែងនូវតម្លៃនៃអចលនវត្ថុដែលបញ្ចាំនោះ។ ប៉ុន្តែម្ចាស់សិទ្ធិនៃការបញ្ចាំពុំអាចអនុវត្តការបញ្ចាំ(ហ៊ីប៉ូតែក) អចលនវត្ថុរបស់ខ្លួនបានឡើយ នៅក្រោយ

[27] កថាខណ្ឌទី១ មាត្រា ៨២៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[28] មាត្រា ៨២៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[29] មាត្រា ៨១៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[30] មាត្រា ៨១៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

ពេលដែលប្រាក់ត្រូវបង់ ឬវត្ថុផ្សេងទៀតត្រូវបានប្រគល់ឲ្យអ្នកបង្កើត។ ហេតុផលដែលបានចែងយ៉ាងដូច្នេះ ដោយសារតែការបញ្ចាំអចលនវត្ថុត្រូវបានបង្កើតឡើង និងអាចអនុវត្តបានតែចំពោះកម្មវត្ថុណាមួយដែលជាក់លាក់តែប៉ុណ្ណោះ ប៉ុន្តែនៅក្រោយពេលដែលតម្លៃបានបំប្លែង ឬកើតចេញពីការលក់ ឬ បាត់បង់វត្ថុជាក់លាក់នោះត្រូវបានប្រគល់ឲ្យអ្នកបង្កើតនៃការបញ្ចាំនោះហើយ ចាប់តាំងពីពេលនោះមកវាមិនអាចធ្វើការបែងចែកពីទ្រព្យសម្បត្តិផ្សេងបានទេ។ ហេតុនេះ ការបញ្ចាំអចលនវត្ថុមិនអាចអនុវត្តចំពោះទ្រព្យនោះបានទៀតទេ។ ដូច្នេះ បើសិនជាម្ចាស់បំណុលហ៊ីប៉ូតែកចង់អនុវត្តឧបាទេសកម្មលើអចលនវត្ថុរបស់ខ្លួនឲ្យបានមុនការប្រគល់ប្រាក់ ឬវត្ថុដែលកើតចេញពីការលក់ ឬ ការបាត់បង់ ឬការខូចខាតចំពោះកម្មវត្ថុនោះឲ្យទៅកូនបំណុលហ៊ីប៉ូតែក។

## ៧. ការហាមឃាត់ចំពោះការបញ្ចាំផ្តាច់

ទោះបីជាកិច្ចសន្យាបញ្ចាំ ត្រូវបានបង្កើតឡើងតាមរយៈការព្រមព្រៀងដោយគ្មានវិការៈរវាងកូនបំណុល និងម្ចាស់បំណុលក៏ដោយ ក៏ច្បាប់មិនធ្វើការអនុញ្ញាតឲ្យបង្កើតឡើងនូវកិច្ចសន្យាបញ្ចាំផ្តាច់ ដែលត្រូវធ្វើមុនពេលកំនត់សងនោះទេ។

ប៉ុន្តែច្បាប់បានកម្រិតនូវសិទ្ធិមួយចំនួនចំពោះភាគីនៃការបញ្ចាំ ដែលអ្នកដែលបានបង្កើតសិទ្ធិលើការបញ្ចាំ មិនអាចព្រមព្រៀងឲ្យម្ចាស់សិទ្ធិលើការបញ្ចាំ ទទួលកម្មសិទ្ធិលើវត្ថុបញ្ចាំ ឬធ្វើការចាត់ចែងវត្ថុបញ្ចាំ ដែលបានធ្វើមុនកំណត់ពេលត្រូវសងតាមការព្រមព្រៀងរបស់ភាគីបានឡើយ[31]។

[31] មាត្រា ៨២៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

# ជំពូកទី២

# ការបញ្ចាំចលនវត្ថុ

ចំពោះការបញ្ចាំចលនវត្ថុ ត្រូវបានបង្កើតឡើង និងអនុវត្តទៅតាមវិធានដូចខាងក្រោមនេះ ៖

## ១. អត្ថន័យនៃការបញ្ចាំចលនវត្ថុ

ការបញ្ចាំចលនវត្ថុ សំដៅទៅលើបបគតិយុត្តិមួយដែលត្រូវបានចែង និងកំណត់ថា គឺជាការដែលត្រូវបានធ្វើឡើងដោយអ្នកបង្កើតសិទ្ធិលើការបញ្ចាំបានយកចលនវត្ថុរបស់ខ្លួនមកធ្វើជាកម្មវត្ថុនៃការដាក់បញ្ចាំ ដើម្បីធានាសិទ្ធិលើបំណុលរបស់ខ្លួនជាមួយម្ចាស់សិទ្ធិលើការបញ្ចាំ។ កិច្ចសន្យាបញ្ចាំនេះ មិនបានតម្រូវឲ្យមានការចុះបញ្ជីទេ គឺគ្រាន់តែប្រគល់ការកាន់កាប់ចលនវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំ ពីកូនបំណុលទៅម្ចាស់បំណុល នោះកិច្ចសន្យាបញ្ចាំនេះនឹងមានអានុភាពអនុវត្ត។ ម្ចាស់សិទ្ធិលើការបញ្ចាំ(ម្ចាស់បំណុ ល) អាចយកសិទ្ធិនៃការកាន់កាប់វត្ថុបញ្ចាំទៅតតាំងជាមួយតតិយជនបាន។

## ២. ការបង្កើតលក្ខខណ្ឌអានុភាពនៃសិទ្ធិលើការបញ្ចាំចលនវត្ថុ

ការបង្កើតសិទ្ធិលើការបញ្ចាំ ចំពោះចលនវត្ថុ ត្រូវតែមានការគោរពតាមលក្ខខណ្ឌដូចខាងក្រោមនេះ៖

### ២.១ លក្ខខណ្ឌទម្រង់នៃការបង្កើតកិច្ចសន្យាបញ្ចាំចលនវត្ថុ

ចំពោះកិច្ចសន្យាបញ្ចាំចលនវត្ថុ គឺត្រូវអនុលោមទៅតាមលក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់ដោយស្របតាមបទបញ្ញត្តិនៃក្រមរដ្ឋប្បវេណីដែលបានចែង ដែលពាក់ព័ន្ធទៅនឹងលក្ខខណ្ឌជាទូទៅនៅក្នុងការបង្កើតកិច្ចសន្យាដែរ។ ដូចដែលបានរៀបរាប់នៅក្នុងជំពូកទី១ នៅក្នុងលក្ខខណ្ឌគ្រឹះយើងសង្កេតឃើញថារួមមាន៖ ការព្រមព្រៀងរបស់គូភាគីដែលគ្មានវិការៈចូលរួម សមត្ថភាពរបស់គូភាគី និងកម្មវត្ថុនៃកិច្ចសន្យា ដែលកម្មវត្ថុនៅក្នុងកិច្ចសន្យាបញ្ចាំចលនវត្ថុ គឺត្រូវតែជាចលនទ្រព្យ។

ចំណែកឯលក្ខខណ្ឌទម្រង់នៃកិច្ចសន្យានេះវិញ គឺត្រូវតែធ្វើជាលិខិតឯកជន ដែលជាច្បាប់របស់គូភាគីនៃកិច្ចសន្យាបញ្ចាំចលនវត្ថុនេះ។

#### ២.១.១ លិខិតឯកជន

លិខិតឯកជន គឺជាលិខិតទាំងឡាយណាដែលបង្កើតឡើងដោយបុគ្គលឯកជន មានចុះហត្ថលេខា និងស្នាមផ្តិតម្រាមដៃ[32] ដែលលិខិតឯកជននោះមានច្រើនប្រភេទ នៅក្នុងសកម្មភាពរស់នៅជាក់ស្តែងដូចជា លិខិតឯកតោភាគី កិច្ចសន្យាទ្វេភាគី ប្រាតិភោគអចលនវត្ថុជាដើម...។

កិច្ចសន្យាទាំងនេះ ទោះបីមានការព្រមព្រៀងដែលគ្មានវិការៈពីភាគីនៃកិច្ចសន្យាក៏ដោយ ក៏កិច្ចសន្យានោះពុំមានសុពលភាពពេញលេញក្នុងការអនុវត្តបានដែរ បើពុំបានចុះបញ្ជីនៅក្រសួង ឬស្ថាប័នដែលពាក់ព័ន្ធដែលច្បាប់តម្រូវនោះ។ លិខិតឯកជននេះ អាចធ្វើឡើងក្រោមរូបភាព ២ (ពីរ) យ៉ាងអាស្រ័យទៅលើឆន្ទៈនៃការព្រមព្រៀងរបស់ភាគី គឺ៖ ការធ្វើដោយផ្ទាល់មាត់ក៏បាន និងធ្វើជាលាយល័ក្ខណ៍អក្សរក៏បាន។

[32] សទ្ធានុក្រម រដ្ឋប្បវេណី ឆ្នាំ ២០០៧, ទំព័រ ១៩

យើងឃើញថាមានការសន្យា ឬការព្រមព្រៀងជាច្រើនដែលភាគីនៃកិច្ចសន្យាមានសិទ្ធិសម្រេចថា ធ្វើលិខិតជាលាយល័ក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ និងមិនតម្រូវចុះបញ្ជីទេ បើភាគីនៃកិច្ចសន្យាយល់ថា ត្រឹមត្រូវអាចទទួលយកបាន វាមានភាពងាយស្រួលសម្រាប់ភាគីជាដើម។

ជាក់ស្តែង មាត្រា ៤ នៃក្រឹត្យច្បាប់លេខ ៣៨ បានចែងថា កិច្ចសន្យាគ្រប់ប្រភេទ ស្តីពីប្រាក់ ឬវត្ថុមួយចំនួន ឬមានតម្លៃលើសពី ៥០០០ (ប្រាំពាន់) រៀល ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ និងមាត្រា ៥៧ ច្បាប់ដដែលនេះ បានចែងចំពោះការអនុវត្តជាក់ស្តែងភាគីនៃកិច្ចសន្យាមានសិទ្ធិធ្វើជាលិខិត ឬមិនធ្វើបានអាស្រ័យទៅតាមការព្រមព្រៀងរបស់ភាគីជាកត្តាសំខាន់។

### ២.១.២ ការផ្ទេរសិទ្ធិកាន់កាប់ចលនវត្ថុ

ដើម្បីឲ្យកិច្ចសន្យាបញ្ចាំចលនវត្ថុមួយមានអានុភាពអនុវត្តបាន ត្រូវបំពេញនូវលក្ខខណ្ឌដូចខាងក្រោមនេះ៖

- ❖ ការព្រមព្រៀងរវាងអ្នកបង្កើតសិទ្ធិលើការបញ្ចាំ និងម្ចាស់សិទ្ធិលើការបញ្ចាំនៃកិច្ចសន្យាបញ្ចាំ។
- ❖ ការផ្ទេរការកាន់កាប់នូវវត្ថុបញ្ចាំ[33]៖ សិទ្ធិលើការបញ្ចាំត្រូវកើតមានឡើងដោយកូនបំណុល ឬតតិយជនដែលបង្កើតសិទ្ធិលើការបញ្ចាំនោះ ប្រគល់នូវវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំទៅឲ្យម្ចាស់សិទ្ធិលើការបញ្ចាំកាន់កាប់។
  - ➢ ប្រភេទនៃការផ្ទេរការកាន់កាប់នូវវត្ថុបញ្ចាំ មាន ៤ (បួន) ប្រភេទគឺ៖
    - ការផ្ទេរការកាន់កាប់ដោយជាក់ស្តែង
    - ការផ្ទេរការកាន់កាប់ដោយសង្ខេប
    - ការផ្ទេរការកាន់កាប់ដោយបញ្ជា
    - ការផ្ទេរការកាន់កាប់ដោយប្តូរលក្ខណៈនៃការកាន់កាប់(មិនប្រើ)[34]។

លក្ខខណ្ឌតតាំងនៃការបញ្ចាំចលនវត្ថុ គឺមានលក្ខណៈខុសពីអចលនវត្ថុត្រង់មិនមានការចុះបញ្ជីទេ វាមានលក្ខខណ្ឌតតាំងម្ចាស់សិទ្ធិលើការបញ្ចាំចលនវត្ថុត្រង់មាន ការកាន់កាប់ជានិរន្តរ៍នូវវត្ថុបញ្ចាំនោះ ដោយម្ចាស់សិទ្ធិលើការបញ្ចាំ។

ជារួម ចំពោះគោលការណ៍នៃកិច្ចសន្យាបញ្ចាំចលនវត្ថុនេះ អ្នកបង្កើតសិទ្ធិលើការបញ្ចាំចលនវត្ថុបន្ទាប់ពីបានបង្កើតកិច្ចសន្យាហើយ ខ្លួនមានកាតព្វកិច្ចត្រូវតែប្រគល់ចលនវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំនោះទៅឲ្យម្ចាស់សិទ្ធិលើការបញ្ចាំនោះធ្វើការគ្រប់គ្រង។ ហើយម្ចាស់សិទ្ធិលើការបញ្ចាំចលនវត្ថុនឹងត្រូវបានបាត់បង់សិទ្ធិតតាំងនៅពេលដែលវត្ថុដែលជាកម្មវត្ថុនៃការដាក់បញ្ចាំនោះ ត្រូវបានបាត់បង់ដោយករណីណាមួយ។

គូភាគីនៃការបញ្ចាំចលនវត្ថុរួមមានដូចជា៖

- ❖ អ្នកបង្កើតសិទ្ធិលើការបញ្ចាំ (មានកូនបំណុល ឬតតិយជនធានាដោយវត្ថុ)
- ❖ ម្ចាស់សិទ្ធិលើការបញ្ចាំ (មានម្ចាស់បំណុល)។

[33] មាត្រា ៨១៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[34] មាត្រា ៨២៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

### ២.២ អានុភាពនៃការបញ្ចាំចលនវត្ថុ

អានុភាពនៃសិទ្ធិលើការបញ្ចាំចលនវត្ថុចំពោះគូភាគី គឺមានទៅលើទំហំសិទ្ធិលើបំណុលដែលត្រូវបានធានាដូចជា[35]៖

- ប្រាក់ដើម
- ការប្រាក់ (ចំពោះ ២ ឆ្នាំចុងក្រោយតែប៉ុណ្ណោះ)
- ប្រាក់ធានាសំណង ក្នុងករណីបំពានកិច្ចសន្យាដែលត្រូវបានបង្កើតឡើងដោយគូភាគីដោយការព្រមព្រៀងគ្នា។
- សោហ៊ុយដើម្បីអនុវត្តសិទ្ធិលើការបញ្ចាំ
- សោហ៊ុយលើការថែរក្សាទៅលើវត្ថុបញ្ចាំ
- សំណងការខូចខាតដោយសារការមិនអនុវត្តកាតព្វកិច្ច ឬវិការៈកំបាំងនៃវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំ។

### ២.៣ សិទ្ធិរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ

សិទ្ធិរបស់ម្ចាស់សិទ្ធិលើការបញ្ចាំចលនវត្ថុ គឺមានលក្ខណៈខុសគ្នាពីសិទ្ធិលើការបញ្ចាំអចលនវត្ថុដូចខាងក្រោមនេះ៖

- ជាគោលការណ៍ ច្បាប់ម្ចាស់សិទ្ធិលើការបញ្ចាំ ពុំមានសិទ្ធិប្រើប្រាស់ និងជួលវត្ថុបញ្ចាំបានទេ ប្រសិនបើគ្មានការយល់ព្រមណាមួយចេញពីកូនបំណុល។ លើកលែងតែមានការប្រើប្រាស់ត្រឹមកម្រិតចាំបាច់ដើម្បីថែរក្សាវត្ថុបញ្ចាំ[36]។
- កូនបំណុលអាចទាមទារឲ្យរំលត់សិទ្ធិលើការបញ្ចាំបាន ប្រសិនបើម្ចាស់សិទ្ធិមិនបានគោរពតាមបទបញ្ញត្តិដែលបានកំណត់នោះទេ។ វាមានចែងនៅក្នុង ច្បាប់សារធាតុ ដែលកូនបំណុលអាចទាមទារតាមផ្លូវតុលាការបាន។ ប៉ុន្តែ គឺវារលត់តែសិទ្ធិលើការបញ្ចាំតែប៉ុណ្ណោះ ចំណែកឯសិទ្ធិលើបំណុលរបស់ម្ចាស់សិទ្ធិលើបំណុល គឺនៅតែមានដដែល ដែលនៅតែមានអត្ថិភាពសិទ្ធិលើបំណុល។
- ម្ចាស់សិទ្ធិលើការបញ្ចាំ មានសិទ្ធិឃាត់ទុកនូវវត្ថុបញ្ចាំ រហូតដល់ពេលដែលបានទទួលការសងចំពោះសិទ្ធិលើបំណុលរបស់ខ្លួនត្រូវបានរលត់ដោយអ្នកបង្កើតសិទ្ធិលើការបញ្ចាំ(កូនបំណុល)[37]។
- ម្ចាស់សិទ្ធិលើការបញ្ចាំដែលទទួលបានផល ដែលកើតចេញពីវត្ថុបញ្ចាំត្រូវយកមកកាត់សិទ្ធិលើបំណុលរបស់ខ្លួន ដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀត[38]។
- ម្ចាស់សិទ្ធិលើការបញ្ចាំ ត្រូវកាន់កាប់វត្ថុបញ្ចាំដោយមានការប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិតឲ្យដូចជារបស់ខ្លួនដែរ[39]។ កូនបំណុលអាចធ្វើការទាមទារឲ្យរំលត់សិទ្ធិលើការបញ្ចាំបាន នៅក្នុងករណីដែលម្ចាស់សិទ្ធិលើការបញ្ចាំនោះមិនបានគោរពករណីយកិច្ច ដូចដែលច្បាប់សារធាតុបានកំណត់

[35] មាត្រា ៨២០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧
[36] មាត្រា ៨៣១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧
[37] មាត្រា ៨២១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧
[38] មាត្រា ៨២២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧
[39] មាត្រា ៨២៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

ទុក។ វា គឺជាគោលការណ៍សុចរិតនៃការគ្រប់គ្រង។

- ម្ចាស់សិទ្ធិលើការបញ្ចាំ ប្រសិនបានចំណាយចាំបាច់សម្រាប់ការគ្រប់គ្រងថែរក្សាទៅលើវត្ថុបញ្ចាំ ម្ចាស់សិទ្ធិលើការបញ្ចាំអាចទាមទារឲ្យកម្មសិទ្ធិករនៃវត្ថុបញ្ចាំ ( អ្នកបង្កើតសិទ្ធិលើការបញ្ចាំ ឬ ហៅថាកូនបំណុល) ឲ្យសងនូវរាល់ការចំណាយនោះមកវិញបាន។
- ប្រសិនបើម្ចាស់សិទ្ធិលើការបញ្ចាំ បានចំណាយដើម្បីបង្កើនតម្លៃទៅលើវត្ថុបញ្ចាំ នោះម្ចាស់សិទ្ធិលើការបញ្ចាំ អាចទាមទារឲ្យកម្មសិទ្ធិករនៃវត្ថុបញ្ចាំនោះសងសំណងដែលខ្លួនបានចំណាយទាំងអស់ ឬតម្លៃកំណើនវត្ថុនោះបាន (យោងតាមមាត្រា ៨២៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧)។

### ៣. ការបញ្ចាំបន្ត

ការបញ្ចាំបន្ត ត្រូវតែមានលក្ខខណ្ឌចម្បងដូចខាងក្រោមនេះ៖

- ដោយមានការយល់ព្រមពីអ្នកបង្កើតសិទ្ធិលើកិច្ចសន្យាបញ្ចាំ (តាមរយៈការធ្វើឡើងជាទម្រង់លាយល័ក្ខណ៍ជាកំណត់)។
- ការបញ្ចាំបន្ត ក្រោមការទទួលខុសត្រូវរបស់ម្ចាស់សិទ្ធិលើការបញ្ចាំទាំងស្រុង ប្រសិនបើមានការខូចខាតណាមួយ ដោយមិនមានការយល់ព្រមពីអ្នកដែលបានបង្កើតសិទ្ធិលើការបញ្ចាំ(កូនបំណុល)[40]។

### ៤. ការហាមឃាត់ការបញ្ចាំផ្តាច់

រាល់ការបញ្ចាំទាំងអស់ គឺច្បាប់មិនអនុញ្ញាតឲ្យមានការបញ្ចាំផ្តាច់នោះទេ។ វាមានលក្ខណៈដូចតទៅនេះ៖

- ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ត្រង់មាត្រា ៨២៧ នៃក្រមនេះ បានចែង និងធ្វើការកំណត់ថា៖ មិនមានការអនុញ្ញាតឲ្យមានការបញ្ចាំផ្តាច់ជាដាច់ខាត ទោះបីជាមានការព្រមព្រៀងណាមួយត្រូវបានបង្កើតឡើងរវាងគូភាគីនៃអ្នកដែលបានបង្កើតសិទ្ធិលើការបញ្ចាំ និងម្ចាស់សិទ្ធិលើការបញ្ចាំក៏ដោយ ឬក៏ជាកិច្ចសន្យាដែលបានធ្វើឡើងទុកមុនពេលកំណត់ត្រូវសង ដើម្បីឲ្យម្ចាស់សិទ្ធិលើការបញ្ចាំទទួលបានជាកម្មសិទ្ធិលើវត្ថុបញ្ចាំ ឬចាត់ចែងវត្ថុបញ្ចាំនោះឡើយ។
- ប៉ុន្តែ ប្រសិនបើជាគូភាគីបានធ្វើកិច្ចសន្យាបញ្ចាំផ្តាច់នៅក្រោយកាលបរិច្ឆេទ នៃការសងនោះបានមកដល់ ការបង្ហាញឆន្ទៈរបស់គូភាគី ជាពិសេស គឺអ្នកបង្កើតសិទ្ធិលើការបញ្ចាំនោះ បានបង្ហាញឆន្ទៈដោយគ្មានវិការៈទេ នាំឲ្យកិច្ចសន្យានោះមានអានុភាពអនុវត្តបាន ដោយឈរលើគោលការណ៍ស្វ័យគ្រចិត្តរបស់គូភាគី។ នេះបានន័យថា មិនឲ្យមានការធ្វើការបង្កើតកិច្ចសន្យាមុនកាលបរិច្ឆេទនៃការសងបានទេ[41]។

### ៥. ការអនុវត្តសិទ្ធិលើការបញ្ចាំចលនវត្ថុ

ការអនុវត្តសិទ្ធិលើការបញ្ចាំចលនវត្ថុមានលក្ខណៈសំខាន់ ២ (ពីរ) យ៉ាងគឺ៖

#### ៥.១ ការលក់ដោយបង្ខំ

ដើម្បីធ្វើការយកប្រាក់ មកសងសិទ្ធិលើបំណុលរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ ដោយមានអាទិភាពជាង

[40] មាត្រា ៨២៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[41] មាត្រា ៨២៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

ម្ចាស់បំណុលផ្សេងៗទៀត។ តាមរយៈការដាក់ពាក្យសុំទៅអាជ្ញាសាលា ដើម្បីអនុវត្តការលក់ដោយបង្ខំក្នុងការយកប្រាក់មកចាត់ចែងសងម្ចាស់សិទ្ធិលើការបញ្ចាំ។ ជាទូទៅ គឺជាចំណាយទៅលើសោហ៊ុយនានាដែលកើតពីកម្មវត្ថុបញ្ចាំនោះ។

### ៥.២ ការអនុវត្តសិទ្ធិលើការបញ្ចាំដោយសង្ខេប

ការអនុវត្តសិទ្ធិលើការបញ្ចាំដោយសង្ខេប គឺត្រូវធ្វើការស្នើរសុំដីកាសម្រេចពីតុលាការអនុវត្ត ដើម្បីឲ្យយកវត្ថុបញ្ចាំមកសងផ្ទាល់តែម្តង តាមការវាយតម្លៃរបស់អ្នកវាយតម្លៃបាន លុះត្រាតែមានមូលហេតុច្បាស់លាស់ (កថាខណ្ឌទី១ នៃមាត្រា ៨៣២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧)។ ដោយត្រូវតែអនុលោមតាមលក្ខខណ្ឌមួយចំនួនដូចខាងក្រោមនេះ ដែលរួមមានដូចជា៖

- មានមូលហេតុត្រឹមត្រូវ
- ជូនដំណឹងអំពីការទាមទារនោះទៅកាន់កូនបំណុលជាមុន
- តុលាការអនុវត្តខុសពីអាជ្ញាសាលា ដែលយើងត្រូវតែធ្វើការដាក់ពាក្យសុំឲ្យតុលាការអនុវត្តចេញដីកាសម្រេច ដោយយកវត្ថុបញ្ចាំមកសងដល់ម្ចាស់សិទ្ធិលើការបញ្ចាំ(ម្ចាស់បំណុល) ដើម្បីកាត់កងជាមួយសិទ្ធិលើបំណុលផ្ទាល់តែម្តង។ នីតិវិធីនេះ មានលក្ខណៈចំណាយតិចជាងការអនុវត្តលក់ដោយបង្ខំជាមួយលំហូរនីតិវិធីរបស់អាជ្ញាសាលា ក្នុងរឿងការអនុវត្តការលក់ដោយបង្ខំ[42]។

---

[42] មាត្រា ៥០៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

# ជំពូកទី៣
# ការបញ្ចាំអចលនវត្ថុ

ការដាក់បញ្ចាំ មិនមែនមានត្រឹមតែការបញ្ចាំចលនវត្ថុតែមួយនោះទេ ក្នុងនោះអចលនទ្រព្យក៏ត្រូវបានគេយកមកធ្វើជាកម្មវត្ថុក្នុងការដាក់បញ្ចាំ ដើម្បីធានាបំណុលរបស់ខ្លួនផងដែរ។ ចំពោះការបញ្ចាំអចលនវត្ថុនេះ យើងនឹងធ្វើការបកស្រាយនូវខ្លឹមសារដូចតទៅនេះ៖

## ១. អត្ថន័យនៃការបញ្ចាំអចលនវត្ថុ

ការបញ្ចាំអចលនវត្ថុ គឺជាកិច្ចសន្យាដែលត្រូវបានបង្កើតឡើងដោយអ្នកបង្កើតសិទ្ធិលើការបញ្ចាំ (កូនបំណុល) ប្រគល់អចលនវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំឲ្យទៅម្ចាស់សិទ្ធិលើការបញ្ចាំ (ម្ចាស់បំណុល) របស់ខ្លួនធ្វើការកាន់កាប់ ដើម្បីធានាបំណុល។ បានន័យថា ដើម្បីធានាបំណុលរបស់ខ្លួន ច្បាប់នេះតម្រូវឲ្យកូនបំណុលប្រគល់អចលនវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំទៅឲ្យម្ចាស់បំណុលជាចាំបាច់[43]។

ម៉្យាងវិញទៀត ក្រមរដ្ឋប្បវេណីបានឲ្យនិយមន័យជាទូទៅថា ម្ចាស់សិទ្ធិលើការបញ្ចាំមានសិទ្ធិកាន់កាប់វត្ថុដែលបានទទួលពីកូនបំណុល ឬតតិយជន ដើម្បីធានាសិទ្ធិលើបំណុលរបស់ខ្លួន និងទទួលបានការសងចំពោះសិទ្ធិលើបំណុលរបស់ខ្លួនពីវត្ថុនោះ ដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀត។ មានន័យថា ការបញ្ចាំ គឺអនុញ្ញាតឲ្យម្ចាស់បំណុលធ្វើការកាន់កាប់នូវវត្ថុបញ្ចាំដែលបានទទួលពីកូនបំណុល និងទទួលបានសំណងចំពោះសិទ្ធិលើបំណុលរបស់ខ្លួន ដែលបានមកពី តម្លៃថ្លៃនៃវត្ថុដែលមានអទិភាពជាងម្ចាស់បំណុលផ្សេងៗទៀត[44]។

## ២. ការបង្កើតលក្ខខណ្ឌអានុភាពនៃសិទ្ធិលើកិច្ចសន្យាបញ្ចាំអចលនវត្ថុ

ជាគោលការណ៍ ដើម្បីឲ្យកិច្ចសន្យាមួយមានសុពលភាព និងមានលក្ខណៈគតិយុត្ត គូភាគីនៃកិច្ចសន្យាត្រូវគោរពតាមលក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់នៅពេលបង្កើតកិច្ចសន្យានោះឡើង។

កិច្ចសន្យាបញ្ចាំអចលនវត្ថុនឹងអាចកើតឡើងនៅពេលដែលអ្នកបង្កើតសិទ្ធិលើការបញ្ចាំ(កូនបំណុល) ឬតតិយជនបានព្រមព្រៀងប្រគល់វត្ថុបញ្ចាំនោះទៅឲ្យម្ចាស់សិទ្ធិលើការបញ្ចាំ។ ប៉ុន្តែ កិច្ចសន្យានេះមិនអាចកើតឡើងបានទេ បើការព្រមព្រៀងប្រគល់វត្ថុនោះកើតចេញពីការបង្ហាញឆន្ទៈដែលមានភ្ជាប់មកជាមួយនឹងវិការៈមកជាមួយនោះ។

ចំពោះកិច្ចសន្យាបញ្ចាំអចលនវត្ថុនេះ មានភាពខុសប្លែកពីទម្រង់នៃកិច្ចសន្យាទូទៅ ដែលយើងបានដឹងរួចមកហើយថា កិច្ចសន្យាអាចធ្វើក្រោមទម្រង់ជាលាយក្ខណ៍អក្សរក៏បាន ឬជាទម្រង់ផ្ទាល់មាត់ក៏បាននោះ។ ប៉ុន្តែនៅក្នុងការបញ្ចាំអចលនវត្ថុ ចាំបាច់គឺ ត្រូវតែធ្វើឡើងក្រោមទម្រង់ជាលាយល័ក្ខណ៍អក្សរតែប៉ុណ្ណោះ ពោលគឺធ្វើជាលិខិតយថាភូតដែលផ្ទុយពីការបញ្ចាំចលនវត្ថុ ដែលត្រូវធ្វើជាលិខិតឯកជននោះ ( យោងតាម មាត្រា ៩ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ឆ្នាំ២០១១)។

[43] កថាខណ្ឌទី១ មាត្រា ២០៦ នៃច្បាប់ភូមិបាលឆ្នាំ ២០០១

[44] មាត្រា ២១៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

### ២.១ លិខិតយថាភូត

លិខិតយថាភូត ជាលិខិតដែលធ្វើឡើងតាមរូបមន្តច្បាប់ ដោយមន្ត្រីសាធារណៈ ដែលត្រូវបានអនុញ្ញាតឲ្យប្រតិបត្តិមុខងារនោះ។ តាមន័យចង្អៀត គឺជាលិខិតទាំងឡាយណាដែលបានរៀបចំឡើងដោយសាការី[45]។

កិច្ចសន្យាអាចធ្វើឡើងដោយផ្ទាល់មាត់ ឬជាលាយល័ក្ខណ៍អក្សរ។

ការកំណត់ត្រូវធ្វើដោយទម្រង់លិខិតយថាភូត និងចុះបញ្ជី ដោយកត់សម្គាល់ថា កម្មវត្ថុនៃកិច្ចសន្យាស្ថិតក្នុងដែនសមត្ថកិច្ចគ្រប់គ្រងដោយអាជ្ញាធរដែនដី និងច្បាប់រដ្ឋជាដើម។ ដូច្នេះ ករណីនេះកិច្ចសន្យាដែលមិនបានចុះបញ្ជីនៅស្ថាប័នគ្រប់គ្រងគល់បញ្ជីនេះ ត្រូវចាត់ទុកថាជាមោឃៈ ឬមិនទាន់បានធ្វើឲ្យបានត្រឹមត្រូវតាមនីតិវិធីច្បាប់ ដូច្នេះតតិយជនដែលប៉ះពាល់ផលប្រយោជន៍មានសិទ្ធិប្តឹងតវ៉ាបាន ឬភាគីនៃកិច្ចសន្យាត្រូវធ្វើកិច្ចសន្យាចំពោះអាជ្ញាធរមានសមត្ថកិច្ច។ ជាក់ស្តែង ដូចជា កិច្ចសន្យាបញ្ចាំអចលនវត្ថុនេះ[46]។

ចំណែកឯច្បាប់ភូមិបាល ឆ្នាំ២០០១ វិញបានកំណត់ថា ចំពោះកិច្ចសន្យាបញ្ចាំអចលនវត្ថុត្រូវតែបង្កើតឡើងតាមទម្រង់លិខិតយថាភូត ទើបអាចយកជាការបាន និងអាចធ្វើការតតាំងជាមួយតតិយជនបានផងដែរ។

ចំណែកឯមាត្រា ២០៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ វិញបានចែងថា "កិច្ចសន្យាបញ្ចាំអចលនវត្ថុ គឺជាកិច្ចសន្យាដែលតាមកិច្ចសន្យានោះ កូនបំណុលត្រូវប្រគល់ឲ្យម្ចាស់បំណុលនូវទ្រព្យមួយដែលជារបស់ខ្លួន ដើម្បីធានាបំណុល។ ម្ចាស់បំណុលមានសិទ្ធិ ក្នុងការសុំលក់វត្ថុនោះ ដើម្បីធ្វើការសងបំណុលតាមបុព្វសិទ្ធិ និងសិទ្ធិបុរិមា ដែលខ្លួនមានជាងម្ចាស់បំណុលដទៃ។"

ជារួម សិទ្ធិលើការបញ្ចាំអចលនវត្ថុអាចកើតមានឡើងទៅបាន លុះត្រាតែមានការប្រគល់វត្ថុបញ្ចាំនោះទៅឲ្យម្ចាស់សិទ្ធិលើការបញ្ចាំធ្វើការកាន់កាប់ ។ ពោលគឺ ករណីនេះមិនអនុញ្ញាតឲ្យប្រគល់នូវអចលនវត្ថុបញ្ចាំតាមរយៈការប្តូរលក្ខន្តិកៈនៃការកាន់កាប់ទេ បានន័យថាអ្នកបង្កើតសិទ្ធិលើការបញ្ចាំមិនបានប្រគល់វត្ថុជាក់ស្តែងទេ ហើយម្ចាស់សិទ្ធិលើការបញ្ចាំទទួលការកាន់កាប់ដោយប្រយោលតែប៉ុណ្ណោះ គឺមិនត្រូវបានច្បាប់ធ្វើការហាមឃាត់ចំពោះករណីបែបនេះទេ (យោងតាមមាត្រា ៨២៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧)។ ទន្ទឹមនឹងនេះផងដែរ ក្រមរដ្ឋប្បវេណីមិនអនុញ្ញាតឲ្យធ្វើការប្រគល់ប័ណ្ណកម្មសិទ្ធិជំនួសការប្រគល់អចលនវត្ថុ ដែលជាកម្មវត្ថុនៃការបញ្ចាំនោះទេ ដោយសារតែសិទ្ធិលើការបញ្ចាំអចលនវត្ថុ ដោយមិនប្រគល់ការកាន់កាប់នេះ អាចជំនួសដោយហ៊ីប៉ូតែកបាន។

### ២.២ ការផ្ទេរសិទ្ធិកាន់កាប់អចលនវត្ថុ

ការផ្ទេរការកាន់កាប់នេះ មាន ៤ (បួន) ប្រភេទសំខាន់ៗ ដែលរួមមានដូចជា[47]៖

❖ **ត្រូវតែមានការប្រគល់ដោយជាក់ស្តែង**៖ គឺមានការប្រគល់ដោយជាក់ស្តែងនូវវត្ថុបញ្ចាំដោយផ្ទាល់រវាងម្ចាស់បំណុល និងកូនបំណុលនៃកិច្ចសន្យាបញ្ចាំ។

**ឧទាហរណ៍**៖ លោក ក ជាអ្នកបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុ បានដាក់បញ្ចាំដី ១ កន្លែង ទៅឲ្យលោក ខ ដែលជាម្ចាស់សិទ្ធិលើការបញ្ចាំ ដោយលោក ក បានធ្វើការប្រគល់ដី ១ កន្លែងនោះ ទៅឲ្យលោក ខ

[45] សទ្ទានុក្រម នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ ,ទំព័រ ១៩

[46] មាត្រា ៦៥ នៃក្រឹត្យច្បាប់លេខ ៣៨

[47] មាត្រា ២២៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

ធ្វើការកាន់កាប់។ នេះ គឺជារូបភាពនៃការប្រគល់ដោយជាក់ស្តែង។

❖ **ការប្រគល់ឲ្យសង្ខេប៖** គឺជាការព្រមព្រៀងដោយសង្ខេប ពីការប្រគល់ដល់ភាគីដែលជាម្ចាស់សិទ្ធិលើការបញ្ចាំ ដោយសារម្ចាស់សិទ្ធិលើការបញ្ចាំបានបង្កើតភតិសន្យា មុនកាលបរិច្ឆេទនៃការបង្កើតសិទ្ធិលើការបញ្ចាំ[48]។

**ឧទាហរណ៍៖** នៅឆ្នាំ ២០១៩ លោក ក ជាភតិបតី បានធ្វើកិច្ចសន្យាជួលនូវដី១កន្លែងជាមួយលោក ខ ដែលភតិកៈ ។ នៅឆ្នាំ ២០២០ លោក ក ដែលជាអ្នកបង្កើតសិទ្ធិលើការបញ្ចាំ បានដាក់បញ្ចាំដី១កន្លែងនោះទៅឲ្យលោក ខ ដែលជាម្ចាស់សិទ្ធិលើការបញ្ចាំ ហើយលោក ក និង លោក ខ បានព្រមព្រៀងគ្នាថា មានការផ្ទេរការកាន់កាប់។ នេះ គឺជារូបភាពនៃការប្រគល់ដោយសង្ខេប។

❖ **ការផ្ទេរការកាន់កាប់ដោយបញ្ជា៖** គឺសំដៅទៅលើការព្រមព្រៀងរវាងអ្នកបង្កើតសិទ្ធិលើការបញ្ចាំ និងម្ចាស់សិទ្ធិលើការបញ្ចាំដោយបញ្ជាថា កម្មសិទ្ធិករនៃវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំមានអត្ថិភាពនៃសិទ្ធិលើការបញ្ចាំ ដោយម្ចាស់សិទ្ធិលើការបញ្ចាំត្រូវជូនដំណឹងទៅតតិយជន ដែលកំពុងបានធ្វើការកាន់កាប់ដោយកិច្ចសន្យា (ភតិសន្យា ឬសិទ្ធិជួលអចិន្ត្រៃយ៍) គឺជាលក្ខខណ្ឌចម្បងនៃការបង្កើតសិទ្ធិលើការបញ្ចាំ។ ជាគោលការណ៍ ត្រូវមានលក្ខខណ្ឌ ២ (ពីរ) សំខាន់នៅក្នុងករណី៖

➢ មានការព្រមព្រៀងរវាងគូភាគីនៃម្ចាស់សិទ្ធិលើការបញ្ចាំ និងអ្នកបង្កើតសិទ្ធិលើការបញ្ចាំ។

➢ ជូនដំណឹងទៅតតិយជន ដែលបានកំពុងកាន់កាប់ដោយកិច្ចសន្យា (ដែលអាចជាភតិសន្យា ឬសិទ្ធិជួលអចិន្ត្រៃយ៍ជាអាទិ៍)។

**ឧទាហរណ៍៖** កាលពីឆ្នាំ ២០១៩ លោក ក ជាភតិបតី បានធ្វើកិច្ចសន្យាជួលដី១កន្លែង ជាមួយលោក ខ ដែលជាភតិកៈ។ នៅឆ្នាំ ២០២០ លោក ក ដែលជាអ្នកបង្កើតសិទ្ធិលើការបញ្ចាំ បានធ្វើការដាក់បញ្ចាំដី១កន្លែងនោះ ទៅឲ្យលោក គ ដែលជាម្ចាស់សិទ្ធិលើការបញ្ចាំ ដោយលោក ក និង លោក គ បានព្រមព្រៀងថា ផ្ទេរការកាន់កាប់ដោយបញ្ជា លោក ក ជូនដំណឹងទៅ លោក ខ ថាដី១កន្លែងនោះត្រូវបានបញ្ចាំឲ្យលោក គ។ នេះ គឺជារូបភាពនៃការផ្ទេរការកាន់កាប់ដោយបញ្ជា។

❖ **ការប្តូរលក្ខណៈនៃការកាន់កាប់៖** មិនត្រូវបានគេយកមកប្រើប្រាស់ទេ ដោយយោងតាមមាត្រា ៨១៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។ វាជាយន្តការនៃការបញ្ចាំដោយមានការអនុញ្ញាតដោយម្ចាស់សិទ្ធិលើការបញ្ចាំ ដោយឲ្យអ្នកបង្កើតសិទ្ធិលើការបញ្ចាំរក្សាការកាន់កាប់ដដែល។ វានឹងក្លាយទៅជារូបភាពដែលមានលក្ខណៈជាហ៊ីប៉ូតែកវិញ[49]។

**ឧទាហរណ៍៖** លោក ក ជាអ្នកបង្កើតសិទ្ធិលើការបញ្ចាំ បានដាក់បញ្ចាំដី១កន្លែង ទៅឲ្យ លោក ខ ដែលជាម្ចាស់សិទ្ធិលើការបញ្ចាំ ដោយលោក ក និងលោក ខ បានព្រមព្រៀងគ្នាថា មានការផ្ទេរការកាន់កាប់ ប៉ុន្តែមិនអនុញ្ញាតឲ្យលោក ក នៅបន្តកាន់កាប់លើដី១កន្លែងជាដដែល។ នេះ គឺជារូបភាពនៃការប្តូរលក្ខណៈនៃការកាន់កាប់ ប៉ុន្តែករណីនេះ មិនត្រូវបានគេយកមកប្រើប្រាស់នោះទេ។

[48] មាត្រា ៥៩៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[49] មាត្រា ៨១៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

## ៣. ការមិនអនុញ្ញាតឲ្យបញ្ចាំផ្ដាច់

ច្បាប់ភូមិបាល ឆ្នាំ២០០១ បានហាមឃាត់ភាគីនៃកិច្ចសន្យាបញ្ចាំអចលនវត្ថុមិនអាចធ្វើការបញ្ចាំផ្ដាច់ជាដាច់ខាត។

ក្នុងករណីណាក៏ដោយ ម្ចាស់បំណុល មិនអាចក្លាយជាម្ចាស់កម្មសិទ្ធិករនៃទ្រព្យជាប់កិច្ចសន្យានោះបានឡើយ ហើយខសន្យាណាដែលផ្ទុយនឹងបទបញ្ញត្តិនេះត្រូវទុកជាមោឃៈ[50]។

ម្យ៉ាងវិញទៀត ចំពោះអ្នកដែលបានបង្កើតសិទ្ធិលើការបញ្ចាំមិនអាចព្រមព្រៀងឲ្យម្ចាស់សិទ្ធិលើការបញ្ចាំទទួលនូវសិទ្ធិជាកម្មសិទ្ធិលើការបញ្ចាំ ឬចាត់ចែងវត្ថុបញ្ចាំទៅតាមវិធីផ្សេងដែលច្បាប់បានកំណត់ដោយសកម្មភាពបង្កើតសិទ្ធិលើការបញ្ចាំ ឬដោយកិច្ចសន្យាដែលបានធ្វើមុនពេលកំណត់សងបានទេ។ មានន័យថាមិនអនុញ្ញាតឲ្យម្ចាស់សិទ្ធិលើការបញ្ចាំក្លាយជាកម្មសិទ្ធិករ ឬធ្វើការចាត់ចែងលើវត្ថុបញ្ចាំតាមរយៈការលក់ក្ដី ការដូរក្ដី ឬធ្វើប្រទានកម្មក្ដី ទោះបីជាអ្នកបានបង្កើតសិទ្ធិលើការបញ្ចាំបានព្រមព្រៀងនៅពេលបង្កើតកិច្ចសន្យាក៏ដោយនោះ។ ប៉ុន្តែផ្ទុយមកវិញ វានឹងមានអានុភាព កាលបើមានការអនុញ្ញាតពីច្បាប់[51]។

## ៤. ការកំណត់រយៈពេលនៃការបញ្ចាំ

នៅក្នុងក្រមរដ្ឋប្បវេណី ការបញ្ចាំអចលនវត្ថុមិនអនុញ្ញាតឲ្យគូភាគីព្រមព្រៀងគ្នាបង្កើតកិច្ចសន្យាបញ្ចាំអចលនវត្ថុមានរយៈពេលលើសពី ៥ (ប្រាំ) ឆ្នាំឡើងទៅបានទេ ប៉ុន្តែកិច្ចសន្យាបញ្ចាំនោះ អាចធ្វើបន្តទៀតបានទៅលើអចលនវត្ថុដដែលនោះ។

មាត្រា ៨៣៨ នៃក្រមរដ្ឋប្បវេណីបានកំណត់យ៉ាងច្បាស់ថា៖

១. អំឡុងពេលដែលមានអត្ថិភាពនៃសិទ្ធិលើការបញ្ចាំអចលវត្ថុមិនអាចលើសពី៥ (ប្រាំ)ឆ្នាំបានឡើយ។ ប្រសិនបើ បានបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុលើសពីអំឡុងពេលនេះ អំឡុងពេលត្រូវបន្ថយមកត្រឹម ៥ឆ្នាំ។

២. កិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុអាចធ្វើបន្តទៀតបាន។ ប៉ុន្តែ អំឡុងពេលនៃការបន្តនេះមិនអាចឲ្យលើសពី ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលបន្តបានឡើយ[52]។

## ៥. អានុភាពនៃសិទ្ធិលើកិច្ចសន្យាបញ្ចាំអចលនវត្ថុ

### ៥.១ ទំហំអានុភាពនៃសិទ្ធិលើការបញ្ចាំអចលនវត្ថុ

នៅពេលដែលមានការបញ្ចាំអចលនវត្ថុមួយ ត្រូវបានបង្កើតឡើងនៅលើដីមួយកន្លែងការបញ្ចាំនោះមានអានុភាពលើវត្ថុដែលភ្ជាប់នឹងដីនោះ រួមទាំងអាគារដែលមាននៅលើដីផងដែរ។ ទោះបីជាអាគារនោះ ត្រូវបានសង់នៅមុនពេល ឬក្រោយពេលដែលមានការបញ្ចាំក៏ដោយ ហើយដែលភាគីមិនអាចធ្វើការកំណត់នូវលក្ខខណ្ឌផ្សេងពីនេះ ក្នុងកិច្ចសន្យាបញ្ចាំបានឡើយ[53]។

ការកំណត់បែបនេះ ដោយហេតុថា យោងតាមមាត្រា ១២២ នៃក្រមនេះ បានចែងថា វត្ថុដែលនៅជាប់នឹងដី ឬវត្ថុដែលក្លាយជាភាគមួយនៃដី ជាពិសេស អាគារ ឬ សំណង់ដែលសាងសង់នៅលើដីហើយមិនអាច

[50] មាត្រា ២១០ នៃច្បាប់ភូមិបាល ឆ្នាំ ២០០១

[51] មាត្រា ៨២៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[52] កថាខណ្ឌទី១ មាត្រា ៨៣៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[53] មាត្រា ៨៤៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

ប្តូរកន្លែងបាន គឺជាសមាសភាគនៃដី។ ហេតុនេះហើយ ទើបនាំឲ្យសិទ្ធិលើការបញ្ចាំដែលមាននៅលើដីមួយកន្លែងនឹងមានអានុភាពទៅលើអ្វី ដែលជាសមាសភាគនៃដីនោះ។

សិទ្ធិនៃការបញ្ចាំនៅលើអចលនវត្ថុមួយកន្លែង មិនមានអានុភាពទៅលើផលដែលកើតចេញពីអចលនវត្ថុនោះទេ មិនថាជាផលស៊ីវិល ឬធម្មជាតិឡើយ។ ដោយសារតែ ការបញ្ចាំត្រូវបានបង្កើតជាថ្នូរទៅនឹងតម្លៃនៅលើអចលនវត្ថុមួយ ដើម្បីធានាកាតព្វកិច្ច ប៉ុន្តែអ្នកបង្កើតការបញ្ចាំនៅលើអចលនវត្ថុមួយ គឺនៅតែមានសិទ្ធិប្រើប្រាស់ និងអាស្រ័យផលលើអចលនវត្ថុនោះដដែល ដូចនេះ ផលជាកម្មសិទ្ធិរបស់អ្នកធានាដោយវត្ថុ។ មានន័យថាទោះបីជាដី ឬអាគារ ត្រូវបានបញ្ចាំទៅហើយក្តី ក៏ថ្លៃឈ្នួលដែលកើតចេញពីដី ឬអាគារនោះនៅតែជារបស់អ្នកធានាវត្ថុដដែល។ ប៉ុន្តែ ក្នុងករណីដែលអចលនវត្ថុដែលបានដាក់បញ្ចាំនោះត្រូវបានដាក់លក់ដោយការអនុវត្តការបញ្ចាំ អ្នកទិញនឹងធ្វើនូវលទ្ធកម្មសិទ្ធិពេញលេញ ហើយម្ចាស់វត្ថុ និងត្រូវបាត់បង់កម្មសិទ្ធិលើអចលនវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំនេះដែរ។ សិទ្ធិប្រើប្រាស់ និងអាស្រ័យផលលើអចលនវត្ថុរបស់ម្ចាស់វត្ថុក៏ត្រូវរលត់ដែរ។

អានុភាពនៃសិទ្ធិលើការបញ្ចាំអចលនវត្ថុ គឺម្ចាស់សិទ្ធិលើការបញ្ចាំមានសិទ្ធិទទួលបានការសង ដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងៗទៀត ប៉ុន្តែបានតែប្រាក់ដើម និងការប្រាក់ ២ (ពីរ) ឆ្នាំ ចុងក្រោយប៉ុណ្ណោះ ដែលជាទំហំនៃសិទ្ធិដែលត្រូវបានធានា[54]។

ម្ចាស់សិទ្ធិលើការបញ្ចាំ មានសិទ្ធិធ្វើការប្រើប្រាស់ និងអាស្រ័យផលលើអចលនវត្ថុបញ្ចាំ តាមវិធីប្រើប្រាស់នៃអចលនវត្ថុនោះ។ តែម្ចាស់សិទ្ធិលើការបញ្ចាំ មិនអាចធ្វើការទាមទារការប្រាក់លើសិទ្ធិលើបំណុលបានឡើយ (យោងតាម មាត្រា ៨៣៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧)។

ចំពោះបន្ទុកក្នុងការគ្រប់គ្រង និងបន្ទុកផ្សេងៗទៀតទាក់ទងនឹងអចលនវត្ថុ គឺម្ចាស់សិទ្ធិលើការបញ្ចាំជាអ្នកទទួលបន្ទុកចេញសោហ៊ុយនេះ (យោងតាមមាត្រា ៨៣៥ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧)។ ប៉ុន្តែ ក៏នៅមានករណីលើកលែងដែរ ពោលគឺ គូភាគីអាចធ្វើការព្រមព្រៀងគ្នាផ្ទុយនឹងបទបញ្ញត្តិខាងលើនេះបាន (យោងតាម មាត្រា ៨៣៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧)។

### ៥.២ សិទ្ធិទាមទារសំណងរបស់អ្នកធានាដោយវត្ថុ

ប្រសិនបើបុគ្គលដែលបានបង្កើតការបញ្ចាំអចលនវត្ថុ ដើម្បីធានាកាតព្វកិច្ចរបស់អ្នកដទៃបានសងចំពោះកាតព្វកិច្ចនោះ ឬបាត់បង់នូវកម្មសិទ្ធិលើអចលនវត្ថុដោយសារ ការអនុវត្តការបញ្ចាំនោះ អ្នកនោះត្រូវមានសិទ្ធិទាមទារសំណងពីកូនបំណុលដោយយោងទៅតាមបទបញ្ញត្តិស្តីពី ការធានា នៅក្នុងមាត្រា ៨៥០ នៃក្រមរដ្ឋប្បវេណី។ បទបញ្ញត្តិនេះបានចែង និងបានកំណត់ដោយធ្វើការឆ្លើយតបទៅនឹងមាត្រា ៩១១ និង បទបញ្ញត្តិនៃមាត្រាដែលទាក់ទងមួយចំនួនផ្សេងទៀតនៃក្រមនេះ។

### ៥.៣ លំដាប់នៃការបញ្ចាំអចលនវត្ថុ

ក្នុងករណីដែលបានបង្កើតហ៊ីប៉ូតែកទៅលើអចលនវត្ថុ ដើម្បីធានាសិទ្ធិលើបំណុលច្រើន លំដាប់នៃហ៊ីប៉ូតែកនោះ ត្រូវអនុលោមតាមពេលវេលាដែលបានចុះបញ្ជី[55]។ ចំណុចនេះផងដែរ កូនបំណុលអាចបង្កើតសិទ្ធិហ៊ីប៉ូ

[54] មាត្រា ៨៣៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[55] មាត្រា ៨៥១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

តែកលើទ្រព្យតែមួយទៅឲ្យម្ចាស់បំណុលច្រើនគ្នា ដែលនេះជាចំណុចដែលមានប្រយោជន៍បំផុត ក្នុងចំណោមចំណុចជាច្រើនបើប្រៀបធៀបទៅនឹងការធានា។

នៅក្នុងការអនុវត្តហ៊ីប៉ូតែកចំពោះអចលនវត្ថុនេះដែរ មានបទបញ្ញត្តិមួយចំនួនដែលមានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ដែលមានការពាក់ព័ន្ធយ៉ាងជិតស្និទ្ធទៅនឹងប្រធានបទនេះដែលនឹងត្រូវលើកយកមកអធិប្បាយនៅពេលនេះ ទោះបីជាយើងកំពុងសិក្សាពីច្បាប់សារធាតុក្តី។ នីតិវិធីនៃការអនុវត្តនេះ ដើម្បីដោះស្រាយវិវាទនៃហ៊ីប៉ូតែកច្រើន ឬវិវាទនានារវាងហ៊ីប៉ូតែកជាមួយនឹងម្ចាស់សិទ្ធិប្រត្យក្ស ឬសិទ្ធិប្រាតិភោគប្រត្យក្សផ្សេងទៀតនៅលើអចលនវត្ថុតែមួយដែលជាកម្មវត្ថុនៃការអនុវត្តហ៊ីប៉ូតែកនោះ។ ចំណុចទាំងនេះនឹងត្រូវបានធ្វើការបកស្រាយបង្ហាញដូចខាងក្រោមនេះ៖

ជាគោលការណ៍ ការអនុវត្តសិទ្ធិប្រាតិភោគប្រត្យក្ស គឺធ្វើឡើងតាមវិធីលក់ដោយបង្ខំ ដើម្បីទទួលសំណងជាអាទិភាពពីប្រាក់ដែលបានមកពីការលក់នោះ។ **តើសិទ្ធិប្រាតិភោគប្រត្យក្សផ្សេងដទៃទៀតក្រៅពីសិទ្ធិប្រាតិភោគប្រត្យក្សដែលត្រូវបានអនុវត្តលើអចលនវត្ថុនោះ ដូចជាហ៊ីប៉ូតែក នឹងត្រូវបានរលត់ក្រោយការលក់ឬយ៉ាងណា?** យោងតាម មាត្រា ៥១០ កថាខណ្ឌទី១ និង ទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៖ *សិទ្ធិប្រាតិភោគប្រត្យក្សលើអចលនវត្ថុ សិទ្ធិប្រត្យក្សប្រើប្រាស់ និង អាស្រ័យផលលើអចលនវត្ថុ និង សិទ្ធិជួលអចលនវត្ថុដែលអាចតតាំងនឹងសិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលនៃការអនុវត្ត ត្រូវបន្តអត្ថិភាពក្រោយការលក់ដោយបង្ខំដែលជាការអនុវត្តសិទ្ធិប្រាតិភោគ។ ក្រៅពីសិទ្ធិដែលបានកំណត់ខាងលើនេះ សិទ្ធិលើអចនវត្ថុត្រូវបានរលត់ដោយការលក់។*

តាមរយៈមាត្រានេះ យើងឃើញថា បើពាក្យសុំឲ្យចាប់ផ្តើមនីតិវិធីអនុវត្តសិទ្ធិប្រាតិភោគ ត្រូវធ្វើឡើងដោយម្ចាស់បំណុល ដែលមានសិទ្ធិប្រាតិភោគប្រត្យក្សណាមួយមុននោះ សិទ្ធិប្រត្យក្សផ្សេងទៀតរួមទាំង សិទ្ធិប្រាតិភោគប្រត្យក្សផងដែរ ដែលឋិតនៅក្នុងអាទិភាពខ្ពស់ជាងម្ចាស់សិទ្ធិប្រាតិភោគប្រត្យក្សដែលបានដាក់ពាក្យសុំអនុវត្តមុននោះ មិនរលត់ដោយនីតិវិធីដែលបានដាក់ពាក្យអនុវត្តមុនទេ (មាត្រា ៥១០ កថាខណ្ឌទី១)ផ្ទុយទៅវិញបើសិទ្ធិប្រត្យក្ស ឬ សិទ្ធិប្រាតិភោគប្រត្យក្សនោះមានលំដាប់អាទិភាពទាបជាងពាក្យសុំអនុវត្តមុននោះពេលនោះសិទ្ធិប្រត្យក្ស ឬសិទ្ធិប្រាតិភោគប្រត្យក្សលើអចលនវត្ថុនោះ ត្រូវរលត់ដោយការអនុវត្ត (មាត្រា ៥១០ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)។

ដូច្នេះ នៅក្នុងក្រមរដ្ឋប្បវេណីកម្ពុជាបានអនុម័តយកគោលការណ៍ទទួលបន្តចំពោះសិទ្ធិប្រាតិភោគប្រត្យក្ស មានន័យថាកំណត់ឲ្យអ្នកទិញនូវអចលនវត្ថុនៃការអនុវត្តទទួលបន្តនូវបន្ទុកទាំងឡាយដែលមានលើអចលនវត្ថុនោះ ក្រោយពេលអនុវត្តដោយបង្ខំ។ គោលការណ៍នេះ យកចិត្តទុកដាក់ លើការការពារអ្នកដែលមានសិទ្ធិប្រាតិភោគលើអចលនវត្ថុ។ គោលការណ៍ទទួលបន្តចំពោះសិទ្ធិប្រាតិភោគប្រត្យក្សនេះដែរ អ្នកទិញអាចអចលនវត្ថុមួយក្នុងតម្លៃមួយថោកជាងតម្លៃពិតប្រាកដនៃអចលនវត្ថុនោះដោយគ្មានជាប់បន្ទុកសិទ្ធិប្រត្យក្ស ឬសិទ្ធិប្រាតិភោគប្រត្យក្សផ្សេងទៀតនោះទេ ដោយសារខ្លួនត្រូវទទួលបន្តនូវបន្ទុកនៃកាតព្វកិច្ចដែលត្រូវធានាដោយសិទ្ធិប្រាតិភោគប្រត្យក្សជាលក្ខខណ្ឌមូលដ្ឋាន។

ព្រមជាមួយគ្នានេះដែរ មាត្រា ៤៩៩ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី បានចែងថា អ្នកទិញត្រូវទទួលខុសត្រូវ សងនូវសិទ្ធិលើបំណុលដែលត្រូវបានធានាដោយសិទ្ធិប្រាតិភោគ ដែលអ្នកទិញបានទទួលបន្ត។

ហើយអ្វីដែលគួរឲ្យកត់សម្គាល់នោះ គឺថាម្ចាស់សិទ្ធិហ៊ីប៉ូតែកដែលបិតនៅក្នុងលំដាប់ទី១ អាចទទួលបានការសងដោយមានអាទិភាពជាងម្ចាស់បំណុលហ៊ីប៉ូតែកដែលបិតក្នុងលំដាប់បន្ទាប់។

### ៥.៤ ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា

ក្នុងករណីដែលម្ចាស់បំណុលហ៊ីប៉ូតែកមានសិទ្ធិទាមទារការប្រាក់ ឬប្រាក់ធនលាភផ្សេងទៀត ម្ចាស់បំណុលហ៊ីប៉ូតែក អាចអនុវត្តហ៊ីប៉ូតែកនោះបានតែចំពោះចំនួននៃការសងដែលបានកំណត់ពេលសម្រាប់អំឡុងពេល ២ (ពីរ) ឆ្នាំចុងក្រោយតែប៉ុណ្ណោះ។ ប៉ុន្តែចំពោះធនលាភដែលបានមកពីមុនមក ប្រសិនបើបានចុះបញ្ជីពិសេស ក្រោយពីបានដល់ពេលកំណត់ត្រូវសងហ៊ីប៉ូតែកនេះអាចអនុវត្តចាប់ពីពេលដែលបានចុះបញ្ជីនោះ[56]។ ចំពោះប្រាក់ដែលត្រូវបានបង់ក្នុងអំឡុងពេល ២ (ពីរ ) ឆ្នាំ ចុងក្រោយ ក្នុងករណីដែលម្ចាស់បំណុលហ៊ីប៉ូតែកមានសិទ្ធិទាមទារឲ្យសងសំណងនៃការខូចខាតព្រមទាំងការប្រាក់ និងធនលាភផ្សេងទៀត មិនអាចលើសចំនួនសរុបសម្រាប់អំឡុងពេល ២ (ពីរ)ឆ្នាំបានឡើយ។ បានជាច្បាប់កំណត់ដូច្នេះ ពីព្រោះថាវាមានភាពចាំបាច់សម្រាប់ការពារម្ចាស់បំណុលហ៊ីប៉ូតែកដទៃផ្សេងទៀត ដែលស្ថិតនៅលំដាប់ទាបជាង ដើម្បីឲ្យដឹងថា តើតម្លៃនៃអចលនវត្ថុ ដែលត្រូវបានយកមកដាក់ជាប្រាតិភោគនោះចំនួនប៉ុន្មាន[57]ជាដើម។

## ៦. ការអនុវត្តកិច្ចសន្យាបញ្ចាំអចលនវត្ថុ

### ៦.១ សិទ្ធិ និងភាតព្វកិច្ចរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ

#### ៦.១.១ សិទ្ធិនៃម្ចាស់សិទ្ធិលើការបញ្ចាំ

##### ៦.១.១.១ សិទ្ធិប្រើប្រាស់ និងអាស្រ័យផល

ច្បាប់ភូមិបាលឆ្នាំ ២០០១ បានធ្វើការកម្រិតនូវសិទ្ធិប្រើប្រាស់ និងអាស្រ័យផលរបស់ម្ចាស់បំណុលលើអចលនវត្ថុដែលបានដាក់បញ្ចាំ ពោលគឺ ម្ចាស់បំណុលដែលបានកាន់កាប់ទ្រព្យដាក់បញ្ចាំ មានសិទ្ធិអាស្រ័យផលពីពីទ្រព្យនោះ ដូចជា ផលុបភោគដែរ តែលុះត្រាតែមានចែងក្នុងកិច្ចសន្យាដាក់បញ្ចាំ[58]។

ចំពោះក្រមរដ្ឋប្បវេណីវិញ បានអនុញ្ញាតឲ្យម្ចាស់សិទ្ធិលើការបញ្ចាំប្រើប្រាស់ និងអាស្រ័យផលពីអចលវត្ថុដាក់បញ្ចាំ ដោយពុំចាំបាច់មានការយល់ព្រមពីអ្នកបង្កើតសិទ្ធិលើការបញ្ចាំទេ ព្រោះក្រមនេះបានប្រើពាក្យ *អាចប្រើប្រាស់ និងអាស្រ័យផល* ហើយឲ្យតែយកទៅប្រើប្រាស់តាមវិធីនៃអចលនវត្ថុនោះ គឺប្រើទៅតាមលក្ខណៈដើមវត្ថុ។

**ឧទាហរណ៍៖** បើអចលនវត្ថុបញ្ចាំជា ដីសម្រាប់ធ្វើកសិកម្ម ម្ចាស់សិទ្ធិលើការបញ្ចាំមិនអាច យកដីនោះមកសង់ជាផ្ទះល្វែងសម្រាប់ជួលបានទេ ពោលគឺ ត្រូវប្រើប្រាស់ដីនោះសម្រាប់ធ្វើជាដីកសិកម្មដូចទៅនឹងលក្ខណៈដើមរបស់ដី ដែលជាកម្មវត្ថុនៃការដាក់បញ្ចាំនោះ។

មាត្រា ៨៣៤ ត្រង់កថាខណ្ឌទី១ នៃក្រមនេះ បានចែង និងកំណត់ថា ម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុអាចប្រើប្រាស់ និងអាស្រ័យផល ពីអចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ តាមវិធីប្រើប្រាស់នៃអចលនវត្ថុនោះ។

[56] មាត្រា ៨៥១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[57] មាត្រា ៨៥២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[58] កថាខណ្ឌទី១ មាត្រា ២១២ នៃច្បាប់ភូមិបាល ឆ្នាំ២០០១

### ៦.១.១.២ ការសន្យាពិសេសនៅក្នុងកិច្ចសន្យាបញ្ចាំអចលនវត្ថុ

ដូចដែលបានលើកឡើងហើយថា ម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុអាចប្រើប្រាស់ និងអាស្រ័យផលពីអចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ និងត្រូវចេញសោហ៊ុយគ្រប់គ្រង និងទទួលបន្ទុកផ្សេងៗ ចំពោះអចលនវត្ថុនោះ ហើយមិនអាចទាមទារការប្រាក់នៃសិទ្ធិលើបំណុលរបស់ខ្លួនបានទេ ទោះបីជាយ៉ាងណាក៏ដោយភាគីនៃកិច្ចសន្យាបញ្ចាំ អាចធ្វើការព្រមព្រៀងទាក់ទងនឹងលក្ខខណ្ឌដែលផ្ទុយពីនេះនៅក្នុងកិច្ចសន្យារបស់ខ្លួនបានផ្អែកលើ ការសន្យាពិសេសនៅក្នុងសកម្មភាពបង្កើតសិទ្ធិលើការបញ្ចាំ[59]។

**ឧទាហរណ៍៖** បើសិនជាកិច្ចព្រមព្រៀងមួយ ម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុអាចរួចផុតពីការចេញសោហ៊ុយគ្រប់គ្រង ឬបន្ទុកផ្សេងទៀតដែលទាក់ទងនឹងអចលនវត្ថុ បើទោះបីជា ម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុមានសិទ្ធិប្រើប្រាស់ និងអាស្រ័យផលក្តី ដូចគ្នាផងដែរ បើសិនជាមានកិច្ចព្រមព្រៀងមួយ ដែលអនុញ្ញាតឲ្យម្ចាស់បំណុលទាមទារការប្រាក់នៃសិទ្ធិលើបំណុល ទោះបីជា ម្ចាស់បំណុលមានសិទ្ធិប្រើប្រាស់ និងអាស្រ័យផលលើអចលនវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំក៏ដោយ កិច្ចព្រមព្រៀងនោះនឹងត្រូវទទួលស្គាល់អានុភាពហើយម្ចាស់បំណុលអាចទាមទារការប្រាក់នៃសិទ្ធិលើបំណុលនោះបាន។

### ៦.១.១.៣ បទបញ្ញត្តិពិសេស ស្តីពីដីសម្រាប់ធ្វើកសិកម្ម

#### ៦.១.១.៣.១ សិទ្ធិលើបំណុលដែលគ្មានកំណត់ពេល

បើសិទ្ធិលើបំណុលដែលមានកំណត់ពេលច្បាស់លាស់ ម្ចាស់បំណុលនឹងធ្វើការត្រៀមខ្លួនរួចជាស្រេចក្នុងការប្រគល់ដីសម្រាប់ធ្វើកសិកម្មនោះទៅឲ្យកូនបំណុលវិញនៅពេលដល់កំណត់នៃកិច្ចសន្យា ដែលវាមិនអាចធ្វើឲ្យមានផលប៉ះពាល់ដល់ប្រយោជន៍ម្ចាស់បំណុលទេ។ ផ្ទុយមកវិញ ម្ចាស់សិទ្ធិលើបំណុលដែលគ្មានកំណត់ពេល អាចធានាដោយវត្ថុ អាចធ្វើការរំលត់ហ៊ីប៉ូតែកនៅពេលណាក៏បាន ដោយអនុវត្តកាតព្វកិច្ចដែលត្រូវបានធានាហ៊ីប៉ូតែក។ ដូច្នេះ បើកូនបំណុលរំលត់ហ៊ីប៉ូតែកក្នុងពេលដែលម្ចាស់បំណុល បានដាំដំណាំនៅលើដីដែលសម្រាប់ធ្វើកសិកម្ម ហើយច្បាប់បានតម្រូវឲ្យម្ចាស់បំណុលប្រគល់ដីនោះឲ្យកូនបំណុល វានឹងធ្វើឲ្យប៉ះពាល់ប្រយោជន៍យ៉ាងធ្ងន់ធ្ងរដល់ម្ចាស់បំណុល។ កត្តានេះហើយ ទើបច្បាប់ផ្តល់សិទ្ធិដល់ម្ចាស់សិទ្ធិលើការបញ្ចាំអាចប្រើប្រាស់ដីសម្រាប់កសិកម្មនេះ ទោះបីជាបំណុលនោះបានរលត់ដោយការសងក៏ដោយ បើរដូវប្រមូលកសិផលដែលម្ចាស់សិទ្ធិលើការបញ្ចាំ(ម្ចាស់បំណុល) បានដាំ ឬសាបពីមុនមក នឹងមកដល់ក្នុងអំឡុងពេល ១(មួយ) ឆ្នាំក្រោយការសងបំណុលក៏ដោយ ក៏ម្ចាស់សិទ្ធិលើការបញ្ចាំ មានសិទ្ធិប្រើប្រាស់ដីនោះរហូតដល់រដូវប្រមូលកសិផលនោះ[60]។

#### ៦.១.១.៣.២ សិទ្ធិលើបំណុលដែលមានកំណត់ពេល

ចំពោះសិទ្ធិលើបំណុលដែលមានកំណត់ពេលច្បាស់លាស់វិញ ទោះបីជាម្ចាស់បំណុលបានសាប ឬដាំដំណាំនៅលើដីសម្រាប់ធ្វើកសិកម្ម បើពេលកំណត់បានមកដល់ ហើយកូនបំណុលបានសងធ្វើឲ្យសិទ្ធិលើបំណុលបានរលត់ម្ចាស់បំណុលត្រូវប្រគល់ដីនោះមកឲ្យកូនបំណុលវិញ ម្ចាស់បំណុលមិនអាចអះអាងមិន

[59] មាត្រា ៨៣៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[60] កថាខណ្ឌទី២ មាត្រា ៨៣៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

ប្រគល់ដីដោយមូលហេតុដូរប្រមូលផលនឹងមកដល់ក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ដូចសិទ្ធិលើបំណុលដែលគ្មានកំណត់ពេលទេ។ ប៉ុន្តែ បើសិនជាសិទ្ធិលើបំណុលបានរលត់មុនពេលកំណត់ដោយការសង នោះម្ចាស់សិទ្ធិលើការបញ្ចាំ អាចប្រើដីនោះសម្រាប់ធ្វើកសិកម្ម បើរដូវប្រមូលផលពីដំណាំដែលខ្លួនបានសាប ឬដាំពីមុនមកនឹងដល់ក្នុងអំឡុងពេល ១(មួយ) ឆ្នាំ រហូតរដូវប្រមូលផល ព្រោះសិទ្ធិលើបំណុលបានរលត់មុនពេលកំណត់ និងមិនមែនជាកំហុសរបស់ម្ចាស់បំណុល។ ប៉ុន្តែទោះបីជានៅក្នុងករណីនេះក៏ដោយ ប្រសិនបើកាលបរិច្ឆេទនៃការកំណត់សងនឹងដល់មុនពេលប្រមូលផល បញ្ញត្តិនេះមិនត្រូវបានគេយកមកអនុវត្តបានឡើយ ពីព្រោះការបាត់បង់នូវការប្រមូលផល គឺអាចរំពឹងបានចាប់តាំងពីពេលចាប់ផ្តើម[61]។

### ៦.១.១.៤ សិទ្ធិបញ្ចាំបន្ត

ជាគោលការណ៍ច្បាប់ម្ចាស់សិទ្ធិលើការបញ្ចាំ មិនអាចយកវត្ថុបញ្ចាំទៅដាក់បញ្ចាំបន្តបានទេ បើគ្មានការយល់ព្រមពីអ្នកបង្កើតសិទ្ធិលើការបញ្ចាំ។ ប៉ុន្តែ មានអញ្ញត្រកម្មមួយដែលអនុញ្ញាតឲ្យម្ចាស់សិទ្ធិលើការបញ្ចាំអាចយកវត្ថុបញ្ចាំនោះទៅដាក់បញ្ចាំបន្តទៀតបាន ដោយពុំចាំបាច់មានការយល់ព្រមពីអ្នកបង្កើតសិទ្ធិលើការបញ្ចាំនោះទេ ក្រោមការទទួលខុសត្រូវទាំងស្រុងរបស់ខ្លួន រួមទាំងការខូចខាតដែលកើតពីប្រធានសក្តិផងដែរ[62]។

ម៉្យាងទៀតច្បាប់បានអនុញ្ញាតឲ្យម្ចាស់សិទ្ធិលើការបញ្ចាំ អាចយកវត្ថុបញ្ចាំទៅដាក់បញ្ចាំបន្តទៀតបានដើម្បីធានាកាតព្វកិច្ចរបស់ខ្លួន និងតតិយជន។ ហើយម្ចាស់សិទ្ធិលើការបញ្ចាំបន្ត មានសិទ្ធិទទួលបានជាមុននូវប្រាក់ ដែលបានមកពីការលក់ដោយបង្ខំនូវអចលនវត្ថុ ដោយមិនលើសពីទំហំនៃសិទ្ធិលើបំណុលដែលបានធានាដោយសិទ្ធិលើការបញ្ចាំដើមបានឡើយ (យោងតាម មាត្រា ៨៥៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧)។

**ឧទាហរណ៍៖** លោក ក បានទទួលបញ្ចាំដីមួយកន្លែង ដើម្បីធានាបំណុល១០០០$ ពីលោក ខ។

លោក ក បានជំពាក់ លោក គ ចំនួន ១៥០០$ ហើយ លោក ក បានយកដីនោះទៅបញ្ចាំឲ្យលោក គ ដើម្បីធានាបំណុល។ នៅពេលលក់ដីនោះ លោក គ អាចទទួលបានតែ ១០០០$ ប៉ុណ្ណោះ ដោយមានអាទិភាពជាង លោក ក។

### ៦.១.១.៥ សិទ្ធិឃាត់ទុកអចលនវត្ថុបញ្ចាំ

ម្ចាស់បំណុល ដែលជាម្ចាស់សិទ្ធិលើការបញ្ចាំ អាចធ្វើការឃាត់ទុកវត្ថុបញ្ចាំបាន រហូតដល់ពេលដែលទទួលបានការសងចំពោះសិទ្ធិលើបំណុលដែលបានកំណត់នៅក្នុងមាត្រា ៨២០ នៃក្រមរដ្ឋប្បវេណី (ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា)។ ប៉ុន្តែ សិទ្ធិនេះមិនអាចតតាំង ចំពោះម្ចាស់បំណុលដែលមានអាទិភាពជាងខ្លួនបានឡើយ[63]។

### ៦.១.១.៦ សិទ្ធិប្តឹងឲ្យលក់ដោយបង្ខំ

បើសិនជាកូនបំណុលមិនអាចអនុវត្តកាតព្វកិច្ច នៅពេលដែលត្រូវកំណត់សងនោះទេ ម្ចាស់បំណុលមានសិទ្ធិប្តឹងទៅតុលាការឲ្យដាក់លក់អចលនវត្ថុនោះដោយបង្ខំ ដើម្បីសងខ្លួនជាអាទិភាពដោយសិទ្ធិបុរិមា និងបុព្វសិទ្ធិមុនម្ចាស់បំណុលផ្សេងទៀត (យោងតាម កថាខណ្ឌទី១ មាត្រា ២១១ នៃច្បាប់ភូមិបាល ឆ្នាំ ២០០១)។

[61] វាក្យខណ្ឌទី២ កថាខណ្ឌទី៣ មាត្រា ៨៣៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[62] កថាខណ្ឌទី១ និងទី២ មាត្រា ៨២៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[63] មាត្រា ៨២១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

ក្នុងករណីដែលអ្នកបង្កើតសិទ្ធិលើការបញ្ចាំពុំបានអនុវត្តកាតព្វកិច្ចទេ ម្ចាស់សិទ្ធិលើការបញ្ចាំអាចស្នើសុំទៅតុលាការឲ្យដាក់លក់នូវអចលនវត្ថុនោះបាន[64]។ ទន្ទឹមនឹងនេះផងដែរ បើនៅក្រោយពេលបង្កើតសិទ្ធិលើការបញ្ចាំ អ្នកបង្កើតសិទ្ធិលើការបញ្ចាំបានសាងសង់ និងមានកម្មសិទ្ធិលើអាគារដែរនោះ លើដីដាក់បញ្ចាំនោះ ម្ចាស់សិទ្ធិលើការបញ្ចាំអាចលក់ដោយបង្ខំនូវដី និងអាគារនោះបាន។ ប៉ុន្តែបើថ្លៃលក់ដីគ្មានអាគារមានតម្លៃខ្ពស់ជាងដីដែលមានអាគារពីលើ នោះម្ចាស់សិទ្ធិលើការបញ្ចាំអាចរុះរើ ឬទាមទារឲ្យរុះរើអាគារនោះមុនពេលលក់បាន។

ម្យ៉ាងវិញទៀត បើអាគារនៅលើដីដែលបានដាក់បញ្ចាំជាកម្មសិទ្ធិរបស់តតិយជន ដោយផ្អែកលើសិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ ឬ សិទ្ធិជួល ប្រសិនបើតតិយជននោះមិនអាចយកសិទ្ធិទាំងនោះរបស់ខ្លួនមកតតាំងជាមួយម្ចាស់សិទ្ធិលើការបញ្ចាំបានទេ ម្ចាស់សិទ្ធិលើការបញ្ចាំក៏អាចលក់ដោយបង្ខំនូវអាគារនោះ និងដីបញ្ចាំបានដែរ[65]។

### ៦.១.២. ភាតព្វកិច្ច

#### ៦.១.២.១ ប្រគល់វត្ថុបញ្ចាំ

អចលនវត្ថុ ដែលជាប់កិច្ចសន្យាបញ្ចាំនឹងត្រូវសងជាចាំបាច់មកកូនបំណុលវិញចាប់ពីពេលដែលកូនបំណុលបានសងបំណុលទាំងស្រុងរួចហើយ។ មានន័យថា បើដល់ពេលត្រូវកំណត់សង ហើយកូនបំណុលបានសងបំណុលនោះរួចរាល់ នោះម្ចាស់បំណុលត្រូវប្រគល់ទាំងវត្ថុ និងប័ណ្ណកម្មសិទ្ធិទៅឲ្យកូនបំណុលវិញ។

ម៉្យាងទៀតនៅពេលផុតរយៈនៃការបញ្ចាំ ដោយកូនបំណុលបានសងប្រាក់អស់វិញក្តី ឬ ដោយផុតរយៈពេលប្តឹងក្តីក៏ម្ចាស់បំណុលត្រូវសងមកកូនបំណុលវិញនូវទ្រព្យ ឬតម្លៃនៃទ្រព្យ ក្នុងករណីបើសិនជាទ្រព្យនោះត្រូវបានវិនាសដោយកំហុសរបស់ខ្លួន[66]។

#### ៦.១.២.២ ថែរក្សា ឬចេញសោហ៊ុយ

ម្ចាស់បំណុលមានកាតព្វកិច្ចថែរក្សាទុកទ្រព្យនោះដោយមានការប្រុងប្រយ័ត្នជានិច្ច ប្រៀបដូចជាការមើលថែទ្រព្យសម្បត្តិរបស់ខ្លួនយ៉ាងនោះដែរ ពោលគឺកាន់កាប់ថែទាំក្នុងនាមជាអ្នកកាន់កាប់ដោយស្មោះត្រង់ និងសុច្ចរិត។ បើសិនជាទ្រព្យនោះ បានខូចខាតដោយអំពើ ឬកំហុសណាមួយរបស់ខ្លួន នោះត្រូវសងតម្លៃខូចខាតនោះដោយកាត់ប្រាក់ក្នុងបំណុល ពោលគឺត្រូវប្រើប្រាស់ និងធ្វើការថែរក្សាឲ្យបានល្អ ដើម្បីជៀសវាងការវិនាសខូចខាតដោយប្រការណាមួយ[67]។ ទន្ទឹមនឹងនេះដែរ ម្ចាស់សិទ្ធិលើបំណុលត្រូវទទួលបន្ទុកនូវសោហ៊ុយគ្រប់គ្រង និងបន្ទុកផ្សេងៗទៀតចំពោះ អចលនវត្ថុបញ្ចាំ ដោយហេតុខ្លួនមានសិទ្ធិប្រើប្រាស់ និងអាស្រ័យផលលើអចលនវត្ថុនោះ[68]។

ម្ចាស់សិទ្ធិលើការបញ្ចាំ ពុំអាចទាមទារការប្រាក់នៃសិទ្ធិលើបំណុលរបស់ខ្លួនពីអ្នកបង្កើតសិទ្ធិលើការបញ្ចាំបានទេ ដោយសារតែខ្លួនអាចប្រើប្រាស់ និងអាស្រ័យផលលើអចលនវត្ថុនោះបាន។ ហេតុដូចនេះ ត្រូវចាត់

[64] មាត្រា ៨៥៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[65] មាត្រា ៨៥៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[66] កថាខណ្ឌទី១ មាត្រា ២០៩ និង មាត្រា ២១៣ នៃច្បាប់ភូមិបាល ឆ្នាំ ២០០១

[67] វាក្យខណ្ឌទី២ និងទី៣ នៃមាត្រា ២១២ នៃច្បាប់ភូមិបាល ឆ្នាំ ២០០១

[68] មាត្រា ៨៣៥ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

ទុកថាថ្នូរនឹងការប្រាក់ដែលខ្លួនត្រូវទទួលពីកូនបំណុល (នេះបើយោងតាមមាត្រា ៨៣៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧)។

### ៦.២ សិទ្ធិ និងភារកិច្ចនៃអ្នកបង្កើតសិទ្ធិលើការបញ្ចាំ

#### ៦.២.១ សិទ្ធិទាមទារវត្ថុបញ្ចាំ និងសំណងខូចខាត

ម្ចាស់បំណុលត្រូវទទួលខុសត្រូវចំពោះការវិនាសបាត់បង់ទ្រព្យបញ្ចាំ ពោលគឺ ត្រូវសងតម្លៃខូចខាតនៃការបញ្ចាំដោយកាត់ប្រាក់ក្នុងបំណុលរបស់ខ្លួនបាន ប្រសិនបើទ្រព្យនោះត្រូវបានខូចខាតដោយអំពើ ឬកំហុសណាមួយរបស់ខ្លួន[69]។ ម៉្យាងទៀតកូនបំណុល មានសិទ្ធិទទួលប្រាក់បញ្ចាំមកវិញ បើខ្លួនបានសងបំណុលគ្រប់ចំនួនហើយ។ ម្ចាស់បំណុលមិនអាចបដិសេធដោយយកលេសថា កូនបំណុលនៅជំពាក់មួយផ្សេងទៀតបានទេ ទោះបីជាបំណុលនោះដល់ពេលកំណត់ត្រូវទារក៏ដោយ។ ប៉ុន្តែម្ចាស់បំណុលអាចបដិសេធមិនប្រគល់បាន បើមានកិច្ចសន្យាបញ្ចាំថ្មីមួយទៀតលើទ្រព្យដដែល ហើយបានរៀបចំឡើងតាមទម្រង់នៃច្បាប់[70]។

#### ៦.២.២ ភារកិច្ចសងសំណង

បើម្ចាស់សិទ្ធិលើការបញ្ចាំបានចេញចំណាយជាចាំបាច់ ដើម្បីគ្រប់គង និងថែរក្សាវត្ថុបញ្ចាំ អ្នកបង្កើតសិទ្ធិលើការបញ្ចាំមានករណីយកិច្ចសងនូវចំណាយនោះវិញ តាមការទាមទាររបស់ម្ចាស់សិទ្ធិលើការបញ្ចាំ។ ទន្ទឹមនឹងនេះ អ្នកបង្កើតសិទ្ធិលើការបញ្ចាំទទួលបន្ទុកសងនូវចំណាយទាំងអស់ ឬសងនូវតម្លៃប្រាក់ដែលកើនទៅម្ចាស់សិទ្ធិលើការបញ្ចាំ បើអ្នកនោះបានចេញចំណាយធ្វើឲ្យកើនថ្លៃវត្ថុបញ្ចាំនោះ[71]។

## ៧. ការរលត់សិទ្ធិនៃការបញ្ចាំអចលនវត្ថុ

យោងតាមមាត្រា ៧៦៩ កថាខណ្ឌទី៤ នៃក្រមនេះ ក្នុងករណីដែលសិទ្ធិលើបំណុលដែលត្រូវបានធានាបានរលត់ដោយការសង ឬអាជ្ញាយុកាលនៃការរលត់សិទ្ធិ ឬហេតុផ្សេងទៀត នោះសិទ្ធិប្រាតិភោគប្រត្យក្សក៏ត្រូវបានរលត់ដែរ។ ករណីនេះ ហៅថា ភាពបន្ទាប់បន្សំនៃសិទ្ធិប្រាតិភោគប្រត្យក្ស[72]។

### ៧.១ ការរលត់ដោយការទាមទារ

ត្រង់ផ្នែកនេះ យើងនឹងលើកយកនូវបទបញ្ញត្តិស្ដីពី ហ៊ីប៉ូតែកមកធ្វើការបកស្រាយ ពីព្រោះថា បទបញ្ញត្តិនេះគឺ អាចយកមកប្រតិបត្តិបានដូចទៅនឹងការបញ្ចាំអចលនវត្ថុដែរ។

ក្នុងករណីដែលតតិយជនដែលបានទិញនូវកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬផលុបភោគចំពោះអចលនវត្ថុបានសងថ្លៃលក់នោះទៅម្ចាស់បំណុល តាមការទាមទាររបស់ម្ចាស់បំណុលអចលនវត្ថុ ហើយការអចលនវត្ថុត្រូវរលត់សម្រាប់តតិយជននោះ។

ការបញ្ចាំអចលនវត្ថុនឹងត្រូវរលត់ ប្រសិនបើតតិយជន ដែលបានធ្វើលទ្ធកម្មនៃអចលនវត្ថុបញ្ចាំ សងថ្លៃលក់អចលនវត្ថុដែលខ្លួនត្រូវបង់ដើម្បីធ្វើលទ្ធកម្មអចលនវត្ថុនោះ តាមការទាមទាររបស់ម្ចាស់បំណុលនៃការបញ្ចាំអចលនវត្ថុ។ មានន័យថា ការបញ្ចាំអចលនវត្ថុនឹងត្រូវរលត់ ប្រសិនបើម្ចាស់បំណុលនៃការបញ្ចាំនោះទាមទារឲ្យ

---

[69] វាក្យខណ្ឌទី៣ មាត្រា ២១២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[70] កថាខណ្ឌទី១ មាត្រា ២១៨ នៃច្បាប់ភូមិបាល ឆ្នាំ ២០០១

[71] មាត្រា ៨២៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[72] មាត្រា ៧៧១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

តតិយជនដែលបានធ្វើលទ្ធកម្មសងថ្លៃលក់អចលនវត្ថុ ហើយតតិយជនដែលបានធ្វើលទ្ធកម្មនោះបានសងថ្លៃលក់តាមការទាមទារនោះ។

### ៧.២ ការរលត់ដោយអាជ្ញាយុកាល

ចំពោះអាជ្ញាយុកាលនៃការរលត់ការបញ្ចាំអចលនវត្ថុ ត្រង់មាត្រា ៨៦៥ នៃក្រមរដ្ឋប្បវេណី ស្តីពីហ៊ីប៉ូតែក មិនបានបញ្ញត្តិថា "ហ៊ីប៉ូតែកត្រូវមិនរលត់ដោយអាជ្ញាយុកាលចំពោះកូនបំណុល និងអ្នកដែលបានបង្កើតហ៊ីប៉ូតែកឡើយ" ប្រសិនបើសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែកនោះមិនរលត់ព្រមគ្នាទេ។

ដោយហេតុថា ហ៊ីប៉ូតែកបង្កើតឡើងដើម្បីធានាសិទ្ធិលើបំណុល ដែលត្រូវបានធានា ទោះបីជាម្ចាស់បំណុលមិនបានធ្វើនីតិវិធីផ្អាកអាជ្ញាយុកាលចំពោះហ៊ីប៉ូតែកក៏ដោយ ក៏ហ៊ីប៉ូតែកមិនត្រូវបានរលត់ដោយឯកឯងបានឡើយ[73]។

### ៧.៣ ការរលត់ការបញ្ចាំអចលនវត្ថុដោយលទ្ធកម្មនូវការបញ្ចាំអចលនវត្ថុដោយអាជ្ញាយុកាល

ហ៊ីប៉ូតែក ត្រូវបានរលត់នៅពេលដែលតតិយជនក្រៅពីកូនបំណុល ឬអ្នកបង្កើតហ៊ីប៉ូតែកបានបំពេញនូវលក្ខខណ្ឌ សម្រាប់អាជ្ញាយុកាលនៃលទ្ធកម្មចំពោះអចលនវត្ថុហ៊ីប៉ូតែក[74]។ បទបញ្ញត្តិនេះ ត្រូវបានរៀបចំឡើងដោយសារតែលទ្ធកម្មកម្មសិទ្ធិដោយអាជ្ញាយុកាល គឺមិនមែនជាលទ្ធកម្មបន្តទេ តែវាជាលទ្ធកម្មកម្មសិទ្ធិដំបូង។ មានន័យថា លទ្ធកម្មកម្មសិទ្ធិតាំងពីដំបូង គឺជាការធ្វើលទ្ធកម្មកម្មសិទ្ធិពេញលេញដោយគ្មានជាប់បន្ទុកដែលមាននោះ។

ចំណែកឯលទ្ធកម្មបន្តដូចជា លទ្ធកម្មកម្មសិទ្ធិតាមរយៈការលក់ទិញវិញ ប្រសិនបើអ្នកទិញបានទិញដីដែលមានបន្ទុកជាហ៊ីប៉ូតែក អ្នកទិញនោះអាចធ្វើលទ្ធកម្មកម្មសិទ្ធិដែលមានបន្ទុកហ៊ីប៉ូតែក។ ម៉្យាងវិញទៀត ហ៊ីប៉ូតែកជាសិទ្ធិប្រត្យក្សហើយត្រូវបានយកមកតតាំងចំពោះតតិយជននៅពេលចុះបញ្ជី។ ដូចនេះទោះបីជា អ្នកទិញបានដឹងពីអត្ថិភាពនៃហ៊ីប៉ូតែក ក៏ដោយក៏ម្ចាស់ហ៊ីប៉ូតែក អាចអះអាងពីហ៊ីប៉ូតែករបស់ខ្លួនចំពោះអ្នកទិញអចលនវត្ថុដែលជាប់ហ៊ីប៉ូតែកបានដែរ។ ប៉ុន្តែមានករណីបុគ្គលមួយចំនួនធ្វើលទ្ធកម្មកម្មសិទ្ធិ តាមរយៈការលក់ទិញតែបែរជាអះអាងថា ខ្លួនបានបំពេញលក្ខខណ្ឌនៃអាជ្ញាយុកាលលទ្ធកម្មនៃកម្មសិទ្ធិនៅពេលជាមួយគ្នា។ នៅក្នុងករណីនេះ តតិយជនអាចធ្វើលទ្ធកម្មនូវកម្មសិទ្ធិ ប៉ុន្តែហ៊ីប៉ូតែកមិនត្រូវរលត់ទេ ប្រសិនបើតតិយជនដែលបានធ្វើលទ្ធកម្ម នូវអចលនវត្ថុដែលជាប់ហ៊ីប៉ូតែកបានដឹងថា ហ៊ីប៉ូតែកត្រូវបានបង្កើតឡើងលើអចលនវត្ថុនោះ ( យោងកថាខណ្ឌទី២ មាត្រា ៨៦៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧)។

## ៨. ការអនុវត្តដូចគ្នាតាមបទបញ្ញត្តិស្តីពីហ៊ីប៉ូតែក

យោងតាមមាត្រា ៨៣៩ នៃក្រមរដ្ឋប្បវេណី បានចែងថា ក្រៅពីបទបញ្ញត្តិនៃផ្នែកទី៣ ដែលស្តីពីការបញ្ចាំអចលនវត្ថុ និងបញ្ញត្តិនៃជំពូកទី ៥ (ស្តីអំពីហ៊ីប៉ូតែក) ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការបញ្ចាំអចលនវត្ថុ។ ខាងក្រោមនេះ គឺជាឧទាហរណ៍មួយចំនួនស្តីពីការអនុវត្តដូចគ្នានឹងបទបញ្ញត្តិស្តីពីហ៊ីប៉ូតែក។

[73] មាត្រា ៨៦៥ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[74] កថាខណ្ឌទី១ មាត្រា ៨៦៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

បទបញ្ញត្តិស្តីពីការតតាំងហ៊ីប៉ូតែក ដែលមានចែងនៅក្នុងមាត្រា ៨៤៥ នៃក្រមរដ្ឋប្បវេណី ក៏ត្រូវបានយកមកអនុវត្តដូចគ្នានឹងការបញ្ចាំដែរ។ ហេតុនេះ ដើម្បីឲ្យការបញ្ចាំមួយអាចតតាំងនឹងតតិយជនបាន សិទ្ធិលើការបញ្ចាំនោះ ត្រូវធ្វើឡើងដោយលិខិតយថាភូត និងត្រូវធ្វើការចុះបញ្ជី។

ចំពោះទំហំអានុភាពនៃហ៊ីប៉ូតែក ដែលមានចែងនៅក្នុងមាត្រា ៨៤៦ ក៏អនុវត្តដូចគ្នាជាមួយនឹងការបញ្ចាំដែរ ពោលគឺ នៅពេលដែលការបញ្ចាំមួយត្រូវបានបង្កើតឡើងនៅលើដីមួយកន្លែង ការបញ្ចាំនោះមានអានុភាពលើវត្ថុដែលភ្ជាប់នឹងដីនោះរួមទាំងអាគារ ដែលមាននៅលើដីដែលជាប់ការបញ្ចាំនោះផងដែរ។ ទោះបីជាអាគារនោះត្រូវបានសង់នៅមុនពេល ឬក្រោយពេលបង្កើតសិទ្ធិលើការបញ្ចាំក៏ដោយ ហើយដែលភាគីមិនអាចកំណត់លក្ខខណ្ឌផ្សេងពីនេះនៅក្នុងកិច្ចសន្យាបញ្ចាំរបស់ខ្លួនបានឡើយ។ ដោយហេតុថា ជាទូទៅ យោងតាមមាត្រា ១២២ នៃក្រមដដែលនេះ បានចែងកំណត់ថា វត្ថុដែលនៅជាប់នឹងដី ឬវត្ថុដែលក្លាយជាភាគមួយនៃដីពិសេសអាគារ ឬសំណង់ដែលសង់នៅលើដីហើយមិនអាចប្តូរកន្លែងបាន គឺជាសមាសភាគនៃដី។ ហេតុនេះ នាំឲ្យសិទ្ធិលើការបញ្ចាំដែលមាននៅលើដីមួយកន្លែងនឹងមានអានុភាពទៅលើអ្វីដែលជា សមាសភាគនៃដីនោះដែរ។

ទន្ទឹមនឹងនេះ មាត្រា ៨៥១ ដែលស្តីអំពីលំដាប់នៃហ៊ីប៉ូតែក ក៏ត្រូវយកមកអនុវត្តដូចគ្នានឹងការបញ្ចាំដែរមានន័យថា អាទិភាពនៃសិទ្ធិលើការបញ្ចាំ គឺអាស្រ័យលើពេលវាលានៃការចុះបញ្ជីសុរិយោដីនៃសិទ្ធិទាំងនោះ។

ដូចគ្នាដែរ មាត្រា ៨៥២ ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានាដែលអនុវត្តចំពោះហ៊ីប៉ូតែក ក៏ត្រូវគេអនុវត្តចំពោះសិទ្ធិលើការបញ្ចាំដែរ។ មានន័យថា ក្នុងករណីដែលម្ចាស់បំណុលនៃសិទ្ធិលើការបញ្ចាំមានសិទ្ធិក្នុងការទាមទារការប្រាក់ ឬធនលាភផ្សេងទៀត ម្ចាស់បំណុលនៃសិទ្ធិលើការបញ្ចាំអាចអនុវត្តសិទ្ធិលើការបញ្ចាំនោះបានតែចំពោះចំនួននៃការសងដែលកំណត់ពេលវេលាសម្រាប់អំឡុងពេល ២ (ពីរ) ឆ្នាំចុងក្រោយតែប៉ុណ្ណោះ។ ប៉ុន្តែចំពោះធនលាភដែលមានពីមុនមក ប្រសិនបើបានចុះបញ្ជីពិសេសក្រោយពីបានដល់ពេលកំណត់ត្រូវសងសិទ្ធិលើការបញ្ចាំនេះអាចអនុវត្តបានចាប់ពីពេលដែលបានចុះបញ្ជីនោះ។

ការកំណត់ដូច្នេះ ពីព្រោះវាមានភាពចាំបាច់សម្រាប់ការពារម្ចាស់បំណុលនៃសិទ្ធិប្រាតិភោគប្រត្យក្សដទៃទៀតដែលស្ថិតក្នុងលំដាប់ទាបជាង ដើម្បីឲ្យដឹងថា តើនៅសល់ចំនួនប៉ុន្មានដែលមិនត្រូវបានធានា ដើម្បីឲ្យពួកគេដឹងថា តើពួកគេត្រូវខ្ចីចំនួនប៉ុន្មានជាដើម។

# ជំពូកទី៤
# ការបញ្ចាំសិទ្ធិ

ការបញ្ចាំសិទ្ធិ គឺមានលំហូរនីតិវិធីនៃការបង្កើតកិច្ចសន្យាបញ្ចាំដូចទៅនឹងការបង្កើតកិច្ចសន្យាបញ្ចាំចលនវត្ថុ និង ការបញ្ចាំអចលនវត្ថុដែរ ប៉ុន្តែការបញ្ចាំសិទ្ធិនៅមានចំណុចបន្ថែមផ្សេងទៀតដូចតទៅនេះ៖

## ១. អត្ថន័យនៃការបញ្ចាំសិទ្ធិ

យើងអាចធ្វើការបកស្រាយថា ការបញ្ចាំសិទ្ធិ គឺជាយន្តការមួយដែលម្ចាស់សិទ្ធិលើបំណុលណាមួយជាកំណត់របស់ខ្លួនដាក់ប្រាតិភោគសិទ្ធិលើបំណុលរបស់ខ្លួន ដោយយកទៅដាក់ប្រាតិភោគបន្តសម្រាប់ការធានាសិទ្ធិលើបំណុលមួយផ្សេងទៀត។

## ២. ការបង្កើតសិទ្ធិលើការបញ្ចាំសិទ្ធិ

### ២.១ លក្ខខណ្ឌបង្កើតអានុភាពចំពោះកិច្ចសន្យាបញ្ចាំសិទ្ធិ

ដើម្បីឲ្យមានអានុភាពអនុវត្តបាន ការបញ្ចាំសិទ្ធិ គឺត្រូវមានការព្រមព្រៀងរវាងភាគី។ ពាក់ព័ន្ធនឹងការបញ្ចាំសិទ្ធិ ជាទូទៅ ការព្រមព្រៀងត្រូវបានចាត់ទុកថា ជាលក្ខខណ្ឌដើម្បីបង្កើតឲ្យមានអានុភាពសម្រាប់ការបង្កើត ពីព្រោះថាសិទ្ធិ គឺជាទ្រព្យអរូបីយ៍ ហើយមិនអាចប្រគល់បានទេ។ ជាករណីលើកលែងប្រសិនបើ ការអនុវត្តសិទ្ធិនោះ តម្រូវឲ្យមានការកាន់កាប់នូវឯកសារដូចជា មូលប្បទានប័ត្រ ការបង្កើតសិទ្ធិនោះតម្រូវឲ្យមានការប្រគល់នូវឯកសារនោះតាមលក្ខណៈនៃការបញ្ចាំ។

#### ២.១.១ ការព្រមព្រៀង

ចំពោះលក្ខខណ្ឌទម្រង់នៃការបង្កើតកិច្ចសន្យាបញ្ចាំសិទ្ធិនេះ ត្រូវធ្វើឡើងការព្រមព្រៀងរវាងអ្នកបង្កើតសិទ្ធិលើការបញ្ចាំសិទ្ធិ និងម្ចាស់សិទ្ធិលើការបញ្ចាំសិទ្ធិ ។

ការបញ្ចាំសិទ្ធិ គឺតម្រូវឲ្យមានវត្តមានរបស់ភាគីសំខាន់ៗចូលរួមដែលរួមមានដូចជា៖

- អ្នកបង្កើតសិទ្ធិលើការបញ្ចាំសិទ្ធិ (កូនបំណុល និងតតិយជនដែលធានាដោយវត្ថុធានា)
- ម្ចាស់កម្មសិទ្ធិលើការបញ្ចាំសិទ្ធិ (ម្ចាស់បំណុល)
- និងកម្មវត្ថុ៖ សិទ្ធិលើចលនវត្ថុ អចលនវត្ថុ និងសិទ្ធិលើបំណុល។

ដូច្នេះ លក្ខខណ្ឌសុពលក្នុងការបង្កើតសិទ្ធិលើការបញ្ចាំសិទ្ធិ គឺមានលក្ខណៈដូចគ្នានឹងលក្ខខណ្ឌក្នុងការបង្កើតកិច្ចសន្យាបញ្ចាំចលនវត្ថុ និងកិច្ចសន្យាបញ្ចាំអចលនវត្ថុដែរ។

- **លិខិតមានកាលបរិច្ឆេទស្ថាពរ គឺជាលិខិតដែលមានលក្ខណៈដូចខាងក្រោម៖**

១. លិខិតយថាភូត (កាលបរិច្ឆេទនៃការធ្វើលិខិតយថាភូត គឺជាកាលបរិច្ឆេទស្ថាពរ)

២. លិខិតឯកជន ដែលសាការី ឬ ក្រឡាបញ្ជីតុលាការចុះនិទ្ទេសអំពីកាលបរិច្ឆេទដែលខ្លួនត្រូវបានបង្ហាញលិខិតឯកជននោះ និងបានចុះហត្ថលេខា។ កាលបរិច្ឆេទនោះ គឺជាកាលបរិច្ឆេទស្ថាពរ។

៣. លិខិតឯកជនដែលមានជនណាម្នាក់ ក្នុងចំណោមជនដែលបានចុះហត្ថលេខា លើលិខិតនោះបានទទួលមរណៈភាព។ ថ្ងៃដែលជននោះបានទទួលមរណៈភាពត្រូវក្លាយជាកាលបរិច្ឆេទស្ថាពរ។ នេះជាការសន្មត់របស់ច្បាប់។

៤. លិខិតឯកជនដែលត្រូវបានយកជាអាគតដ្ឋាន[75] នៅក្នុងលិខិតដែលមានកាលបរិច្ឆេទស្ថាពរ។ ក្នុងករណីនេះ កាលបរិច្ឆេទនៅក្នុងលិខិតដែលមានកាលបរិច្ឆេទស្ថាពរ គឺជាកាលបរិច្ឆេទស្ថាពរ (យោងតាម មាត្រា ៨ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី)។

### ២.១.២ លក្ខខណ្ឌតតាំង

ការបង្កើតការបញ្ចាំសិទ្ធិ ត្រូវមានលក្ខណៈ និងលក្ខខណ្ឌតតាំង[76]ដូចខាងក្រោម៖

- ចំពោះកូនបំណុលទី៣៖ ត្រូវតែមានការជូនដំណឹងពីការបង្កើតសិទ្ធិលើការបញ្ចាំ ឬព្រមទាំងត្រូវតែមានការយល់ព្រមពីកូនបំណុលទី៣។
- ចំពោះតតិយជនផ្សេងទៀត៖ ការជូនដំណឹងត្រូវតាមលិខិតដែលមានកាលបរិច្ឆេទស្ថាពរ ទើបអាចមកតតាំងជាមួយតតិយជនបានតាមផ្លូវច្បាប់។

កូនបំណុលទី៣ គឺជាតតិយជនដែលមិនមានជាកូនបំណុលរបស់ខ្លួនតែផ្ទុយទៅវិញកូនបំណុលទី៣ គឺជាកូនបំណុលរបស់កូនបំណុលរបស់ខ្លួនតាមរយៈលិខិតដែលមានកាលបរិច្ឆេទស្ថាពរ។

## ២.២ ការអនុវត្តនៃការបញ្ចាំសិទ្ធិ

ការអនុវត្តសិទ្ធិលើការបញ្ចាំសិទ្ធិ[77] អាចធ្វើទៅបានក្នុងករណី ២ (ពីរ) យ៉ាងដូចខាងក្រោម៖

១. កម្មវត្ថុនៃបំណុល គឺជាប្រាក់៖ ម្ចាស់សិទ្ធិប្រមូលសិទ្ធិលើបំណុលដោយផ្ទាល់ពីកូនបំណុលទី៣ តែម្តង និងជាក់ស្តែង។

២. កម្មវត្ថុនៃបំណុល មិនមែនជាប្រាក់ ពោលគឺជា វត្ថុ (ចលនវត្ថុ ឬអចលនវត្ថុ)៖ ម្ចាស់សិទ្ធិដែលមានសិទ្ធិលើការបញ្ចាំលើវត្ថុដែលខ្លួនបានទទួលជាការសងមុនម្ចាស់បំណុលផ្សេងៗទៀត[78]។

## ៣.ការប្រៀបធៀប ការបញ្ចាំចលនវត្ថុ ការញ្ចាំអចលនវត្ថុ និងការបញ្ចាំសិទ្ធិលើបំណុល

ការប្រៀបធៀបនេះ គឺយើងនឹងលើកមកបង្ហាញតែ ៤ (បួន) ចំណុចសំខាន់ៗតែប៉ុណ្ណោះ។

ខាងក្រោមនេះ គឺជាតារាងប្រៀបធៀបនៅការបញ្ចាំទាំងបីប្រភេទ ដែលមានខ្លឹមសារដូចតទៅនេះ៖

### តារាងប្រៀបធៀបរវាងការបញ្ចាំទាំងបីប្រភេទនៃកិច្ចសន្យាបញ្ចាំ

| | ការបញ្ចាំចលនវត្ថុ | ការបញ្ចាំអចលនវត្ថុ | ការបញ្ចាំសិទ្ធិលើបំណុល |
|---|---|---|---|
| **កម្មវត្ថុនៃការបញ្ចាំ** | ចលនវត្ថុ | អចលនវត្ថុ | សិទ្ធិលើបំណុល |

[75] អាគតដ្ឋាន៖ ទីដែលមក ឬទីដែលស្រង់ ឬចម្លងយកមក,ទីដើម(ប្រភពដើម) ,ដំណើរសេចក្តីរឿង ។ល។ ឧទាហរណ៍៖ រឿងនិទាននេះមានអាគតដ្ឋានពុំប្រាកដ។ ដកស្រង់ពីវចនានុក្រមខ្មែរ សម្តេង សង្ឃរាជ ជួន ណាត។

[76] មាត្រា ៨៤១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[77] មាត្រា ៨៤២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[78] មាត្រា ៨៤២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

| **លក្ខខណ្ឌសុពលភាពនៃកិច្ចសន្យាចំពោះគូភាគី** | ការព្រមព្រៀង | ការព្រមព្រៀង | ការព្រមព្រៀង |
|---|---|---|---|
| **លក្ខខណ្ឌតតាំងនៃកិច្ចសន្យាចំពោះតតិយជន** | ការកាន់កាប់ជានិរន្តន៍នៃវត្ថុបញ្ចាំនោះ | លិខិតយថាភូត និង ការចុះបញ្ជី សុរិយោដី | ការជូនដំណឹងទៅកូនបំណុលទី៣ (បី) ឬការយល់ព្រមពីកូនបំណុលទី៣ (បី) ដែលត្រូវធ្វើឡើងដោយលិខិតដែលមានកាលបរិច្ឆេទស្គាល់ |
| **លំដាប់នៃអាទិភាពក្នុងករណីប្រជែងជាមួយសិទ្ធិប្រត្យក្សផ្សេងទៀត** | អាស្រ័យទៅលើលំដាប់នៃការចាប់ផ្តើមកាន់កាប់ | អាស្រ័យលើពេលវេលានៃការចុះបញ្ជីសុរិយោដី | អាស្រ័យទៅលើកាលបរិច្ឆេទស្គាល់នៃលិខិតជូនដំណឹងនោះ។ |

# សន្និដ្ឋាន

យោងតាមការបកស្រាយនៃប្រធានបទខាងលើ យើងសង្កេតឃើញថា សិទ្ធិលើការបញ្ចាំ គឺជាប្រភេទមួយនៃនីតិប្រាតិភោគដែលស្ថិតក្នុងប្រាតិភោគប្រត្យក្ស ដែលត្រូវបានចែង និងកំណត់សំដៅទៅដល់សិទ្ធិក្នុងការកាន់កាប់វត្ថុដែលបានមកពីកូនបំណុល ឬតតិយជនធានាដោយវត្ថុ ដើម្បីធានាសិទ្ធិលើបំណុលឲ្យកូនបំណុល និងទទួលការសងចំពោះសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលពីវត្ថុនោះ ដោមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀត។ តាមរយៈកម្មវត្ថុនៃកិច្ចសន្យាបញ្ចាំ យើងឃើញថា វាមានលក្ខណៈពិសេសជាងកិច្ចសន្យាទូទៅដែលមានតែចលនវត្ថុ ឬអចលវត្ថុប៉ុណ្ណោះដែលជាកម្មវត្ថុចម្បងនៅក្នុងកិច្ចសន្យានោះ ប៉ុន្តែសិទ្ធិលើបំណុល ឬអាចហៅបានថា សិទ្ធិលើទ្រព្យសម្បត្តិរបស់ម្ចាស់បំណុលក៏ត្រូវបានច្បាប់បញ្ញត្តិជាកម្មវត្ថុនៅក្នុងកិច្ចសន្យាបញ្ចាំផងដែរ។

យ៉ាងណាមិញ ការបញ្ចាំត្រូវបានកើតឡើងតាមរយៈការព្រមព្រៀងរបស់គូភាគីនៃកិច្ចសន្យាដោយគ្មានវិការៈ ដែលក្នុងនោះអ្នកដែលបានបង្កើតសិទ្ធិលើការបញ្ចាំ (កូនបំណុល) ឬតតិយជនដែលធានាដោយវត្ថុនោះត្រូវធ្វើការប្រគល់វត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យាបញ្ចាំទៅឲ្យម្ចាស់សិទ្ធិលើការបញ្ចាំ (ម្ចាស់បំណុល)។ ហេតុនេះការព្រមព្រៀងបង្កើតសិទ្ធិលើការបញ្ចាំដោយកូនបំណុល និងម្ចាស់បំណុល គឺជាលក្ខខណ្ឌចាំបាច់ និងដាច់ខាតតែម្តង។

ក្រោយពីបានបង្កើតសិទ្ធិលើការបញ្ចាំស្របតាមលក្ខខណ្ឌនៃច្បាប់កំណត់ហើយនោះ ម្ចាស់សិទ្ធិលើការបញ្ចាំ មានសិទ្ធិក្នុងការកាន់កាប់វត្ថុបញ្ចាំនោះ រីឯអ្នកដែលបានបង្កើតសិទ្ធិលើការបញ្ចាំ (កូនបំណុល) មិនអាចធ្វើការបន្តការកាន់កាប់វត្ថុបញ្ចាំបានទៀតទេ។ ក្នុងករណីប្រសិនបើកូនបំណុលមិនបានអនុវត្តកាតព្វកិច្ចសងបំណុលកទៅតាមពេលកំណត់សងទេ យើងឃើញថា ច្បាប់បានអនុញ្ញាតឲ្យម្ចាស់បំណុលមានសិទ្ធិជាអាទិភាពក្នុងការឃាត់ទុកវត្ថុបញ្ចាំនោះបាន ប៉ុន្តែម្ចាស់បំណុលមិនអាចធ្វើការតតាំងដោយអនុវត្តសិទ្ធិនេះចំពោះម្ចាស់បំណុលផ្សេងទៀតដែលមានអាទិភាពនៃសិទ្ធិខ្ពស់ជាងខ្លួនបានឡើយ។ក្រៅពីសិទ្ធិកាន់កាប់ និងសិទ្ធិឃាត់ទុកវត្ថុបញ្ចាំនេះ ម្ចាស់សិទ្ធិលើការបញ្ចាំមានសិទ្ធិធ្វើការទទួលយកផលដែលទទួលបានពីវត្ថុបញ្ចាំ ក៏ដូចជាសិទ្ធិដែលអាចទាមទារឲ្យកូនបំណុលធ្វើការទូរទាត់សងនូវការចំណាយជាចាំបាច់សម្រាប់គ្រប់គ្រង និងថែរក្សាវត្ថុបញ្ចាំដែលជាសោហ៊ុយនានាមកឲ្យខ្លួនវិញបាន ជាពិសេសគឺម្ចាស់សិទ្ធិអាចធ្វើការបញ្ចាបន្តនូវសិទ្ធិលើបំណុលរបស់ខ្លួនបានជាដើម។

ទោះបីជាកិច្ចសន្យាបញ្ចាំ អាចចាត់ទុកថាជាកិច្ចសន្យាភាគី ឬបុគ្គលក៏ដោយ បើទោះជាកិច្ចសន្យាបញ្ចាំបានបង្កើតឡើងដោយគ្មានវិការៈយ៉ាងណាក្តីក៏ច្បាបមិនអនុញ្ញាតឲ្យភាគីទាំងសងខាងអាចបងកើតបាននូវកិច្ចសន្យាបញ្ចាំផ្តាច់ដែលបានធ្វើមុនពេលកំណត់ត្រូវសងបានឡើយ។ ប៉ុន្តែច្បាប់បានកំណត់ចែងនូវករណីលើកលែងដល់ម្ចាស់បំណុល ពោលគឺច្បាប់មិនបានធ្វើការហាមឃាត់ម្ចាស់បំណុលក្នុងការទទួលកម្មសិទ្ធិលើវត្ថុបញ្ចាំ ឬចាត់ចែងវត្ថុបញ្ចាំដែលធ្វើក្រោយពេលកំណត់សងនៃកិច្ចសន្យាបញ្ចាំនោះទេ។ ទាំងនេះសុទ្ធតែជាលក្ខខណ្ឌដែលច្បាប់អនុម័ត ដែលជាពិសេសគឺ ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ តែម្តងដែលបានបញ្ញត្តិទុក ដើម្បីជាប្រយោជន៍ទៅដល់គូភាគីនៃកិច្ចសន្យាបញ្ចាំនេះផងដែរ។

# អនុសាសន៍

ដោយសារតែការអនុវត្តជាក់ស្តែង ដែលបានកំពុងតែមានវត្តមានក្នុងពេលបច្ចុប្បន្នភាពនៅកម្ពុជាយើងនេះ នៅមានកង្វះខាតនៅឡើយ ដូច្នេះដើម្បីចូលរួមអោយមាននូវអត្ថិភាពនៃប្រសិទ្ធិភាព ព្រមទាំងប្រសិទ្ធិផលនៃការអនុវត្តនៃកិច្ចនីតិវិធីដែលមានលក្ខណៈសុពល និងអានុភាពក្នុងក្របខ័ណ្ឌច្បាប់វិជ្ជមាន និង នៅជាធរមានរបស់ច្បាប់នៃព្រះរាជាណាចក្រកម្ពុជាយើងនាពេលបច្ចុប្បន្ននេះទៅលើកិច្ចសន្យាបញ្ជាំនៅក្នុងសកម្មភាព សង្គមនាពេលបច្ចុប្បន្នឲ្យមានលក្ខណៈល្អប្រសើរជាងមុន និងលក្ខណៈត្រឹមត្រូវទៅតាមលក្ខខណ្ឌដែលច្បាប់បានតម្រូវសម្រាប់គូភាគីនោះ យើងខ្ញុំសូមចូលរួមចំណែកក្នុងការផ្តល់មតិយោបល់ ក៏ដូចជាអនុសាសន៍មួយចំនួនជាសារវន្តបំផុតដែលអាចជាកត្តា និងជាពុទ្ធិដែលមិនអាចកាត់ថ្លៃបានទៅដល់ការអភិវឌ្ឍន៍សង្គម ជាពិសេសនៅក្នុងក្របខ័ណ្ឌនៃវិស័យពាណិជ្ជកម្មនៃពាណិជ្ជកិច្ចរបស់ពួកគេដែលតែងតែមាននូវអន្តរទំនាក់ទំនង ឬ ក៏ដូចជាមាននូវសម្ព័ន្ធភាពនឹងគ្នាក្នុងវិស័យមួយនេះ របស់ពលរដ្ឋទូទៅដែលជាសមាជិកភាពរបស់រដ្ឋនៃសង្គមជាតិនីតិរដ្ឋនៃព្រះរាជាណាចក្រកម្ពុជាបានមួយចំណែកដូចខាងក្រោមនេះ៖

- សូមសំណូមពរទៅដល់ប្រជាជនគ្រប់រូប គប្បីចូលរួមសិក្សាស្វែងយល់ឲ្យបានស៊ីជម្រៅបន្ថែមទៀតពាក់ព័ន្ធនឹងការបង្កើតកិច្ចសន្យាបញ្ជាំ ក៏ដូចជាកិច្ចសន្យាប្រាតិភោគផ្សេងៗឲ្យបានត្រឹមត្រូវ ដើម្បីប្រយោជន៍ដល់ខ្លួន ក៏ដូចជាភាគីទាំងសងខាងដើម្បីទទួលបានពីការការពារដោយច្បាប់ (ដូចមានសុភាសិតច្បាប់មួយបានពំនោលពោលថា "ប្រសិនបើ ជារាស្ត្រប្រជាដែលបានកំពុងរស់នៅក្នុងសង្គមជាតិនីតិរដ្ឋមួយ ហើយរាស្ត្រប្រជាដែលជាសមាជិភាពនៃសង្គមនីតិរដ្ឋនោះបានធ្វើការបំភ្លេចច្បាប់ នោះច្បាប់នៃសង្គមនីតិរដ្ឋនោះនឹងបំភ្លេចអ្នកនោះវិញដូចគ្នា")។ នេះបានសរបញ្ជាក់ និងស្តែងអោយឃើញថា ប្រសិនជាយើងចូលរួមគោរពច្បាប់នៃសង្គមនីតិរដ្ឋ នោះសង្គមនៃនីតិរដ្ឋនោះក៏បានធ្វើការគោរព និងការពារនូវសិទ្ធិ និងផលប្រយោជន៍ជាសារវន្តដល់បុគ្គលនោះត្រឡប់មកវិញជាក់ជាមិនខានឡើយ។ វាជាតក្កវិជ្ជាវិទ្យាសាស្ត្រដែលជាច្បាប់សកលមួយ។ ប្រសិនបើយើងនិយាយទៅដល់ច្បាប់នៃទស្សនៈវិជ្ជាសកលវិញបានលើកឡើងថា "ប្រសិនជាយើងគោរពគេ នោះគេនឹងគោរពយើងវិញ"។ តម្លៃរបស់បុគ្គលម្នាក់ៗត្រូវមានជាអត្ថិភាព ឬ នត្ថិភាពវាស្រ័យលើទង្វើដែលយើងបានប្រព្រឹត្តទៅគេមុនប៉ុណ្ណោះ។
- គ្រប់បុគ្គលដែលបានអនុវត្តនូវកិច្ចប្រភេទនេះ មិនត្រូវបង្កើតកិច្ចសន្យាទាំងឡាយណាដោយកំណត់តែទៅលើប្រយោជន៍ខ្លួនតែម្ខាង ឬបង្កើតដោយមានការលោភបំពានសិទ្ធិភាគីម្ខាងទៀត ដែលជាហេតុនាំឲ្យមានផលប៉ះពាល់សិទ្ធិបុគ្គល ក៏ដូចជាការប៉ះពាល់ទៅដល់ការបំពេញនូវកិច្ចការប្រកបរបរនានាប្រចាំថ្ងៃរបស់បុគ្គលដែលជាធាតុដ៏សំខាន់នៅក្នុងសកម្មភាពសេដ្ឋកិច្ចក្នុងសង្គមជាតិនៃនីតិរដ្ឋមួយឡើយ។ ហើយ ចំពោះកិច្ចទាំងឡាយណាដែលបានប្រតិបត្តិទៅក្នុងការអនុវត្តកិច្ចសន្យាលើការបញ្ជាំនេះ ដែលស្តែងឡើងដោយមានគំនិតទុច្ចរិត និង មានឧបាយកលក្នុងភាពកេងយកចំណេញហួសហេតុពីសំណាក់ភាគីម្ខាងនៃកិច្ចសន្យា នោះច្បាប់របស់សង្គមជាតិនៃនីតិរដ្ឋនោះនឹងមិនឈរឱបដៃមើលសមាជិកភាពរបស់ខ្លួនត្រូវបានរងគ្រោះតាមរយៈអំពើមួយ ដែលធ្វើអោយប៉ះពាល់ដល់ផលប្រយោជន៍បុគ្គល ឬអាចជាបច្ច័យដែលជាធាតុនាំទៅដល់ផលប្រយោជន៍ទូទៅរបស់រដ្ឋ ឬ សណ្តាប់ធ្នាប់សាធារ

ណៈ ព្រមទាំងរបៀបរៀបរយ ទំនៀមទម្លាប់ល្អរបស់សង្គមជាតិដែលមានអរិយធម៌ដោយឈរលើគោលការណ៍នៃការគោរពនៃនីតិរដ្ឋ ដែលគ្រប់បុគ្គលទាំងអស់ដែលមានទំនាក់ទំនងគតិយុត្តរវាងខ្លួននឹងរដ្ឋត្រូវតែ មានកាតព្វកិច្ចចូលរួមធ្វើ និងចូលរួមក្នុងការគោរពច្បាប់អោយខានតែបានទាំងអស់គ្នា។ ទាំងនេះជាកត្តាលីករមួយនៃឧបករណ៍គតិយុត្តដែលតម្រូវអោយសមាជិកភាពសង្គមទាំងអស់ ត្រូវអនុវត្តនៃការចូលរួមសិក្សាស្វែងយល់អោយបានជាអតិបរមា ធ្វើយ៉ាងណាអោយខ្លួនមានការយល់ដឹង និង មានសមត្ថភាពគ្រប់គ្រាន់នៅក្នុងការអនុវត្តរាល់លើកិច្ចសន្យាទាំងឡាយជាពិសេសគឺកិច្ចសន្យាបញ្ចាំ ដែលខ្លួនបង្កើតឡើងក្នុងឆន្ទៈទទួលខុសត្រូវ ក្នុងឋានៈភាព ជាបុគ្គលភាពគតិយុត្តទៅលើគ្រប់លទ្ធផលទៅតាមផ្លូវច្បាប់ដែលត្រូវបានកំណត់ថា បុគ្គលគ្រប់រូប គឺជាប្រធាននៃនីតិ ឬ ជាប្រធាននៃសិទ្ធិ និង កាតព្វកិច្ចក្នុងរាល់កិច្ចទាំងឡាយដែលបានទទួលបានក្នុងឋានៈមួយដែលច្បាប់ធ្វើការផ្តល់អោយដោយសមភាពនិង តុល្យភាពគ្នាព្រមទាំងកិច្ចដែលខ្លួនត្រូវតែប្រតិបត្តិអោយខានតែបាន នូវគណនេយ្យភាពរបស់បុគ្គលម្នាក់ក្នុងសកម្មភាពនៃការរស់នៅក្នុងជីវភាពរបស់សង្គម ជាពិសេស ក្នុងកិច្ចទាំងឡាយណាដែលមានការជាប់ពាក់ព័ន្ធនឹងកិច្ចសន្យាដែលខ្លួនបានបង្កើតឡើង។ ហើយដើម្បីអនុញ្ញាត និង នាំខ្លួនកុំអោយក្លាយជាជនរងគ្រោះដោយសារការបង្កើតកិច្ចសន្យាក្នុងក្របខ័ណ្ឌពាណិជ្ជកម្មក្តី សាជីវកម្មក្តី កិច្ចសន្យាឯកត្តោភាគីក្តី ជាពិសេសកិច្ចសន្យាទាំងឡាយណាដែលត្រូវបានធ្វើឡើងក្នុងការកំណត់អំពីកាតព្វកិច្ចរបស់ភាគី នោះភាគីគួរគប្បីមានការសិក្សាស្វែងយល់តាមរយៈនៃការស្វ័យសិក្សាពីឯកសារគតិយុត្តតាមរយៈនៃ ការអានអត្ថបទផ្សព្វផ្សាយពីចំណេះដឹងពីការបង្កើតកិច្ចសន្យា ព្រមទាំងចំណេះផ្សេងៗដែលពាក់ព័ន្ធ ដើម្បីជាមូលដ្ឋានគតិយុត្តសម្រាប់ការឈានទៅដល់ការមានសមត្ថភាពគ្រប់គ្រាន់ ក្នុងការបង្កើតកិច្ចសន្យាទាំងឡាយទាំងពួងដោយខ្លួនមានគុណភាពនៃចំណេះដឹងដ៏សមស្របមួយសម្រាប់ការយល់ដឹងនៃការការពារផលប្រយោជន៍ និង សិទ្ធិផ្សេងៗរបស់ខ្លួនដែលត្រូវបានធ្វើការការពារដោយច្បាប់នៃសង្គមនីតិរដ្ឋដែលរាស្ត្រប្រជាគ្រប់រូប គឺត្រូវតែមានការរស់នៅក្នុងក្របខណ្ឌនៃភាពក្រោមច្បាប់ទាំងអស់គ្នា។

- ចំពោះបុគ្គលដែលមានសិទ្ធិលើបំណុល ដែលជាពិសេសគឺ ម្ចាស់បំណុលនោះ មិនត្រូវបង្កើតកិច្ចសន្យាបញ្ចាំ ដោយឆ្លៀតពេលយកឱកាសនេះ ដើម្បីធ្វើការកេងចំណេញទៅលើទ្រព្យសម្បត្តិរបស់ភាគីដែលជាកូនបំណុល ដែលក្នុងកាលៈទេសៈនេះកូនបំណុល គឺជាជនដែលគ្មានសមត្ថភាពគ្រប់គ្រាន់ក្នុងការយល់ដឹងពីលក្ខខណ្ឌទាំងនោះជាដើម។ ក្នុងន័យផងដែរ ច្បាប់ គឺមានយុត្តិធម៌ណាស់សម្រាប់គូរភាគីនៃកិច្ចសន្យាទាំងឡាយទាំងពួង ពិសេស គឺកិច្ចសន្យាបញ្ចាំតែម្តង ដែលក្នុងបុព្វហេតុនៃការបង្កើតកិច្ចសន្យាបញ្ចាំ គឺបានធ្វើការការពារគូរភាគីដោយសមភាព និងតុល្យភាពបំផុតសម្រាប់ភាគីដែលត្រូវបានរងគ្រោះដោយការបំពារបំពានទៅលើការអនុវត្តកិច្ចសន្យា ដែលត្រូវបង្កើតឡើងដោយឆន្ទៈរបស់ភាគីដោយអវត្តមាននៃការបង្ហាញឆន្ទៈដោយនត្ថិភាពនៃវិការៈរបស់គូរភាគីនៃកិច្ចសន្យា។ ទោះបីជាភាគីនៃម្ចាស់សិទ្ធិនៃការបញ្ចាំនោះមានឥទ្ធិពលទាំងផ្នែកសេដ្ឋកិច្ច សង្គម និងចំណេះដឹង ព្រមទាំងផ្នែកផ្សេងៗទៀតក្តី ក៏ច្បាប់មានការពារដល់ជននោះក្នុងក្របខ័ណ្ឌទំហំមួយដែលច្បាប់បានកំណត់ទុកជាមុនក្នុង

ច្បាប់វិជ្ជមាន និងនៅជាធរមាន ក្នុងកម្រិតដែលមានភាពយុត្តិធម៌បំផុតដល់ភាគី មិនថាភាគីខាងអ្នកបង្កើតសិទ្ធិលើការបញ្ជាំ ឬម្ចាស់សិទ្ធិលើការបញ្ជាំនោះទេ។ នេះស្តែងអោយយើងទាំងអស់គ្នាដែលជាសមាជិកភាពរបស់សង្គមជាតិនៃនីតិរដ្ឋ គឺបានធ្វើការការពារដល់ជនគ្រប់រូបដោយសមភាព ស្មើភាពយុត្តិធម៌ ពិសេស គឺតុល្យភាព និងគណនេយ្យភាពរបស់គូរភាគីនៃកិច្ចសន្យាដោយមិនលំអៀងទៅកាន់ភាគីណាទៅភាគីណាមួយឡើយ។ ច្បាប់ គឺជាពុម្ពអក្សរ ដែលត្រូវបានបង្កើតឡើងដោយកិច្ចសន្យាសង្គមក្នុងការសំដែងឆន្ទៈរបស់រាស្ត្រប្រជារបស់រដ្ឋទាំងមូល នៅក្នុងការជ្រើសរើសសភាតំណាងអោយខ្លួននៅក្នុងការទទួលបាននីតិសម្បទា ក្នុងការអនុម័តច្បាប់ទាំងឡាយសម្រាប់គ្រប់គ្រងសណ្តាប់ធ្នាប់របស់សង្គមទាំងមូលអោយមានរបៀបរៀបរយ ថ្លៃថ្នូរ សមភាពមិនចំពោះ មិនថាបុគ្គលណាមួយដែលជាសមាជិករបស់សង្គមដោយសារ វណ្ណៈ ធនធាន ពូជសាសន៍ ពណ៌សម្បុរ ភេទ នយោបាយ សាសនា ។ល។ និង ។ល។ ឡើយ។

- ម្យ៉ាងវិញទៀត យើងខ្ញុំក៏សូមសំណូមពរទៅដល់មន្ត្រីអ្នកអនុវត្តច្បាប់ និងពលរដ្ឋទាំងអស់ មេត្តាគោរពឲ្យមានម៉ត់ចត់នូវក្រមសីលធម៌ ព្រមទាំងគោលការណ៍ទាំងឡាយណាដែលបានចែងនៅក្នុងច្បាប់ជាធរមានឲ្យបានម៉ឺងម៉ាត់ម៉ត់ចត់ជាទីបំផុត ព្រោះដើម្បីជាប្រយោជន៍ទៅដល់ខ្លួន ក៏ដូចជាទៅដល់ភាគីដែលអនុវត្តនូវកិច្ចសន្យាបញ្ជាំផ្ទាល់ និងសង្គមជាតិទាំងមូលមានការរីកចម្រើនផងដែរ។ ជាពិសេសបំផុតយើងខ្ញុំ ក៏សូមសំណូមពរទៅដល់ស្ថាប័នធំរបស់ជាតិពិសេសតែម្តង គឺក្រសួងយុត្តធម៌ជាមួយក្រសួងពត៌មាន មេត្តាបំផុសនៅការផ្សព្វផ្សាយការអប់រំអោយបានទូលំទូលាយដល់ក្នុងកម្រិតជាអតិបរមាធ្វើយ៉ាងណាអោយការផ្សព្វផ្សាយអប់រំនោះ អោយដល់សំណាក់ប្រជាពលរដ្ឋគ្រប់ជាន់ថ្នាក់ទាំងអស់ដែលជាសមាជិកភាពរបស់សង្គម ដើម្បីអោយទទួលបាននូវចំណេះដឹងនៅក្នុងការអនុវត្តទៅលើកិច្ចសន្យាទាំងឡាយទាំងពួង ដែលជាពិសេស គឺកិច្ចសន្យានៃការបញ្ជាំដែលមានលក្ខណៈ និងមានប្រជាប្រិយភាព ចំពោះការអនុវត្តជាប្រចាំនៅក្នុងគ្រប់ទិដ្ឋភាពនៃការរស់នៅរបស់បងប្អូនប្រជាជនខ្មែរយើងតែម្តង គឺត្រូវធ្វើការផ្សព្វផ្សាយអប់រំយ៉ាងណាអោយពលរដ្ឋរបស់យើង បានទទួលនូវការយល់ដឹងអោយមានភាពស៊ីជម្រៅទៅលើនីតិវិធីនៃការអនុវត្តសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួន ដើម្បីចៀសអោយខានតែបាននូវការខ្វះខាត ឬ កង្វះនៃចំណេះដឹងផ្នែកនេះដែលជាហេតុ និងជាបច្ច័យអោយពួកគេក្លាយខ្លួនជាជនរងគ្រោះដោយការកង្វះការចេះដឹងក្នុងការអនុវត្តសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួន ក្នុងក្របខណ្ឌនៃការអនុវត្តកិច្ចសន្យាបញ្ជាំដោយមិនដឹងខ្លួនពីការដែលនាំអោយពួកគេបានបាត់បង់នូវសិទ្ធិ និង ផលប្រយោជន៍ជាប់ពាក់ព័ន្ធរបស់គេ។ ពិសេសទៀតនោះ គឺភាគីនៃអ្នកបង្កើតសិទ្ធិលើការបញ្ជាំ ដែលជាភាគីដែលគ្មានអំណាចទាំងផ្នែកសេដ្ឋកិច្ច និងសង្គម ព្រមទាំងចំណេះដឹង ចាញ់ប្រៀបធៀបជាមួយនឹងគូភាគីម្ខាងនៃកិច្ចសន្យាបញ្ជាំដែលជាភាគីម្ចាស់បំណុលនៃក្នុងកិច្ចសន្យា។ ដែលយើងអាចនិយាយបានថាគឺអាចប្រឈមនឹងភាពងាយរងគ្រោះបំផុតសម្រាប់ភាគីនៃអ្នកបង្កើតសិទ្ធិលើការបញ្ជាំ ប្រសិនជាពួកគេមិនមានការយល់ដឹងអោយមានលក្ខណៈសមស្របទៅតាមការកំណត់ អំពីសិទ្ធិនិងកាតព្វកិច្ចគូភាគីនៃកិច្ចសន្យាដែលបានមានការចែងនិងកំណត់ទុកក្នុងច្បាប់សារធាតុនៃនីតិឯកជន សម្រាប់ជាយន្តការ

គតិយុត្តនៅក្នុងការការពារជនគ្រប់រូបពីការបំពាន ឬការរំលោភលើសិទ្ធិ និងផលប្រយោជន៍ជាសារវ័ន្ត របស់ភាគីនៃកិច្ចសន្យាពិសេស គឺភាគីនៃអ្នកបង្កើតសិទ្ធិលើការបញ្ចាំតែម្តង។

ដូច្នោះ ជាអនុនសាសន៍ចុងក្រោយគឺ យើងខ្ញុំសូមធ្វើការសំណូមពរយ៉ាងដាច់អង្គាការទៅដល់ក្រសួង ដែលសមត្ថកិច្ចស្អួលបំផុត នៅក្នុងការចូលរួមផ្សព្វផ្សាយអប់រំទោះក្នុងតម្លៃណា ឬ ទោះក្នុងរូបភាពនៃការ ផ្សព្វផ្សាយអប់រំបែបណានោះទេ គឺថាត្រូវតែប្រើអោយអស់នូវគ្រប់យន្តការតាមដែលអាចធ្វើទៅបាន ក្នុងបេសកម្ម ដ៏មានតម្លៃដែលមិនអាចកាត់ថ្លៃបាន ដើម្បីឈានទៅដល់ការដែលអាចកាត់បន្ថយនូវភាពងាយរងគ្រោះរបស់ភា គីនៃកិច្ចសន្យាដោយសារភាពនៃការខ្វះការចេះដឹងពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីនៃកិច្ចសន្យាបញ្ចាំ ហើយវាក៏ ជាយានឈានទៅដល់ការមានជម្លោះ ឬ វិវាទរវាងគ្នានឹងគ្នាដែលជាបុព្វហេតុនាំអោយសមាជិកភាពរបស់សង្គម មិនមានសុភមង្គលសុខដុមនីយកម្មនៃការរស់នៅដោយការមានវិវាទនោះ ហើយវាក៏ជាប្រភពដែលនាំអោយ សង្គមមានការបែកបាក់ បែងចែកវណ្ណៈសង្គម ហើយក៏ជាគ្រោះមួយរបស់ជាតិដែលតម្រូវអោយមានការអប់រំ ផ្សព្វផ្សាយធ្វើយ៉ាងណាអោយពលរដ្ឋទូទៅ ត្រូវតែទទួលអោយបាននូវការយល់ដឹងអោយខានតែបានសម្រាប់ ការចូលរួមការកាត់បន្ថយនៃវិវាទដែលជាប្រភពនៃកង្វះការយល់ដឹង ដែលបានស្តែងឡើងតាមរយៈការមិនទទួល បាននូវការផ្សព្វផ្សាយអប់រំផ្នែកច្បាប់ ដែលមានការពាក់ព័ន្ធ និងមានសម្ព័ន្ធភាពយ៉ាងជិតស្និតក្នុងទិដ្ឋទូទៅនៃកា រស់នៅរបស់ពួកគេនៅក្នុងសង្គមជាតិទាំងមូលនៃនីតិរដ្ឋមួយនេះ។

# ឯកសារយោង

## ១. ប្រភពឯកសារជាបទដ្ឋានគតិយុត្ត

- ក្រឹត្យច្បាប់លេខ ៣៨ ក្រ.ច ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា៖ ប្រកាសឲ្យប្រើនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ ១៩៨៨
- ច្បាប់ភូមិបាល ៖ អនុម័តនៅថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩២
- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- ច្បាប់ភូមិបាល៖ ប្រកាសឲ្យប្រើនៅថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១
- ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានអនុម័តនៅថ្ងៃទី២៦ ខែ ឧសភា ឆ្នាំ ២០០៦
- ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា, អនុម័តថ្ងៃទី ៦ ខែ មេសា ឆ្នាំ ២០០៧
- អនក្រ-១១៤ ស្តីពីការដាក់បញ្ចាំ-ផ្ទេរ-នូវសិទ្ធិជួលរយៈពេលវែង- ឬសិទ្ធិលើដីសម្បទានសេដ្ឋកិច្ច នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ ២០០៧ (យោងតាមភាពចាំបាច់របស់រាជរដ្ឋាភិបាល ដែលបានប្រកាសឲ្យប្រើ)
- ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានអនុម័តនៅថ្ងៃទី ៥ ខែតុលា ឆ្នាំ២០០៧ និងប្រកាសឲ្យនៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧
- សទ្ទានុក្រមពាក្យច្បាប់ ខ្មែរ-អង់គ្លេស-បារាំង ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី,បោះពុម្ពដោយទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ២០០៧
- ច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ, អនុម័តថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០០៩
- សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៤ ៖ គន្លឹទី៦ ។ រៀបចំឡើងដោយគណៈកម្មការទទួលបន្ទុកសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី , បោះពុម្ពនៅឆ្នាំ ២០១០
- ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, អនុម័ត ថ្ងៃទី៦ ខែមេសា ឆ្នាំ ២០១១។

## ២. ប្រភពឯកសារជាសៀវភៅ

- វចនានុក្រមខ្មែរ សម្តេចសង្ឃរាជ ជួន ណាត https://g.co/kgs/9fa1mR
- សៀវភៅក្រមរដ្ឋប្បវេណី ភាគ៥ , បោះពុម្ពនៅខែ មីនា ឆ្នាំ២០១២
- សៀវភៅមេរៀនស្តីពីក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១៖ រៀបរៀងដោយគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ, ក្រសួងយុត្តិធម៌, រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា, និងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, បោះពុម្ពលើកទី១ នៅភ្នំពេញ ខែធ្នូ ឆ្នាំ ២០១៥
- មេរៀនសង្ខេបនីតិរដ្ឋប្បវេណីស្តីពី សិទ្ធិប្រាតិភោគប្រត្យក្ស៖ រៀបរៀងដោយមេធាវី អ៊ីវ ប៉ូលី ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១
- អត្ថបទមេរៀនផ្នែករដ្ឋប្បវេណីស្តីពី នីតិប្រាតិភោគ៖ រៀបរៀងដោយអ្នកស្រីបណ្ឌិត ចាំង ស៊ីណាត ដែល

ជាសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំ ២០១៨

- សៀវភៅនីតិរដ្ឋប្បវេណី៖ រៀបរៀងដោយសាស្ត្រាចារ្យ អម សុផាណារ៉ាត នៃសាកលវិទ្យាល័យភូមិន្ទ នីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៨-២០១៩
- សៀវភៅ នីតិកាតព្វកិច្ច ភាគទី១ ៖ រៀបរៀងដោយលោកបណ្ឌិត ញឹក វុធ្ធី នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៩-២០២០
- អត្ថបទមេរៀនផ្នែកនីតិរដ្ឋប្បវេណីស្តីពី នីតិកិច្ចសន្យាពិសេស៖ រៀបរៀងដោយលោកសាស្ត្រាចារ្យ គី ប៊ុនទ្រាន ឆ្នាំសិក្សា ២០២០-២០២១
- អត្ថបទមេរៀនផ្នែកវិធីសាស្ត្រគតិយុត្ត៖ ដែលរៀបរៀងដោយលោកស្រីបណ្ឌិត ព្រុំ ទេវី , អនុប្រធានវិទ្យាស្ថានសង្គមសាស្ត្រ និងវិទ្យាសាស្ត្រសង្គមនៃរាជបណ្ឌិតសភាកម្ពុជា ឆ្នាំសិក្សា ២០២០-២០២១។

### ៣. ប្រភពឯកសារជាទេបសាយ

- https://www.khsearch.com/qna/30744ចូលមើលថ្ងៃទី២ ឧសភា ២០២១, វេលាម៉ោង ១៦ និង ៣២ នាទីរសៀល។
- https://www.khsearch.com/qna/25625 ចូលមើលថ្ងៃទី ២ ឧសភា ២០២១, វេលាម៉ោង ១៦ និង ១៨នាទីរសៀល។

# ឧបសម្ព័ន្ធ

# ក្រមរដ្ឋប្បវេណី

## ព្រះរាជក្រម

នស/រកម/១២០៧/០៣០

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរជ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមរដ្ឋប្បវេណី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្រប តាមទម្រង់ និងគតិនៃក្រមនេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៤ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

# ជំពូកទី ៤
# សិទ្ធិលើការបញ្ចាំ

## ផ្នែកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ៨១៦.-** អត្ថន័យនៃសិទ្ធិលើការបញ្ចាំ

ម្ចាស់សិទ្ធិលើការបញ្ចាំ មានសិទ្ធិកាន់កាប់វត្ថុដែលបានទទួលពីកូនបំណុល ឬ តតិយជនដើម្បីធានាសិទ្ធិលើបំណុលរបស់ខ្លួន និង ទទួលការសងចំពោះសិទ្ធិលើបំណុលរបស់ខ្លួនពីវត្ថុនោះ ដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀត ។

**មាត្រា ៨១៧.-** ឧបាទេសកម្មលើវត្ថុ

១-សិទ្ធិលើការបញ្ចាំអាចអនុវត្តបានចំពោះទឹកប្រាក់ ឬ វត្ថុផ្សេងទៀតដែលអ្នកបង្កើតត្រូវទទួល ដោយការលក់ ការបាត់បង់ ឬ ការខូចខាតនូវវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំ ។ ប៉ុន្តែ ម្ចាស់សិទ្ធិលើការបញ្ចាំពុំអាចអនុវត្តសិទ្ធិរបស់ខ្លួនបានឡើយ នៅក្រោយពេលដែលទឹកប្រាក់ត្រូវបានបង់ ឬ វត្ថុផ្សេងត្រូវបានប្រគល់ ទៅឱ្យអ្នកបង្កើត ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះតម្លៃថ្នូរនឹងសិទ្ធិប្រត្យក្សដែលបង្កើតឡើង ដោយអ្នកបង្កើតសិទ្ធិលើការបញ្ចាំ លើវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ ។

**មាត្រា ៨១៨.-** ការបង្កើតសិទ្ធិលើការបញ្ចាំ និង ការប្រគល់វត្ថុជាចាំបាច់

១-សិទ្ធិលើការបញ្ចាំត្រូវកើតឡើង ដោយកូនបំណុល ឬ តតិយជនដែលបង្កើតសិទ្ធិលើការបញ្ចាំនោះ ប្រគល់នូវវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំ ទៅឱ្យម្ចាស់សិទ្ធិលើការបញ្ចាំ ។

២-ការប្រគល់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវរាប់បញ្ចូលទាំងការប្រគល់ដោយសង្ខេប ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ នៃមាត្រា ២២៩

(ការផ្ទេរការកាន់កាប់) នៃក្រមនេះ ។

**មាត្រា ៨១៩.–** ការហាមការកាន់កាប់ដោយផ្ទាល់ ដោយអ្នកបង្កើតសិទ្ធិលើការបញ្ចាំ

ម្ចាស់សិទ្ធិលើការបញ្ចាំមិនអាចឱ្យអ្នកបង្កើតសិទ្ធិលើការបញ្ចាំនោះកាន់កាប់ដោយផ្ទាល់លើវត្ថុបញ្ចាំនោះ បានឡើយ ។

**មាត្រា ៨២០.–** ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា

សិទ្ធិលើការបញ្ចាំត្រូវធានានូវ ប្រាក់ដើម ការប្រាក់ ប្រាក់ធានាសងក្នុងករណីមិនគោរពកិច្ចសន្យា សោហ៊ុយដើម្បីអនុវត្តសិទ្ធិលើការបញ្ចាំ សោហ៊ុយដើម្បីថែរក្សាវត្ថុបញ្ចាំ ព្រមទាំងសំណងនៃការខូចខាតដែលកើតឡើងដោយសារការមិនអនុវត្តកាតព្វកិច្ច ឬ វិការៈកំបាំងនៃវត្ថុបញ្ចាំ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានកំណត់ផ្សេង ក្នុងសកម្មភាពបង្កើតសិទ្ធិលើការបញ្ចាំនោះ ។

**មាត្រា ៨២១.–** អានុភាពនៃការឃាត់ទុក

ម្ចាស់សិទ្ធិលើការបញ្ចាំអាចឃាត់ទុកវត្ថុបញ្ចាំបាន រហូតដល់ពេលដែលទទួលការសងចំពោះសិទ្ធិលើបំណុលដែលបានកំណត់នៅក្នុងមាត្រា ៨២០ (ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា) ខាងលើនេះ ។ ប៉ុន្តែ សិទ្ធិនេះមិនអាចតតាំង ចំពោះម្ចាស់បំណុលដែលមានអាទិភាពជាងខ្លួនបានឡើយ ។

**មាត្រា ៨២២.–** សិទ្ធិទទួលការសងពីផលដោយមានអាទិភាព

១-ម្ចាស់សិទ្ធិលើការបញ្ចាំអាចទទួលផលដែលកើតពីវត្ថុបញ្ចាំ និង អាចយកផលនោះមកកាត់សិទ្ធិលើបំណុលរបស់ខ្លួន ដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀតបាន ។

២-ផលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកកាត់ការប្រាក់នៃសិទ្ធិលើបំណុលជាមុនសិន ហើយ ប្រសិនបើមានសំណល់ ត្រូវយកទៅកាត់ប្រាក់ដើម ។

**មាត្រា ៨២៣.-** ករណីយកិច្ចរបស់ម្ចាស់សិទ្ធិលើការបញ្ចាំក្នុងការរក្សាទុកនូវវត្ថុបញ្ចាំ

១-ម្ចាស់សិទ្ធិលើការបញ្ចាំ ត្រូវកាន់កាប់វត្ថុបញ្ចាំនោះដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត ។

២-ប្រសិនបើម្ចាស់សិទ្ធិលើការបញ្ចាំបានធ្វើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ កូនបំណុលអាចទាមទាររំលត់សិទ្ធិលើការបញ្ចាំនោះបាន ។

**មាត្រា ៨២៤.-** សិទ្ធិទាមទារឱ្យសងសោហ៊ុយរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ

១-ប្រសិនបើម្ចាស់សិទ្ធិលើការបញ្ចាំបានចេញចំណាយជាចាំបាច់សម្រាប់ការគ្រប់គ្រង និង ថែរក្សាវត្ថុ ចំពោះវត្ថុបញ្ចាំ ម្ចាស់សិទ្ធិលើការបញ្ចាំនោះ អាចទាមទារឱ្យកម្មសិទ្ធិករនៃវត្ថុនោះសងនូវចំណាយនោះវិញបាន ។

២-ប្រសិនបើម្ចាស់សិទ្ធិលើការបញ្ចាំបានចេញចំណាយបង្កើនតម្លៃនៃវត្ថុបញ្ចាំ ម្ចាស់សិទ្ធិលើការបញ្ចាំនោះអាចទាមទារឱ្យកម្មសិទ្ធិករនៃវត្ថុនោះសងនូវចំណាយទាំងអស់ដែលខ្លួនបានចេញ ឬ សងនូវតម្លៃប្រាក់ដែលកើននោះវិញ តាមការជ្រើសរើសរបស់ខ្លួនបាន ក្នុងករណីដែលកំណើនតម្លៃនោះនៅតែមាន ។ ប៉ុន្តែ តុលាការអាចកំណត់ពេលសមរម្យដើម្បីសង តាមការទាមទាររបស់កម្មសិទ្ធិករបាន ។

**មាត្រា ៨២៥.-** អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

ការប្រើសិទ្ធិលើការបញ្ចាំ មិនរារាំងដំណើរការនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលឡើយ ។

**មាត្រា ៨២៦.-** ការបញ្ចាំបន្ត

១-ម្ចាស់សិទ្ធិលើការបញ្ចាំអាចយកវត្ថុបញ្ចាំនោះទៅដាក់បញ្ចាំបន្តទៀតបាន ដោយទទួលការយល់ព្រមពីអ្នកបង្កើតសិទ្ធិលើការបញ្ចាំនោះ ដើម្បីធានានូវកាតព្វកិច្ចរបស់ខ្លួន ។

២-ក្នុងអំឡុងពេលដែលមានអត្ថិភាពនៃសិទ្ធិលើការបញ្ចាំ ម្ចាស់សិទ្ធិនោះអាចយកវត្ថុបញ្ចាំនោះទៅដាក់បញ្ចាំបន្តទៀត ក្រោមការទទួលខុសត្រូវរបស់ខ្លួនបាន ។ ក្នុងករណី

នេះ ម្ចាស់សិទ្ធិលើការបញ្ចាំនោះក៏ត្រូវទទួលខុសត្រូវ ចំពោះការខូចខាតដោយប្រធានសក្តិ ដែលមិនអាចកើតមានឡើងប្រសិនបើមិនបានដាក់បញ្ចាំបន្តទេ ។

៣-នៅពេលចែកចំណែកថ្លៃលក់ដោយបង្ខំនៃវត្ថុបញ្ចាំ ម្ចាស់សិទ្ធិលើការបញ្ចាំបន្ត អាចទទួលនូវការសងចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលរបស់ខ្លួនទាំងអស់ ដោយមានកម្រិត នៃចំនួនទឹកប្រាក់ដែលត្រូវចែកចំណែកទៅឱ្យម្ចាស់សិទ្ធិលើការបញ្ចាំ ។ ប៉ុន្តែ ប្រសិនបើ សិទ្ធិលើបំណុលរបស់ខ្លួន មិនទាន់ដល់ពេលកំណត់ត្រូវសងទេ ម្ចាស់សិទ្ធិលើការបញ្ចាំបន្ត គ្រាន់តែអាចទាមទារឱ្យតម្កល់នូវចំនួនទឹកប្រាក់ដែលខ្លួនអាចទទួលការសងបានប៉ុណ្ណោះ ។

**មាត្រា ៨២៧.-** ការហាមកិច្ចសន្យាបញ្ចាំផ្តាច់

បើពុំមានបញ្ញត្តិពិសេសនៅក្នុងក្រមនេះ ឬ ច្បាប់ផ្សេងទៀតទេ អ្នកដែលបង្កើត សិទ្ធិលើការបញ្ចាំ មិនអាចព្រមព្រៀង ឱ្យម្ចាស់សិទ្ធិលើការបញ្ចាំទទួលកម្មសិទ្ធិលើវត្ថុបញ្ចាំ ឬ ចាត់ចែងវត្ថុបញ្ចាំ តាមវិធីផ្សេងពីវិធីដែលច្បាប់បានកំណត់ ដោយសកម្មភាពបង្កើត សិទ្ធិលើការបញ្ចាំ ឬ ដោយកិច្ចសន្យាដែលធ្វើមុនកំណត់ពេលត្រូវសងបានទេ ។

**មាត្រា ៨២៨.-** សិទ្ធិទាមទារសំណងរបស់អ្នកធានាដោយវត្ថុ

ប្រសិនបើអ្នកដែលបង្កើតសិទ្ធិលើការបញ្ចាំដើម្បីធានាកាតព្វកិច្ចរបស់អ្នកដទៃ បានសងចំពោះកាតព្វកិច្ចនោះ ឬ បានបាត់បង់នូវកម្មសិទ្ធិលើវត្ថុបញ្ចាំ ដោយសារការ អនុវត្តសិទ្ធិលើការបញ្ចាំនោះ អ្នកនោះត្រូវមានសិទ្ធិទាមទារសំណង ចំពោះកូនបំណុល ដោយយោងទៅតាមបញ្ញត្តិស្តីពីការធានា ។

## ផ្នែកទី ២

## ការបញ្ចាំចលនវត្ថុ

**មាត្រា ៨២៩.-** លក្ខខណ្ឌតតាំងនៃសិទ្ធិលើការបញ្ចាំ

ម្ចាស់សិទ្ធិលើការបញ្ចាំចលនវត្ថុ មិនអាចតតាំងសិទ្ធិលើការបញ្ចាំនោះចំពោះតតិយ-

ផនបានឡើយ ប្រសិនបើខ្លួនមិនបានកាន់កាប់ជានិរន្តរ៍នូវវត្ថុបញ្ចាំនោះ ។

**មាត្រា ៨៣០.-** ករណីដែលការកាន់កាប់ត្រូវបានដកយក

ក្នុងករណីដែលម្ចាស់សិទ្ធិលើការបញ្ចាំចលនវត្ថុត្រូវបានដកយកនូវការកាន់កាប់វត្ថុបញ្ចាំ ម្ចាស់សិទ្ធិលើការបញ្ចាំនោះ អាចយកវត្ថុបញ្ចាំមកវិញបាន តាមរយៈបណ្តឹងទាមទារឱ្យប្រគល់វត្ថុកាន់កាប់មកវិញ តែប៉ុណ្ណោះ ។

**មាត្រា ៨៣១.-** ការប្រើប្រាស់ និង អាស្រ័យផលពីវត្ថុបញ្ចាំ ដោយម្ចាស់សិទ្ធិលើការបញ្ចាំ

១-បើពុំមានការយល់ព្រមពីសំណាក់កូនបំណុលទេ ម្ចាស់សិទ្ធិលើការបញ្ចាំ មិនអាចប្រើប្រាស់ ឬ ជួលវត្ថុបញ្ចាំបានឡើយ ។ ប៉ុន្តែ ម្ចាស់សិទ្ធិលើការបញ្ចាំអាចប្រើប្រាស់បាន ត្រឹមតែកម្រិតដែលចាំបាច់ក្នុងការរក្សាវត្ថុបញ្ចាំនោះ ។

២-បើម្ចាស់សិទ្ធិលើការបញ្ចាំបានប្រព្រឹត្តផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ កូនបំណុលអាចទាមទារឱ្យរំលត់សិទ្ធិលើការបញ្ចាំបាន ។

**មាត្រា ៨៣២.-** ការអនុវត្តសិទ្ធិលើការបញ្ចាំដោយសង្ខេប

១-ប្រសិនបើម្ចាស់សិទ្ធិលើការបញ្ចាំចលនវត្ថុមិនបានទទួលការសងចំពោះសិទ្ធិលើបំណុលរបស់ខ្លួនទេ ម្ចាស់សិទ្ធិនោះអាចទាមទារទៅតុលាការឱ្យយកវត្ថុបញ្ចាំមកសងផ្ទាល់តែម្តង តាមការវាយតម្លៃរបស់អ្នកវាយតម្លៃបាន លុះត្រាតែមានមូលហេតុត្រឹមត្រូវ ។ ក្នុងករណីនេះ ម្ចាស់សិទ្ធិលើការបញ្ចាំត្រូវជូនដំណឹងអំពីការទាមទារនោះទៅកូនបំណុលជាមុន ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើចំនួនទឹកប្រាក់ដែលវាយតម្លៃដោយអ្នកវាយតម្លៃនោះ លើសពីចំនួននៃកាតព្វកិច្ចដែលត្រូវសងម្ចាស់សិទ្ធិលើការបញ្ចាំចលនវត្ថុ ត្រូវសងនូវចំនួនទឹកប្រាក់ដែលនៅសល់ ទៅកម្មសិទ្ធិករនៃវត្ថុបញ្ចាំនោះវិញ ។

**មាត្រា ៨៣៣.-** លំដាប់នៃសិទ្ធិលើការបញ្ចាំចលនវត្ថុ

ក្នុងករណីដែលបានបង្កើតសិទ្ធិលើការបញ្ចាំលើចលនវត្ថុតែមួយ ដើម្បីធានាសិទ្ធិលើបំណុលច្រើន លំដាប់នៃសិទ្ធិលើការបញ្ចាំទាំងនោះត្រូវអនុលោមតាមពេលវេលាដែលបានបង្កើតនោះ ។

## ផ្នែកទី ៣
## ការបញ្ចាំអចលនវត្ថុ

**មាត្រា ៨៣៤.-** សិទ្ធិប្រើប្រាស់ និង អាស្រ័យផលរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ

១-ម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុអាចប្រើប្រាស់ និង អាស្រ័យផលពីអចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ តាមវិធីប្រើប្រាស់នៃអចលនវត្ថុនោះ ។

២-ចំពោះដីដែលសិទ្ធិលើការបញ្ចាំ បានបង្កើតដើម្បីធានាសិទ្ធិលើបំណុលដែលគ្មានពេលកំណត់ ក្នុងករណីដែលម្ចាស់សិទ្ធិលើការបញ្ចាំប្រើដីនោះដើម្បីធ្វើកសិកម្ម ទោះបីជាសិទ្ធិលើបំណុលរលត់ដោយការសងក៏ដោយ បើរដូវប្រមូលផលពីដំណាំដែលម្ចាស់សិទ្ធិបំណុលបានសាប ឬ ដាំពីមុន នឹងដល់ នៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ក៏ម្ចាស់សិទ្ធិលើការបញ្ចាំ អាចប្រើដីនោះ រហូតដល់ពេលដល់រដូវប្រមូលផលនោះ ។

៣-ចំពោះដីដែលសិទ្ធិលើការបញ្ចាំ បានបង្កើតដើម្បីធានាសិទ្ធិលើបំណុលដែលមានពេលកំណត់ ក្នុងករណីដែលម្ចាស់សិទ្ធិលើការបញ្ចាំប្រើដីនោះដើម្បីធ្វើកសិកម្ម ទោះបីជាសិទ្ធិលើបំណុលរលត់ដោយការសងនៅមុនពេលកំណត់ក៏ដោយ បើរដូវប្រមូលផលពីដំណាំដែលម្ចាស់សិទ្ធិបំណុលបានសាប ឬ ដាំពីមុន នឹងដល់ នៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ក៏ម្ចាស់សិទ្ធិលើការបញ្ចាំអាចប្រើដីនោះ រហូតដល់ពេលដល់រដូវប្រមូលផលនោះ ។ ប៉ុន្តែ ទោះបីជារដូវប្រមូលផលនោះ នឹងដល់ នៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំក្រោយការសងនៅមុនពេលកំណត់ក៏ដោយ បើរដូវប្រមូលផលនោះ នឹងដល់ ក្រោយពេលកំណត់នៃការសងកាតព្វកិច្ច ម្ចាស់សិទ្ធិលើការបញ្ចាំ ត្រូវប្រគល់ដីវិញភ្លាម ក្រោយពេលទទួលការសង ។

**មាត្រា ៨៣៥.–** បន្ទុកសោហ៊ុយគ្រប់គ្រង

ម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុត្រូវចេញសោហ៊ុយគ្រប់គ្រង និង ត្រូវទទួលបន្ទុកផ្សេងៗចំពោះអចលនវត្ថុនោះ ។

**មាត្រា ៨៣៦.–** ការប្រាក់នៃសិទ្ធិលើបំណុល

ម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុ មិនអាចទាមទារការប្រាក់នៃសិទ្ធិលើបំណុលរបស់ខ្លួនបានទេ ។

**មាត្រា ៨៣៧.–** អានុភាពនៃការសន្យាពិសេស

បញ្ញត្តិនៃមាត្រា ៨៣៤ (សិទ្ធិប្រើប្រាស់ និង អាស្រ័យផលរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ) មាត្រា ៨៣៥ (បន្ទុកសោហ៊ុយគ្រប់គ្រង) និង មាត្រា ៨៣៦ (ការប្រាក់នៃសិទ្ធិលើបំណុល) ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានការសន្យាពិសេសនៅក្នុងសកម្មភាពបង្កើតសិទ្ធិលើការបញ្ចាំ ។

**មាត្រា ៨៣៨.–** រយៈពេលដែលមានអត្ថិភាព

១-រយៈពេលដែលមានអត្ថិភាពនៃសិទ្ធិលើការបញ្ចាំអចលនវត្ថុ មិនអាចលើសពី ៥ (ប្រាំ) ឆ្នាំបានឡើយ ។ ប្រសិនបើបានបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុលើសពីរយៈពេលនេះ រយៈពេលត្រូវបន្ថយមកត្រឹម ៥ (ប្រាំ) ឆ្នាំ ។

២-កិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុអាចធ្វើបន្តទៀតបាន ។ ប៉ុន្តែរយៈពេលនៃការបន្តនេះមិនអាចធ្វើឱ្យលើសពី ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលបន្តបានឡើយ ។

**មាត្រា ៨៣៩.–** ការអនុវត្តដូចគ្នា តាមបញ្ញត្តិស្តីពីហ៊ីប៉ូតែក

ក្រៅពីបញ្ញត្តិនៃផ្នែកទី ៣ (ការបញ្ចាំអចលនវត្ថុ) នេះ បញ្ញត្តិនៃជំពូកទី ៩ (ហ៊ីប៉ូតែក) ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការបញ្ចាំអចលនវត្ថុ ។

## ផ្នែកទី ៤
## ការបញ្ចាំសិទ្ធិ

**មាត្រា ៨៤០.–** កម្មវត្ថុនៃការបញ្ចាំសិទ្ធិ

១-សិទ្ធិលើការបញ្ចាំអាចមានកម្មវត្ថុជាសិទ្ធិលើទ្រព្យសម្បត្តិបាន ។

២-ក្រៅពីបញ្ញត្តិនៃផ្នែកទី ៤ (ការបញ្ចាំសិទ្ធិ) នេះ បញ្ញត្តិនៃផ្នែកទី ២ (ការបញ្ចាំចលនវត្ថុ) និង ផ្នែកទី ៣ (ការបញ្ចាំអចលនវត្ថុ) ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសិទ្ធិលើការបញ្ចាំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ៨៤១.–** ល័ក្ខខ័ណ្ឌតតាំងនៃសិទ្ធិលើការបញ្ចាំសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ

១-ក្នុងករណីដែលយកសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ មកធ្វើជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ សិទ្ធិលើការបញ្ចាំនេះ មិនអាចតតាំងចំពោះកូនបំណុលទី ៣ និងតតិយជនផ្សេងទៀតបានឡើយ លើកលែងតែករណីដែលបានជូនដំណឹងអំពីការបង្កើតសិទ្ធិលើការបញ្ចាំដល់កូនបំណុលទី ៣ ឬ មានការយល់ព្រមពីកូនបំណុលទី ៣ នោះ ។

២-ការជូនដំណឹង ឬ ការយល់ព្រមដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនអាចតតាំងចំពោះតតិយជន ក្រៅពីកូនបំណុលទី ៣ បានឡើយ ប្រសិនបើមិនបានធ្វើឡើងដោយលិខិតដែលមានកាលបរិច្ឆេទស្ថាពរ ។

**មាត្រា ៨៤២.–** ការអនុវត្តសិទ្ធិលើការបញ្ចាំដោយប្រមូលសិទ្ធិលើបំណុល

១-ម្ចាស់សិទ្ធិលើការបញ្ចាំអាចប្រមូលសិទ្ធិលើបំណុលដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំបាន ។

២-ប្រសិនបើកម្មវត្ថុនៃសិទ្ធិលើបំណុលជាប្រាក់ ម្ចាស់សិទ្ធិលើការបញ្ចាំអាចប្រមូលសិទ្ធិលើបំណុល ត្រឹមតែភាគដែលស្មើនឹងចំនួនប្រាក់នៃសិទ្ធិលើបំណុលរបស់ខ្លួនប៉ុណ្ណោះ ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ បើកំណត់ពេល

ត្រូវសងនៃសិទ្ធិលើបំណុលបានមកដល់ មុនកំណត់ពេលត្រូវសងនៃសិទ្ធិលើបំណុលរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ ម្ចាស់សិទ្ធិលើការបញ្ចាំនេះ អាចឱ្យកូនបំណុលទី ៣ តម្កល់ប្រាក់សងនេះបាន ។ ក្នុងករណីនេះ សិទ្ធិលើការបញ្ចាំមានអត្ថិភាពលើប្រាក់តម្កល់នោះ ។

៤-ប្រសិនបើកម្មវត្ថុនៃសិទ្ធិលើបំណុលមិនមែនជាប្រាក់ទេ ម្ចាស់សិទ្ធិលើការបញ្ចាំមានសិទ្ធិលើការបញ្ចាំលើវត្ថុដែលខ្លួនបានទទួលជាការសង ។

# ជំពូកទី ៥
# ហ៊ីប៉ូតែក

## ផ្នែកទី ១
## អត្ថន័យនៃហ៊ីប៉ូតែក

**មាត្រា ៨៤៣.-** អត្ថន័យនៃហ៊ីប៉ូតែក

១-ម្ចាស់បំណុលហ៊ីប៉ូតែកមានសិទ្ធិទទួលការសងចំពោះសិទ្ធិលើបំណុលរបស់ខ្លួនដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀត ចំពោះអចលនវត្ថុដែលបានដាក់ជាប្រាតិភោគនៃកាតព្វកិច្ច ដោយកូនបំណុល ឬ តតិយជនមិនផ្ទេរការកាន់កាប់ ។

២-សិទ្ធិផ្លូវលអចិន្ត្រៃយ៍ និង ផលុបភោគ ក៏អាចយកមកធ្វើជាកម្មវត្ថុនៃហ៊ីប៉ូតែកបានដែរ ។ ក្នុងករណីនេះ បញ្ញត្តិនៃជំពូកទី ៥ (ហ៊ីប៉ូតែក) នេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ។

៣-ក្នុងករណីដែលច្បាប់ពិសេសទទួលស្គាល់ការយកទ្រព្យសម្បត្តិផ្សេងក្រៅពីអចលនវត្ថុ មកធ្វើជាកម្មវត្ថុនៃហ៊ីប៉ូតែក បញ្ញត្តិនៃច្បាប់ពិសេសនោះត្រូវយកមកអនុវត្ត ។

## ផ្នែកទី ២
## ការបង្កើតហ៊ីប៉ូតែក

**មាត្រា ៨៤៤.-** ការបង្កើតហ៊ីប៉ូតែក

ហ៊ីប៉ូតែកនឹងត្រូវបានបង្កើតឡើង ដោយការព្រមព្រៀងគ្នារវាងម្ចាស់បំណុល និង

# ច្បាប់

# ស្ដីពី

# ការអនុវត្តក្រមរដ្ឋប្បវេណី

# ព្រះរាជក្រម

នស/រកម/០៥១១/០០៧

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរជ្ជបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ដែលរដ្ឋសភា បានអនុម័ត កាលពីថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១១ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១១ នាសម័យប្រជុំពេញអង្គលើកទី៩ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ ៖



ROYAUME DU CAMBODGE

# ជំពូកទី ១
# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.- គោលដៅ**

ច្បាប់នេះ បញ្ញត្តិអំពីកាលបរិច្ឆេទនៃការអនុវត្តក្រមរដ្ឋប្បវេណី ដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧ (តទៅហៅថា "ក្រមរដ្ឋប្បវេណី") ដែលកំណត់ក្នុងកថាខណ្ឌទី ១ មាត្រា ១៣០៥ (កាលបរិច្ឆេទនៃការអនុវត្តជាអាទិ៍) នៃក្រមរដ្ឋប្បវេណី និង អំពីវិធានការអន្តរកាល និង ចំណុចចាំបាច់ផ្សេងទៀតដែលទាក់ទងនឹងការអនុវត្តក្រមរដ្ឋប្បវេណី ដែលកំណត់ក្នុងកថាខណ្ឌទី ២ នៃមាត្រា ១៣០៥ នោះ ។

**មាត្រា ២.- គោលបំណង**

ច្បាប់នេះ មានគោលបំណងធានាស្ថិរភាពនៃទំនាក់ទំនងគតិយុត្តផ្នែករដ្ឋប្បវេណី និង ធានាឲ្យមានការអនុវត្តបានត្រឹមត្រូវនូវបទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណី ។

**មាត្រា ៣.- វិសាលភាព**

ច្បាប់នេះ មានវិសាលភាពអនុវត្តចំពោះបញ្ហាដែលទាក់ទងនឹងការអនុវត្តក្រមរដ្ឋប្បវេណី ។

**មាត្រា ៤.- កាលបរិច្ឆេទនៃការអនុវត្តក្រមរដ្ឋប្បវេណី**

ក្រមរដ្ឋប្បវេណីត្រូវអនុវត្តចាប់ពីកាលបរិច្ឆេទនៃការអនុវត្តច្បាប់នេះ ។

**មាត្រា ៥.- គោលការណ៍នៃការអនុវត្តក្រមរដ្ឋប្បវេណី**

១-ក្រមរដ្ឋប្បវេណី មិនត្រូវអនុវត្តចំពោះបញ្ហាដែលបានកើតឡើងមុនកាលបរិច្ឆេទនៃការអនុវត្ត ដែលកំណត់នៅក្នុងមាត្រា ៤ (កាលបរិច្ឆេទនៃការអនុវត្តក្រមរដ្ឋប្បវេណី) ខាងលើនេះ (តទៅហៅថា "កាលបរិច្ឆេទនៃការអនុវត្ត") ឡើយ លើកលែងតែមានបញ្ញត្តិផ្សេងទៀត។ ប៉ុន្តែទំនាក់ទំនងគតិយុត្តជាបន្តដែលបានកើតឡើង មុនកាលបរិច្ឆេទនៃការអនុវត្ត ហើយនៅតែមានអត្ថិភាពក្រោយកាលបរិច្ឆេទនៃការអនុវត្ត ត្រូវអនុលោមតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី គិតត្រឹមពីកាលបរិច្ឆេទនៃការអនុវត្ត ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

២-អានុភាពដែលបានកើតឡើងដោយបទដ្ឋានគតិយុត្ត ឬ បញ្ញត្តិទំនៀមទម្លាប់នៃកម្ពុជានៅមុនកាលបរិច្ឆេទនៃការអនុវត្តក្រមរដ្ឋប្បវេណី មិនត្រូវបានរារាំងឡើយ ក្រោយកាលបរិច្ឆេទនៃការអនុវត្ត លើកលែងតែមានបញ្ញត្តិផ្សេងទៀតនៅក្នុងជំពូកទី ៥ (អន្តរប្បញ្ញត្តិ) នៃច្បាប់នេះ ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង កថាខណ្ឌទី ២ ខាងលើនេះ មិនត្រូវរារាំងការយកក្រមរដ្ឋប្បវេណីមកអនុវត្តជាគោលការណ៍សមធម៌ ចំពោះបញ្ហាដែលកើតឡើងមុនកាលបរិច្ឆេទនៃការអនុវត្ត ក្នុងករណីពុំមានបទដ្ឋានគតិយុត្ត ឬ បញ្ញត្តិទំនៀមទម្លាប់ ដែលកំណត់អំពីបញ្ហានេះ ឬ ក្នុងករណីមិនដឹងច្បាស់ថាមានបញ្ញត្តិទំនៀមទម្លាប់ ។

## ជំពូកទី ២
## បញ្ញត្តិសារធាតុ

### មាត្រា ៦.- ការដាក់ជូនបញ្ជីសារពើភ័ណ្ឌ ជាអាទិ៍ ទៅតុលាការ

១-តុលាការដែលកំណត់ក្នុងកថាខណ្ឌទី ១ មាត្រា ៧២ (ករណីយកិច្ចធ្វើសេចក្តីរាយការណ៍អំពីការស្រាវជ្រាវទ្រព្យសម្បត្តិនីតិបុគ្គល) នៃក្រមរដ្ឋប្បវេណី គឺជាសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងនៃទីស្នាក់ការកណ្តាលរបស់នីតិបុគ្គល ។

២-តុលាការដែលទទួលការដាក់ជូនបញ្ជីសារពើភ័ណ្ឌជាអាទិ៍ ពីនីតិបុគ្គល អាចស្រាវជ្រាវនីតិបុគ្គលនោះ បង្គាប់ឲ្យនីតិបុគ្គលនោះធ្វើនីតិវិធីដែលកំណត់ក្នុងមាត្រា ៧៨ (ធនក្ស័យនៅក្នុងពេលជម្រះបញ្ជី) នៃក្រមរដ្ឋប្បវេណីភ្លាមៗ និង ធ្វើការចាត់ចែងចាំបាច់ផ្សេងទៀត ដើម្បីធ្វើការជម្រះបញ្ជីឲ្យបានឆាប់រហ័សនិងត្រឹមត្រូវ ។

### មាត្រា ៧.- ការជូនដំណឹងអំពីការបង្ហាញឆន្ទៈទៅអ្នកនៅឆ្ងាយ

១-ការបង្ហាញឆន្ទៈទៅអ្នកនៅឆ្ងាយ អាចបញ្ជាក់បានដោយប្រើ "ការផ្តល់ដំណឹងឆ្លើយតបពីការបានទទួល" នៃលិខិតអនុសិដ្ឋដែលមាន "ការផ្តល់ដំណឹងឆ្លើយតបពីការបានទទួល" និងឯកសារចម្លងនៃលិខិតដែលត្រូវបានចុះនិទ្ទេសដោយក្រឡាបញ្ជីតុលាការ តាមវិធីខាងក្រោម :

ក-អ្នកបង្ហាញឆន្ទៈត្រូវយកមកនូវលិខិតដែលនឹងត្រូវផ្ញើជូនតាមរយៈលិខិតអនុសិដ្ឋ ឯកសារចម្លងនៃលិខិតនេះ និងរូបមន្តនៃ "ការផ្តល់ដំណឹងឆ្លើយតបពីការបានទទួល" ឲ្យក្រឡាបញ្ជីតុលាការ ។

ប្រសិនបើក្រឡាបញ្ជីតុលាការអាចធ្វើឯកសារចម្លងនៃលិខិតនោះដោយខ្លួនឯង ក្រឡាបញ្ជីតុលាការអាចលើកលែងឲ្យអ្នកបង្ហាញឆន្ទៈពីការបង្ហាញឯកសារចម្លងនៃលិខិតនោះបាន ។

ខ-ក្រឡាបញ្ជីតុលាការត្រូវ :

-ពិនិត្យ និង បញ្ជាក់ថា ឯកសារនោះពិតជាឯកសារចម្លងនៃលិខិតដែលនឹងត្រូវផ្ញើជូនតាមរយៈលិខិតអនុសិដ្ឋ ឬ ធ្វើឯកសារចម្លងនៃលិខិតដែលនឹងត្រូវផ្ញើជូនតាមរយៈលិខិតអនុសិដ្ឋនោះ

-ដាក់លិខិតដើមនៅក្នុងស្រោមសំបុត្រ និងបិទស្រោមសំបុត្រនោះ

-ចុះលេខដូចគ្នា និងបោះត្រាផ្លូវការនៅរឹមទំព័រនៃឯកសារចម្លង ស្រោមសំបុត្រ និងរូបមន្តនៃ "ការផ្តល់ដំណឹងឆ្លើយតបពីការបានទទួល"

-ចុះនិទ្ទេសលើឯកសារចម្លងថា បានធ្វើតាមបែបបទខាងលើនេះ

-ប្រគល់ឯកសារទាំងនេះ ទៅអ្នកបង្ហាញឆន្ទៈ។

នៅពេលធ្វើនីតិវិធីខាងលើនេះ ក្រឡាបញ្ជីតុលាការត្រូវសរសេរថ្ងៃ ខែ ឆ្នាំ លេខ និង ឈ្មោះអ្នកបង្ហាញឆន្ទៈនៅក្នុងសៀវភៅ ។

គ-អ្នកបង្ហាញឆន្ទៈត្រូវផ្ញើជូនឯកសារដើមដែលត្រូវបានដាក់ក្នុងស្រោមសំបុត្រ តាមបែបបទខាងលើនេះ តាមលិខិតអនុសិដ្ឋ ។

២-ដើម្បីធ្វើនីតិវិធីដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ អ្នកបង្ហាញឆន្ទៈត្រូវបង់ពន្ធដែលត្រូវបានកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ចំណូលពន្ធនេះ ត្រូវបង្វែរចូលទៅថវិការដ្ឋ ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវរារាំងវិធីបញ្ជាក់ផ្សេងទៀតឡើយ ។

## មាត្រា ៨.- និយមន័យនៃលិខិតដែលមានកាលបរិច្ឆេទស្ថាពរ

"លិខិតដែលមានកាលបរិច្ឆេទស្ថាពរ" ដែលកំណត់ក្នុងកថាខណ្ឌទី៣ នៃមាត្រា ៤៥៩ ( ឧបាទេសកម្មដោយការសង ) កថាខណ្ឌទី ២ នៃមាត្រា ៥០៣ ( លក្ខខណ្ឌតតាំងនៃអនុប្បទានសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ ) កថាខណ្ឌទី ២ នៃមាត្រា ៨៤១ ( លក្ខខណ្ឌតតាំងនៃសិទ្ធិលើការបញ្ចាំសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ ) និង កថាខណ្ឌទី ២ នៃមាត្រា ៥០៣ ( លក្ខខណ្ឌតតាំងនៃអនុប្បទានសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ ) ដែលត្រូវយកមកអនុវត្តដូចគ្នាផងដែរ តាមបញ្ញត្តិនៃកថាខណ្ឌទី ២

នៃមាត្រា ៤៥៩ (ឧបាទេសកម្មដោយការសង) និង មាត្រា ៥១៣ (ការបង្កើតអនុប្បទានហានៈក្នុងកិច្ចសន្យា) នៃក្រមរដ្ឋប្បវេណី សំដៅលើលិខិតខាងក្រោម :

ក-លិខិតយថាភូត ។

ចំពោះលិខិតយថាភូត កាលបរិច្ឆេទនៃការធ្វើលិខិតនោះ ត្រូវក្លាយជាកាលបរិច្ឆេទស្ថាពរ ។

ខ-លិខិតឯកជនដែលសារការី ឬ ក្រឡាបញ្ជីតុលាការចុះនិទ្ទេសអំពីកាលបរិច្ឆេទដែលខ្លួនត្រូវបានបង្ហាញលិខិតឯកជននេះ និង ចុះហត្ថលេខា ។

ក្នុងករណីនេះ កាលបរិច្ឆេទនោះត្រូវក្លាយជាកាលបរិច្ឆេទស្ថាពរ ។

គ-លិខិតឯកជនដែលមានជនណាម្នាក់ក្នុងចំណោមជនដែលបានចុះហត្ថលេខាលើលិខិតនោះ បានទទួលមរណភាព។

ក្នុងករណីនេះ ថ្ងៃដែលជននោះទទួលមរណភាព ត្រូវក្លាយជាកាលបរិច្ឆេទស្ថាពរ។

ឃ-លិខិតឯកជនដែលត្រូវបានយកជាអាគតដ្ឋាន នៅក្នុងលិខិតដែលមានកាលបរិច្ឆេទស្ថាពរ ។

ក្នុងករណីនេះ កាលបរិច្ឆេទនៅក្នុងលិខិតដែលមានកាលបរិច្ឆេទស្ថាពរនោះ ត្រូវក្លាយជាកាលបរិច្ឆេទស្ថាពរសម្រាប់លិខិតឯកជនដែលត្រូវបានយកជាអាគតដ្ឋាននោះ។

**មាត្រា ៩.- អត្ថន័យនៃលិខិតយថាភូត**

"លិខិតយថាភូត" ដែលកំណត់ក្នុងក្រមរដ្ឋប្បវេណី សំដៅទៅលើលិខិតខាងក្រោម :

ក-លិខិតយថាភូតដែលកំណត់ក្នុងមាត្រា៣៣៦ (ការបង្កើតកិច្ចសន្យាដោយសំណើ និងស្នើការ) មាត្រា ៥១៦ (ការបង្កើតកិច្ចសន្យាលក់ទិញ) និង មាត្រា ៨៦២ (អានុភាពនៃការចាត់ចែងហ៊ីប៉ូតែក) នៃក្រមរដ្ឋប្បវេណី សំដៅទៅលើលិខិតដែលត្រូវធ្វើឡើងដោយសារការី ឬ លិខិតឯកជនដែលសារការីចុះនិទ្ទេសថា លិខិតនោះមានភាពត្រឹមត្រូវតាមច្បាប់ និងចុះកាលបរិច្ឆេទ និងហត្ថលេខាក្រោយពេលខ្លួនបញ្ជាក់ថា លិខិតនោះមានភាពត្រឹមត្រូវតាមច្បាប់ ។ ប៉ុន្តែ ចំពោះលិខិតយថាភូតដែលកំណត់ក្នុងមាត្រា ៣៣៦ (ការបង្កើតកិច្ចសន្យាដោយសំណើ និងស្នើការ) និងមាត្រា៨៦២ (អានុភាពនៃការចាត់ចែងហ៊ីប៉ូតែក) នៃក្រមរដ្ឋប្បវេណី លិខិតដែលមន្ត្រីមានសមត្ថកិច្ចធ្វើឡើង ដើម្បីធ្វើនីតិវិធីនៃការចុះបញ្ជីក៏ជាលិខិតយថាភូតដែរ ។

ខ-លិខិតយថាភូតដែលកំណត់ក្នុងមាត្រា ៨៤៥ (ការតាំងនៃហ៊ីប៉ូតែក) នៃក្រមរដ្ឋប្បវេណី សំដៅទៅលើលិខិតដែលមន្ត្រីមានសមត្ថកិច្ចធ្វើឡើងដើម្បីធ្វើនីតិវិធីនៃការចុះបញ្ជី ។

Kol

គ-លិខិតយថាភូតដែលកំណត់ក្នុងមាត្រា ១១៧២ (បុគ្គលដែលមិនអាចក្លាយជាសាក្សី ជាអាទិ៍) មាត្រា ១១៧៣ (មរតកសាសន៍ដោយលិខិតយថាភូត) និង មាត្រា ១១៨១ (បទប្បញ្ញត្តិពិសេសចំពោះមរតកសាសន៍របស់ជនជាតិខ្មែរដែលរស់នៅបរទេស) នៃក្រមរដ្ឋប្បវេណី សំដៅទៅលើលិខិតដែលត្រូវបានធ្វើឡើងដោយសារការី ឬ កុងស៊ុលតាមបញ្ញត្តិនៃមាត្រានីមួយៗ ខាងលើនេះ ។

## មាត្រា ១០.– ការកំណត់មន្ត្រីទទួលបន្ទុកកិច្ចការសារការី

១-រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវកំណត់មន្ត្រីទទួលបន្ទុកកិច្ចការសារការី ដែលត្រូវទទួលបន្ទុកកិច្ចការសារការីជាបណ្តោះអាសន្នតាមតម្រូវការចាំបាច់ នៅក្នុងអំឡុងពេលរហូតដល់មានការកំណត់ផ្សេងនៅក្នុងច្បាប់មិនលើសពី ២ នាក់ នៅក្នុងដែនសមត្ថកិច្ចនៃសាលាដំបូង ក្នុងចំណោមចៅក្រម ព្រះរាជអាជ្ញា ឬ ឥស្សរជនជាមន្ត្រីរាជការសាធារណៈ ដែលមានបទពិសោធន៍ការងារផ្នែកវិស័យច្បាប់ និង មានសញ្ញាបត្រនីតិសាស្ត្រចាប់ពីបរិញ្ញាបត្រឡើងទៅ ។

២-ចៅក្រមដែលត្រូវបានកំណត់ថាជាមន្ត្រីទទួលបន្ទុកកិច្ចការសារការី ត្រូវបានចាត់ទុកថា មានហេតុនៃការដកហូតសមត្ថកិច្ចដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ២៧ (ការដកហូតចៅក្រមពីសមត្ថកិច្ចជំនុំជម្រះ) នៃក្រមនីតិវិធីរដ្ឋប្បវេណី ចំពោះរឿងក្តីដែលខ្លួនបានចាត់ចែងកិច្ចការសារការី ។

៣-ចំពោះសារការី និងមន្ទីរសារការីដែលបានតែងតាំងនិងបង្កើតឡើងមុនច្បាប់នេះ ត្រូវបន្តមានសមត្ថកិច្ចបំពេញកិច្ចការសារការីស្របតាមក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី និង ច្បាប់ជាធរមាន ។

## មាត្រា ១១.– សិទ្ធិអំណាចរបស់មន្ត្រីទទួលបន្ទុកកិច្ចការសារការី ជាអាទិ៍

១-មន្ត្រីទទួលបន្ទុកកិច្ចការសារការី ត្រូវធ្វើកិច្ចការរបស់សារការី ដែលកំណត់ក្នុងក្រមរដ្ឋប្បវេណី និងច្បាប់នេះ ដូចជាការផ្តល់សេចក្តីបញ្ជាក់លើលក្ខន្តិកៈ ការធ្វើលិខិតយថាភូត ជាអាទិ៍ ជាបណ្តោះអាសន្ន ។

២-ដើម្បីធ្វើលិខិតយថាភូតដែលកំណត់ក្នុងមាត្រា ៩ (អត្ថន័យនៃលិខិតយថាភូត) នៃច្បាប់នេះ មន្ត្រីទទួលបន្ទុកកិច្ចការសារការី ត្រូវពិនិត្យ និង បញ្ជាក់អត្តសញ្ញាណរបស់ភាគីដោយសាក្សី ឬ សំបុត្រកំណើត ឬ សំបុត្របញ្ជាក់កំណើត ហើយក្រៅពីនេះត្រូវធ្វើការចាត់ចែងដែលកំណត់ក្នុងប្រកាសរបស់ក្រសួងយុត្តិធម៌ ។

៣-បុគ្គលដែលប្រើប្រាស់សេវារបស់មន្ត្រីទទួលបន្ទុកកិច្ចការសារការីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបង់ពន្ធ ។ ចំណូលពន្ធនេះត្រូវបង្វែរចូលទៅថវិការដ្ឋ ។

៤-ការបង្កើតលិខិតយថាភូត ដែលត្រូវបានធ្វើឡើងដោយមន្ត្រីទទួលបន្ទុកកិច្ចការសារការី ការប្រគល់ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ ដែលមានអានុភាពដូចគ្នានឹងច្បាប់ដើមនៃលិខិតយថាភូត និងចំណុចចាំបាច់ផ្សេងទៀត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

៥-ប្រាក់ពន្ធ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា ១២.- ការប្រកាសជាសាធារណៈ**

១-ការប្រកាសជាសាធារណៈដែលកំណត់ក្នុងកថាខណ្ឌទី ២ មាត្រា ១៩១ (កម្មសិទ្ធិវត្ថុបាត់) នៃក្រមរដ្ឋប្បវេណី ត្រូវធ្វើឡើងដោយប្រធានប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ ដែលកំណត់ក្នុងកថាខណ្ឌដដែលនោះ ដោយវិធីបិទប្រកាសដែលសរសេរអំពីប្រភេទ និង លក្ខណៈនៃវត្ថុរើស ព្រមទាំងកាលបរិច្ឆេទ និង ទីកន្លែងដែលរើសវត្ថុនោះនៅកន្លែងបិទប្រកាសរបស់ប៉ុស្តិ៍នគរបាលនោះ ។

២-ការប្រកាសជាសាធារណៈដែលកំណត់ក្នុងមាត្រា ១២៨១ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿន) កថាខណ្ឌទី ២ នៃមាត្រា ១២៩១ (ការជ្រើសតាំងអ្នកគ្រប់គ្រង) មាត្រា ១២៩៦ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿនចំពោះម្ចាស់បំណុលជាអាទិ៍) ឬ កថាខណ្ឌទី ១ នៃមាត្រា ១២៩៧ (ការជូនដំណឹងជាសាធារណៈ ស្វែងរកសន្តតិជន) នៃក្រមរដ្ឋប្បវេណី ត្រូវធ្វើឡើងដោយបិទប្រកាសរបស់តុលាការ និងការចុះក្នុងព្រឹត្តិបត្ររបស់ក្រសួងយុត្តិធម៌ ។

**មាត្រា ១៣.- សិទ្ធិរបស់កម្មសិទ្ធិករនៃដី**

១-ចំពោះកម្មសិទ្ធិលើដី "ការប្រើប្រាស់ និងការអាស្រ័យផលវត្ថុដែលជាកម្មសិទ្ធិ" ដែលកំណត់ក្នុងមាត្រា ១៣៨ (និយមន័យនៃកម្មសិទ្ធិ) នៃក្រមរដ្ឋប្បវេណី ត្រូវរួមបញ្ចូលការរៀបចំ ឬ ការកែប្រែដោយសេរីនូវប្រភេទ និងរចនាសម្ព័ន្ធដើមនៃដី ស្របតាមការប្រើប្រាស់ដែលកម្មសិទ្ធិករចង់ធ្វើតាមការកំណត់នៃច្បាប់ និង បទដ្ឋានគតិយុត្តផ្សេងទៀត ។

២-ត្រូវចាត់ទុកជាការកែប្រែនូវប្រភេទ ឬ រចនាសម្ព័ន្ធដើមនៃដី ចំពោះការអនុវត្តកថាខណ្ឌទី ១ ខាងលើនេះ មានការគាស់រានដី ការកាប់ព្រៃឈើ ការដាំដំណាំលើដីនោះ ការចាក់បំពេញដី ការឈូសពង្រាបភ្នំ ការជីកយកដីចេញ ការជីកអណ្តូងរ៉ែ ឬ កន្លែងយកថ្ម ការរៀបចំ ឬ ការធ្វើឲ្យស្ងួតដែនវារិជាត ការរៀបចំដីកសិកម្មទៅជាដីប្រជុំជន ការបង្កើតតំបន់ឧស្សាហកម្ម និង ការបង្កើតទីតាំងរោងចក្រ ជាអាទិ៍ ។

ROYAUME DU CAMBODGE

### មាត្រា ១៤.‒ ភោគៈ

១-ចំពោះដីដែលប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ត្រូវបានចេញ ក្រៅពីត្រូវអនុលោមតាមបញ្ញត្តិនៃច្បាប់ភូមិបាលដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ (តទៅហៅថា "ច្បាប់ភូមិបាល ឆ្នាំ ២០០១") និង មាត្រា ២៤២ (ការការពារភោគីអចលនវត្ថុដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់) នៃក្រមរដ្ឋប្បវេណី បញ្ញត្តិនៃក្រមរដ្ឋប្បវេណី ត្រូវយកមកអនុវត្តចំពោះដីនោះ ដោយចាត់ទុកថាភោគៈដែលប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬ ប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីនោះត្រូវបានចេញជាកម្មសិទ្ធិ លើកលែងតែបញ្ញត្តិនោះមានភាពផ្ទុយនឹងលក្ខណៈភោគៈនោះ ។

២-បុគ្គលដែលទទួលការចេញប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬ ប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ឬ អនុប្បទានិករបស់បុគ្គលនោះ អាចបង្កើតសិទ្ធិប្រត្យក្ស ប្រើប្រាស់ និង អាស្រ័យផល ឬ សិទ្ធិប្រាតិភោគប្រត្យក្សបាន ដោយអនុលោមទៅតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ។

### មាត្រា ១៥.‒ ករណីលទ្ធកម្មកម្មសិទ្ធិ

១-ក្នុងករណីដែលបុគ្គលដែលកំណត់ក្នុងកថាខណ្ឌទី ២ នៃមាត្រា ១៤ (ភោគៈ) ខាងលើនេះបានធ្វើលទ្ធកម្មកម្មសិទ្ធិលើដី ដោយយោងតាមបញ្ញត្តិនៃច្បាប់ភូមិបាល ឆ្នាំ ២០០១ សិទ្ធិដែលត្រូវបានបង្កើតលើដីនោះ មុនពេលលទ្ធកម្មនោះ ត្រូវក្លាយទៅជាសិទ្ធិដែលយកកម្មសិទ្ធិលើដីនោះ ឬ ដីដដែលជាកម្មវត្ថុនៃកម្មសិទ្ធិនោះមកធ្វើជាកម្មវត្ថុ ។

២-ក្នុងការអនុវត្តក្រមរដ្ឋប្បវេណី ប្រសិនបើបញ្ហាអំពីអំឡុងពេលកើតឡើង ចំពោះសិទ្ធិដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ អំឡុងពេលត្រូវគណនា ចាប់ពីពេលដែលសិទ្ធិនោះត្រូវបានបង្កើតជាដំបូង ។ ប៉ុន្តែ ចំពោះអាជ្ញាយុកាលនៃលទ្ធកម្មអំឡុងពេលនោះ ត្រូវគណនាចាប់ពីពេលដែលដីដែលនឹងត្រូវបានធ្វើលទ្ធកម្មនោះ បានក្លាយទៅជាកម្មវត្ថុនៃកម្មសិទ្ធិ ។

### មាត្រា ១៦.‒ អន្តរប្បញ្ញត្តិ

បញ្ញត្តិនៃមាត្រា ៣៨ (អានុភាពនៃសិទ្ធិប្រត្យក្សដែលមានអត្ថិភាពតាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត) បញ្ញត្តិចាប់ពីមាត្រា ៤១ (អំឡុងពេលដែលសិទ្ធិជួលរយៈពេលវែងតាំងពីមុនកាលបរិច្ឆេទនៃការអនុវត្តមានអត្ថិភាព) ដល់មាត្រា ៤៣ (អន្តរប្បញ្ញត្តិស្តីពីសិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ ដែលត្រូវ

បានចុះបញ្ជី) និង បញ្ញត្តិចាប់ពីមាត្រា ៥៤ (ការធានាកាតព្វកិច្ច តាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត) ដល់មាត្រា ៥៧ (អំឡុងពេលដែលសិទ្ធិលើការបញ្ចាំអចលនវត្ថុមានអត្ថិភាព) នៃច្បាប់នេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីដែលប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬ ប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ត្រូវបានចេញនៅមុនកាលបរិច្ឆេទនៃការអនុវត្ត ។

**មាត្រា ១៧.- អត្រាការប្រាក់ដែលត្រូវបានកម្រិត ជាអាទិ៍**

១-អត្រាការប្រាក់ដែលត្រូវបានកម្រិត ដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ៥៨៥ (ការកម្រិតការប្រាក់) នៃក្រមរដ្ឋប្បវេណី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រឹមអត្រាចាប់ពី ១០ (ដប់) ភាគរយទៅ ៣០ (សាមសិប) ភាគរយក្នុង ១ (មួយ) ឆ្នាំ ។

២-ចំពោះការព្រមព្រៀងអំពីការកំណត់ជាមុននូវចំនួននៃសំណង ក្នុងករណីមិនអនុវត្តកាតព្វកិច្ចក្នុងកិច្ចសន្យាខ្ចីបរិភោគដែលមានកម្មវត្ថុជាប្រាក់ ប្រសិនបើផលចែកនៃចំនួនប្រាក់សំណងការខូចខាតដែលបានកំណត់មុន នោះជាមួយនឹងប្រាក់ដើម លើសពីអត្រាដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ភាគដែលលើសនោះត្រូវទុកជាមោឃៈ ។

៣-ប្រកាសខាងលើអាចកំណត់អត្រាដែលកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើបាន ត្រឹមទំហំពី ១,២ ទៅ ២ ដង នៃអត្រាការប្រាក់ដែលត្រូវបានកម្រិត ដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ។

៤-កថាខណ្ឌទី ៣ និង កថាខណ្ឌទី ៤ នៃមាត្រា ៥៨៥ (ការកម្រិតការប្រាក់) នៃក្រមរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីកូនបំណុលដែលបានបង់ផ្នែកលើស ដែលកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើ ។

៥-បញ្ញត្តិនៃកថាខណ្ឌទី ២ និង កថាខណ្ឌទី ៤ ខាងលើ ត្រូវអនុវត្តចំពោះប្រាក់ធានាសំណងក្នុងករណីបំពានកិច្ចសន្យា ដោយចាត់ទុកថា ប្រាក់ធានានោះជាការកំណត់ជាមុននូវចំនួននៃសំណងក្នុងកម្រិតនៃការអនុវត្តបញ្ញត្តិនៃកថាខណ្ឌទី ២ និង កថាខណ្ឌទី ៤ ខាងលើនេះ ។

៦-ក្នុងករណីមិនមានការសន្យាពិសេសណាមួយស្តីពីប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច ក្នុងកិច្ចសន្យាខ្ចីបរិភោគដែលមានកម្មវត្ថុជាប្រាក់ដែលភ្ជាប់ជាមួយនឹងការប្រាក់ បញ្ញត្តិនៃមាត្រានេះ និង មាត្រា ៥៨៥ (ការកម្រិតការប្រាក់) នៃក្រមរដ្ឋប្បវេណី ត្រូវអនុវត្តចំពោះប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវ ដោយចាត់ទុកថា ប្រាក់សំណងការខូចខាតចំពោះការយឺត

ROYAUME DU CAMBODGE * LE MINISTÈRE DU PALAIS ROYAL *

យ៉ាវនោះជាការប្រាក់ ក្នុងកម្រិតនៃការអនុវត្តបញ្ញត្តិនៃមាត្រានេះ និង មាត្រា ៥៨៥ ( ការកម្រិតការប្រាក់ ) នៃក្រមរដ្ឋប្បវេណីនោះ ។

## ជំពូកទី ៣
## ការចុះបញ្ជីនីតិបុគ្គល

### មាត្រា ១៨.- សមត្ថកិច្ចលើការចុះបញ្ជីនីតិបុគ្គល

១-កិច្ចការដែលទាក់ទងនឹងការចុះបញ្ជីនីតិបុគ្គល ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួងយុត្តិធម៌ ។

២-រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវចាត់តាំងមន្ត្រីទទួលបន្ទុកកិច្ចការដែលទាក់ទងនឹងការចុះបញ្ជីនីតិបុគ្គល ។ បញ្ជីនីតិបុគ្គល ត្រូវរក្សាទុកនៅក្រសួងយុត្តិធម៌ ។

### មាត្រា ១៩.- បែបបទ និង ទម្រង់នៃការចុះបញ្ជីនីតិបុគ្គល

បែបបទ និង ទម្រង់នៃការចុះបញ្ជីនីតិបុគ្គលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

### មាត្រា ២០.- ពាក្យសុំចុះបញ្ជីនីតិបុគ្គល

១-ពាក្យសុំចុះបញ្ជីត្រូវធ្វើជាលាយលក្ខណ៍អក្សរ ។

២-ចំណុចដែលកំណត់ក្នុងកថាខណ្ឌទី ១ មាត្រា ៥០ ( ចំណុចដែលត្រូវចុះបញ្ជី ) នៃក្រមរដ្ឋប្បវេណី ត្រូវសរសេរចូលទៅក្នុងពាក្យសុំ ហើយអ្នកតំណាងរបស់សាជីវកម្ម ឬ មូលនិធិដែលនឹងត្រូវក្លាយទៅជានីតិបុគ្គលត្រូវចុះបញ្ជី។ ពាក្យសុំ ត្រូវសរសេរចូលផងដែរនូវចំណុចដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ៨៧ ( ចំណុចដែលត្រូវចុះបញ្ជី និង អំឡុងពេលចុះបញ្ជី ) នៃក្រមរដ្ឋប្បវេណី ប្រសិនបើជាសាជីវកម្មទទួលខុសត្រូវមានកម្រិត ឬចំណុចដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ១០២ ( ចំណុចដែលត្រូវចុះបញ្ជី និង អំឡុងពេលចុះបញ្ជី ) នៃក្រមរដ្ឋប្បវេណី ប្រសិនបើជាសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត ឬ ចំណុចដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ១១៥ ( ចំណុចដែលត្រូវចុះបញ្ជី និង អំឡុងពេលចុះបញ្ជី ) នៃក្រមរដ្ឋប្បវេណី ប្រសិនបើជាមូលនិធិ ។

៣-ពាក្យសុំត្រូវភ្ជាប់មកជាមួយនូវលក្ខន្តិកៈ លិខិតអនុញ្ញាតដែលចេញដោយស្ថាប័នដែលមានសមត្ថកិច្ចត្រួតពិនិត្យ ក្នុងករណីជាមូលនិធិ និងឯកសារផ្សេងទៀតដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

**មាត្រា ២១.- ការប្រតិបត្តិការចុះបញ្ជី**

មន្ត្រីដែលកំណត់ក្នុងកថាខណ្ឌទី ២ នៃមាត្រា ១៨ (សមត្ថកិច្ចលើការចុះបញ្ជីនីតិបុគ្គល) នៃច្បាប់នេះ មិនអាចប្រតិបត្តិការចុះបញ្ជីឲ្យនីតិបុគ្គលណាមួយបានទេ ហេតុទាល់តែអាចបញ្ជាក់បានថា ពាក្យសុំនោះត្រឹមត្រូវតាម ក្រមរដ្ឋប្បវេណី និង បទដ្ឋានគតិយុត្តផ្សេងទៀត ។

**មាត្រា ២២.- ការចុះបញ្ជីចំពោះការផ្លាស់ប្តូរ ជាអាទិ៍**

១-ប្រសិនបើមានការផ្លាស់ប្តូរនូវចំណុចដែលបានសរសេរចូលនៅពេលចុះបញ្ជីនីតិបុគ្គល អ្នកតំណាងនីតិបុគ្គលត្រូវដាក់ពាក្យសុំចុះបញ្ជីចំពោះការផ្លាស់ប្តូរនោះ ។

២-ប្រសិនបើនីតិបុគ្គលត្រូវបានរំលាយ អ្នកជម្រះបញ្ជីត្រូវដាក់ពាក្យសុំចុះបញ្ជីដែលកំណត់ក្នុងមាត្រា ៧០ (ការចុះបញ្ជីអំពីអ្នកជម្រះបញ្ជី និងការរំលាយ) និង មាត្រា ៨០ (ការចុះបញ្ជីអំពីការបញ្ចប់ការជម្រះបញ្ជី) នៃក្រមរដ្ឋប្បវេណី ។

៣-ចំណុចដែលត្រូវសរសេរចូលក្នុងពាក្យសុំ និង ឯកសារដែលត្រូវភ្ជាប់ជាមួយនឹងពាក្យសុំសម្រាប់ការដាក់ពាក្យសុំដែលកំណត់ក្នុងកថាខណ្ឌទី ១ និង កថាខណ្ឌទី ២ ខាងលើនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

**មាត្រា ២៣.- ការបញ្ជាក់**

១-បុគ្គលណាក៏ដោយ ក៏អាចសុំឲ្យធ្វើការបញ្ជាក់ ចំពោះចំណុចដែលបានចុះ ឬ មិនបានចុះនៅក្នុងបញ្ជីនីតិបុគ្គលបានដែរ ដោយត្រូវបង់សោហ៊ុយ ។

២-បុគ្គលដែលមានផលប្រយោជន៍អាចទាមទារមើលពាក្យសុំ និងឯកសារភ្ជាប់ជាមួយនឹងពាក្យសុំនោះបាន ដោយត្រូវបង់សោហ៊ុយ ។

**មាត្រា ២៤.- ករណីលើកលែងចំពោះការចុះបញ្ជីទីស្នាក់ការសាខា**

ទោះបីមានបញ្ញត្តិនៃជំពូកទី ២ (នីតិបុគ្គល) ក្នុងគន្ថីទី ២ ស្តីពីបុគ្គលនៃក្រមរដ្ឋប្បវេណីក៏ដោយ ការចុះបញ្ជីដែលត្រូវធ្វើឡើងនៅទីតាំងនៃទីស្នាក់ការកណ្តាលនៃនីតិបុគ្គល ត្រូវធ្វើនៅក្រសួងយុត្តិធម៌ ហើយមិនចាំបាច់ដាក់ពាក្យសុំដើម្បីចុះបញ្ជីនៅទីតាំងនៃទីស្នាក់ការសាខានៃនីតិបុគ្គលទេ ហេតុដល់ពេលមានការកំណត់ផ្សេងដោយច្បាប់ ។

**មាត្រា ២៥.- ការប្រគល់សិទ្ធិឲ្យរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធ្វើប្រកាស**

ទម្រង់នៃពាក្យសុំ និង បញ្ហាផ្សេងទៀតដែលចាំបាច់សម្រាប់ការចុះបញ្ជីនីតិបុគ្គល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

ចំនួនសោហ៊ុយត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី ៤
## ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

**មាត្រា ២៦.- សមត្ថកិច្ចលើការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ**

១-កិច្ចការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ច របស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

២-រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវចាត់តាំងមន្ត្រីទទួលបន្ទុកកិច្ចការដែលទាក់ទងនឹងការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ។ បញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធត្រូវរក្សាទុកនៅក្រសួងយុត្តិធម៌ ។

**មាត្រា ២៧.- បែបបទ និង ទម្រង់នៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ**

បែបបទ និង ទម្រង់នៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

**មាត្រា ២៨.- ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ**

១-ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវធ្វើរួមគ្នា និងជាលាយល័ក្ខណ៍អក្សរដោយប្តីប្រពន្ធ ឬដោយបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ ។

២-ពាក្យសុំត្រូវសរសេរចូលនូវឈ្មោះ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ កាលបរិច្ឆេទចុះកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ខ្លឹមសារនៃកិច្ចសន្យានោះ និង ចំណុចផ្សេងទៀតដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

៣-ពាក្យសុំត្រូវភ្ជាប់មកជាមួយនូវកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធជាលាយល័ក្ខណ៍អក្សរ និងឯកសារផ្សេងទៀតដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

K.L

## មាត្រា ២៩.- ការប្រតិបត្តិការចុះបញ្ជី

មន្ត្រីដែលកំណត់ក្នុងកថាខណ្ឌទី ២ នៃមាត្រា ២៦ (សមត្ថកិច្ចលើការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ) នៃច្បាប់នេះ មិនអាចប្រតិបត្តិការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធបានទេ ហេតុទាល់តែអាចបញ្ជាក់បានថា ពាក្យសុំនោះត្រឹមត្រូវតាមក្រមរដ្ឋប្បវេណី និង បទដ្ឋានគតិយុត្តផ្សេងទៀត ។

## មាត្រា ៣០.- ការចុះបញ្ជីចំពោះការផ្លាស់ប្តូរ ជាអាទិ៍

១-ប្រសិនបើមានការផ្លាស់ប្តូរនូវចំណុចដែលបានចុះក្នុងបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ប្តីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ត្រូវដាក់ពាក្យសុំចុះបញ្ជីចំពោះការផ្លាស់ប្តូរនោះ ។

២-ប្រសិនបើប្តីប្រពន្ធបានរំលាយអាពាហ៍ពិពាហ៍ ឬ ប្រសិនបើបុគ្គលដែលនឹងត្រូវរៀបអាពាហ៍-ពិពាហ៍ជាមួយគ្នាបានរំលាយកំជាប់ពាក្យប្តីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានោះ ត្រូវដាក់ពាក្យលុបចោលការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធជាមួយគ្នា ។

៣-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះក៏ដោយ ជនដែលបានកំណត់ខាងក្រោមនេះ អាចដាក់ពាក្យសុំលុបចោលការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធតែឯកឯងបាន ប្រសិនបើមានហេតុដូចតទៅនេះ :

ក-ប្រសិនបើសហព័ទ្ធណាម្នាក់បានស្លាប់ គឺ សហព័ទ្ធដែលនៅរស់ ។

ខ-ប្រសិនបើមានសេចក្តីសម្រេចអំពីការបែងចែកទ្រព្យសម្បត្តិ ក្នុងសាលក្រម ឬ សាលដី-ការរំលាយអាពាហ៍ពិពាហ៍ដែលបានចូលជាស្ថាពរ គឺ អតីតសហព័ទ្ធណាម្នាក់ ។

គ-ប្រសិនបើតុលាការបានសម្រេចសេចក្តីអំពីការបែងចែកទ្រព្យសម្បត្តិ ដោយការរំលាយអាពាហ៍ពិពាហ៍ដោយផ្អែកលើបញ្ញត្តិនៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ហើយសេចក្តីសម្រេចនោះចូលជាស្ថាពរ គឺ អតីតសហព័ទ្ធណាម្នាក់ ។

ឃ-ប្រសិនបើហេតុការណ៍ដែលរំលាយកំជាប់ពាក្យ ត្រូវបានបញ្ជាក់ដោយជាក់លាក់ នៅក្នុងសាលក្រម ឬ សាលដីកាស្ថាពរ ដែលសម្រេចអំពីការទាមទារដោយផ្អែកលើហេតុការណ៍រំលាយកំ-ជាប់ពាក្យ គឺ ភាគីណាម្នាក់ ។

មានគោលបំណងបម្រើផលប្រយោជន៍សាធារណៈនៅមុនកាលបរិច្ឆេទនៃការអនុវត្ត ត្រូវធ្វើតាមនីតិវិធីដែលកំណត់ចាប់ពីកថាខណ្ឌទី ២ ខាងក្រោមនេះទៅ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសាជីវកម្មដែលមានទ្រព្យសម្បត្តិឯករាជ្យ មានតម្លៃតិចជាង ២០.០០០.០០០ (ម្ភៃលាន) រៀល ហើយដែលត្រូវនឹងនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត ដែលកំណត់ក្នុងមាត្រា ១០១ (ការបង្កើត និង លក្ខន្តិកៈ) នៃក្រមរដ្ឋប្បវេណី ។

២-ក្នុងករណីដែលសាជីវកម្មដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវនឹងនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិតដែលកំណត់ក្នុងមាត្រា ៨២ (ការបង្កើត និង លក្ខន្តិកៈ) នៃក្រមរដ្ឋប្បវេណី អ្នកតំណាងសាជីវកម្មនោះ ត្រូវធ្វើឯកសារដែលបញ្ជាក់អំពីចំណុចនីមួយៗ ដែលកំណត់ក្នុងកថាខណ្ឌទី ២ នៃមាត្រាដដែល និង ចំណុចផ្សេងទៀតដែលបានកំណត់ដោយសមាជិក ហើយចាំបាច់មានការទទួលសេចក្តីបញ្ជាក់ពីសារការីចំពោះឯកសារនេះ ក្នុងអំឡុងពេល ៣ (បី) ខែចាប់ពីកាលបរិច្ឆេទនៃការអនុវត្ត ។

៣-ក្នុងករណីដែលសាជីវកម្មដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវនឹងនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិតដែលកំណត់ក្នុងមាត្រា ១០១ (ការបង្កើត និង លក្ខន្តិកៈ) នៃក្រមរដ្ឋប្បវេណី អ្នកតំណាងសាជីវកម្មនោះ ត្រូវធ្វើឯកសារដែលបញ្ជាក់អំពីចំណុចនីមួយៗ ដែលកំណត់ក្នុងកថាខណ្ឌទី ២ នៃមាត្រាដដែល និង ចំណុចផ្សេងទៀតដែលបានកំណត់ដោយសមាជិក ហើយចាំបាច់មានការទទួលសេចក្តីបញ្ជាក់ពីសារការីចំពោះឯកសារនេះក្នុងអំឡុងពេល ៣ (បី) ខែ ចាប់ពីកាលបរិច្ឆេទនៃការអនុវត្ត ។

៤-ក្នុងករណីដែលមូលនិធិដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវនឹងនីតិបុគ្គលមូលនិធិដែលកំណត់ក្នុងមាត្រា ១១០ (ការបង្កើត និង លក្ខន្តិកៈ) នៃក្រមរដ្ឋប្បវេណី អ្នកតំណាងមូលនិធិនោះ ត្រូវធ្វើឯកសារដែលបញ្ជាក់អំពីចំណុចនីមួយៗ ដែលកំណត់ក្នុងកថាខណ្ឌទី ២ នៃមាត្រាដដែល និង ចំណុចផ្សេងទៀតដែលបានកំណត់ដោយអ្នកដែលបានធ្វើវិភាគទានទ្រព្យសម្បត្តិ និង ត្រូវទទួលសេចក្តីបញ្ជាក់ពីសារការីចំពោះឯកសារនេះ ហើយចាំបាច់ដាក់ជូនឯកសារនោះ ទៅស្ថាប័នដែលមានសមត្ថកិច្ចត្រួតពិនិត្យ និង ទទួលការអនុញ្ញាតពីសំណាក់ស្ថាប័ននោះ ក្នុងអំឡុងពេល ៣ (បី) ខែ ចាប់ពីកាលបរិច្ឆេទនៃការអនុវត្ត ។ ប៉ុន្តែប្រសិនបើឃើញថា ឯកសារនោះ មានភាពផ្ទុយនឹងក្រមរដ្ឋប្បវេណី ឬ បទដ្ឋានគតិយុត្តផ្សេងទៀត ឬ យល់ឃើញថាចាំបាច់សម្រាប់ ផលប្រយោជន៍សាធារណៈនោះ ស្ថាប័នដែលមានសមត្ថកិច្ចត្រួតពិនិត្យ ចាំបាច់ត្រូវបង្គាប់ឲ្យកែប្រែឯកសារនោះ ។

៥-ឯកសារដែលកំណត់ចាប់ពីកថាខណ្ឌទី ២ ដល់កថាខណ្ឌទី ៤ ខាងលើនេះ ត្រូវមានអានុភាពជាលក្ខន្តិកៈ ចាប់ពីពេលទទួលសេចក្តីបញ្ជាក់ពីសារការី ។

៦-សាជីវកម្ម ឬ មូលនិធិដែលត្រូវបានបង្កើតឡើងដោយអនុក្រឹត្យ ឬ ដោយប្រកាស នៅមុនកាលបរិច្ឆេទ នៃការអនុវត្ត ក្នុងទំហំនៃការអនុវត្តចាប់ពីកថាខណ្ឌទី ២ ដល់កថាខណ្ឌទី ៥ ខាងលើនេះ ត្រូវចាត់ទុកថាបានទទួលសេចក្តីបញ្ជាក់ដោយសារការី ឬ ការអនុញ្ញាតដោយស្ថាប័នដែលមានសមត្ថកិច្ចត្រួតពិនិត្យនៅកាលបរិច្ឆេទនៃការអនុវត្ត ។

**មាត្រា ៣៥.- ការចុះបញ្ជីសាជីវកម្ម ឬមូលនិធិដែលមានអត្ថិភាពតាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត ជាអាទិ៍**

១-ក្នុងករណីដែលអ្នកតំណាងសាជីវកម្ម ឬ មូលនិធិដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ៣៤ (ការចាត់ចែងអំពីសាជីវកម្ម ឬ មូលនិធិដែលមានអត្ថិភាពតាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត) ខាងលើនេះ បានទទួលសេចក្តីបញ្ជាក់ពីសារការី ឬ ការអនុញ្ញាតពីសំណាក់ស្ថាប័នដែលមានសមត្ថកិច្ចត្រួតពិនិត្យដោយយោងតាមបញ្ញត្តិ ចាប់ពីកថាខណ្ឌទី ២ ដល់កថាខណ្ឌទី ៤ នៃមាត្រាដដែលនេះ សាជីវកម្ម ឬ មូលនិធិ នោះចាំបាច់ត្រូវចុះបញ្ជីអំពីចំណុចខាងក្រោមនេះ នៅក្រសួងយុត្តិធម៌ ក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ :

ក-ចំណុចដែលកំណត់ក្នុងមាត្រា ៥០ (ចំណុចដែលត្រូវចុះបញ្ជី) នៃក្រមរដ្ឋប្បវេណី ។

ខ-ថ្ងៃ ខែ ឆ្នាំ ទទួលសេចក្តីបញ្ជាក់ពីសារការី ឬ ថ្ងៃ ខែ ឆ្នាំ ដែលបានទទួលការអនុញ្ញាតពីសំណាក់ស្ថាប័នដែលមានសមត្ថកិច្ចត្រួតពិនិត្យ ។

២-អំឡុងពេលដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវគិតចាប់ពីថ្ងៃទទួលលិខិតបញ្ជាក់អំពីសេចក្តីបញ្ជាក់ពីសារការី ឬ ថ្ងៃដែលលិខិតអនុញ្ញាតបានមកដល់ ។

**មាត្រា ៣៦.- បញ្ជីទ្រព្យសម្បត្តិ ឬ បញ្ជីរាយនាមសមាជិក**

ក្នុងករណីដែលសាជីវកម្ម ឬ មូលនិធិដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ៣៤ (ការចាត់ចែងអំពីសាជីវកម្ម ឬ មូលនិធិដែលមានអត្ថិភាពតាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត) នៃច្បាប់នេះ គ្មានបញ្ជីទ្រព្យសម្បត្តិ ឬបញ្ជីរាយនាមសមាជិកទេ សាជីវកម្ម ឬ មូលនិធិនោះ ចាំបាច់ត្រូវធ្វើបញ្ជីនោះដោយគ្មានការយឺតយ៉ាវ នៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត ហើយត្រូវទុកបញ្ជីនោះនៅទីស្នាក់ការនីមួយៗ ។

**មាត្រា ៣៧.- បញ្ញត្តិពិសេសអំពីពេលដែលនីតិបុគ្គលត្រូវបានបង្កើត**

ក្នុងករណីដែលសាជីវកម្ម ឬ មូលនិធិដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ៣៤ (ការចាត់ចែងអំពីសាជីវកម្ម ឬ មូលនិធិដែលមានអត្ថិភាពតាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត) នៃច្បាប់នេះ បានអនុវត្ត

ROYAUME DU CAMBODGE MINISTRE DU PALAIS ROYAL

នីតិវិធីដែលកំណត់ចាប់ពីកថាខណ្ឌទី ២ ដល់កថាខណ្ឌទី ៤ នៃមាត្រាដដែល និង នៅក្នុងមាត្រា ៣៥ (ការចុះបញ្ជីសាជីវកម្ម ឬ មូលនិធិដែលមានអត្ថិភាពតាំងពីមុនកាលបរិច្ឆេទនៃការអនុវត្តជាអាទិ៍) នៃច្បាប់នេះ មុនកាលបរិច្ឆេទដែលកំណត់ក្នុងបញ្ញត្តិទាំងនោះ សាជីវកម្ម ឬ មូលនិធិនោះ ត្រូវបានចាត់ទុកថាមាននីតិបុគ្គលភាពដោយប្រតិសកម្មតាំងពីកាលបរិច្ឆេទនៃការអនុវត្ត ។

### មាត្រា ៣៨.– អានុភាពនៃសិទ្ធិប្រត្យក្សដែលមានអត្ថិភាពតាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត

១-សិទ្ធិប្រត្យក្សដែលកំណត់ក្នុងគន្ថីទី ៣ ស្តីពីសិទ្ធិប្រត្យក្សនៃក្រមរដ្ឋប្បវេណី ទោះបីសិទ្ធិប្រត្យក្សនោះ បានកើតឡើងនៅមុនកាលបរិច្ឆេទនៃការអនុវត្តក៏ដោយ ក៏មានអានុភាពដូចដែលកំណត់ក្នុងក្រមរដ្ឋប្បវេណី គិតចាប់ពីកាលបរិច្ឆេទនៃការអនុវត្តដែរ ។

២-សិទ្ធិជួលរយៈពេលវែង ផលុបភោគ សិទ្ធិប្រើប្រាស់ សិទ្ធិអាស្រ័យនៅ ឬ សេវភាពកើតពីការព្រមព្រៀង ដោយផ្អែកលើច្បាប់ភូមិបាលឆ្នាំ ២០០១ មុនពេលត្រូវបានធ្វើវិសោធនកម្ម ដោយផ្អែកលើបញ្ញត្តិនៃមាត្រា ៨០ (ការធ្វើវិសោធនកម្មលើបញ្ញត្តិមួយចំនួននៃច្បាប់ភូមិបាលឆ្នាំ ២០០១) នៃច្បាប់នេះ ត្រូវចាត់ទុកជាសិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ សិទ្ធិប្រើប្រាស់ សិទ្ធិអាស្រ័យនៅ ឬសេវភាព ដោយផ្អែកលើក្រមរដ្ឋប្បវេណី គិតចាប់ពីកាលបរិច្ឆេទនៃការអនុវត្ត ។ ក្នុងករណីនេះ អំឡុងពេលដែលសិទ្ធិទាំងនោះមានអត្ថិភាព ត្រូវគណនាចាប់ពីថ្ងៃដែលសិទ្ធិនោះត្រូវបានបង្កើតដោយផ្អែកលើច្បាប់ភូមិបាលឆ្នាំ ២០០១ ។

### មាត្រា ៣៩.– ការកាន់កាប់ចលនវត្ថុតាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត

១-ប្រសិនបើជនដែលកាន់កាប់ចលនវត្ថុ តាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត បំពេញលក្ខខណ្ឌដែលកំណត់ក្នុងមាត្រា ១៩៣ (លទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុ) នៃក្រមរដ្ឋប្បវេណី ជននោះត្រូវទទួលសិទ្ធិ ដែលអាចអនុវត្តលើចលនវត្ថុនោះនៅកាលបរិច្ឆេទនៃការអនុវត្ត។ ក្នុងករណីនេះ បញ្ញត្តិនៃក្រមរដ្ឋប្បវេណី ត្រូវយកមកអនុវត្តចំពោះអានុភាពនៃកិច្ចសន្យាធ្វើអនុប្បទានកម្មសិទ្ធិ ត្រឹមកម្រិតនៃការអនុវត្តមាត្រា ១៩៣ (លទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុ) នៃក្រមរដ្ឋប្បវេណីតែប៉ុណ្ណោះ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវរារាំងក្នុងការអនុវត្តបញ្ញត្តិនៃមាត្រា១៩៤ (អនុប្បទាននូវវត្ថុ លួច ឬវត្ថុបាត់) នៃក្រមរដ្ឋប្បវេណី ។

**មាត្រា ៤០.- ឧបាគមន៍តាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត**

១-ជនដែលស្ថិតនៅក្នុងស្ថានភាពដែលអាចធ្វើលទ្ធកម្មលើកម្មសិទ្ធិ បើយោងតាមបញ្ញត្តិនៃមាត្រា ១៩៨ (ការជាប់គ្នា ការលាយច្របល់គ្នានៃចលនវត្ថុ) ឬ មាត្រា ១៩៩ (ការកែច្នៃចលនវត្ថុ) នៃក្រមរដ្ឋប្បវេណី តាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត ត្រូវចាត់ទុកជាម្ចាស់កម្មសិទ្ធិឯកត្តជន ឬ ម្ចាស់នៃកម្មសិទ្ធិអវិភាគ ដោយយោងតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី គិតចាប់ពីកាលបរិច្ឆេទនៃការអនុវត្ត ។ ប៉ុន្តែ បញ្ញត្តិនេះ មិនរារាំងសិទ្ធិដែលតតិយជនបានធ្វើលទ្ធកម្មដោយត្រឹមត្រូវឡើយ ។

២-ជនដែលបាត់បង់សិទ្ធិ ដោយសារអនុវត្តតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ អាចទាមទារប្រាក់សំណង ដោយយោងតាមបញ្ញត្តិនៃមាត្រា ២០១ (ឧបាគមន៍ និង សិទ្ធិទាមទារប្រាក់សំណង) នៃក្រមរដ្ឋប្បវេណី ។

**មាត្រា ៤១.- អំឡុងពេលដែលសិទ្ធិជួលរយៈពេលវែងតាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត មានអត្ថិភាព**

ចំពោះពោះសិទ្ធិជួលចំរយៈពេលវែងដែលត្រូវបានបង្កើតឡើងតាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត ដោយផ្អែកលើច្បាប់ភូមិបាលឆ្នាំ ២០០១ ហើយដែលអំឡុងពេលនៅសល់មានលើសពី ៥០ (ហាសិប) ឆ្នាំ នៅកាលបរិច្ឆេទនៃការអនុវត្ត ទោះបីមានបញ្ញត្តិនៃមាត្រា ២៤៧ (អំឡុងពេលដែលសិទ្ធិជួលអចិន្ត្រៃយ៍មានអត្ថិភាព) នៃក្រមរដ្ឋប្បវេណីក៏ដោយ ក៏សិទ្ធិនោះត្រូវមានអត្ថិភាពក្នុងអំឡុងពេលដែលបានកំណត់ដោយការព្រមព្រៀងដែរ។ ប៉ុន្តែ ចំពោះសិទ្ធិជួលរយៈពេលវែងដែលអំឡុងពេលនៅសល់ មានលើសពី ៩៩ (កៅសិបប្រាំបួន) ឆ្នាំ វិញ អំឡុងពេលដែលសិទ្ធិនោះមានអត្ថិភាព ត្រូវកំណត់ជា ៩៩ (កៅសិបប្រាំបួន) ឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃការអនុវត្ត ។

**មាត្រា ៤២.- ផលុបភោគដែលត្រូវបានដាក់ធានារ៉ាប់រង**

ចំពោះផលុបភោគដែលត្រូវបានបង្កើតឡើង នៅមុនកាលបរិច្ឆេទនៃការអនុវត្តដោយផ្អែកលើច្បាប់ភូមិបាលឆ្នាំ ២០០១ ហើយវត្ថុដែលជាកម្មវត្ថុនៃផលុបភោគនោះបានដាក់ធានារ៉ាប់រង ក្នុងករណីដែលកម្មវត្ថុនោះត្រូវវិនាស ដោយករណីប្រធានសក្តិ ក្នុងអំឡុងពេលនៃការធានារ៉ាប់រងដោយបុព្វលាភ ធានារ៉ាប់រងដែលបានបង់នៅមុនកាលបរិច្ឆេទនៃការអនុវត្ត ហើយបើកម្មសិទ្ធិករ ឬ ផលុបភោគីបានទទួលថ្លៃ

ព្រះបរមរាជវាំង

ជានាក់ប់រង នោះភាគីម្ខាងទៀតអាចទាមទារ ឲ្យជួសជុល ឬសាងសង់ឡើងវិញនូវវត្ថុដែលជាកម្មវត្ថុនោះ ដោយយកថ្លៃជានាក់ប់រងនោះបាន ទោះបីនៅក្រោយកាលបរិច្ឆេទនៃការអនុវត្តក៏ដោយ ។

## មាត្រា ៤៣.- អន្តរប្បញ្ញត្តិស្តីពីសិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ ដែលត្រូវបាន ចុះបញ្ជី

ប្រសិនបើសិទ្ធិប្រើប្រាស់ ឬសិទ្ធិអាស្រ័យនៅ ដែលត្រូវបានបង្កើតដោយផ្អែកលើច្បាប់ភូមិបាលឆ្នាំ ២០០១ ត្រូវបានចុះបញ្ជី ដោយផ្អែកលើបញ្ញត្តិនៃកថាខណ្ឌទី ៣ មាត្រា ១២០ នៃច្បាប់ភូមិបាលឆ្នាំ ២០០១ ដែលត្រូវយកមកអនុវត្ត ដោយយោងតាមបញ្ញត្តិនៃមាត្រា ១៣៩ នៃច្បាប់ដដែល ទោះបីមានបញ្ញត្តិនៃមាត្រា ២៧៧ (លក្ខខណ្ឌតតាំងនៃសិទ្ធិប្រើប្រាស់ និងសិទ្ធិអាស្រ័យនៅ) នៃក្រមរដ្ឋប្បវេណីក៏ដោយ ហើយទោះបីមិនប្រើប្រាស់ ឬអាស្រ័យនៅជាក់ស្តែងក៏ដោយ ក៏សិទ្ធិនោះអាចតតាំងចំពោះតតិយជនបានដែរ ។

## មាត្រា ៤៤.- អន្តរប្បញ្ញត្តិស្តីពីការប្រាក់សមាស

១-បញ្ញត្តិនៃមាត្រា ៣១៩ (ការប្រាក់សមាស) នៃក្រមរដ្ឋប្បវេណី មិនត្រូវយកមកអនុវត្តឡើយ ចំពោះការប្រាក់ដែលបានកើតឡើងមុនកាលបរិច្ឆេទនៃការអនុវត្ត ។

២-ចំពោះការអនុវត្តកថាខណ្ឌទី ២ នៃមាត្រា ៥៨៦ (ពេលវេលានៃការបង់ការប្រាក់ និងការប្រាក់សមាសដែលកំណត់ដោយច្បាប់) នៃក្រមរដ្ឋប្បវេណី ត្រូវអនុលោមតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ។

## មាត្រា ៤៥.- អន្តរប្បញ្ញត្តិស្តីពីការមិនអនុវត្តកាតព្វកិច្ច

១-ប្រសិនបើបុគ្គលដែលបានទទួលបន្ទុកកាតព្វកិច្ចតាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត មិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន នៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត បុគ្គលនោះត្រូវទទួលខុសត្រូវចំពោះការមិនអនុវត្តកាតព្វកិច្ចនោះ ដោយយោងតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ក្នុងករណីដែលម្ចាស់បំណុលប្រកែកមិនទទួលនូវការអនុវត្តកាតព្វកិច្ច ឬមិនអាចទទួលការអនុវត្តកាតព្វកិច្ចបាន ។

៣-ក្នុងករណីដែលកាតព្វកិច្ចនៃកិច្ចសន្យាដែលបានធ្វើឡើងនៅមុនកាលបរិច្ឆេទនៃការអនុវត្ត ត្រូវបានអនុវត្តនៅក្រោយកាលបរិច្ឆេទនៃការអនុវត្តបញ្ញត្តិស្តីពីការទទួលខុសត្រូវក្នុងការធានា នៅក្នុងក្រមរដ្ឋប្បវេណី ត្រូវយកមកអនុវត្តចំពោះការអនុវត្តកាតព្វកិច្ចនោះ ។

**មាត្រា ៤៦.- អន្តរប្បញ្ញត្តិស្តីពីបញ្ញត្តិពិសេសអំពីកាតព្វកិច្ចជាប្រាក់**

ក្នុងករណីដែលបុគ្គលទទួលបន្ទុកកាតព្វកិច្ចដែលមានគោលបំណងឲ្យសងជាប្រាក់ មិនបានអនុវត្តកាតព្វកិច្ចនោះ តាំងពីមុនកាលបរិច្ឆេទនៃការអនុវត្តទេ បញ្ញត្តិនៃមាត្រា ៣៩៩ (បញ្ញត្តិពិសេសអំពីកាតព្វកិច្ចជាប្រាក់) នៃក្រមរដ្ឋប្បវេណី ត្រូវយកមកអនុវត្ត ចំពោះចំនួនទឹកប្រាក់ដែលជាសំណងនៃការខូចខាតដែលកើតឡើងនៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត ។

**មាត្រា ៤៧.- អន្តរប្បញ្ញត្តិស្តីពីការទូទាត់**

១-ទោះបីកាតព្វកិច្ចបានកើតឡើងមុនកាលបរិច្ឆេទនៃការអនុវត្តក៏ដោយ ក៏អាចរួចផុតពីកាតព្វកិច្ចនោះដោយការទូទាត់ ដោយយោងតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណីបានដែរ ។

២-ក្នុងករណីដែលកាតព្វកិច្ចទាំងសងខាងស្របនឹងលក្ខខណ្ឌទូទាត់ទៅវិញទៅមកតាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត អានុភាពនៃការរលត់កាតព្វកិច្ចដោយការទូទាត់ ត្រូវកើតឡើងដោយប្រតិសកម្មមកដល់ត្រឹមកាលបរិច្ឆេទនៃការអនុវត្ត ។

**មាត្រា ៤៨.- អន្តរប្បញ្ញត្តិស្តីពីអាជ្ញាយុកាលនៃការរលត់សិទ្ធិ**

១-បញ្ញត្តិស្តីពីអាជ្ញាយុកាលនៃការរលត់សិទ្ធិនៅក្នុងក្រមរដ្ឋប្បវេណី ត្រូវយកមកអនុវត្តចំពោះសិទ្ធិលើបំណុលដែលមិនទាន់រលត់ដោយអាជ្ញាយុកាល មុនកាលបរិច្ឆេទនៃការអនុវត្ត ។

២-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើក៏ដោយ ប្រសិនបើអំឡុងពេលអាជ្ញាយុកាលនៃការរលត់សិទ្ធិដែលបានចាប់ផ្តើមគិតមុនកាលបរិច្ឆេទនៃការអនុវត្តវែងជាងអំឡុងពេលអាជ្ញាយុកាលនៃការរលត់សិទ្ធិលើបំណុល ដែលកំណត់ក្នុងក្រមរដ្ឋប្បវេណី សិទ្ធិលើបំណុលនោះ មិនត្រូវផុតអាជ្ញាយុកាលនៃការរលត់សិទ្ធិ រហូតដល់ពេលផុតអំឡុងពេលអាជ្ញាយុកាលនៃការរលត់សិទ្ធិដែលបានកំណត់ដោយច្បាប់ ឬបទដ្ឋានគតិយុត្តកន្លងមក ។ ប៉ុន្តែ ក្នុងករណីដែលអំឡុងពេលអាជ្ញាយុកាលដែលនៅសល់នោះវែងជាងអាជ្ញាយុកាលនៃការរលត់សិទ្ធិលើបំណុលដែលកំណត់ក្នុងក្រមរដ្ឋប្បវេណី ដោយគណនាចាប់ពីកាលបរិច្ឆេទនៃការអនុវត្ត នោះបញ្ញត្តិនៃក្រមរដ្ឋប្បវេណី ត្រូវយកមកអនុវត្ត ដោយគណនាចាប់ពីកាលបរិច្ឆេទនៃការអនុវត្តនោះទៅ ។

ROYAUME DU CAMBODGE · LE MINISTRE du PALAIS ROYAL

៣-ចំពោះសិទ្ធិដែលគ្មានកំណត់អំឡុងពេលអាជ្ញាយុកាលនៃការរំលត់សិទ្ធិ បញ្ញត្តិស្តីពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនៅក្នុងក្រមរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដោយគណនាពីកាលបរិច្ឆេទនៃការអនុវត្ត ។

## មាត្រា ៤៩.- ពេលចាប់ផ្តើមការអនុវត្តបញ្ញត្តិស្តីពីការផ្អាកអាជ្ញាយុកាល និង ការបង្អង់ការសម្រេចអាជ្ញាយុកាល

ក្នុងករណីដែលបញ្ញត្តិនៃមាត្រា ៤៨ (អន្តរប្បញ្ញត្តិស្តីពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិ) ខាងលើនេះ ត្រូវយកមកអនុវត្តបញ្ញត្តិស្តីពីការផ្អាកអាជ្ញាយុកាល និងការបង្អង់ការសម្រេចអាជ្ញាយុកាល នៅក្នុងក្រមរដ្ឋប្បវេណី ត្រូវយកមកអនុវត្តចាប់ពីកាលបរិច្ឆេទនៃការអនុវត្ត ។

## មាត្រា ៥០.- ការអនុវត្តដូចគ្នាចំពោះអំឡុងពេលដែលច្បាប់បានកំណត់

បញ្ញត្តិនៃមាត្រា ៤៨ (អន្តរប្បញ្ញត្តិស្តីពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិ) និង មាត្រា ៤៩ (ពេលចាប់ផ្តើមការអនុវត្តបញ្ញត្តិស្តីពីការផ្អាកអាជ្ញាយុកាល និង ការបង្អង់ការសម្រេចអាជ្ញាយុកាល) ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអំឡុងពេលដែលច្បាប់បានកំណត់ដែលគ្មានលក្ខណៈជាអំឡុងពេលនៃអាជ្ញាយុកាល ។

## មាត្រា ៥១.- អន្តរប្បញ្ញត្តិស្តីពីកិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ការប្រាក់

ក្នុងករណីដែលអ្នកខ្ចីនៃកិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ការប្រាក់ដែលត្រូវបានបង្កើតឡើង នៅមុនកាលបរិច្ឆេទនៃការអនុវត្ត បានទទួលមរណភាព នៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត បញ្ញត្តិនៃវាក្យខណ្ឌទី២ នៃមាត្រា ៦១ នៃក្រឹត្យ-ច្បាប់ លេខ៣៨ ក្រ.ច ចុះនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៨៨ ស្តីពីកិច្ចសន្យា និង ការទទួលខុសត្រូវក្រៅកិច្ចសន្យា (តទៅហៅថា "ក្រឹត្យ-ច្បាប់ លេខ៣៨ ក្រ.ច") មិនត្រូវយកមកអនុវត្តឡើយ ។

## មាត្រា ៥២.- អន្តរប្បញ្ញត្តិក្នុងករណីដែលវត្ថុជួលមានវិការៈ

១-ក្នុងករណីដែលកតិសន្យាដែលបានធ្វើឡើងមុនកាលបរិច្ឆេទនៃការអនុវត្ត នៅតែមានអត្ថិភាពក្រោយកាលបរិច្ឆេទនៃការអនុវត្តនេះ បញ្ញត្តិនៃមាត្រា ៦០៥ (ការទទួលខុសត្រូវរបស់កតិបតីចំពោះវិការៈនៃវត្ថុជួល) នៃក្រមរដ្ឋប្បវេណី ត្រូវយកមកអនុវត្តចំពោះកតិសន្យានោះ ។ ក្នុងករណីនេះ ប្រសិនបើអំឡុងពេលដែលកំណត់ក្នុង កថាខណ្ឌទី ៦ នៃមាត្រា ៦០៥ (ការទទួលខុសត្រូវរបស់កតិបតីចំពោះវិការៈនៃវត្ថុ

ROYAUME DU CAMBODGE * SECRETARIAT ROYAL * LE MINISTRE DU PALAIS

ជួល) នៃក្រមរដ្ឋប្បវេណី បានចាប់ផ្តើមមានដំណើរការមុនកាលបរិច្ឆេទនៃការអនុវត្ត អំឡុងពេលនោះ គឺ ១ (មួយ) ឆ្នាំ ដោយគណនាចាប់ពីកាលបរិច្ឆេទនៃការអនុវត្ត ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលអំឡុងពេល ១ (មួយ) ឆ្នាំ ដែលកំណត់ក្នុងកថាខណ្ឌទី៦ នៃមាត្រា៦០៥ (ការទទួលខុសត្រូវរបស់កតិបតីចំពោះវិការៈនៃវត្ថុជួល) នៃក្រមរដ្ឋប្បវេណីបានកន្លងផុត ១ (មួយ) ឆ្នាំ មុនកាលបរិច្ឆេទនៃការអនុវត្ត ។

### មាត្រា ៥៣.- អន្តរប្បញ្ញត្តិស្តីពីសេចក្តីចម្រើនដោយឥតហេតុ

បញ្ញត្តិនៃមាត្រា ៧៤១ (ការផ្តល់តាវកាលិកដោយមូលហេតុខុសច្បាប់) នៃក្រមរដ្ឋប្បវេណី ត្រូវយកមកអនុវត្តផងដែរ ចំពោះសេចក្តីចម្រើនដោយឥតហេតុដែលបានកើតឡើង មុនកាលបរិច្ឆេទនៃការអនុវត្ត ។

### មាត្រា ៥៤.- ការធានាភាពឥតប្រតិបត្តិកាតព្វកិច្ចតាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត

១-ទោះបីជាសិទ្ធិប្រាតិភោគប្រត្យក្សដែលកំណត់ក្នុងក្រមរដ្ឋប្បវេណី បានកើតឡើងនៅមុនកាលបរិច្ឆេទនៃការអនុវត្តក៏ដោយ ក៏សិទ្ធិប្រាតិភោគប្រត្យក្សនោះ មានអានុភាពដូចដែលកំណត់ក្នុងក្រមរដ្ឋប្បវេណីដែរ នៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត ។

២-សិទ្ធិលើការបញ្ចាំ ឬ ហ៊ីប៉ូតែក ដោយផ្អែកលើច្បាប់ភូមិបាលឆ្នាំ ២០០១ ត្រូវចាត់ទុកថាជាសិទ្ធិលើការបញ្ចាំ ឬហ៊ីប៉ូតែក ដោយផ្អែកលើក្រមរដ្ឋប្បវេណី នៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត ។

៣-ការបញ្ចាំសិទ្ធិដែលត្រូវបានបង្កើតឡើង នៅមុនកាលបរិច្ឆេទនៃការអនុវត្ត ហើយដែលអាចតតាំងចំពោះកូនបំណុលទី៣ ឬតតិយជនផ្សេងទៀត តាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត ក៏អាចតតាំងចំពោះកូនបំណុលទី ៣ ឬតតិយជនផ្សេងទៀតក្រោយកាលបរិច្ឆេទនៃការអនុវត្តបានដែរ ។

៤-ការបញ្ចាំចលនវត្ថុ ដោយផ្អែកលើក្រឹត្យ-ច្បាប់ លេខ៣៨ ក្រ.ច ត្រូវចាត់ទុកថាជាសិទ្ធិលើការបញ្ចាំ ដោយផ្អែកលើក្រមរដ្ឋប្បវេណី នៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត ។

### មាត្រា ៥៥.- ការចាត់ចែងអំពីការដាក់ធានា

១-ការដាក់ធានា ដោយផ្អែកលើច្បាប់ភូមិបាលឆ្នាំ ២០០១ ត្រូវចាត់ទុកជាហ៊ីប៉ូតែក ដោយផ្អែកលើក្រមរដ្ឋប្បវេណី ក្រោយកាលបរិច្ឆេទនៃការអនុវត្ត ។

២-ការចុះបញ្ជីអំពីការដាក់ធានា ត្រូវចាត់ទុកជាការចុះបញ្ជីហ៊ីប៉ូតែកដែលត្រូវបានចាត់ទុកដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនរាំងភាគីក្នុងការចុះបញ្ជីហ៊ីប៉ូតែក

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS

ដោយលុបចោលការចុះបញ្ជីអំពីការដាក់ធានា ។

៣-ម្ចាស់សិទ្ធិលើការដាក់ធានា ត្រូវប្រគល់នូវប័ណ្ណកម្មសិទ្ធិទៅអ្នកបង្កើតវិញភ្លាមក្រោយកាលបរិច្ឆេទនៃការអនុវត្ត។

## មាត្រា ៥៦.– ការចាត់ចែងអំពីកិច្ចសន្យាបង្កើតសិទ្ធិប្រាតិភោគប្រត្យក្សដែលមិនទាន់ចុះបញ្ជី

១-ក្នុងករណីធ្វើកិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំ ដោយលិខិតយថាភូតដែលបានកំណត់នៅក្នុងមាត្រា ២០៧ នៃច្បាប់ភូមិបាលឆ្នាំ ២០០១ ហើយវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំនោះ ត្រូវបានប្រគល់រួច តែមិនទាន់ចុះបញ្ជីនៅមុនកាលបរិច្ឆេទនៃការអនុវត្តទេ អានុភាពនៃសិទ្ធិលើការបញ្ចាំនោះ ត្រូវកើតឡើងតាំងពីកាលបរិច្ឆេទនៃការអនុវត្ត ។

២-ក្នុងករណីធ្វើកិច្ចសន្យាបង្កើតហ៊ីប៉ូតែក ដោយលិខិតយថាភូតដែលបានកំណត់នៅក្នុងមាត្រា ២០១ នៃ ច្បាប់ភូមិបាលឆ្នាំ ២០០១ តែមិនទាន់ចុះបញ្ជីនៅមុនកាលបរិច្ឆេទនៃការអនុវត្តទេ អានុភាពនៃហ៊ីប៉ូតែកនោះ ត្រូវកើតឡើងតាំងពីកាលបរិច្ឆេទនៃការអនុវត្ត ។

៣-ក្នុងករណីធ្វើកិច្ចសន្យាបង្កើតសិទ្ធិលើការដាក់ធានា ដោយលិខិតយថាភូតដែលកំណត់ក្នុងមាត្រា ២២០ នៃច្បាប់ភូមិបាលឆ្នាំ ២០០១ តែមិនទាន់ចុះបញ្ជី នៅមុនកាលបរិច្ឆេទនៃការអនុវត្តទេ ត្រូវចាត់ទុកថាធ្វើកិច្ចសន្យា បង្កើតហ៊ីប៉ូតែក នៅកាលបរិច្ឆេទនៃការអនុវត្ត ។

៤-ប្រសិនបើហ៊ីប៉ូតែកដែលកំណត់ក្នុងកថាខណ្ឌទី ៣ ខាងលើនេះត្រូវបានចុះបញ្ជី ម្ចាស់បំណុលហ៊ីប៉ូតែកត្រូវប្រគល់ប័ណ្ណកម្មសិទ្ធិទៅអ្នកបង្កើតវិញ ។

## មាត្រា ៥៧.– អំឡុងពេលដែលសិទ្ធិលើការបញ្ចាំអចលនវត្ថុ មានអត្ថិភាព

ចំពោះការបញ្ចាំអចលនវត្ថុដែលត្រូវបានបង្កើតឡើង នៅមុនកាលបរិច្ឆេទនៃការអនុវត្ត ហើយដែលអំឡុងពេលនៅសល់ ដែលសិទ្ធិលើការបញ្ចាំនោះមានអត្ថិភាព មានលើសពី ៥ (ប្រាំ) ឆ្នាំ នៅកាលបរិច្ឆេទនៃការអនុវត្ត នោះអំឡុងពេលដែលសិទ្ធិនោះមានអត្ថិភាព ត្រូវកំណត់ជា ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការអនុវត្ត ។

**មាត្រា ៥៨.- ការកំណត់ការធានាបំណុលអណ្តែតសាកល**

ក្នុងករណីធ្វើកិច្ចសន្យាធានាបំណុលអណ្តែត ដោយមិនកំណត់ទំនាក់ទំនងគតិយុត្តជានិរន្តរ៍ ដែលជាមូលដ្ឋាននៃការកើតកាតព្វកិច្ចចម្បង នៅមុនកាលបរិច្ឆេទនៃការអនុវត្ត ប្រាក់ដើមនៃសិទ្ធិលើបំណុលដែលត្រូវបានធានា ដោយកិច្ចសន្យាធានាបំណុលអណ្តែតនោះ ត្រូវកំណត់ជាស្ថាពរនៅកាលបរិច្ឆេទនៃការអនុវត្ត ។

**មាត្រា ៥៩.- ការបាត់ខ្លួនរបស់សហព័ទ្ធ**

ក្នុងករណីមានពាក្យសុំឲ្យប្រកាសអំពីការបាត់ខ្លួនរបស់សហព័ទ្ធ ដែលបានធ្វើឡើងដោយផ្អែកលើបញ្ញត្តិនៃ មាត្រា១០ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារដែលត្រូវបានប្រកាសឲ្យប្រើដោយក្រឹត្យលេខ ៥៦ ក្រ. ចុះនៅ ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៨៩ (តទៅហៅថា "ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ") នៅមុនកាលបរិច្ឆេទនៃការអនុវត្តការប្រកាសអំពីការបាត់ខ្លួននោះ ត្រូវអនុលោមទៅតាមកិច្ចការដែលបានធ្វើពីមុនមក។

**មាត្រា ៦០.- អន្តរប្បញ្ញត្តិស្តីពីការប្រកាសផ្សាយជាសាធារណៈអំពីអាពាហ៍ពិពាហ៍**

ការប្រកាសផ្សាយជាសាធារណៈ ដែលបានធ្វើឡើងដោយផ្អែកលើបញ្ញត្តិចាប់ពីមាត្រា ១១ ដល់មាត្រា ១៣ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ នៅមុនកាលបរិច្ឆេទនៃការអនុវត្ត ត្រូវចាត់ទុកថាជាការជូនដំណឹងជាសាធារណៈដែលកំណត់ក្នុងមាត្រា ៩៥៥ (ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ និងការចុះបញ្ជីអាពាហ៍ពិពាហ៍) នៃក្រមរដ្ឋប្បវេណី ។

**មាត្រា ៦១.- អន្តរប្បញ្ញត្តិស្តីពីការប្តឹងជំទាស់ និង ការប្តឹងទាស់មិនឲ្យរៀបអាពាហ៍-ពិពាហ៍**

ការប្តឹងជំទាស់ និង ការប្តឹងទាស់មិនឲ្យរៀបអាពាហ៍ពិពាហ៍ ក្នុងករណីដែលកំណត់ក្នុងមាត្រា ៦០ (អន្តរប្បញ្ញត្តិ ស្តីពីការប្រកាសផ្សាយជាសាធារណៈអំពីអាពាហ៍ពិពាហ៍) ខាងលើនេះ ត្រូវអនុលោមតាមកិច្ចការដែលបានធ្វើពីមុនមក ។

ROYAUME DU CAMBODGE • LE MINISTÈRE DU PALAIS ROYAL

## មាត្រា ៦២.- អន្តរប្បញ្ញត្តិស្តីពីការលុបចោលអាពាហ៍ពិពាហ៍ ជាអាទិ៍

១-ទោះបីអាពាហ៍ពិពាហ៍ដែលបានធ្វើឡើង នៅមុនកាលបរិច្ឆេទនៃការអនុវត្តអាចត្រូវបានប្រកាសជាមោឃៈបាន ដោយយោងតាមបញ្ញត្តិចាប់ពីមាត្រា ២១ ដល់មាត្រា ២៦ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារក៏ដោយ ប្រសិនបើអាពាហ៍ពិពាហ៍នោះ មិនអាចលុបចោលបាន ដោយយោងតាមបញ្ញត្តិចាប់ពីមាត្រា ៩៥៩ (ការលុបចោលអាពាហ៍ពិពាហ៍) ដល់មាត្រា ៩៦៣ (ការលុបចោលអាពាហ៍ពិពាហ៍ដោយការឆបោក ឬ ការគំរាម) នៃក្រមរដ្ឋប្បវេណីទេ អាពាហ៍ពិពាហ៍នោះមិនអាចត្រូវបានប្រកាសជាមោឃៈបានឡើយ ។

២-ទោះបីអាពាហ៍ពិពាហ៍បានធ្វើឡើង នៅមុនកាលបរិច្ឆេទនៃការអនុវត្តក៏ដោយ ប្រសិនបើមានហេតុដែលកំណត់ចាប់ពីមាត្រា ៩៤៨ (អាយុគ្រប់លក្ខណៈរៀបអាពាហ៍ពិពាហ៍) ដល់មាត្រា ៩៥៤ (ការរៀបអាពាហ៍ពិពាហ៍របស់ជននៅក្រោមអាណាព្យាបាលទូទៅ) នៃក្រមរដ្ឋប្បវេណី អាពាហ៍ពិពាហ៍នោះអាចលុបចោលបាន ដោយផ្អែកលើបញ្ញត្តិចាប់ពីមាត្រា ៩៥៩ (ការលុបចោលអាពាហ៍ពិពាហ៍) ដល់មាត្រា ៩៦៣ (ការលុបចោលអាពាហ៍ពិពាហ៍ ដោយការឆបោក ឬ ការគំរាម) នៃក្រមរដ្ឋប្បវេណី ។ ក្នុងករណីនេះ ចំពោះអាពាហ៍ពិពាហ៍ដែលភាគីរួចខ្លួនពីការគំរាម នៅមុនកាលបរិច្ឆេទនៃការអនុវត្ត តែមិនទាន់កន្លងផុតអំឡុងពេល ៦ (ប្រាំមួយ) ខែ គិតពីពេលរួចខ្លួនពីការគំរាម នៅកាលបរិច្ឆេទនៃការអនុវត្ត ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៩៦៣ (ការលុបចោលអាពាហ៍ពិពាហ៍ ដោយការឆបោក ឬ ការគំរាម) នៃក្រមរដ្ឋប្បវេណី ក៏ដោយ ភាគីនោះអាចលុបចោលអាពាហ៍ពិពាហ៍បានដោយ យកការគំរាមមកជាមូលហេតុ រហូតដល់អំឡុងពេល ៦ (ប្រាំមួយ) ខែ កន្លងផុត គិតពីពេលដែលភាគីនោះបានរួចខ្លួនពីការគំរាម ។

៣-ក្នុងករណីដែលជនពាក់ព័ន្ធនឹងផលប្រយោជន៍ ក្រៅពីជនដែលកំណត់ក្នុងមាត្រា ៩៦០ (ការលុបចោល អាពាហ៍ពិពាហ៍ដែលមិនត្រឹមត្រូវតាមច្បាប់ជាអាទិ៍) នៃក្រមរដ្ឋប្បវេណី បានដាក់ពាក្យសុំប្រកាសមោឃភាពនៃអាពាហ៍ពិពាហ៍ នៅមុនកាលបរិច្ឆេទនៃការអនុវត្តដោយផ្អែកលើបញ្ញត្តិនៃមាត្រា ២៦ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ជនពាក់ព័ន្ធនឹងផលប្រយោជន៍នោះ ក៏មានលក្ខណសម្បត្តិជាដើមចោទនៃបណ្តឹងនោះ ក្រោយកាលបរិច្ឆេទនៃការអនុវត្តដែរ ។

## មាត្រា ៦៣.- អន្តរប្បញ្ញត្តិស្តីពីមូលហេតុនៃការលែងលះគ្នា

១-ក្នុងករណីដែលហេតុដែលបានកើតឡើង នៅមុនកាលបរិច្ឆេទនៃការអនុវត្ត ត្រូវនឹងមូលហេតុនៃការលែងលះគ្នាដែលកំណត់ក្នុងមាត្រា ៩៧៨ (មូលហេតុនៃការលែងលះគ្នា) នៃក្រមរដ្ឋប្បវេណី ប្តី ឬប្រពន្ធអាចដាក់ពាក្យបណ្តឹងសុំលែងលះគ្នាបាន ។

២-ចំពោះបណ្តឹងសុំលែងលះគ្នាដែលបានដាក់មុនកាលបរិច្ឆេទនៃការអនុវត្ត ប្តីប្រពន្ធ ក៏អាចលែងលះគ្នាបានដែរ ប្រសិនបើមានមូលហេតុដែលកំណត់ក្នុងមាត្រា ៣៩ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ។ ក្នុងករណីនេះ បញ្ញត្តិនៃកថាខណ្ឌទី ២ និងកថាខណ្ឌទី ៣ នៃមាត្រា ៩៧៨ (មូលហេតុនៃការលែងលះគ្នា) នៃក្រមរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ។

## មាត្រា ៦៤.- អន្តរប្បញ្ញត្តិស្តីពីនីតិវិធីលែងលះគ្នា

១-ការដាក់ពាក្យសុំលែងលះគ្នាទៅក្រុមប្រឹក្សាឃុំ សង្កាត់ និងការបញ្ជូនសំណុំរឿងដែលបានធ្វើឡើងដោយ ក្រុមប្រឹក្សាឃុំ សង្កាត់ទៅតុលាការ ដោយផ្អែកលើបញ្ញត្តិនៃមាត្រា ៤២ នៃច្បាប់ស្តីពីអាពាហ៍-ពិពាហ៍ និងគ្រួសារ នៅមុនកាលបរិច្ឆេទនៃការអនុវត្ត ត្រូវចាត់ទុកថា បានធ្វើឡើងដោយផ្អែកលើបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៩៨២ (បណ្តឹងនៃការលែងលះគ្នា) នៃក្រមរដ្ឋប្បវេណី ។

២-ការចាត់វិធានការបណ្តោះអាសន្នដែលបានធ្វើឡើង ដោយផ្អែកលើបញ្ញត្តិនៃមាត្រា ៤៤ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ដោយតុលាការដែលបានទទួលពាក្យបណ្តឹង នៅកាលបរិច្ឆេទនៃការអនុវត្ត ត្រូវចាត់ទុកជាការចាត់ចែងរក្សាការពារដែលបានធ្វើឡើង ដោយផ្អែកលើបញ្ញត្តិនៃមាត្រា ៩៨៣ (ការចាត់ចែងរក្សាការពារ) នៃក្រមរដ្ឋប្បវេណី ។

៣-ក្នុងករណីដែលប្រពន្ធសម្រាលកូន នៅមុនកាលបរិច្ឆេទនៃការអនុវត្ត ឬមានផ្ទៃពោះ នៅកាលបរិច្ឆេទនៃការអនុវត្ត ប្តីមិនអាចសុំលែងលះគ្នា ក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ក្រោយកំណើតកូននោះបានឡើយ ។ ប្រសិនបើ ប្រពន្ធសម្រាលកូនក្នុងអំឡុងពេល ៣០០ (បីរយ) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការអនុវត្តនោះត្រូវសន្មតថាប្រពន្ធនោះមានផ្ទៃពោះ នៅកាលបរិច្ឆេទនៃការអនុវត្ត ។

## មាត្រា ៦៥.- ការសន្មតបិតុភាព ជាអាទិ៍

១-ការសន្មតបិតុភាព និងការបដិសេធនូវបិតុភាពដែលបានកើតឡើងដោយជនដែលត្រូវបានសន្មតថាជាឪពុកជាអាទិ៍ ចំពោះកូនដែលបានកើតនៅមុនកាលបរិច្ឆេទនៃការអនុវត្ត ត្រូវអនុលោមតាមកិច្ចការដែលបានធ្វើពីមុនមក ។

២-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ កូនដែលបានកើតមុនកាលបរិច្ឆេទនៃការអនុវត្ត អាចដាក់ពាក្យប្តឹងបដិសេធបិតុភាពបាន ដោយផ្អែកលើបញ្ញត្តិនៃមាត្រា ៩៩១ (បណ្តឹងបដិសេធបិតុភាព ពីកូន) នៃក្រមរដ្ឋប្បវេណី ចំពោះជនដែលត្រូវបានសន្មតថាជាឪពុក។ ប៉ុន្តែការសន្មតបិតុភាពក្នុងករណីនេះ ត្រូវអនុលោមតាមកិច្ចការដែលបានធ្វើពីមុនមក ។



៣-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ចំពោះលក្ខណសម្បត្តិរបស់ជនដែលអាចដាក់ពាក្យប្តឹងបដិសេធបិតុភាពបាន នៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត ត្រូវអនុលោមតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី ។ ប៉ុន្តែ ក្នុងករណីដែលទាយាទរបស់ជនដែលត្រូវបានសន្មតថាជាឪពុក បានដាក់ពាក្យប្តឹងបដិសេធបិតុភាពសម្រាប់ជននោះ នៅមុនកាលបរិច្ឆេទនៃការអនុវត្ត ដោយផ្អែកលើបញ្ញត្តិនៃមាត្រា ៨៧ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ទាយាទនោះអាចរក្សាបន្តនូវបណ្តឹងនោះ សម្រាប់ជនដែលត្រូវបានសន្មតថាជាឪពុក ក្រោយកាលបរិច្ឆេទនៃការអនុវត្តបានដែរ ។

## មាត្រា ៦៦.- ការទទួលស្គាល់ដោយបង្ខំ

១-ក្នុងករណីដែលជនដែលបានក្លាយទៅជានីតិជន លើសពីអំឡុងពេល ២ (ពីរ) ឆ្នាំ នៅកាលបរិច្ឆេទនៃការអនុវត្ត បានដឹងជាដំបូងថាជាឪពុកក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ មុនកាលបរិច្ឆេទនៃការអនុវត្ត ជននោះអាចប្តឹងទាមទារឲ្យទទួលស្គាល់ ដោយផ្អែកលើបញ្ញត្តិនៃក្រមរដ្ឋប្បវេណីបាន ក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃការអនុវត្ត ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ៩៧ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារក៏ដោយ ។ ក្នុងករណីនេះ បញ្ញត្តិនៃកថាខណ្ឌទី ៣ នៃមាត្រា ១០០១ (បណ្តឹងទាមទារឲ្យទទួលស្គាល់) នៃក្រមរដ្ឋប្បវេណី មិនត្រូវយកមកអនុវត្តឡើយ ។

២-ក្នុងករណីដែលជនដែលបានក្លាយទៅជានីតិជន ក្នុងអំឡុងពេល ២ (ពីរ) ឆ្នាំ មុនកាលបរិច្ឆេទនៃការអនុវត្ត ជននោះអាចប្តឹងទាមទារឲ្យទទួលស្គាល់ ដោយផ្អែកលើបញ្ញត្តិនៃក្រមរដ្ឋប្បវេណីបាន ក្នុងអំឡុងពេល ១(មួយ) ឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃការអនុវត្ត ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ៣ និង កថាខណ្ឌទី៤ នៃមាត្រា ១០០១ (បណ្តឹងទាមទារឲ្យទទួលស្គាល់) នៃក្រមរដ្ឋប្បវេណីក៏ដោយ ។

## មាត្រា ៦៧.- សុំកូនដែលបានធ្វើមុនកាលបរិច្ឆេទនៃការអនុវត្ត

ចំពោះសុំកូនដែលត្រូវបានធ្វើនៅមុនកាលបរិច្ឆេទនៃការអនុវត្ត ដោយកិច្ចសន្យាសុំកូនដែលបានទទួលការបញ្ជាក់ ដោយផ្អែកលើបញ្ញត្តិនៃមាត្រា ១១៣ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារបញ្ញត្តិស្តីពីសុំកូនពេញលេញ នៅក្នុងក្រមរដ្ឋប្បវេណី ត្រូវយកមកអនុវត្ត នៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត ។ ប៉ុន្តែ បញ្ញត្តិនេះមិនប៉ះពាល់ដល់ហេតុការណ៍ដែលបានកើតឡើង មុនកាលបរិច្ឆេទនៃការអនុវត្តឡើយ ។

## មាត្រា ៦៨.- អន្តរប្បញ្ញត្តិស្តីពីការដាក់ពាក្យសុំកូន

ក្នុងករណីដែលកាលបរិច្ឆេទនៃការអនុវត្ត បានចូលមកដល់ នៅពេលកំពុងតែដាក់ពាក្យសុំឲ្យក្រុមប្រឹក្សាឃុំ សង្កាត់បញ្ជាក់អំពីកិច្ចសន្យាសុំកូន ដោយផ្អែកលើបញ្ញត្តិនៃមាត្រា ១១៣ នៃច្បាប់ស្តីពីអាពាហ៍-

ពិពាហ៍ និង គ្រួសារ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបញ្ជូនសំណុំរឿងនោះទៅតុលាការ ។ ក្នុងករណីនេះ ក្រុមប្រឹក្សាឃុំ សង្កាត់ អាចភ្ជាប់មតិរបស់ខ្លួនបាន ហើយតុលាការគិតពិចារណាមតិនោះ ។

**មាត្រា ៦៩._ អំណាចមេបាក្រោយការលែងលះគ្នា**

ឪពុក ឬម្តាយ ដែលត្រូវបានសម្រេចឲ្យរក្សាកូន ដោយផ្អែកលើបញ្ញត្តិនៃមាត្រា ៧៣ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ នៅមុនកាលបរិច្ឆេទនៃការអនុវត្ត ត្រូវចាត់ទុកថា ត្រូវបានកំណត់ជាអ្នកមានអំណាច មេបា ដោយយោងតាមបញ្ញត្តិនៃមាត្រា ១០៣៧ (ការសម្រេចអំពីអ្នកមានអំណាចមេបានៅពេលលែងលះគ្នា) នៃក្រមរដ្ឋប្បវេណី ។

**មាត្រា ៧០._ អន្តរប្បញ្ញត្តិស្តីពីការសុំដកហូតអំណាចមេបា ជាអាទិ៍**

១-តុលាការអាចប្រកាសព្យួរ ឬដកហូតអំណាចមេបា ឬសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិ ដោយអង្គហេតុដែលបានកើតឡើង មុនកាលបរិច្ឆេទនៃការអនុវត្តបាន ។

២-ជនដែលបានដាក់ពាក្យសុំឲ្យដកហូតអំណាចមេបា ដោយផ្អែកលើបញ្ញត្តិនៃមាត្រា១២០ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ មុនកាលបរិច្ឆេទនៃការអនុវត្ត ត្រូវមានលក្ខណសម្បត្តិជាអ្នកដាក់ពាក្យសុំ ទោះបីមានបញ្ញត្តិនៃមាត្រា ១០៤៨ (ការប្រកាសព្យួរ ឬការដកហូតអំណាចមេបា) នៃក្រមរដ្ឋប្បវេណីក៏ដោយ ។

**មាត្រា ៧១._ ការអនុវត្តបញ្ញត្តិស្តីពីសន្តតិកម្ម**

បញ្ញត្តិស្តីពីសន្តតិកម្ម ត្រូវយកមកអនុវត្ត ចំពោះតែសន្តតិកម្មដែលបានចាប់ផ្តើមក្រោយកាលបរិច្ឆេទនៃការអនុវត្តប៉ុណ្ណោះ ។ ក្នុងករណីនេះ បញ្ញត្តិស្តីពីសន្តតិកម្ម ត្រូវយកមកអនុវត្ត ចំពោះហេតុការណ៍ដែលបានកើតឡើងមុនកាលបរិច្ឆេទនៃការអនុវត្តផងដែរ ។

## ជំពូកទី ៦
## ប្រតិបត្តិការដែលមានកិច្ចធានា

**មាត្រា ៧២._ គោលបំណងនៃជំពូកនេះ**

១-ជំពូកនេះមានគោលបំណងសម្របសម្រួល រវាងប្រតិបត្តិការដែលកំណត់ក្នុងក្រមរដ្ឋប្បវេណី ដូចជាប្រាតិភោគលើចលនវត្ថុ ជាអាទិ៍ និងប្រតិបត្តិការដែលកំណត់ក្នុងច្បាប់ស្តីពីប្រតិបត្តិការដែលមាន

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

កិច្ចធានា ដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៧/០១២ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៧ (តទៅ ហៅថា "ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា") ។

២-បញ្ញត្តិនៃជំពូកនេះ ត្រូវបានបញ្ចូលនៅក្នុងចំណោមច្បាប់ផ្សេងដែលកំណត់ក្នុងកថាខណ្ឌទី ២ មាត្រា ១ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ។

## មាត្រា ៧៣.- អានុភាពនៃប្រតិបត្តិការដែលមានកិច្ចធានា ដែលត្រូវបានធ្វើឡើង នៅមុនកាលបរិច្ឆេទនៃការអនុវត្តក្រមរដ្ឋប្បវេណី

ប្រតិបត្តិការដែលត្រូវបានធ្វើឡើង នៅមុនកាលបរិច្ឆេទនៃការអនុវត្តក្រមរដ្ឋប្បវេណី ដោយយោងតាមបញ្ញត្តិនៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ត្រូវមានអានុភាពបន្ត នៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត ។

## មាត្រា ៧៤.- ការប្តូរទៅប្រតិបត្តិការដោយផ្អែកលើក្រមរដ្ឋប្បវេណី

១-ក្នុងករណីដែលប្រតិបត្តិការដែលកំណត់ក្នុងមាត្រា ៧៣ (អានុភាពនៃប្រតិបត្តិការដែលមានកិច្ចធានា ដែលត្រូវបានធ្វើឡើង នៅមុនកាលបរិច្ឆេទនៃការអនុវត្តក្រមរដ្ឋប្បវេណី) ខាងលើនេះ បំពេញលក្ខខណ្ឌដែលកំណត់ក្នុងក្រមរដ្ឋប្បវេណី ប្រសិនបើភាគីបង្ហាញឆន្ទៈថា ប្តូរទៅប្រតិបត្តិការដោយផ្អែកលើបញ្ញត្តិនៃក្រមរដ្ឋប្បវេណី នោះត្រូវចាត់ទុកថាភាគីបានធ្វើប្រតិបត្តិការនោះ នៅកាលបរិច្ឆេទនៃការអនុវត្ត ដោយយោងតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី ។ ប៉ុន្តែ ការប្តូរនេះមិនអាចធ្វើឲ្យខូចប្រយោជន៍ដល់សិទ្ធិរបស់តតិយជនឡើយ ។

២-ក្នុងករណីដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ភាគីនៃប្រតិបត្តិការដែលត្រូវបានប្តូរនោះ មិនអាចអះអាងអានុភាពនៃប្រតិបត្តិការដោយយោងតាមបញ្ញត្តិនៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាឡើយ ។

## មាត្រា ៧៥.- បញ្ញត្តិសន្មត

ចំពោះប្រតិបត្តិការដែលត្រូវបានធ្វើឡើង នៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត ប្រសិនបើមានភាពមិនច្បាស់លាស់រវាងភាគីនៃប្រតិបត្តិការនោះថា ប្រតិបត្តិការនោះ ត្រូវបានធ្វើឡើង ដោយយោងតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី ឬ បញ្ញត្តិនៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ប្រតិបត្តិការនោះត្រូវសន្មតថា ត្រូវបានធ្វើឡើងដោយយោងតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី ។

**មាត្រា ៧៦.– អាទិភាពរវាងប្រតិបត្តិការដោយយោងតាមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា និង ប្រតិបត្តិការដោយយោងតាមក្រមរដ្ឋប្បវេណី**

ប្រសិនបើប្រតិបត្តិការដែលត្រូវបានធ្វើឡើង ដោយយោងតាមបញ្ញត្តិនៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ចំពោះកម្មវត្ថុណាមួយ និងប្រតិបត្តិការដែលត្រូវបានធ្វើឡើងដោយយោងតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី ចំពោះកម្មវត្ថុដដែលមានវិសមិតភាពអាទិភាពរវាងប្រតិបត្តិការទាំងនោះ ត្រូវសម្រេចតាមពេលវេលាដែលអាចយកប្រតិបត្តិការនោះមកតតាំងចំពោះតតិយជន ។

**មាត្រា ៧៧.– ការការពារបុគ្គលសុច្ចរិត**

បញ្ញត្តិនៃមាត្រា ៧៦ (អាទិភាពរវាងប្រតិបត្តិការដោយយោងតាមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា និង ប្រតិបត្តិការដោយយោងតាមក្រមរដ្ឋប្បវេណី) ខាងលើនេះ មិនរារាំងការអនុវត្តមាត្រា ១៩៣ (លទ្ធកម្មដោយ សុច្ចរិតនូវកម្មសិទ្ធិលើចលនវត្ថុ) និង មាត្រា ១៩៤ (អនុប្បទាននូវវត្ថុលួច ឬ វត្ថុបាត់) នៃក្រមរដ្ឋប្បវេណី ។

## ជំពូកទី ៧
## វិសោធនកម្ម និង និរាករណ៍នូវបទបញ្ញត្តិមួយចំនួននៃច្បាប់ជាធរមាន

**មាត្រា ៧៨.– និរាករណ៍នូវបទបញ្ញត្តិមួយចំនួននៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ**

ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ត្រូវបាត់បង់អានុភាពចាប់ពីកាលបរិច្ឆេទនៃការអនុវត្ត លើកលែងតែបញ្ញត្តិនៃមាត្រា ៧៦ មាត្រា ៧៧ និង បញ្ញត្តិពីមាត្រា៧៩ ដល់មាត្រា ៨១ នៃច្បាប់នោះនៅតែមានអានុភាពនៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត រហូតដល់ពេលដែលកំណត់ផ្សេងដោយច្បាប់ ។

**មាត្រា ៧៩.– និរាករណ៍នូវបទបញ្ញត្តិមួយចំនួននៃក្រឹត្យ-ច្បាប់ លេខ ៣៨ ក្រ.ច ស្តីពីកិច្ចសន្យា និង ការទទួលខុសត្រូវក្រៅកិច្ចសន្យា**

ក្រឹត្យ-ច្បាប់ លេខ ៣៨ ក្រ.ច ត្រូវបាត់បង់អានុភាពចាប់ពីកាលបរិច្ឆេទនៃការអនុវត្ត លើកលែងតែមាត្រា ៨៣ ដល់មាត្រា៨៨ នៃក្រឹត្យ-ច្បាប់ លេខ ៣៨ ក្រ.ច នោះនៅតែមានអានុភាព នៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត រហូតដល់ពេលដែលកំណត់ផ្សេងដោយច្បាប់ ។

**មាត្រា ៨០.- វិសោធនកម្មនូវបទប្បញ្ញត្តិមួយចំនួននៃច្បាប់ភូមិបាល ឆ្នាំ២០០១**

ច្បាប់ភូមិបាលឆ្នាំ ២០០១ ត្រូវធ្វើវិសោធនកម្មដូចខាងក្រោម :

ត្រូវលុបកថាខណ្ឌទី ៣ នៃមាត្រា ៦ ។

ត្រូវលុបកថាខណ្ឌទី ១ និង កថាខណ្ឌទី ៣ នៃមាត្រា ១០ ។

ត្រូវកែចំណងជើងនៃជំពូកទី ៦ ទៅជា "អំពីលទ្ធកម្មនៃកម្មសិទ្ធិ" ។

ត្រូវលុបមាត្រា ៦៣ ដល់មាត្រា ៦៨ ។

ត្រូវលុបកថាខណ្ឌទី ១ នៃមាត្រា ៦៩ ។

ត្រូវកែផ្នែកទី ២ នៃជំពូកទី ៦ ដូចតទៅ :

"ផ្នែកទី ២ ត្រូវបានលុបមាត្រា ៧០ ដល់មាត្រា ៧១" ។

ត្រូវលុបមាត្រា ៧៥ និង មាត្រា ៧៦ ។

ត្រូវកែមាត្រា ៧៨ ថា "ដីដែលធ្លាក់ទៅជាទ្រព្យរដ្ឋ ដោយយោងតាមបញ្ញត្តិនៃមាត្រា ១៣០០ (មរតក ដែលធ្លាក់ទៅជាទ្រព្យរដ្ឋ) នៃក្រមរដ្ឋប្បវេណី ត្រូវបញ្ចូលក្នុងទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ។

ត្រូវលុបចាប់ពីមាត្រា ៧៩ ដល់មាត្រា ៨២ ។

ត្រូវលុបមាត្រា ៨៤ ។

ត្រូវកែចំណងជើងនៃមាតិកាទី ៣ ទៅជា"អំពីវិធានដី និង សេវភាព" ។

ត្រូវកែចំណងជើងនៃជំពូកទី ៧ ទៅជា"អំពីវិធានដី" ។

ត្រូវកែផ្នែកទី ១ ដល់ផ្នែកទី ៤ នៃជំពូកទី ៧ ដូចតទៅ :

"ផ្នែកទី ១ ដល់ផ្នែកទី ៤ ត្រូវបានលុប

មាត្រា ៨៥ ដល់មាត្រា ១១៣ ត្រូវបានលុប" ។

ត្រូវកែចំណងជើងនៃជំពូកទី ៨ ទៅជា"អំពីសេវភាព" ។

ត្រូវលុបមាត្រា ១១៧ និង មាត្រា ១១៨ ។

ត្រូវកែផ្នែកទី ១ និង ផ្នែកទី ២ នៃជំពូកទី ៨ ដូចតទៅ :

"ផ្នែកទី ១ និង ផ្នែកទី ២ ត្រូវបានលុប

មាត្រា ១១៩ ដល់មាត្រា ១៤១ ត្រូវបានលុប" ។

K.l

ត្រូវលុបចាប់ពីមាត្រា ១៤២ ដល់មាត្រា ១៤៧ ។

ត្រូវលុបចាប់ពីមាត្រា ១៤៩ ដល់មាត្រា ១៦៧ ។

ត្រូវកែចំណងជើងនៃមាតិកាទី ៤ ទៅជា "អំពីសហកម្មសិទ្ធិ" ។

ត្រូវកែជំពូកទី ៩ ដូចតទៅ :

"ជំពូកទី ៩ ត្រូវបានលុប

មាត្រា ១៦៨ ដល់មាត្រា ១៧៤ ត្រូវបានលុប" ។

ត្រូវកែជំពូកទី ១១ ដូចតទៅ :

"ជំពូកទី ១១ ត្រូវបានលុប

មាត្រា ១៨៦ ដល់មាត្រា ១៩៦ ត្រូវបានលុប"។

ត្រូវកែមាតិកាទី ៥ ដូចតទៅ :

"មាតិកាទី ៥ ត្រូវបានលុប

មាត្រា ១៩៧ ត្រូវបានលុប

ជំពូកទី ១២ ដល់ជំពូកទី ១៤ ត្រូវបានលុប

មាត្រា ១៩៨ ដល់មាត្រា ២២៥ ត្រូវបានលុប" ។

ត្រូវកែពាក្យ "ការដាក់ធានា" ទៅជា "ផលុបភោគ" នៅក្នុងមាត្រា ២២៩ និង មាត្រា ២៣៨ ។

ត្រូវកែឃ្លា "ដោយលិខិតលក់ ឲ្យ ដូរ ឬ ជម្រះមរតក ដែលត្រូវបានធ្វើឡើងដោយ បុគ្គលដែលមាននីតិសម្បទា ដូចមានចែងក្នុងមាត្រា ៦៥ នៃច្បាប់នេះ" ទៅជា "ដោយលិខិតជាលាយលក្ខណ៍អក្សរតាមទម្រង់លិខិតយថាភូតធ្វើ ដោយអាជ្ញាធរមានសមត្ថកិច្ច" នៅក្នុងកថាខណ្ឌទី ២ មាត្រា ២៤៤ ។

ត្រូវកែមាត្រា ២៤៥ ទៅជា "កិច្ចសន្យាដើម្បីផ្ទេរកម្មសិទ្ធិលើអចលនវត្ថុ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរតាមទម្រង់លិខិតយថាភូត ដោយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីចុះបញ្ជីកិច្ចសន្យានោះនៅរដ្ឋបាលសុរិយោដី" ។

ត្រូវលុបមាត្រា ២៤៦ ។

ត្រូវលុបឃ្លា "ហើយការខូចខាតទាំងឡាយដែលបណ្តាលមកពីអំពើនេះ ត្រូវដោះស្រាយដោយសំណងរដ្ឋប្បវេណី" នៅក្នុងមាត្រា ២៤៧ ។

ត្រូវលុបកថាខណ្ឌទី ២ នៃមាត្រា ២៥៣ ។

**មាត្រា៨១._ វិសោធនកម្មនូវបទបញ្ញត្តិមួយចំនួននៃក្រមរដ្ឋប្បវេណី**

ក្រមរដ្ឋប្បវេណី ដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០០៧ ត្រូវធ្វើវិសោធនកម្មដូចខាងក្រោម :

ត្រូវកែឃ្លា "លក្ខណៈដើមនៃសមាសភាគនោះ" ទៅជា "លក្ខណៈដើមនៃវត្ថុនោះ" នៅក្នុងមាត្រា១២១(សមាសភាគនៃវត្ថុ) ។

ត្រូវកែឃ្លា "ក្នុងទំហំដែលច្បាប់បានកម្រិត" ទៅជា "ក្នុងទំហំដែលច្បាប់ និង បទដ្ឋានគតិយុត្តផ្សេងៗទៀតបានកម្រិត" នៅក្នុងមាត្រា ១៣៨ (និយមន័យនៃកម្មសិទ្ធិ)។

ត្រូវកែពាក្យ "អាជ្ញាធរខេត្ត ក្រុង" ទៅជា "អាជ្ញាធររាជធានី ខេត្ត" នៅក្នុងវាក្យខណ្ឌទី ៣ និង វាក្យខណ្ឌទី ៤ នៃមាត្រា ១៨៥ (កម្មសិទ្ធិនៃបាតទន្លេ ឬ ស្ទឹងចាស់ ដោយសារការបង្កើតផ្លូវទឹកថ្មី) ។

ត្រូវកែឃ្លា "ដោយបានដឹងថាខ្លួនគ្មានសិទ្ធិកាន់កាប់ទេ" ទៅជា "ដោយបានដឹងថាខ្លួនគ្មានសិទ្ធិអំណាចក្នុងការកាន់កាប់ទេ" និង កែឃ្លា "ដោយមិនបានដឹងថាខ្លួនគ្មានសិទ្ធិទេ" ទៅជា "ដោយមិនបានដឹងថាខ្លួនគ្មានសិទ្ធិអំណាចទេ" នៅក្នុងវាក្យខណ្ឌទី ១ កថាខណ្ឌទី ១ នៃមាត្រា ២៣៣ (ការកាន់កាប់ ដោយមានវិការៈ) ។

ត្រូវបន្ថែមពាក្យ "ឬ ប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី" បន្ទាប់ពីពាក្យ "ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ" នៅក្នុងកថាខណ្ឌទី ១ និង កថាខណ្ឌទី ៣ នៃមាត្រា ២៤២ (ការការពារភោគីអចលនវត្ថុដែលមានប័ណ្ណ សំគាល់សិទ្ធិកាន់កាប់) ។

ត្រូវកែពាក្យ "ផលុបភោគី" ទៅជា"ម្ចាស់សេវភាព" នៅក្នុងកថាខណ្ឌទី ៤ មាត្រា ២៩១ (ករណីយកិច្ចរបស់ម្ចាស់សេវភាព) ។

ត្រូវកែឃ្លា "បើភាគីម្ខាងនៃកិច្ចសន្យាបានប្រើឋានៈខ្លួនដែលមានអាទិភាពជាងភាគីម្ខាងទៀតខាងផ្នែកសេដ្ឋកិច្ច ឬ ផ្នែកសង្គម ឬ បានប្រើស្ថានភាពផ្សេងទៀតដែលភាគីម្ខាងទៀតមិនអាចប្រឆាំងតបបានទេ" ទៅជា "បើភាគីម្ខាងនៃកិច្ចសន្យាបានប្រើដោយមិនត្រឹមត្រូវនូវឋានៈខ្លួនដែលមានអាទិភាពជាងភាគីម្ខាងទៀត ខាងផ្នែកសេដ្ឋកិច្ច ឬ ផ្នែកសង្គម ឬ បានប្រើដោយមិនត្រឹមត្រូវនូវស្ថានភាពផ្សេងទៀតដែលភាគីម្ខាងទៀតមិនអាចប្រឆាំងតបបានទេ" នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៣៤៩ (ការរំលោភបំពានលើស្ថានភាព) ។

ត្រូវបន្ថែមពាក្យ "ក្រៅផ្លូវតុលាការ ឬ" មុនពាក្យ "តាមផ្លូវតុលាការ" នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៣៨៥ (សិទ្ធិរបស់ម្ចាស់បំណុលក្នុងការទាមទារឲ្យអនុវត្តកាតព្វកិច្ច) ។

ត្រូវកែពាក្យ "ការមិនអនុវត្តកាតព្វកិច្ច" ទៅជា "ការអនុវត្តកាតព្វកិច្ចមិនបានពេញលេញ" នៅក្នុងមាត្រា ៣៩៣ (ការអនុវត្តកាតព្វកិច្ចមិនបានពេញលេញ) ។

ត្រូវលុបឃ្លា "ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ" នៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ៤១២ (សិទ្ធិរំលាយក្នុងករណីដែលកម្មវត្ថុនៃកិច្ចសន្យាត្រូវបានខូចខាត ឬ បាត់បង់) ។

ត្រូវកែពាក្យ "ប៉ុន្តែ" ទៅជា "ក្នុងករណីនេះ" នៅក្នុងវាក្យខណ្ឌទី ២ នៃមាត្រា ៤២០ (ការទទួលបន្ទុកហានិភ័យចំពោះកិច្ចសន្យាអញ្ញមញ្ញដែលមានអត្ថន័យត្រូវធ្វើ ឬ មិនត្រូវធ្វើ) ។

ត្រូវកែឃ្លា "សិទ្ធិលើបំណុលនោះ" ទៅជា "ម្ចាស់បំណុល" ហើយបន្ថែម "ឬ អ្នកដែលទទួលបន្ទុកបន្តវត្តពីអ្នកនោះ" បន្ទាប់ពីពាក្យ "អ្នកដែលបានទទួលផលប្រយោជន៍ពីអំពើរបស់កូនបំណុលនោះ" នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៤២៨ (លក្ខខណ្ឌនៃការលុបចោលនូវអំពើដែលនាំឲ្យខូចខាតផលប្រយោជន៍)។

ត្រូវកែឃ្លា "ពេលដែលការទាញហេតុផលដោយផ្ទាល់មាត់" ទៅជា "ពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់" នៅក្នុងវាក្យខណ្ឌទី២ នៃមាត្រា៤២៩ (សិទ្ធិដែលត្រូវបានរក្សាការពារ) ។

ត្រូវកែឃ្លា "នៅពេលដែលម្ចាស់បំណុលមិនព្រមចំពោះការតម្កល់ ឬ សាលក្រម ឬ សាលដីកាដែលប្រកាសថាការតម្កល់នោះមានសុពលភាព មិនទាន់ចូលជាស្ថាពរទេ" ទៅជា "នៅក្នុងអំឡុងពេលដែលម្ចាស់បំណុលមិនទាន់ព្រមចំពោះការតម្កល់ ឬ ក្នុងអំឡុងពេលដែលសាលក្រម ឬ សាលដីកាដែលប្រកាសថាការតម្កល់នោះ មានសុពលភាពមិនទាន់ចូលជាស្ថាពរទេ" នៅក្នុងវាក្យខណ្ឌទី ១ កថាខណ្ឌទី ២ នៃមាត្រា ៤៥៧ (ការតម្កល់) ។

ត្រូវកែឃ្លា "មិនអាចយកហេតុនោះតតាំងចំពោះអនុប្បទាយីបានឡើយ" ទៅជា "មិនអាចយកហេតុនោះ តតាំងចំពោះអនុប្បទានិកបានឡើយ" នៅក្នុងវាក្យខណ្ឌទី ១ កថាខណ្ឌទី ១ នៃមាត្រា ៥០៥ (អានុភាពនៃការជូនដំណឹង និង ការយល់ព្រម) ។

ត្រូវកែឃ្លា "នៅក្នុងមាត្រា ១៣៣ (ការបង្កើត ការផ្ទេរ និង ការកែប្រែនូវសិទ្ធិប្រត្យក្សដោយការព្រមព្រៀង) មាត្រា ១៣៤ (លក្ខខណ្ឌតតាំងនៃការបង្កើត ការផ្ទេរ និង ការកែប្រែនូវសិទ្ធិប្រត្យក្ស) មាត្រា ១៣៥ (លក្ខខណ្ឌដើម្បីបង្កើតអានុភាពនៃការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដោយការព្រមព្រៀង)

Kol

មាត្រា ១៦០ (លទ្ធកម្មនៃកម្មសិទ្ធិលើ អចលនវត្ថុ) និង មាត្រា ១៨៧ (លទ្ធកម្មនៃកម្មសិទ្ធិលើចលនវត្ថុ) ទៅជា "ចាប់ពីមាត្រា ១៣៣ (ការបង្កើត ការផ្ទេរ និង ការកែប្រែនូវសិទ្ធិប្រត្យក្សដោយការព្រមព្រៀង) ដល់មាត្រា ១៣៥ (លក្ខខណ្ឌដើម្បីបង្កើតអានុភាពនៃការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដោយការព្រមព្រៀង)" នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៥២៨ (ការផ្ទេរកម្មសិទ្ធិ) ។

ត្រូវកែពាក្យ "សិទ្ធិជួលជាអចិន្ត្រៃយ៍" ទៅជា "សិទ្ធិជួលអចិន្ត្រៃយ៍" និង បន្ថែមពាក្យ "សិទ្ធិអាស្រ័យនៅ" បន្ទាប់ពីពាក្យ "សិទ្ធិប្រើប្រាស់" នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៥៣៤ (ការទទួលខុសត្រូវក្នុងការធានាក្នុងករណីដែលមានសិទ្ធិប្រត្យក្សជាផលុបភោគជាអាទិ៍) ។

ត្រូវកែឃ្លា "អ្នកទិញត្រូវបានបង្ហាញ" ទៅជា "អ្នកលក់ត្រូវបានបង្ហាញ" នៅក្នុងចំណុច គ កថាខណ្ឌទី ២ នៃ មាត្រា ៥៣៩ (ករណីយកិច្ចផ្តល់វត្ថុដែលគ្មានវិការៈ) ។

ត្រូវបន្ថែមពាក្យ "ស្រូវ" បន្ទាប់ពីពាក្យ "ស្បៀងអាហារ" នៅក្នុងមាត្រា ៥៧៨ (និយមន័យនៃការខ្ចីបរិភោគ) ។

ត្រូវកែឃ្លា "ការទាមទារដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ" ទៅជា "ការទាមទារដែលកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើនេះ" នៅក្នុងកថាខណ្ឌទី ៤ នៃមាត្រា ៦០៥ (ការទទួលខុសត្រូវរបស់ភតិបតី ចំពោះវិការៈនៃវត្ថុជួល) ។

ត្រូវកែពាក្យ "សមាជិកគណៈកម្មការនាយក" ទៅជា "អភិបាល" នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៧៤៨ (អំពើអនីត្យានុកូលរបស់នីតិបុគ្គល) ។

ត្រូវកែពាក្យ "ចំនួនទឹកប្រាក់នៃការខូចខាត" ទៅជា "ចំនួនទឹកប្រាក់នៃសំណងការខូចខាត" នៅក្នុងមាត្រា ៧៦៣ (ការទូទាត់ប្រាក់ចំណេញ និង ខាត) និង មាត្រា ៧៦៤ (ការទូទាត់នូវកំហុស) ។

ត្រូវលុបឃ្លា "សិទ្ធិលើការបញ្ចាំដើម្បីធានាបំណុលអណ្តែត ឬ" នៅក្នុងកថាខណ្ឌទី ២ នៃមាត្រា៧៧០ (ភាពទៅជាមួយគ្នានៃសិទ្ធិប្រាតិភោគប្រត្យក្ស) ។

ត្រូវកែពាក្យ "អាហារកិច្ច" ទៅជា "អាហារកាតព្វកិច្ច" នៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ៧៨៦ (ឯកសិទ្ធិ ចំពោះសោហ៊ុយសម្រាប់បុណ្យសព) និង មាត្រា៧៨៧ (ឯកសិទ្ធិចំពោះការផ្តល់នូវវត្ថុសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ) ។

ROYAUME DU CAMBODGE LE MINISTRE ... PALAIS

ក.ជ

ត្រូវកែឃ្លា "ចំពោះប្រាក់ដែលអនុប្បទានិក ឬ ភតិកៈបន្តនោះទទួល" ទៅជា "ចំពោះប្រាក់ដែលអនុប្បទាយី ឬ ភតិបតីបន្តទទួល" នៅក្នុងវាក្យខណ្ឌទី ២ នៃមាត្រា ៧៩១ (ទំហំនៃវត្ថុដែលជាកម្មវត្ថុនៃឯកសិទ្ធិចំពោះការជួលអចលនវត្ថុ ក្នុងករណីអនុប្បទាននូវសិទ្ធិជួល ឬ ជួលបន្ត) ។

ត្រូវកែឃ្លា "ដើម្បីផលប្រយោជន៍របស់ម្ចាស់បំណុលផ្សេងទៀត" ទៅជា "ដើម្បីផលប្រយោជន៍របស់ម្ចាស់បំណុលហ៊ីប៉ូតែកផ្សេងទៀត" នៅក្នុងវាក្យខណ្ឌទី ១ កថាខណ្ឌទី ១ នៃមាត្រា ៨៦១ (អនុប្បទាន ឬ ការបោះបង់ និង ការផ្លាស់ប្តូរនូវលំដាប់នៃហ៊ីប៉ូតែក) ។

ត្រូវកែពាក្យ "បញ្ចូល" ទៅជា "បញ្ចូល" នៅក្នុងកថាខណ្ឌទី ១ មាត្រា ៩០៣ (ទំហំនៃការធានាកាតព្វកិច្ច) ។

ត្រូវលុបឃ្លា "ដោយមិនចាំបាច់មានការយល់ព្រមពីកូនបំណុលផ្សេងទៀត" នៅក្នុងកថាខណ្ឌទី ៣ នៃមាត្រា ៩២២ (ការបង្កើតកាតព្វកិច្ចដោយសាមគ្គីភាព) ។

ត្រូវកែឃ្លា "តាមសមាមាត្រនៃបន្ទុករបស់កូនបំណុលផ្សេងទៀត" ទៅជា "តាមសមាមាត្រនឹងចំនួនភាគរយនៃចំនួនទឹកប្រាក់សរុបនៃកាតព្វកិច្ច" នៅក្នុងវាក្យខណ្ឌទី ២ កថាខណ្ឌទី ១ នៃមាត្រា ៩៣២ (សិទ្ធិទាមទារសំណងរបស់កូនបំណុលដែលបានសង) ។

ត្រូវលុបឃ្លា "ឬ លែងទទួលស្គាល់" នៅក្នុងចំណងជើង និង បញ្ញត្តិនៃមាត្រា៩៤២ (ការរលត់ញាតិភាព ដោយការកាត់កាល់ ឬ លែងទទួលស្គាល់) ។

ត្រូវកែឃ្លា "ប្តី ឬ ប្រពន្ធទាំងសងខាង" ទៅជា "ប្តីប្រពន្ធទាំងសងខាង" នៅចំណុច ខ នៃមាត្រា ៩៧៥ (ការទទួលខុសត្រូវដោយសាមគ្គីភាព ចំពោះកាតព្វកិច្ច) ។

ត្រូវកែឃ្លា "អចលនវត្ថុ" ទៅជា "អចលនវត្ថុសម្រាប់ការអាស្រ័យនៅរបស់គ្រួសារ" នៅក្នុងកថាខណ្ឌទី ៣ នៃមាត្រា ៩៧៦ (ការចាត់ចែងទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ) ។

ត្រូវកែពាក្យ "ខេត្ត ក្រុង" ទៅជា "រាជធានី ខេត្ត" នៅក្នុងចំណុច ខ នៃមាត្រា ១០៤២ (ករណីយកិច្ចពិភាក្សាអំពីចំណុចសំខាន់ៗ ទាក់ទងទៅនឹងកូន) ។

ត្រូវកែឃ្លា "សហព័ទ្ធ និង ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់អនីតិជននៅក្រោមអាណាព្យាបាល" ទៅជា "សហព័ទ្ធ និង ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន" នៅក្នុងមាត្រា ១០៧៦ (បុគ្គលដែលមិនអាចក្លាយជាអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន) ។



ត្រូវកែពាក្យ "ខេត្ត ក្រុង" ទៅជា "រាជធានី ខេត្ត" នៅក្នុងចំណុច ខ នៃមាត្រា ១០៤២ (ករណីយកិច្ចពិភាក្សាអំពីចំណុចសំខាន់ៗ ទាក់ទងទៅនឹងកូន) ។

ត្រូវកែឃ្លា "សហព័ទ្ធ និង ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់អនីតិជននៅក្រោមអាណាព្យាបាល" ទៅជា "សហព័ទ្ធ និង ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន" នៅក្នុងមាត្រា ១០៧៦ (បុគ្គលដែលមិនអាចក្លាយជាអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន) ។

ត្រូវកែឃ្លា "សហព័ទ្ធ និង ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់ជននៅក្រោមអាណាព្យាបាលទូទៅ" ទៅជា "សហព័ទ្ធ និង ញាតិនៅក្នុង ៤ (បួន) ថ្នាក់របស់អ្នកអាណាព្យាបាលទូទៅ" នៅក្នុងមាត្រា ១១១១ (បុគ្គលដែលមិន អាចក្លាយជាអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ) ។

ត្រូវកែឃ្លា "នៅមុនពេលចាប់ផ្តើមសន្តតិកម្ម" ទៅជា "នៅមុន ឬ ព្រមគ្នានឹងពេលចាប់ផ្តើមសន្តតិកម្ម" នៅក្នុងវាក្យខណ្ឌទី១ កថាខណ្ឌទី១ នៃមាត្រា១១៥៧ (សន្តតិកម្មជំនួស) ។

ត្រូវបន្ថែមឃ្លា "ចំពោះសន្តតិកម្មនោះ" បន្ទាប់ពីឃ្លា "បុគ្គលនោះមិនមែនជាសន្តតិជន" នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៦១ (អានុភាពនៃការបោះបង់) ។

ត្រូវកែឃ្លា "ការបែងចែកត្រូវធ្វើជាលាយលក្ខណ៍អក្សរទៅតាមទម្រង់នីមួយៗដែលចាំបាច់នៅក្នុងការផ្ទេរសិទ្ធិនោះ" ទៅជា "ការបែងចែកត្រូវធ្វើទៅតាមទម្រង់ចាំបាច់ដើម្បីផ្ទេរសិទ្ធិនីមួយៗនោះ ដូចជាលិខិតជាលាយលក្ខណ៍អក្សរជាអាទិ៍" នៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ១២៦៦ (ការពិភាក្សាបែងចែកមរតក) ។

## មាត្រា ៨២.- ការចាត់ចែងអំពីក្រមរដ្ឋប្បវេណីចាស់

ក្រមរដ្ឋប្បវេណីចាស់ ដែលបានអនុញ្ញាតប្រកាសឲ្យប្រើ ដោយព្រះមហាក្សត្រ នៅថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩២០ និង ដែលត្រូវបានធ្វើវិសោធនកម្មបន្តបន្ទាប់រហូតដល់មុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ មិនមានអានុភាពឡើយ ។

## មាត្រា ៨៣.- អានុភាពនៃច្បាប់ និងបទដ្ឋានគតិយុត្តផ្សេងទៀត

ក្រៅពីច្បាប់ និង បទដ្ឋានគតិយុត្តដែលកំណត់ចាប់ពីមាត្រា ៧៨ (ការធ្វើឲ្យនិរាករនូវច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ) ដល់មាត្រា ៨២ (ការចាត់ចែងអំពីក្រមរដ្ឋប្បវេណីចាស់) ច្បាប់ និង បទដ្ឋានគតិយុត្តផ្សេងទៀតដែល មានអានុភាពនៅកាលបរិច្ឆេទនៃការអនុវត្ត ហើយផ្ទុយនឹងបញ្ញត្តិនៃក្រមរដ្ឋប្បវេណី និងត្រូវមានអានុភាពត្រឹមទំហំ ដែលផ្ទុយនឹងក្រមរដ្ឋប្បវេណី ចាប់ពីកាលបរិច្ឆេទនៃការអនុវត្ត ។

## ជំពូកទី ៨
## អវសានប្បញ្ញត្តិ

**មាត្រា៨៤.– ការលបរិច្ឆេទនៃការអនុវត្ត**

ក្រោយពេលចូលជាធរមាននៅទូទាំងប្រទេស ច្បាប់នេះត្រូវផ្សព្វផ្សាយក្នុងរយៈពេល ៦ (ប្រាំមួយ) ខែ ទើបត្រូវអនុវត្ត ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី *៣១* ខែ *ឧសភា* ឆ្នាំ ២០១១

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

៣រល.១១០៥.៥០៩

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
**ហត្ថលេខា**
**អង្គ វង្ស វឌ្ឍានា**

លេខៈ ៤៦៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១១
...ជាតិបាល

**ឃុន ជិនកេន**

# មាតិកា

ទំព័រ

**ជំពូកទី ១ បទប្បញ្ញត្តិទូទៅ** ........ ១
**មាត្រា ១.**- គោលដៅនៃច្បាប់នេះ ........ ១
**មាត្រា ២.**- គោលបំណងនៃច្បាប់នេះ ........ ១
**មាត្រា ៣.**- វិសាលភាពនៃច្បាប់នេះ ........ ១
**មាត្រា ៤.**- កាលបរិច្ឆេទនៃការអនុវត្តក្រមរដ្ឋប្បវេណី ........ ១
**មាត្រា ៥.**- គោលការណ៍នៃការអនុវត្តក្រមរដ្ឋប្បវេណី ........ ១
**ជំពូកទី ២ បញ្ញត្តិសារធាតុ** ........ ២
**មាត្រា ៦.**- ការដាក់ជូនបញ្ជីសារពើភណ្ឌ ជាអាទិ៍ ទៅតុលាការ ........ ២
**មាត្រា ៧.**- ការជូនដំណឹងអំពីការបង្ហាញឆន្ទៈទៅអ្នកនៅឆ្ងាយ ........ ២
**មាត្រា ៨.**- និយមន័យនៃលិខិតដែលមានកាលបរិច្ឆេទស្អាពរ ........ ៣
**មាត្រា ៩.**- អត្ថន័យនៃលិខិតយថាភូត ........ ៤
**មាត្រា ១០.**- ការកំណត់មន្ត្រីទទួលបន្ទុកកិច្ចការសារការី ........ ៥
**មាត្រា ១១.**- សិទ្ធិអំណាចរបស់មន្ត្រីទទួលបន្ទុកកិច្ចការសារការី ជាអាទិ៍ ........ ៥
**មាត្រា ១២.**- ការប្រកាសជាសាធារណៈ ........ ៦
**មាត្រា ១៣.**- សិទ្ធិរបស់កម្មសិទ្ធិករនៃដី ........ ៦
**មាត្រា ១៤.**- ភោគៈ ........ ៧
**មាត្រា ១៥.**- ក្នុងករណីដែលលទ្ធកម្មកម្មសិទ្ធិ ........ ៧
**មាត្រា ១៦.**- អន្តរប្បញ្ញត្តិ ........ ៧
**មាត្រា ១៧.**- អត្រាការប្រាក់ដែលត្រូវបានកម្រិត ជាអាទិ៍ ........ ៨
**ជំពូកទី ៣ ការចុះបញ្ជីនីតិបុគ្គល** ........ ៩
**មាត្រា ១៨.**- សមត្ថកិច្ចលើការចុះបញ្ជីនីតិបុគ្គល ........ ៩

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

**មាត្រា ១៩.-** បែបបទ និងទម្រង់នៃការចុះបញ្ជីនីតិបុគ្គល ......៩
**មាត្រា ២០.-** ពាក្យសុំចុះបញ្ជីនីតិបុគ្គល ......៩
**មាត្រា ២១.-** ការប្រតិបត្តិការចុះបញ្ជី ......១០
**មាត្រា ២២.-** ការចុះបញ្ជីចំពោះការផ្លាស់ប្តូរ ជាអាទិ៍ ......១០
**មាត្រា ២៣.-** ការបញ្ជាក់ ......១០
**មាត្រា ២៤.-** ករណីលើកលែងចំពោះការចុះបញ្ជីទីស្នាក់ការសាខា ......១០
**មាត្រា ២៥.-** ការប្រគល់សិទ្ធិឲ្យរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធ្វើប្រកាស ......១១
**ជំពូកទី ៤ ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ** ......១១
**មាត្រា ២៦.-** សមត្ថកិច្ចលើការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ......១១
**មាត្រា ២៧.-** បែបបទ និងទម្រង់នៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ......១១
**មាត្រា ២៨.-** ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ......១១
**មាត្រា ២៩.-** ការប្រតិបត្តិការចុះបញ្ជី ......១២
**មាត្រា ៣០.-** ការចុះបញ្ជីចំពោះការផ្លាស់ប្តូរ ជាអាទិ៍ ......១២
**មាត្រា ៣១.-** ការបញ្ជាក់ ......១៣
**មាត្រា ៣២.-** ការប្រគល់សិទ្ធិឲ្យរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធ្វើប្រកាស ......១៣
**ជំពូកទី ៥ អន្តរប្បញ្ញត្តិ** ......១៣
**មាត្រា ៣៣.-** ការអនុញ្ញាតឲ្យអនីតិជនប្រកបអាជីវកម្ម ......១៣
**មាត្រា ៣៤.-** ការចាត់ចែងអំពីសាជីវកម្ម ឬ មូលនិធិដែលមានអត្ថិភាពតាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត ......១៣
**មាត្រា ៣៥.-** ការចុះបញ្ជីសាជីវកម្ម ឬមូលនិធិដែលមានអត្ថិភាពតាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត ជាអាទិ៍ ......១៥
**មាត្រា ៣៦.-** បញ្ជីទ្រព្យសម្បត្តិ ឬបញ្ជីរាយនាមសមាជិក ......១៥

ROYAUME DU CAMBODGE * LE MINISTÈRE DU PALAIS

**មាត្រា ៣៧**.. បញ្ញត្តិពិសេសអំពីពេលដែលនីតិបុគ្គលត្រូវបានបង្កើត....................១៥
**មាត្រា ៣៨**.. អានុភាពនៃសិទ្ធិប្រត្យក្សដែលមានអត្ថិភាពតាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត....១៦
**មាត្រា ៣៩**.. ការកាន់កាប់ចលនវត្ថុតាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត....................១៦
**មាត្រា ៤០**.. ឧបាគមន៍តាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត....................១៦
**មាត្រា ៤១**.. អំឡុងពេលដែលសិទ្ធិជួលរយៈពេលវែងតាំងពីមុនកាលបរិច្ឆេទនៃការអនុវត្តមាន អត្ថិភាព....................១៧
**មាត្រា ៤២**.. ផលុបភោគដែលត្រូវបានដាក់ជានាវ៉ាប់វង....................១៧
**មាត្រា ៤៣**.. អន្តរប្បញ្ញត្តិស្តីពីសិទ្ធិប្រើប្រាស់ និងសិទ្ធិអាស្រ័យនៅ ដែលត្រូវបានចុះបញ្ជី..........១៨
**មាត្រា ៤៤**.. អន្តរប្បញ្ញត្តិស្តីពីការប្រាក់សមាស....................១៨
**មាត្រា ៤៥**.. អន្តរប្បញ្ញត្តិស្តីពីការមិនអនុវត្តកាតព្វកិច្ច....................១៨
**មាត្រា ៤៦**.. អន្តរប្បញ្ញត្តិស្តីពីបញ្ញត្តិពិសេសអំពីកាតព្វកិច្ចជាប្រាក់....................១៩
**មាត្រា ៤៧**.. អន្តរប្បញ្ញត្តិស្តីពីការទូទាត់....................១៩
**មាត្រា ៤៨**.. អន្តរប្បញ្ញត្តិស្តីពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិ....................១៩
**មាត្រា ៤៩**.. ពេលចាប់ផ្តើមការអនុវត្តបញ្ញត្តិស្តីពីការផ្អាកអាជ្ញាយុកាល និងការបង្អង់ការសម្រេច អាជ្ញាយុកាល....................២០
**មាត្រា ៥០**.. ការអនុវត្តដូចគ្នាចំពោះអំឡុងពេលដែលច្បាប់បានកំណត់....................២០
**មាត្រា ៥១**.. អន្តរប្បញ្ញត្តិស្តីពីកិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ការប្រាក់....................២០
**មាត្រា ៥២**.. អន្តរប្បញ្ញត្តិក្នុងករណីដែលវត្ថុជួលមានវិការៈ....................២០
**មាត្រា ៥៣**.. អន្តរប្បញ្ញត្តិស្តីពីសេចក្តីចម្រើនដោយឥតហេតុ....................២១
**មាត្រា ៥៤**.. ការធានាកាតព្វកិច្ចតាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត....................២១
**មាត្រា ៥៥**.. ការចាត់ចែងអំពីការដាក់ធានា....................២១
**មាត្រា ៥៦**.. ការចាត់ចែងអំពីកិច្ចសន្យាបង្កើតសិទ្ធិប្រាតិភោគប្រត្យក្សដែលមិនទាន់ចុះបញ្ជី....២២
**មាត្រា ៥៧**.. អំឡុងពេលដែលសិទ្ធិលើការបញ្ចាំអចលនវត្ថុ មានអត្ថិភាព....................២២
**មាត្រា ៥៨**.. ការកំណត់ការធានាបំណុលអណ្តែតសាកល....................២៣

**មាត្រា ៥៩.-** ការបាត់ខ្លួនរបស់សហព័ទ្ធ ........................................ ២៣
**មាត្រា ៦០.-** អន្តរប្បញ្ញត្តិស្តីពីការប្រកាសផ្សាយជាសាធារណៈអំពីអាពាហ៍ពិពាហ៍ .................. ២៣
**មាត្រា ៦១.-** អន្តរប្បញ្ញត្តិស្តីពីការប្តឹងជំទាស់ និងប្តឹងទាស់មិនឲ្យរៀបអាពាហ៍ពិពាហ៍ ............ ២៣
**មាត្រា ៦២.-** អន្តរប្បញ្ញត្តិស្តីពីការលុបចោលអាពាហ៍ពិពាហ៍ ជាអាទិ៍ ........................ ២៤
**មាត្រា ៦៣.-** អន្តរប្បញ្ញត្តិស្តីពីមូលហេតុនៃការលែងលះគ្នា ........................ ២៤
**មាត្រា ៦៤.-** អន្តរប្បញ្ញត្តិស្តីពីនីតិវិធីលែងលះគ្នា ........................ ២៥
**មាត្រា ៦៥.-** ការសន្មតបិតុភាព ជាអាទិ៍ ........................ ២៥
**មាត្រា ៦៦.-** ការទទួលស្គាល់ដោយបង្ខំ ........................ ២៦
**មាត្រា ៦៧.-** សុំកូនដែលបានធ្វើមុនកាលបរិច្ឆេទនៃការអនុវត្ត ........................ ២៦
**មាត្រា ៦៨.-** អន្តរប្បញ្ញត្តិស្តីពីការដាក់ពាក្យសុំកូន ........................ ២៦
**មាត្រា ៦៩.-** អំណាចមេបាក្រោយការលែងលះគ្នា ........................ ២៧
**មាត្រា ៧០.-** អន្តរប្បញ្ញត្តិស្តីពីការសុំដកហូតអំណាចមេបា ជាអាទិ៍ ........................ ២៧
**មាត្រា ៧១.-** ការអនុវត្តបញ្ញត្តិស្តីពីសន្តតិកម្ម ........................ ២៧
**ជំពូកទី ៦ ប្រតិបត្តិការដែលមានកិច្ចធានា** ........................ ២៧
**មាត្រា ៧២.-** គោលបំណងនៃជំពូកនេះ ........................ ២៧
**មាត្រា ៧៣.-** អានុភាពនៃប្រតិបត្តិការដែលមានកិច្ចធានា ដែលត្រូវបានធ្វើឡើងនៅមុនកាលបរិច្ឆេទនៃការអនុវត្តក្រមរដ្ឋប្បវេណី ........................ ២៨
**មាត្រា ៧៤.-** ការប្តូរទៅប្រតិបត្តិការដោយផ្អែកលើក្រមរដ្ឋប្បវេណី ........................ ២៨
**មាត្រា ៧៥.-** បញ្ញត្តិសន្មត ........................ ២៨
**មាត្រា ៧៦.-** អាទិភាពរវាងប្រតិបត្តិការដោយយោងតាមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា និង ប្រតិបត្តិការដោយយោងតាមក្រមរដ្ឋប្បវេណី ........................ ២៩
**មាត្រា ៧៧.-** ការការពារបុគ្គលសុចរិត ........................ ២៩
**ជំពូកទី ៧ វិសោធនកម្ម និងនិរាករណ៍នូវបទប្បញ្ញត្តិមួយចំនួននៃច្បាប់ជាធរមាន** ...២៩
**មាត្រា ៧៨.-** និរាករណ៍នូវបទប្បញ្ញត្តិមួយចំនួននៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ........... ២៩

LE MINISTERE DU PALAIS ROYAL

**មាត្រា ៧៩.**- និរាករណ៍នូវបទប្បញ្ញត្តិមួយចំនួននៃក្រឹត្យ-ច្បាប់ លេខ ៣៨ ក្រ.ច ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា ..... ២៩

**មាត្រា ៨០.**- វិសោធនកម្មនូវបទប្បញ្ញត្តិមួយចំនួននៃច្បាប់ភូមិបាល ឆ្នាំ ២០០១ ..... ៣០

**មាត្រា ៨១.**- វិសោធនកម្មនូវបទប្បញ្ញត្តិមួយចំនួននៃក្រមរដ្ឋប្បវេណី ..... ៣២

**មាត្រា ៨២.**- ការចាត់ចែងអំពីក្រមរដ្ឋប្បវេណីចាស់ ..... ៣៦

**មាត្រា ៨៣.**- អានុភាពនៃច្បាប់ និងបទដ្ឋានគតិយុត្តផ្សេងទៀត ..... ៣៦

**ជំពូកទី ៨ អវសានបញ្ញត្តិ** ..... ៣៧

**មាត្រា ៨៤.**- កាលបរិច្ឆេទនៃការអនុវត្ត ..... ៣៧

# ក្រឹត្យច្បាប់លេខ ៣៨

# ស្តីពី

# កិច្ចសន្យា

# និង

# ការទទួលខុសត្រូវក្រៅកិច្ចសន្យា

# ក្រុមប្រឹក្សារដ្ឋ

## ក្រឹត្យ-ច្បាប់

## ក្រឹត្យ-ច្បាប់ លេខ ៣៨ ក្រ.ច

## ស្តីពី

## កិច្ចសន្យានិងការទទួលខុសត្រូវក្រៅកិច្ចសន្យា

- បានឃើញរដ្ឋធម្មនុញ្ញ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំរដ្ឋសភា និងក្រុមប្រឹក្សារដ្ឋ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ០៤ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២
- បានឃើញច្បាប់ ស្តីពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៣ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភ : ឆ្នាំ ១៩៨២
- បានឃើញច្បាប់ ស្តីពីការចាត់តាំងអង្គការតុលាការ និងអយ្យការ ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០២ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៗ ឆ្នាំ ១៩៨២
- បានឃើញច្បាប់ ស្តីពីការបង្កើតតុលាការកំពូល និងមហាអយ្យការអមតុលាការប្រជាជនកំពូល ដែលប្រ-កាសអោយប្រើតាមក្រឹត្យលេខ ២៨ ក្រ ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៨៥
- បានឃើញក្រឹត្យ ច្បាប់លេខ ៣៤ ក្រ.ច ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៨៧ ស្តីពីការចាត់តាំង និងសកម្ម-ភាពរបស់តុលាការកំពូល និងមហាអយ្យការអមតុលាការប្រជាជនកំពូល
- បានឃើញក្រឹត្យ-ច្បាប់លេខ ០៧ ក្រ.ច ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ១៩៨២ ស្តីពីសមត្ថកិច្ច និងនីតិវិធីនៃការធ្វើច្បាប់ និងបទបញ្ជា
- តាមសំណើរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី

## សំរេច

## ជំពូកទី ១

## ស្តីអំពីកិច្ចសន្យា

## ផ្នែកទី : ១ បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

កិច្ចសន្យា គឺជាឆន្ទៈព្រមព្រៀងរវាងបុគ្គលពីរនាក់ ឬច្រើននាក់ដើម្បីបង្កើតកែប្រែ ឬរំលត់កាតព្វកិច្ចមួយ ឬច្រើន ដែលទាក់ទិននឹងខ្លួន ។

ក្នុងអត្ថន័យខាងលើ បុគ្គលអាចជារូបវន្តបុគ្គល ឬជានីតិបុគ្គល ។

នីតិបុគ្គល អាចធ្វើកិច្ចសន្យាតាមរយៈបុគ្គលដែលជាតំណាងរបស់ខ្លួន ។

**មាត្រា ២.-**

កិច្ចសន្យាទាំងឡាយត្រូវរួមចំណែកក្នុងការផ្សារភ្ជាប់ផលប្រយោជន៍បុគ្គល និងផលប្រយោជន៍សង្គម ។

ភាគីនៃកិច្ចសន្យា ត្រូវសហការនឹងគ្នាក្នុងបរិយាសទុកចិត្ត ស្មោះត្រង់នឹងគ្នា អនុវត្តសមស្របនឹងគោលការណ៍សីល-ធម៌សង្គម ហើយជាពិសេស កំចាត់ចោលនូវគំនិត "មនុស្សជិះជាន់មនុស្ស" ។

## ផ្នែកទី ២ : សុពលភាព និងទម្រង់នៃកិច្ចសន្យា

**មាត្រា ៣.-**

កិច្ចសន្យាទាំងឡាយនឹងយកជាការបាន លុះណាតែកាតព្វកិច្ចដែលកើតអំពីកិច្ចសន្យានោះ :

- កើតចេញពីការព្រមព្រៀងដោយពិតប្រាកដ និងដោយសេរី
- កើតចេញពីជនដែលមានសមត្ថភាពចុះកិច្ចសន្យា
- មានវត្ថុមួយដែលជាក់លាក់ ដែលអាចធ្វើកើត និងដែលស្របច្បាប់ របៀបរៀបរយសាធារណៈ ឬទំនៀមទំ-លាប់ដ៏ល្អប្រពៃ ។

**មាត្រា ៤.-**

កិច្ចសន្យា អាចធ្វើដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ ។ ច្បាប់អាចកំណត់អោយមានទម្រង់មួយជាក់លាក់ក្នុងការធ្វើកិច្ចសន្យា ។ កិច្ចសន្យាទាំងឡាយណាដែលមិនបានធ្វើតាមទម្រង់ដែលច្បាប់បានកំណត់ ត្រូវទុកជាមោឃៈ លើកលែងតែមានបទបញ្ញត្តិនៃវិធានច្បាប់ណាមួយកំណត់ផ្ទុយពីនេះ ។

កិច្ចសន្យាគ្រប់ប្រភេទ ស្តីពីប្រាក់ ឬវត្ថុដែលមានចំនួន ឬមានតម្លៃលើសពីប្រាំពាន់រៀលត្រូវធ្វើជាលាយល័ក្ខអក្សរ។

## ផ្នែកទី ៣ : មោឃភាពនៃកិច្ចសន្យា

**មាត្រា ៥.-**

ត្រូវទុកជាមោឃៈដាច់ខាត :

- កិច្ចសន្យាទាំងឡាយណាដែលមិនស្របនឹងច្បាប់ របៀបរៀបរយសាធារណៈ ឬទំនៀមទំលាប់ដ៏ល្អប្រពៃ ។
- កិច្ចសន្យាទាំងឡាយណាដែលមិនស្របនឹងផលប្រយោជន៍សង្គម ឬមិនស្របនឹងគោលការណ៍សីលធម៌សង្គម ។
- កិច្ចសន្យាទាំងឡាយណាដែលមានតាវកាលិក "កម្មវត្ថុនៃកិច្ចសន្យា" មិនអាចធ្វើកើត ។

**មាត្រា ៦.-**

អាចទុកជាមោឃៈបាន :

- កិច្ចសន្យាទាំងឡាយណាដែលមិនកើតចេញពីការព្រមព្រៀងដោយពិតប្រាកដ ឬដោយសេរី ។
- កិច្ចសន្យាទាំងឡាយណាដែលកើតចេញពីបុគ្គលគ្មានសមត្ថភាពចុះកិច្ចសន្យា ។

**មាត្រា ៧.-**

មិនអាចចាត់ទុកថា មានការព្រមព្រៀងត្រឹមត្រូវទេ កាលណាការព្រមព្រៀងនោះធ្វើដោយការភ័ន្តច្រឡំ ដោយមានហិង្សា ឬដោយការបន្លំបោកប្រាស់ ។

**មាត្រា ៨.-**

ការភ័ន្តច្រឡំនឹងទៅជាមូលហេតុមោឃភាពនៃកិច្ចសន្យាបាន បើមានការភ័ន្តច្រឡំទៅលើសារជាតិនៃរបស់ដែលជាកម្មវត្ថុនៃកិច្ចសន្យា ។

ការភ័ន្តច្រឡំទៅលើបុគ្គល មិនអាចចាត់ទុកជាមូលហេតុមោឃភាពនៃកិច្ចសន្យាបានឡើយលើកលែងតែបុគ្គលនោះជាមូលហេតុចម្បងនៃកិច្ចសន្យា ។

**មាត្រា ៩.-**

ហិង្សានឹងទៅជាមូលហេតុមោឃភាពនៃកិច្ចសន្យាបាន កាលណាហិង្សានោះជាការគំរាមកំហែង បង្ខិតបង្ខំតាមផ្លូវកាយ ឬផ្លូវចិត្ត ប្រព្រឹត្តទៅលើភាគីណាមួយ ឬទៅលើប្ដី ឬប្រពន្ធ បុព្វញាតិ ឬបច្ឆាញាតិណាមួយរបស់ភាគីនោះ ។

**មាត្រា ១០.-**

ការបន្លំបោកប្រាស់ ជាមូលហេតុមោឃភាពនៃកិច្ចសន្យា កាលណាមានឧបាយកល អំពើបញ្ឆោត អំពើបន្លំភូតភរប្រព្រឹត្តដោយភាគីណាមួយ ដែលជាហេតុបញ្ជាក់ច្បាស់ថា បើគ្មានកិច្ចកលទាំងនោះទេ ភាគីម្ខាងទៀតប្រាកដជាមិនធ្វើកិច្ចសន្យានោះឡើយ ។

**មាត្រា ១១.-**

កាលណានៅពេលចុះកិច្ចសន្យា ភាគីណាមួយឆ្លៀតទាញយកផលប្រយោជន៍ពីស្ថានភាពរបស់ភាគីម្ខាងទៀត ធ្វើកិច្ចសន្យាដោយមានចំណេញច្រើនមិនសមស្របមកលើខ្លួន ភាគីរងគ្រោះអាចប្ដឹងបដិសេធកិច្ចសន្យានោះបានជានិច្ច ។

**មាត្រា ១២.-**

នៅពេលចុះកិច្ចសន្យា កាលណាមានភាពខុសគ្នា មិនសមស្របរវាងតម្លៃនៃតាវកាលិក និងតម្លៃតាវកាលិកតបវិញភាគីរងគ្រោះអាចប្ដឹងបដិសេធកិច្ចសន្យាបាន ក្នុងលក្ខណៈដែលខ្លួនពុំដែលមានបំណងធ្វើអំណោយទេនោះ ។

**មាត្រា ១៣.-**

ភាគីដែលដោះសារ សំអាងថា ខ្លួនបានចុះកិច្ចសន្យាដោយមានការភ័ន្តច្រឡំ ដោយមានហិង្សា ឬដោយមានការបន្លំបោកប្រាស់ ដើម្បីមិនអនុវត្តកាតព្វកិច្ចដែលកើតចេញពីកិច្ចសន្យានេះ ត្រូវជូនភស្តុតាងអំពីរឿងនេះ ។

**មាត្រា ១៤.-**

ជនទាំងឡាយដែលមានអាយុគ្រប់ ១៨ឆ្នាំ អាចធ្វើកិច្ចសន្យាបានគ្រប់ពេលវេលា លើកលែងតែជនគំហាត់ដែលមានចែងក្នុងច្បាប់ ។

**មាត្រា ១៥.-**

អនីតិជន អាយុតិចជាង ១៨ ឆ្នាំ មិនអាចធ្វើអោយកើតសិទ្ធិ ឬករណីយកិច្ចនានា ជាពិសេស មិនអាចចុះកិច្ចសន្យាដោយគ្មានការយល់ព្រមពីអ្នកអាណាព្យាបាលស្របច្បាប់របស់ខ្លួនបានឡើយ ។

កិច្ចសន្យាដែលធ្វើដោយអនីតិជន គ្មានការយល់ព្រមជាបឋមពីអ្នកអាណាព្យាបាលស្របច្បាប់របស់ខ្លួននឹងអាចយកទៅអនុវត្តបាន លុះត្រាតែអាណាព្យាបាលស្របច្បាប់ឯកភាពលើកិច្ចសន្យានោះ ក្រោយពេលដែលអនីតិជន បានចុះកិច្ចសន្យានោះរួច ។

ប៉ុន្តែ ចំពោះកិច្ចសន្យាទាំងឡាយណា ធ្វើដោយអនីតិជនសំរាប់បំពេញការរស់នៅប្រចាំថ្ងៃនោះមិនចាំបាច់មានការយល់ព្រមពីអ្នកអាណាព្យាបាលស្របច្បាប់នៃអនីតិជននោះឡើយ ។

**មាត្រា ១៦.-**

គូសន្យានៃអសមត្ថជន មិនអាចដោះសា ដើម្បីគេចកែពីកាតព្វកិច្ចនៃកិច្ចសន្យា ដោយសំអាងថា រូបជនដែលចុះកិច្ចសន្យាជាមួយនឹងខ្លួននោះជាអសមត្ថជន បានឡើយ ។

**មាត្រា ១៧.-**

កិច្ចសន្យាទាំងឡាយ ត្រូវមានជាវត្ថុស្ថិតក្នុងពាណិជ្ជកម្ម ។ វត្ថុនោះត្រូវចែងអោយប្រាកដ ដោយឡែកពីគ្នា តាមប្រភេទ តាមបរិមាណ និងតាមគុណភាព ។

វត្ថុដែលនឹងមានក្នុងអនាគតកាល ក៏អាចជាវត្ថុនៃកិច្ចសន្យាបានដែរ ។ ប៉ុន្តែកិច្ចសន្យាលក់មរតក ដែលមានម្ចាស់នៅរស់ពុំអាចធ្វើបានឡើយ ទោះបីម្ចាស់មរតកនោះយល់ព្រមផងក៏ដោយ ។

**មាត្រា ១៨.-**

ជនគ្រប់រូប អាចនឹងប្តឹងសុំមោឃភាពដាច់ខាតនៃកិច្ចសន្យាដែលមានចែងក្នុងមាត្រា ៥ បានគ្រប់ពេលវេលា ។

**មាត្រា ១៩.-**

ក្នុងករណីមោឃភាពនៃកិច្ចសន្យា បណ្តាលមកពីមូលហេតុអសមត្ថភាព ការភ័ន្តច្រឡំ ហិង្សា ឬការបន្លំបោកប្រាស់ ការសុំមោឃភាពនៃកិច្ចសន្យានេះ អាចនឹងធ្វើបានដោយភាគីរងគ្រោះ ឬដោយជនទាំងឡាយណាដែលមានប្រយោជន៍ស្របច្បាប់ ក្នុងការសុំមោឃភាពនោះ ។

ភាគីរងគ្រោះ ឬជនដែលមានប្រយោជន៍ស្របច្បាប់ក្នុងការសុំមោឃភាព ត្រូវអោយដំណឹងទៅភាគីម្ខាងទៀត ។ ភាគីដែលទទួលដំណឹងត្រូវឆ្លើយតបជាបន្ទាន់ ។ ក្រោយពេលអោយដំណឹង ភាគីរងគ្រោះ ឬជនដែលមានប្រយោជន៍ស្របច្បាប់ក្នុងការសុំមោឃភាព អាចប្តឹងសុំមោឃភាពនៃកិច្ចសន្យានោះក្នុងរយៈពេល ១២ខែ យ៉ាងយូរ ។

**មាត្រា ២០.-**

សិទ្ធិសុំប្តឹងមោឃភាពនៃកិច្ចសន្យាដែលមានចែងក្នុងមាត្រា ១៩ ត្រូវរលត់ ប្រសិនបើក្រោយពីពេលប្តឹងសុំមោឃភាពនោះមក ជនដែលមានសិទ្ធិប្តឹងនេះយល់ព្រមអនុវត្តកាតព្វកិច្ចរបស់ខ្លួន ឬសុំឈប់ប្តឹងវិញដោយលាយល័ក្ខអក្សរ អំពីមោឃភាពនៃកិច្ចសន្យានោះ ។

**មាត្រា ២១.-**

ក្នុងករណីមានមោឃភាពនៃកិច្ចសន្យា ស្ថានភាពដែលមាននៅមុនពេលចុះកិច្ចសន្យាត្រូវមានឡើងវិញ ។

## ផ្នែកទី ៤ : អានុភាព និងការបកស្រាយនៃកិច្ចសន្យា

**មាត្រា ២២.-**

កិច្ចសន្យាទុកជាច្បាប់របស់គូភាគី ។

កិច្ចសន្យានឹងអាចកែប្រែបាន លុះត្រាតែមានការយល់ព្រមរបស់គូភាគី ។ កិច្ចសន្យាត្រូវយកទៅអនុវត្តដោយសុចរិត និងតាមបំណងនៃគូភាគី ។

កិច្ចសន្យាមានអានុភាពតែទៅលើភាគីនៃកិច្ចសន្យាតែប៉ុណ្ណោះ ។

**មាត្រា ២៣.-**

កាលបើកិច្ចសន្យាធ្វើឡើងដោយមានន័យមិនច្បាស់ កិច្ចសន្យានោះត្រូវបកស្រាយតាមទម្លាប់ប្រើ ឬតាមទំនៀមទំលាប់នៃកន្លែងដែលកិច្ចសន្យានោះបានធ្វើ កុំអោយតែការបកស្រាយនោះផ្ទុយនឹងបទបញ្ញត្តិនៃក្រឹត្យ-ច្បាប់នេះ ។

ក្នុងករណីសង្ស័យ កិច្ចសន្យាត្រូវបានបកស្រាយជាប្រយោជន៍នៃភាគីកូនបំណុល ។

**មាត្រា ២៤.-**

ភាគីកូនបំណុលនៃកិច្ចសន្យា មានកាតព្វកិច្ចសងដោយទ្រព្យសម្បត្តិជាចលនវត្ថុ និងអចលនវត្ថុ បច្ចុប្បន្ន និងអនាគត ។

## ផ្នែកទី ៥ : អាជ្ញាយុកាលនៃកិច្ចសន្យា

**មាត្រា ២៥.-**

លើកលែងតែច្បាប់ចែងផ្សេងពីនេះ កាតព្វកិច្ចទាំងឡាយដែលកើតចេញពីកិច្ចសន្យាត្រូវផុតអាជ្ញាយុកាល កាលបើភាគីដើមបំណុលមិនប្តឹងទាមទារអោយអនុវត្តក្នុងអំឡុងពេល ៥ ឆ្នាំ គិតពីថ្ងៃកំណត់ក្នុងកិច្ចសន្យា ឬបើគ្មានកំណត់ថ្ងៃទេ ត្រូវគិតពីថ្ងៃចុះកិច្ចសន្យា ។

**មាត្រា ២៦.-**

អាជ្ញាយុកាលត្រូវបានផ្អាកសិន កាលបើភាគីកូនបំណុលអវត្តមានពីលំនៅស្ថានហើយអវត្តមាននេះត្រូវបានរដ្ឋអំណាចមូលដ្ឋានបញ្ជាក់ត្រឹមត្រូវតាមច្បាប់ ។

បណ្តឹងរបស់ភាគីដើមបំណុល ក៏ត្រូវផ្អាកអាជ្ញាយុកាលនៃកិច្ចសន្យាដែរ ។

**មាត្រា ២៧.-**

កូនបំណុល ឬអ្នកធានា អាចនឹងលើកយកអាជ្ញាយុកាលមកតវ៉ាបាន ។ បើកូនបំណុល ឬអ្នកធានាពុំបានលើកយកអាជ្ញាយុកាលមកតវ៉ាទេ តុលាការប្រជាជន ត្រូវលើកជូសសាមីខ្លួន ។

**មាត្រា ២៨.-**

ភាគីកូនបំណុល ឬអ្នកធានាដែលបានបំពេញកាតព្វកិច្ចដែលផុតអាជ្ញាយុកាលរួចទៅហើយ ពុំអាចទាមទារយកចំនួនទឹកប្រាក់ ឬតម្លៃនេះយកវិញបានឡើយ ។

## ផ្នែកទី ៦ : ការអនុវត្តកិច្ចសន្យា

**មាត្រា ២៩.-**

កាតព្វកិច្ចទាំងឡាយដែលមានចែងក្នុងកិច្ចសន្យា ត្រូវតែអនុវត្តយ៉ាងទៀងទាត់ និងត្រឹមត្រូវ ជាពិសេសអំពីបរិមាណ គុណភាព ទីកន្លែង និងរយៈពេលកំណត់ ។

**មាត្រា ៣០.-**

ភាគីនីមួយៗ នៃកិច្ចសន្យាគឺ :

- កូនបំណុល ចំពោះកាតព្វកិច្ចដែលខ្លួនត្រូវធ្វើ
- ដើមបំណុល ចំពោះកាតព្វកិច្ចដែលខ្លួនត្រូវទារ

**មាត្រា ៣១.-**

ភាគីដើមបំណុលមិនអាចត្រូវបានបង្ខំ :

- អោយទទួលយកវត្ថុផ្សេងពីវត្ថុដែលខ្លួនត្រូវបាននោះឡើយ ថ្វីត្បិតតែតម្លៃនៃវត្ថុបង្ខំអោយយកនោះស្មើ ឬលើសតម្លៃនៃវត្ថុដែលត្រូវបាន ។
- អោយព្រមទទួលយកការអនុវត្តមួយផ្នែកនៃកិច្ចសន្យា ។ ប៉ុន្តែដោយយោលទៅលើស្មារតីសុចរិត និងស្ថានភាពក្រលំបាករបស់ភាគីកូនបំណុល តុលាការប្រជាជនអាចអោយបន្ថយរយៈពេលអនុវត្ត និងបង្គាប់ឱ្យបង្អង់បណ្តឹងសិន ។ ក្នុងករណីពិសេសនេះ សេចក្តីសំរេចត្រូវតែដាក់មូលហេតុអោយបានច្បាស់លាស់ ហើយតុលាការប្រជាជនត្រូវប្រើអំណាចនេះដោយប្រុងប្រយ័ត្នបំផុត ។

**មាត្រា ៣២.-**

ការអនុវត្តតាមកិច្ចសន្យា ត្រូវប្រព្រឹត្តទៅនៅលំនៅឋានរបស់កូនបំណុលក្នុងករណីដែលកិច្ចសន្យាពុំបានកំណត់កន្លែងផ្សេងទៀត ។

**មាត្រា ៣៣.-**

ក្នុងករណីគ្មានកំណត់រយៈពេលដើម្បីអនុវត្តកិច្ចសន្យា កូនបំណុលអាចសង ឬផ្តល់ទៅនៅពេលណាក៏បាន ហើយដើមបំណុលក៏អាចទារនៅពេលណាក៏បាន ។

## ជំពូកទី ២
## អំពីកិច្ចសន្យាមួយចំនួន ដែលត្រូវធ្វើញឹកញាប់
## ផ្នែកទី ១ : ការលក់

**មាត្រា ៣៤.-**

ការលក់ ជាកិច្ចសន្យាមួយដែលបុគ្គលម្នាក់មានកាតព្វកិច្ចផ្ទេរកម្មសិទ្ធិនៃវត្ថុមួយ ឬសិទ្ធិណាមួយអោយទៅបុគ្គលម្នាក់ទៀតដែលមានកាតព្វកិច្ច ត្រូវប្រគល់ប្រាក់ថ្លៃវត្ថុ ឬសិទ្ធិនោះមកវិញ ។

**មាត្រា ៣៥.-**

ត្រូវទុកជាមោឃៈ :

- ការលក់វត្ថុរបស់អ្នកដទៃ
- ការលក់វត្ថុពីប្តីអោយទៅប្រពន្ធ ឬពីប្រពន្ធអោយទៅប្តី
- ការលក់វត្ថុអវិភាគ "ដែលបំបែកពីគ្នាមិនបាន" ដោយសហកម្មសិទ្ធិករម្នាក់ដោយគ្មានបានទទួលការព្រមព្រៀងពីសហកម្មសិទ្ធិករឯទៀត ។

### ១-កាតព្វកិច្ចរបស់អ្នកលក់ :

**មាត្រា ៣៦.-**

អ្នកលក់ត្រូវរក្សាវត្ថុអោយបានល្អរហូតដល់ថ្ងៃកំណត់ ដើម្បីអាចបានអនុវត្តកាតព្វកិច្ចរបស់ខ្លួនដែលត្រូវប្រគល់វត្ថុនោះ ។

**មាត្រា ៣៧.-**

អ្នកលក់ត្រូវចៀសវាងកុំផ្លាស់ប្តូរ កែប្រែវត្ថុតាមរបៀបណាក៏ដោយ ចាប់តាំងពីថ្ងៃលក់រហូតដល់ថ្ងៃប្រគល់វត្ថុ ។

**មាត្រា ៣៨.-**

អ្នកលក់ត្រូវទទួលខុសត្រូវអំពីការអន្តរាយដែលបណ្តាលឡើងដល់វត្ថុនោះរហូតដល់ថ្ងៃដែលត្រូវប្រគល់ ។ ការលក់អាចរំលាយចោលបាន ប្រសិនបើវត្ថុដែលលក់នោះបាត់ ឬខូចខាតច្រើន មុនពេលប្រគល់ ឬក្នុងករណីដែលអ្នកលក់រកវត្ថុដូចគ្នាមកជំនួសមិនបាន ។ ប្រសិនបើការលក់ត្រូវរំលាយ អ្នកលក់ត្រូវបង់ជំងឺចិត្តអោយអ្នកទិញចំពោះការបាត់វត្ថុ ឬការខូចខាតវត្ថុបណ្តាលមកពីកំហុសរបស់អ្នកលក់ ។

**មាត្រា ៣៩.-**

អ្នកលក់ត្រូវប្រាប់អ្នកទិញនូវគុណភាពជាសារវ័ន្តនៃវត្ថុ ព្រមទាំងស្ថានភាពទាំងឡាយសំខាន់ៗទាក់ទងនឹងវត្ថុនោះ ជាពិសេសប្រាប់អំពីសិទ្ធិដែលអ្នកដទៃមានលើវត្ថុនោះ ឬអំពីបន្ទុកដែលមានលើវត្ថុនោះ ។ ម្យ៉ាងទៀតអ្នកលក់ក៏ត្រូវប្រគល់ដល់ដៃអ្នកទិញនូវឯកសារទាំងឡាយទាក់ទងនឹងស្ថានភាពទាំងនោះ ។

**មាត្រា ៤០.-**

អ្នកលក់ត្រូវប្រគល់ពុំមែនតែវត្ថុដើមប៉ុណ្ណោះទេ ប៉ុន្តែត្រូវប្រគល់ផល ឬវត្ថុរាយរងទាក់ទងនឹងវត្ថុដើមទៀតផង ។

ក្នុងរឿងលក់អចលនវត្ថុ ការប្រគល់ប័ណ្ណនៃអចលនវត្ថុ ទុកជាការប្រគល់អចលនវត្ថុដោយត្រឹមត្រូវ ។ ប្រាក់ចំណាយក្នុងការប្រគល់វត្ថុត្រូវធ្លាក់មកលើអ្នកលក់ ប្រសិនបើគ្មានចែងផ្សេងពីនេះនៅក្នុងកិច្ចសន្យាលក់ទេនោះ ។

**មាត្រា ៤១.-**

ចំពោះអចលនវត្ថុ ការផ្ទេរសិទ្ធិរបស់អ្នកលក់អោយទៅអ្នកទិញទុកជាត្រឹមត្រូវបាន លុះត្រាតែសំបុត្រលក់នោះមានសេចក្តីបញ្ជាក់ និងប្រថាប់ត្រា ។ ចាប់តាំងពីថ្ងៃដែលសំបុត្រនោះមានសេចក្តីបញ្ជាក់ និងប្រថាប់ត្រា តតិយជនជំទាស់លែងបាន ។

ចំពោះអចលនវត្ថុ ការផ្ទេរកម្មសិទ្ធិទុកជាត្រឹមត្រូវបាន ហើយតតិយជនក៏ជំទាស់លែងបាន ចាប់តាំងពីពេលដែលប្រគល់វត្ថុនោះដល់ដៃអ្នកទិញ លើកលែងតែការលក់ត្រូវធ្វើជាសំបុត្រមានសេចក្តីបញ្ជាក់ ។ ក្នុងករណីខាងក្រោយនេះ តតិយជនជំទាស់លែងបាន ចាប់តាំងពីថ្ងៃដែលសំបុត្រនោះមានសេចក្តីបញ្ជាក់ ។

**មាត្រា ៤២.-**

អ្នកលក់ពុំទទួលខុសត្រូវចំពោះវិការៈដែលមើលឃើញពីក្រៅទេ  ប៉ុន្តែត្រូវទទួលខុសត្រូវចំពោះវិការៈដ៏កំបាំងដែលមានមុនពេលលក់ ។

បើអ្នកទិញមានភស្តុតាងថា វិការៈនោះមានមុនពេលលក់ អ្នកទិញអាចទាមទារអោយរំលាយការលក់នោះចោល ឬក៏បន្ថយថ្លៃបាន ។ ទោះនឹងលែងទិញក្តី ទោះនឹងទាមទារអោយបន្ថយថ្លៃក្តី អ្នកទិញត្រូវតវ៉ាក្នុងរយៈពេលមួយឆ្នាំចាប់ពីថ្ងៃប្រគល់វត្ថុ ។ បើមិនតវ៉ាក្នុងរយៈពេលមួយនេះទេ ការនៅស្ងៀមរបស់ខ្លួនទុកជាការយល់ព្រម ។

**មាត្រា ៤៣.-**

អ្នកលក់ត្រូវធានាដល់អ្នកទិញ  ចំពោះការរំខានណាដែលតតិយជនគំរាមថានឹងប្តឹងអោយដកហូតវត្ថុអ្នកទិញ  ។ សេចក្តីគំរាមថា  ប្តឹងអោយដកហូតនោះកើតឡើងក្នុងគ្រាដែលតតិយជនទាមទារអោយអ្នកទិញទទួលស្គាល់សិទ្ធិរបស់ខ្លួនលើវត្ថុនោះ។

**មាត្រា ៤៤.-**

ខណៈណាដែលមានតតិយជនគំរាមថានឹងប្តឹងអោយដកហូត    អ្នកទិញអាចទៅហៅអ្នកលក់អោយមកធានារ៉ាប់រងភ្លាមបាន  ។ ខណៈនោះអ្នកលក់ត្រូវបញ្ចេញប័ណ្ណរបស់ខ្លួនប្រើគ្រប់មធ្យោបាយ ដើម្បីអោយតតិយជនលែងប្តឹងទៅវិញ ឬក៏អោយ បានឈ្នះតតិយជននោះតាមអំណាចសាលក្រមរបស់តុលាការ ។

**មាត្រា ៤៥.-**

បើអ្នកលក់ដែលអ្នកទិញបានហៅអោយធានារ៉ាប់រងជួសខ្លួនរំងាប់សេចក្តីដែលតតិយជនប្រកាន់នោះបាន    អ្នកទិញមិនត្រូវបានជំងឺចិត្តអ្វីឡើយ  ។ បើអ្នកលក់រំងាប់សេចក្តីរំខាននោះមិនបានទេ ការប្តឹងផ្តល់ក៏ត្រូវប្រព្រឹត្តទៅតាមដំណើរ ។

**មាត្រា ៤៦.-**

បើតុលាការកាត់សេចក្ដីអោយដកហូតវត្ថុ អ្នកលក់ត្រូវបង្វិលថ្លៃទាំងអស់ដែលខ្លួនបានទទួលអោយអ្នកទិញវិញ ។ ម៉្យាងទៀតអ្នកលក់ត្រូវចេញជំងឺចិត្តផង នៅក្នុងជំងឺចិត្តនោះត្រូវគិតប្រាក់បង់ខាតក្នុងការធ្វើកិច្ចសន្យា និងប្រាក់ចំណាយផ្សេងៗដែលអ្នកទិញគិតបញ្ចូលទៅក្នុងវត្ថុនោះ តាំងពីថ្ងៃលក់មក ។

**មាត្រា ៤៧.-**

បើអ្នកលក់ស្លាប់ កាតព្វកិច្ចនៃការទទួលរ៉ាប់រងត្រូវធ្លាក់ទៅលើទាយាទទាំងអស់នៃអ្នកលក់ ។

**មាត្រា ៤៨.-**

បើវត្ថុដែលលក់នោះ បានមកដោយអំពើល្មើសជាបទឧក្រិដ្ឋ ឬជាបទល្មើសមធ្យម អ្នកទិញកាលបើដឹងហើយ អាចនឹងទាមទារអោយរំលាយការលក់នោះវិញបាន ទោះបីគ្មានតតិយជនណាគំរាមកំហែងដកហូតវត្ថុនោះវិញក៏ដោយ ។

កិច្ចសន្យាដែលផ្ទុយពីសេចក្ដីនេះ ត្រូវទុកជាមោឃៈ ។

**មាត្រា ៤៩.-**

ប្រសិនបើវត្ថុដដែល ហើយលក់អោយច្រើននាក់តៗគ្នា អ្នកទិញក្រោយបង្អស់ត្រូវហៅអ្នកដែលលក់អោយខ្លួនមកធានារ៉ាប់រង ។ អ្នកលក់នេះនិងប្រកាន់អ្នកដែលលក់អោយខ្លួនតៗគ្នាទៅទៀតតាមត្រូវការ ។

## ២-កាតព្វកិច្ចនៃអ្នកទិញ

**មាត្រា ៥០.-**

អ្នកទិញត្រូវប្រគល់ប្រាក់នៅថ្ងៃ និងនៅទីកន្លែងដែលបានកំណត់ ។ ប្រសិនបើកិច្ចសន្យាពុំមានកំណត់ទីកន្លែង និងថ្ងៃដែលត្រូវប្រគល់ប្រាក់ទេត្រូវសន្មត់ថា ការប្រគល់ប្រាក់ត្រូវធ្វើនៅទីកន្លែង និងនៅពេលដែលប្រគល់វត្ថុ ។

**មាត្រា ៥១.-**

កិច្ចសន្យា អាចតម្រូវអោយអ្នកទិញបង់ប្រាក់នៃតម្លៃវត្ថុ ក្នុងករណីមានការប្រគល់យឺតយ៉ាវ ។ អត្រានៃការប្រាក់នោះ មិនអាចគិតអោយលើសពី ៥ភាគរយ ក្នុងមួយឆ្នាំ ។

ប្រសិនបើកិច្ចសន្យាមិនកំណត់អំពីការប្រាក់ទេ អ្នកទិញត្រូវចេញតែថ្លៃវត្ថុដែលចុះកិច្ចសន្យា ប៉ុន្តែក្នុងករណីដែលវត្ថុនោះបង្កើតជាផល ឬជាផលទុន ការប្រាក់ត្រូវគិតតាមអត្រាដែលច្បាប់កំណត់ ។

**មាត្រា ៥២.-**

បើអ្នកទិញបានទទួលវត្ថុហើយ ហើយមានគេប្រកាន់ថានឹងប្ដឹងអោយដកហូតវត្ថុនោះវិញ អ្នកទិញអាចមិនទាន់បង់ថ្លៃវត្ថុនោះបាន ។ អ្នកទិញត្រូវប្រគល់ថ្លៃវត្ថុនោះទៅអោយអ្នកលក់កាលណាការរំខានបានត្រូវរំងាប់វិញហើយ ។

**មាត្រា ៥៣.-**

ដរាបណាអ្នកទិញមិនទាន់ចេញថ្លៃអោយ ដរាបនោះអ្នកលក់មានសិទ្ធិឃាត់វត្ថុនោះទុកដែរ ។

**មាត្រា ៥៤.-**

បើដល់ថ្ងៃសន្មត់ហើយ អ្នកទិញមិនបានបង់ថ្លៃ អ្នកលក់អាចសុំរំលាយការលក់នោះវិញបាន ប្រសិនបើអ្នកលក់មិនចង់ប្តឹងទាមទារថ្លៃនោះទេ ។ ដរាបណាភាគខ្លះនៃថ្លៃមិនទាន់សងអស់ ដរាបនោះអ្នកលក់អាចសុំរំលាយការលក់បាន ។

**មាត្រា ៥៥.-**

ការរំលាយការលក់តម្រូវអោយភាគីទាំងសងខាងនៃកាតព្វកិច្ចបង្វិលរបស់ដែលខ្លួនបានទទួលអោយគ្នាវិញ ។

អ្នកទិញត្រូវបង្វិលវត្ថុព្រមទាំងផល ឬផលទុនដែលខ្លួនបានយក ។

អ្នកលក់ត្រូវសងទៅអ្នកទិញវិញនូវប្រាក់ដែលអ្នកទិញបានចេញក្នុងថ្លៃវត្ថុ ហើយត្រូវគិតការប្រាក់តាមអត្រាដែលច្បាប់កំណត់ តាំងពីថ្ងៃដែលបានសងថ្លៃមួយលើក ៗ។

## ផ្នែកទី ២ : ការខ្ចីមានការប្រាក់

**មាត្រា ៥៦.-**

ការខ្ចីមានការប្រាក់ ជាកិច្ចសន្យាដែលបុគ្គលម្នាក់ប្រគល់ប្រាក់អោយទៅបុគ្គលម្នាក់ទៀត ហើយបុគ្គលក្រោយនេះមានកាតព្វកិច្ចសងវិញដោយមានតម្លើងទឹកប្រាក់ទៅតាមពេលវេលានៃកិច្ចសន្យា ។

**មាត្រា ៥៧.-**

កិច្ចសន្យាត្រូវធ្វើជាលាយល័ក្ខអក្សរ ។ កិច្ចសន្យាត្រូវកំណត់អោយច្បាស់អំពីទីលំនៅរបស់គូភាគី ចំនួនទឹកប្រាក់ដែលខ្ចី ចំនួនការប្រាក់រយៈពេលខ្ចី និងថ្ងៃសងវិញ ។ កូនបំណុលត្រូវចុះហត្ថលេខាលើកិច្ចសន្យានោះ ។

**មាត្រា ៥៨.-**

បើកិច្ចសន្យាមិនកំណត់ថ្ងៃសង និងមិនកំណត់ការប្រាក់ទេនោះ សន្មតថាគូភាគីព្រមព្រៀងចុះកិច្ចសន្យាសំរាប់រយៈពេលមួយឆ្នាំ ដោយគ្មានការប្រាក់ ។

**មាត្រា ៥៩.-**

នឹងអាចអោយយកការប្រាក់នៃប្រាក់ខ្ចីបាន លុះត្រាតែមានការព្រមព្រៀងនៃគូភាគីក្នុងកិច្ចសន្យា ។ អត្រានៃការប្រាក់មិនត្រូវអោយលើសពី ៥ភាគរយ ក្នុងមួយឆ្នាំ លើកលែងតែមានបទបញ្ញត្តិចែងផ្ទុយពីនេះ ។

**មាត្រា ៦០.-**

ការប្រាក់ដែលអ្នកអោយខ្ចីបានយកលើសរហូតមកក្នុងពេលដែលជំពាក់ ត្រូវកាត់ដាក់ជាសំណងប្រាក់ដើម ។

បើអ្នកខ្ចីបានសងលើសពីប្រាក់ដើម និងការប្រាក់តាមច្បាប់កំណត់ អ្នកអោយខ្ចីនឹងត្រូវបង្ខំអោយសងប្រាក់ដែលខ្លួនបានយកលើសខុសច្បាប់នោះទៅអ្នកខ្ចីវិញ ព្រមទាំងតម្រូវអោយបង់ការប្រាក់ផង គិតពីថ្ងៃដែលបានសង ។ ក្នុងករណីនេះ អ្នកអោយខ្ចីត្រូវជាប់ចោទតាមបទបញ្ញត្តិនៃច្បាប់ព្រហ្មទណ្ឌជាធរមានថែមទៀត ។

**មាត្រា ៦១.-**

ការប្តឹងទារប្រាក់មុនពេលផុតកំណត់នៃកិច្ចសន្យាមិនអាចធ្វើបានទេ ។ ប៉ុន្តែបើអ្នកជំពាក់បំណុលស្លាប់ ប្រាក់ដែលជំពាក់នោះតម្រូវឱ្យទារភ្លាមបាន ហើយទាយាទនៃអ្នកស្លាប់ត្រូវកាត់មរតកសងជាមុនសិន រួចសឹមចែកមរតជាក្រោយ ។

**មាត្រា ៦២.-**

ដើមបំណុល ត្រូវប្រគល់សំបុត្រជំពាក់ ឬសំបុត្របញ្ជាក់អំពីការសងប្រាក់អោយកូនបំណុលនៅពេលកូនបំណុលសងប្រាក់ទៅខ្លួន ។

**មាត្រា ៦៣.-**

ការខ្ចីមានការប្រាក់ លើទ្រព្យសម្បត្តិចលនវត្ថុឯទៀត ត្រូវប្រតិបត្តិតាមបទបញ្ញត្តិកំណត់សំរាប់ការខ្ចីប្រាក់ដែរ ។

## ផ្នែកទី ៣ : ការបញ្ចាំចលនវត្ថុ

**មាត្រា ៦៤.-**

ការបញ្ចាំអចលនវត្ថុ ជាកិច្ចសន្យាដែលកូនបំណុលយកទ្រព្យសម្បត្តិចលនវត្ថុរបស់ខ្លួនទៅទុកនៅដៃដើមបំណុលដើម្បីធានាសំណងបំណុល ។

ដើមបំណុលមានចលនវត្ថុនៅក្នុងដៃ មានសិទ្ធិយកប្រាក់សំណងដែលបានមកពីការលក់ចលនវត្ថុបញ្ចាំមុនដើមបំណុលឯទៀត ។

**មាត្រា ៦៥.-**

កិច្ចសន្យាបញ្ចាំចលនវត្ថុ ត្រូវធ្វើជាលាយល័ក្ខអក្សរ ។ ទ្រព្យដាក់ធានាត្រូវបានប្រគល់ដល់ដៃនៃដើមបំណុល ទើបកិច្ចសន្យានោះទុកជាបានការ ។

កិច្ចសន្យាត្រូវកំណត់ចំនួនទឹកប្រាក់ដែលជំពាក់ និងវត្ថុដែលបញ្ចាំ អោយច្បាស់លាស់ ។

បើកិច្ចសន្យាមិនកំណត់ថា ត្រូវមានការប្រាក់ទេ មិនកំណត់ពេលវេលាដែលត្រូវសងទេ បំណុលនេះត្រូវទុកអោយខ្ចីដោយឥតយកការប្រាក់ក្នុងកំណត់១ឆ្នាំគិតពីថ្ងៃដែលចុះកិច្ចសន្យានោះ ។ បំណុលនេះត្រូវទុកអោយខ្ចីដោយឥតការប្រាក់ក្នុងកំណត់១ឆ្នាំគិតពីថ្ងៃដែលចុះកិច្ចសន្យានោះ ។

**មាត្រា ៦៦.-**

ដើមបំណុលគ្មានសិទ្ធិចាត់ចែងវត្ថុបញ្ចាំតាមអំពើចិត្តរបស់ខ្លួនបានទេ ។ ដើមបំណុលមានករណីយកិច្ចទុកវត្ថុនោះឱ្យបានគង់វង់ និងថែរក្សាឱ្យបានល្អ ។ ក្នុងករណីដែលវត្ថុបញ្ចាំនោះត្រូវខូចខាត ឬបាត់បង់បណ្តាលមកពីកំហុសរបស់ខ្លួន ដើមបំណុលត្រូវជូសជុលសំណងវត្ថុបញ្ចាំនោះ ។

**មាត្រា ៦៧.-**

ប្រសិនបើគ្មានកំណត់ក្នុងកិច្ចសន្យាជាលាយល័ក្ខអក្សរច្បាស់លាស់ទេ ដើមបំណុលមិនត្រូវបានអនុញ្ញាតអោយយកវត្ថុបញ្ចាំនោះទៅប្រើប្រាស់ ឬទាញយកផលប្រយោជន៍ពីវត្ថុបញ្ចាំនោះបានទេ ។ ប៉ុន្តែដើមបំណុលត្រូវបានអនុញ្ញាតអោយទទួលផលធម្មជាតិនៃវត្ថុបញ្ចាំនោះបាន ។ ផលនោះទុកជាអាទិ៍សំរាប់ចំណាយចាំបាច់ទាំងឡាយ ។

ប្រសិនបើដើមបំណុលប្រើវត្ថុបញ្ចាំនោះដោយរំលោភលើកិច្ចសន្យា កូនបំណុលអាចប្តឹងសុំដកវត្ថុបញ្ចាំមកវិញបាន ។

**មាត្រា ៦៨.-**

ប្រសិនបើដើមបំណុលចាត់ចែងចំណាយវត្ថុបញ្ចាំដោយគ្មានបានទទួលការព្រមព្រៀងជាមុនពីកូនបំណុល នោះដើមបំណុលនឹងត្រូវជាប់ទោសតាមបទបញ្ញត្តិនៃច្បាប់ព្រហ្មទណ្ឌជាធរមាន ។

**មាត្រា ៦៩.-**

កាលណាដល់ថ្ងៃកំណត់ ហើយសំណងក៏ត្រូវបានប្រគល់អោយគ្រប់ចំនួនរួចស្រេចនោះដើមបំណុលត្រូវប្រគល់វត្ថុបញ្ចាំទៅម្ចាស់ដើមវិញ ។ បើកូនបំណុលមិនទាន់សងគ្រប់ចំនួនទេ ដើមបំណុលនឹងរក្សាទុកវត្ថុដែលបញ្ចាំនោះសិនបាន ។

**មាត្រា ៧០.-**

ប្រសិនបើដល់ថ្ងៃកំណត់ ហើយកូនបំណុលមិនលោះ ដើមបំណុលអាចទាមទារតាមរយៈតុលាការប្រជាជនឱ្យលក់វត្ថុបញ្ចាំ ។ ប្រាក់ដែលបានមកពីការលក់ ត្រូវសងទៅដើមបំណុលដែលបានទទួលបញ្ចាំវត្ថុនោះ ។ ប្រាក់សល់ពីនោះត្រូវប្រគល់អោយកូនបំណុល ឬដើមបំណុលឯទៀតដែលមានបំណុលដល់កំណត់ត្រូវសង ។

បើប្រាក់ថ្លៃលក់នោះមិនគ្រប់គ្រាន់នឹងសងបំណុលដែលបញ្ចាំវត្ថុនោះទេ កូនបំណុលត្រូវនៅជំពាក់បំណុលដែលនៅសល់តទៅទៀត ។

**មាត្រា ៧១.-**

ត្រូវទុកជាមោឃៈ កិច្ចសន្យាទាំងឡាយណាដែលកំណត់អោយដើមបំណុលទៅជាម្ចាស់កម្មសិទ្ធិនៃវត្ថុបញ្ចាំក្នុងករណីដែលកូនបំណុលមិនបានបំពេញកាតព្វកិច្ច ។

## ផ្នែកទី ៤ : កិច្ចសន្យាសហគ្រាស

**មាត្រា ៧២.-**

កិច្ចសន្យាសហគ្រាស ជាកិច្ចសន្យាដែលបុគ្គលមួយទទួលបន្ទុកធ្វើការងារអ្វីមួយអោយបុគ្គលមួយទៀត ដោយយកថ្លៃសមស្របនឹងទំហំនៃការងារនោះ ។

**មាត្រា ៧៣.-**

ប្រសិនបើថ្លៃការងារមិនបានកំណត់ក្នុងកិច្ចសន្យា តុលាការត្រូវវិនិច្ឆ័យកំណត់ថ្លៃទៅតាមទំលាប់នៃកន្លែងធ្វើការនោះ ។

**មាត្រា ៧៤.-**

ការងារត្រូវធ្វើអោយត្រឹមត្រូវតាមកិច្ចសន្យា ។ បើការងារនោះ មិនត្រូវតាមកំណត់ដែលមានចែងក្នុងកិច្ចសន្យាទេ អ្នកជួលអាច :

ក- ឬមួយមិនព្រមទទួលយកការងារនោះ ហើយក្នុងករណីនេះកិច្ចសន្យាអាចរំលាយបានដោយតម្រូវអោយអ្នកទទួលធ្វើ បង់ជម្ងឺចិត្តនិងសងសំណងខាតផ្សេងៗ ប្រសិនបើមានទៅអោយអ្នកជួល ។

ខ- ឬមួយតម្រូវអោយធ្វើការកែប្រែចាំបាច់ក្នុងរយៈពេលកំណត់ តាមការព្រមព្រៀងនៃគូភាគីដោយអ្នកទទួលធ្វើចេញប្រាក់ផ្ទាល់ខ្លួន ដើម្បីសំរួលតាមការកំណត់នៃកិច្ចសន្យាវិញ ។

គ-ឬមួយព្រមទទួលយកការងារនោះដោយបញ្ចុះថ្លៃ ។

**មាត្រា ៧៥.-**

ប្រសិនបើកិច្ចសន្យាកំណត់រយៈពេលដែលការងារត្រូវតែធ្វើអោយហើយក្នុងពេលណាមួយ ហើយបើការងារនោះធ្វើមិនហើយតាមពេលកំណត់ កិច្ចសន្យាអាចលុបចោលវិញដោយពុំទាន់គិតដល់ជម្ងឺចិត្តដែលអ្នកជួលអាចទាមទារបាន ។

ប៉ុន្តែប្រសិនបើការយឺតយ៉ាវបណ្តាលមកពីករណីប្រធានសក្តិ នោះអ្នកជួលពុំអាចទាមទារជម្ងឺចិត្តបានឡើយ ។

**មាត្រា ៧៦.-**

ប្រសិនបើអ្នកជួលបានសន្យាថានឹងបើកប្រាក់អោយមុនខ្លះ ឬវត្ថុធាតុដើមខ្លះអោយទាន់ពេលវេលា ហើយមិនបានបំពេញកាតព្វកិច្ចតាមកិច្ចសន្យានោះអ្នកជួលពុំអាចលើកយកការយឺតយ៉ាវក្នុងការអនុវត្តការងារមកសំអាង ដើម្បីបញ្ឈប់កិច្ចសន្យានោះបានឡើយ ។

អ្នកទទួលធ្វើអាចសំអាងលើការខាតបង់ពេលវេលារង់ចាំសម្ភារៈយូរ ដើម្បីលប់កិច្ចសន្យា ។ ក្នុងករណីនេះ អ្នកទទួលធ្វើត្រូវបានទទួលឈ្នួលសមស្របតាមការងារដែលខ្លួនបានធ្វើហើយ ។

**មាត្រា ៧៧.-**

អ្នកជួលអាចលប់ចោលកិច្ចសន្យាបានជានិច្ច នៅមុនពេលការងារធ្វើហើយជាស្ថាពរ ប៉ុន្តែត្រូវគិតថ្លៃការងារដែលបានធ្វើ គិតចំណាយផ្សេងៗ និងជម្ងឺចិត្តទៅអោយអ្នកទទួលធ្វើ ។

**មាត្រា ៧៨.-**

បើការងារអន្តរាយមុនពេលធ្វើរួច ដោយកំហុសនៃអ្នកទទួលធ្វើ ហើយអ្នកជួលបានបើកប្រាក់អោយមុន និងផ្តល់វត្ថុធាតុដើមអោយទៀត នោះអ្នកជួលមានសិទ្ធិទារសំណងស្មើនឹងការជួសជុលអន្តរាយ បណ្តាលមកពីការបាត់វត្ថុ និងចំណាយផ្សេងៗដែលខ្លួនបានចាយក្នុងការជួលធ្វើនោះ ។ ប៉ុន្តែបើការខូចខាតបណ្តាលមកពីករណីប្រធានសក្តិ ភាគីនៃកិច្ចសន្យាត្រូវទទួលផលវិបាក ដោយពុំអាចប្តឹងទាមទារពីគ្នាបានឡើយ ។

**មាត្រា ៧៩.-**

អ្នកទទួលធ្វើការងារ ត្រូវទទួលខុសត្រូវខាងបទរដ្ឋប្បវេណីចំពោះជនដែលខ្លួនប្រើអោយធ្វើការងារនោះ ។

**មាត្រា ៨០.-**

កាលបើការងារសំរេចបានហើយ អ្នកទទួលធ្វើ អាចទារថ្លៃនៅពេលប្រគល់ការងារបាន ។

ការប្រគល់ថ្លៃការងារ ទុកជាការព្រមទទួលយកការងារដែលធ្វើរួច ។

**មាត្រា ៨១.-**

កាលបើក្រោយពីបានប្រគល់ការងារមក គុណវិបត្តិ ឬវិការៈដ៏កំបាំងណាមួយបានផុសឡើងបណ្តាលមកពីកំហុសនៃអ្នកទទួលធ្វើក្នុងពេលដែលធ្វើការងារនោះ កិច្ចសន្យាត្រូវរំលាយចោល ឬត្រូវបង្វិលថ្លៃឈ្នួលខ្លះមកអោយអ្នកជួលវិញ ឬក៏ការងារនោះត្រូវជួសជុលដោយបង់ខាតលើអ្នកទទួលធ្វើ ។

អ្នកជួលអាចប្តឹងបានតែក្នុងករណីដែលវិការៈនោះលេចឡើងរយៈពេលដែលអ្នកទទួលធ្វើរ៉ាប់រងទទួលខុសត្រូវដូចមានចែងក្នុងកិច្ចសន្យា ។ បើគ្មានចែងអំពីរយៈពេលរ៉ាប់រងទទួលខុសត្រូវកិច្ចសន្យាទេ អ្នកជួលអាចប្តឹងបានក្នុងរយៈពេលបីឆ្នាំ គិតពីថ្ងៃដែលបានទទួលការងារនោះមក ។

**មាត្រា ៨២.-**

ចំពោះរូបវន្តបុគ្គល បើអ្នកទទួលធ្វើស្លាប់ កិច្ចសន្យានោះត្រូវរលាយ ។

## ផ្នែកទី ៥ : កិច្ចសន្យាដឹកជញ្ជូន

**មាត្រា ៨៣.-**

កិច្ចសន្យាដឹកជញ្ជូន ជាកិច្ចសន្យាដែលអ្នកដឹកជញ្ជូនសន្យាដឹកអ្នកដំណើរ ភារៈវត្ថុ ឬទំនិញពីកន្លែងមួយទៅកន្លែងមួយទៀត ដោយយកថ្លៃតាមការព្រមព្រៀង ឬតាមថ្លៃកំណត់របស់រដ្ឋ ។

**មាត្រា ៨៤.-**

កាលណាអ្នកដឹកជញ្ជូនយឺតយ៉ាវក្នុងការប្រគល់យានដឹកជញ្ជូន អ្នកបញ្ជូនមានសិទ្ធិបញ្ឈប់កិច្ចសន្យា ហើយតម្រូវ :

- អោយសងប្រាក់ចំណាយក្នុងការលើកដាក់ និងប្រាក់ដែលបានបង់រួចហើយទៅអោយអ្នកដឹកជញ្ជូនផ្សេងទៀត ។
- អោយសងជូសជុលអន្តរាយ បណ្តាលមកពីការយឺតយ៉ាវ "ករណីបាត់ ឬខូចភារៈវត្ថុ ឬទំនិញដែលត្រូវដឹកជញ្ជូន ឬការចុះតម្លៃ បណ្តាលមកពីការយឺតយ៉ាវ" ។

**មាត្រា ៨៥.-**

កាលណាអ្នកបញ្ជូនយឺតយ៉ាវក្នុងការលើកដាក់ភារៈវត្ថុ ឬទំនិញ អ្នកដឹកជញ្ជូនមានសិទ្ធិតំរូវអោយជូសជុលការបង់-ខាត និងបញ្ឈប់កិច្ចសន្យា ។

**មាត្រា ៨៦.-**

អ្នកដឹកជញ្ជូនត្រូវទទួលខុសត្រូវអំពីការបាត់បង់ ឬការខូចខាតលើវត្ថុដឹកជញ្ជូន ។ អ្នកដឹកជញ្ជូនក៏ត្រូវទទួលខុសត្រូវអំពីគ្រោះថ្នាក់ដែលបណ្តាលឡើងដល់អ្នកដំណើរក្នុងពេលដែលខ្លួនដឹកជញ្ជូនដែរ ។

អ្នកដឹកជញ្ជូនត្រូវបានរួចខ្លួនពីការទទួលខុសត្រូវខាងលើ ក្នុងករណីប្រធានសក្តិ ឬក្នុងករណីអ្នកដំណើរត្រូវរងគ្រោះដោយមកពីការធ្វេសប្រហែសរបស់ខ្លួន ។

បើភារៈវត្ថុ ឬទំនិញដែលត្រូវគេប្រគល់អោយដឹកជញ្ជូនអន្តរាយដោយចោរកម្ម អ្នកដឹកជញ្ជូនត្រូវជូសជុលសំណងនៃភារៈវត្ថុ ឬទំនិញនេះ ។

**មាត្រា ៨៧.-**

អ្នកដឹកជញ្ជូនត្រូវធានាអំពីការខូចខាតលើវត្ថុ ប្រសិនបើការខូចខាតនោះមិនមែនបណ្តាលមកពីករណីប្រធានសក្តិ ឬវិបត្តិផ្ទាល់នៃវត្ថុនោះ ។ អ្នកដឹកជញ្ជូនត្រូវទទួលខុសត្រូវជាពិសេសចំពោះការបាត់បង់ ឬការខូចខាត បណ្តាលមកពីការ

យឺតយ៉ាវដោយគ្មានមូលហេតុសមស្របនៅពេលដឹកជញ្ជូន ។

**មាត្រា ៨៨.-**

បណ្តឹងសុំជួសជុលការខូចខាត ត្រូវធ្វើក្នុងរយៈពេល ១ឆ្នាំ គិតពីថ្ងៃដែលម្ចាស់របស់បានដឹងថាបាត់ ឬខូចខាត ឬគិតពីថ្ងៃដែលអ្នកដំណើរបានទទួលរងគ្រោះ ។

## ផ្នែកទី ៦ : កិច្ចសន្យានៃការផ្ញើទុក

**មាត្រា ៨៩.-**

កិច្ចសន្យានៃការផ្ញើទុក ជាកិច្ចសន្យាដែលជនម្នាក់ផ្ញើអចលនវត្ថុណាមួយនឹងជនម្នាក់ទៀតអោយរក្សាទុក ដោយឥតយកឈ្នួល ឬយកឈ្នួលហើយអោយប្រគល់វត្ថុនោះ ទៅជនយកមកផ្ញើនោះវិញ ឬប្រគល់អោយជនណាដែលអ្នកផ្ញើប្រាប់ឈ្មោះមកយ៉ាងច្បាស់តាមពេលដែលសន្មត ឬនៅពេលដែលទារយកវត្ថុនោះវិញ ។

**មាត្រា ៩០.-**

តាមគោលការណ៍ បើកិច្ចសន្យាមិនបានចែងអំពីឈ្នួលទេ អ្នកទទួលបញ្ញើមិនត្រូវបានឈ្នួលឡើយ ។

**មាត្រា ៩១.-**

អ្នកទទួលបញ្ញើត្រូវរក្សាបញ្ញើអោយគង់ ហើយត្រូវប្រគល់អោយវិញនៅពេលដែលបានសន្មត់ ឬនៅពេលដែលអ្នកផ្ញើមកយក ។

អ្នកទទួលបញ្ញើ គ្មានយកបញ្ញើទៅប្រើប្រាស់ទេ បើគ្មានការអនុញ្ញាតពីអ្នកផ្ញើ ។

**មាត្រា ៩២.-**

អ្នកទទួលបញ្ញើត្រូវទទួលខុសត្រូវលើការខូចខាត ឬ ការបាត់បង់នៃបញ្ញើដែលបានកើតឡើងដោយកំហុសរបស់ខ្លួន ។

បើបញ្ញើអន្តរាយ ឬបាត់ដោយករណីប្រធានសក្តិ អ្នកទទួលបញ្ញើមិនត្រូវសងទេ ។

**មាត្រា ៩៣.-**

បើផ្ញើមានឈ្នួល ហើយបញ្ញើនោះត្រូវអន្តរាយដោយចោរកម្ម អ្នកទទួលបញ្ញើត្រូវសង ។

បើផ្ញើឥតឈ្នួល ហើយបញ្ញើត្រូវអន្តរាយដោយចោរកម្ម អ្នកទទួលបញ្ញើមិនត្រូវសងទេ ប្រសិនបើអ្នកទទួលបញ្ញើមានភស្តុតាងបញ្ជាក់ថា ខ្លួនមានការប្រុងប្រយ័ត្នដែរក្នុងការរក្សាបញ្ញើនោះ ។

ប៉ុន្តែម្ចាស់សណ្ឋាគារ ម្ចាស់តៀម ម្ចាស់ភោជនាគារ ត្រូវទទួលសងទ្រព្យរបស់ជនទាំងឡាយដែលមកស្នាក់អាស្រ័យក្នុងគ្រឹះស្ថានរបស់ខ្លួន បានផ្ញើទ្រព្យនោះក្នុងគ្រឹះស្ថានរបស់ខ្លួន ហើយត្រូវអន្តរាយដោយចោរកម្ម ។

## ផ្នែកទី ៧ : កិច្ចសន្យានៃការអោយខ្ចីប្រើ

**មាត្រា ៩៤.-**

ការអោយខ្ចីប្រើ គឺគ្មានយកប្រាក់ ឬយកឈ្នួលអ្វីទេ ។ អ្នកដែលអោយវត្ថុណាមួយទៅគេខ្ចីប្រើ នៅតែជាកម្មសិទ្ធិករ

នៃវត្ថុនោះដដែល ។

**មាត្រា ៩៥.-**

អ្នកខ្ចីមិនអាចលក់ ឬ ដូរវត្ថុ ឬ អោយវត្ថុនោះទៅតតិយជនខ្ចីប្រើដោយគ្មានការព្រមព្រៀងពីអ្នកឱ្យខ្ចីបានឡើយ ។

**មាត្រា ៩៦.-**

អ្នកខ្ចី ត្រូវប្រើប្រាស់វត្ថុនោះអោយល្អ ថែទាំបីដូចខ្លួនជាម្ចាស់វត្ថុ និងប្រើអោយសមស្របនឹងមុខការរបស់វា ។

អ្នកខ្ចីត្រូវទទួលរ៉ាប់រងចេញសោហ៊ុយក្នុងការថែទាំវត្ថុនោះ ។

**មាត្រា ៩៧.-**

បើវត្ថុនោះខូចខាត ឬបាត់ដោយករណីប្រធានសក្តិ អ្នកខ្ចីមិនត្រូវទទួលសងឡើយ ប៉ុន្តែបើការខូចខាត ឬការបាត់បណ្តាលមកពីកំហុសរបស់ខ្លួន អ្នកខ្ចីត្រូវទទួលសងតម្លៃវត្ថុនោះទៅអ្នកអោយខ្ចី ។

**មាត្រា ៩៨.-**

អ្នកខ្ចីត្រូវប្រគល់វត្ថុអោយទៅម្ចាស់វត្ថុវិញ នៅពេលដែលបានកំណត់ ។ បើកិច្ចសន្យាគ្មានបានកំណត់យ៉ាងណាទេ អ្នកអោយខ្ចីអាចទារយកវត្ថុរបស់ខ្លួនវិញក្នុងពេលណាក៏បាន ។

**មាត្រា ៩៩.-**

បើអ្នកខ្ចីយកវត្ថុទៅប្រើការក្រៅពីមុខការរបស់វា អ្នកអោយខ្ចីអាចទារវត្ថុរបស់ខ្លួនភ្លាមវិញបាន ថ្វីបើមិនទាន់ដល់រយៈពេលកំណត់ ។

## ផ្នែកទី ៨ : កិច្ចសន្យានៃការជួល

**មាត្រា ១០០.-**

ការជួល ជាកិច្ចសន្យាដែលអ្នកជួលសន្យាថានឹងផ្តល់ទៅអោយអ្នកទទួលជួលនូវវត្ថុណាមួយ ដើម្បីប្រើប្រាស់ជាបណ្តោះអាសន្ន ដោយតម្រូវអោយគិតថ្លៃនៃការជួលវត្ថុនោះអោយអ្នកជួល ។

វត្ថុដែលអាចជួលនោះ គឺវត្ថុជាអចលនវត្ថុ ឬជាចលនវត្ថុ ។

**មាត្រា ១០១.-**

កិច្ចសន្យានៃការជួល អាចកំណត់ ឬមិនកំណត់ក៏បាននូវរយៈពេលនៃការជួលក្នុងករណីដែលគ្មានកំណត់រយៈពេលនៃការជួល ចិរវេលានៃកិច្ចសន្យាមានកំណត់ ១២ឆ្នាំ យ៉ាងយូរ ។

កិច្ចសន្យានៃការជួលដែលមានកំណត់លើសពីមួយឆ្នាំត្រូវធ្វើជាលាយល័ក្ខអក្សរ ។

**មាត្រា ១០២.-**

កាលបើកិច្ចសន្យានៃការជួលបានធ្វើដោយគ្មានសំបុត្រស្នាមហើយប្រសិនបើភាគីម្ខាងប្រកែក បន្ទាល់នៃការជួលនេះនឹងយកសំអាងសាក្សីមកបញ្ជាក់បាន លុះណាតែកិច្ចសន្យានៃការជួលនោះមានកំណត់ត្រឹមតែមួយឆ្នាំប៉ុណ្ណោះ ។

**មាត្រា ១០៣.-**

អ្នកជួលត្រូវប្រគល់វត្ថុដែលមានសភាពនៅល្អអោយទៅអ្នកទទួលជួល ត្រូវចៀសវាង នូវអំពើទាំងពួងដែលនាំឱ្យរំខានដល់អ្នកទទួលជួលហើយត្រូវរ៉ាប់រងដល់អ្នកទទួលជួលអំពីការរំខានទាំងឡាយដែលបណ្តាលមកពីតតិយជនដែលទាមទារសិទ្ធិណាមួយលើវត្ថុជួលនោះ ដូចជាកម្មសិទ្ធិ ការបញ្ចាំជាដើម ។

**មាត្រា ១០៤.-**

អ្នកជួល ត្រូវទទួលបន្ទុកនូវការជួសជុលធំៗចំពោះវត្ថុជួល លើកលែងតែច្បាប់ ឬកិច្ចសន្យាចែងផ្សេងពីនេះ ។

**មាត្រា ១០៥.-**

អ្នកទទួលជួល ត្រូវបង់ប្រាក់ថ្លៃឈ្នួល តាមកាលកំណត់ ត្រូវប្រើប្រាស់វត្ថុជួលអោយសមស្របនឹងមុខការនៃវត្ថុជួល និងតាមការកំណត់នៃកិច្ចសន្យា ត្រូវថែទាំវត្ថុនោះអោយបានគង់វង់ល្អ ត្រូវទទួលបន្ទុកនូវការជួសជុលបន្តិចបន្តួចដែលជាការជួសជុលធម្មតា លើកលែងតែច្បាប់ ឬកិច្ចសន្យាដែលចែងផ្សេងពីនេះ ។

**មាត្រា ១០៦.-**

នៅពេលចប់កិច្ចសន្យា អ្នកទទួលជួលត្រូវប្រគល់ទៅអោយអ្នកជួលវិញនូវវត្ថុជួលដែលត្រូវនៅមានសភាពល្អ គឺគ្មានការបាក់បែក គ្មានការខូចខាត ឬគ្មានការកែប្រែនៃវត្ថុនោះដែលបណ្តាលមកពីអំពើនៃអ្នកទទួលជួល ។

**មាត្រា ១០៧.-**

អ្នកជួលអាចរំលាយកិច្ចសន្យានៃការជួលបាន ប្រសិនបើអ្នកទទួលជួលមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន ឬក៏យកវត្ថុនោះទៅប្រើប្រាស់ខុសអំពីការដែលត្រូវប្រើ ឬក៏ប្រើក្នុងការដែលនាំអោយអន្តរាយដល់វត្ថុនោះ ។

**មាត្រា ១០៨.-**

អ្នកទទួលជួល មិនអាចជួលវត្ថុអោយទៅអ្នកដទៃដោយគ្មានការអនុញ្ញាតពីអ្នកជួលឡើយ លើកលែងកិច្ចសន្យាចែងផ្ទុយពីនេះ ។

**មាត្រា ១០៩.-**

អ្នកទទួលជួលដែលបានជួលវត្ថុបន្ត ត្រូវនៅជាប់កាតព្វកិច្ចជាមួយនឹងអ្នកជួលដដែល ជាអាទិ៍អ្នកទទួលជួលត្រូវទទួលខុសត្រូវលើអ្នកទទួលជួលបន្តពីខ្លួន ចំពោះការមិនបង់ប្រាក់ថ្លៃឈ្នួល ការបែកបាក់ ការខូចខាតទាំងឡាយនៃវត្ថុជួលដែលបណ្តាលមកពីអំពើរបស់អ្នកទទួលជួលបន្ត ។

**មាត្រា ១១០.-**

ចំពោះកិច្ចសន្យានៃការជួលសំរាប់ថិរវេលាគ្មានកំណត់ គូភាគីអាចនឹងរំលាយបាន លុះណាតែមានការអោយដំណឹងមុនមួយខែយ៉ាងតិច ឬពីរខែយ៉ាងយូរ ។

**មាត្រា ១១១.-**

ទោះអ្នកជួលស្លាប់ក្តី ក៏កិច្ចសន្យានៃការជួល ត្រូវតែអនុវត្តតទៅទៀត ។

បើអ្នកទទួលផលស្លាប់វិញ កិច្ចសន្យានៃការជួលនឹងលែងយកមកអនុវត្តបាន លុះណាតែទាយាទលែងចង់ជួលតទៅទៀត ។

## ផ្នែកទី ៩ : កិច្ចធានាដោយបុគ្គល

**មាត្រា ១១២.-**

កិច្ចធានាដោយបុគ្គល ជាកិច្ចសន្យាមួយដែលតតិយជនម្នាក់ ហៅថា អ្នកធានាសន្យានឹងដើមបំណុលថា ខ្លួនទទួលបំពេញកាតព្វកិច្ចរបស់កូនបំណុលជំនួសកូនបំណុល ប្រសិនបើកូនបំណុលនេះមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនចំពោះដើមបំណុល ។ កិច្ចសន្យានេះ ត្រូវធ្វើជាលាយល័ក្ខអក្សរ ។

**មាត្រា ១១៣.-**

បំណុលតែមួយ អាចមានអ្នកធានាច្រើនបាន ។

**មាត្រា ១១៤.-**

កិច្ចធានាណាមួយចែងអំពីកាតព្វកិច្ចដែលច្បាប់ទុកជាមោឃៈ កិច្ចធានានោះទុកជាអសារបង់ ។ ប៉ុន្តែបើមោឃភាពនោះមានមូលហេតុមកពីកូនបំណុលជាអនីតិជន កិច្ចធានានោះនៅទុកជាបានការដដែល ។

**មាត្រា ១១៥.-**

ដើមបំណុលអាចប្តឹងពីអ្នកធានាដំណាលគ្នា និងប្តឹងកូនបំណុលក៏បាន ឬប្តឹងក្រោយក៏បាន ។

**មាត្រា ១១៦.-**

ក្រោយពីមានសាលក្រមរបស់តុលាការប្រជាជន អ្នកធានាអាចទាមទារអោយដើមបំណុលអូសទ្រព្យកូនបំណុលលក់មុនសិន រួចសឹមសំរេចអូសទ្រព្យរបស់ខ្លួនជាក្រោយបាន ។

**មាត្រា ១១៧.-**

បើលក់ទ្រព្យរបស់នៃកូនបំណុលទៅហើយ បានប្រាក់មិនគ្រាន់នឹងសង បំណុលទាំងអស់នេះ អ្នកធានាត្រូវនៅជំពាក់ប្រាក់ដែលនៅខ្វះ ។

**មាត្រា ១១៨.-**

ក្នុងករណីមានអ្នកធានាច្រើននាក់ នោះអ្នកធានាម្នាក់ៗ ត្រូវជាប់ធានាបំណុលទាំងមូល ហាក់ដូចជាអ្នកធានាមានតែម្នាក់ ។ អ្នកធានាទាំងអស់ត្រូវរួបរួមគ្នាសងបំណុលទាំងនោះ ។

**មាត្រា ១១៩.-**

បើអ្នកធានាបានសងប្រាក់ជួសកូនបំណុលដែលខ្លួនធានាហើយ សិទ្ធិទាំងប៉ុន្មាននៃដើមបំណុលត្រូវបានទៅអ្នកធានាទាំងអស់ ។អ្នកធានាមានសិទ្ធិទារអោយកូនបំណុលសងប្រាក់ដែលខ្លួនបានសងជួសមកវិញ ព្រមទាំងការប្រាក់ និងសោហ៊ុយបង់ខាតតាំងពីថ្ងៃដែលខ្លួនបានសងជំនួស ។

**មាត្រា ១២០.-**

កាលបើមានអ្នកធានាម្នាក់បានចេញប្រាក់សងជំនួសកូនបំណុល អ្នកធានានេះអាចប្តឹងទារសំណងបានពីអ្នកធានាដទៃទៀត ដែលត្រូវសងតាមចំណែករៀងៗខ្លួនក្នុងករណីកូនបំណុលស្ថិតនៅក្នុងអសាធនភាព ។

## ជំពូកទី ៣

## អំពីការទទួលខុសត្រូវក្រៅកិច្ចសន្យា

**មាត្រា ១២១.-**

ជនណាបានធ្វើអោយមានការខូចខាតដល់អ្នកដទៃដោយកំហុសរបស់ខ្លួន ជននោះត្រូវជួសជុលការខូចខាតនោះ ។

ទោះបីការខូចខាតកើតមកអំពីអំពើប្រព្រឹត្តដោយអចេតនា ដូចជាការធ្វេសប្រហែស ឬការខ្វះការប្រុងប្រយ័ត្នក្នុងការត្រួតមើល ថែទាំក៏ដោយ ក៏ជនល្មើសត្រូវតែជួសជុលការខូចខាតនោះដែរ ។

**មាត្រា ១២២.-**

ជនវិកលចរិក និងអនីតិជនអាយុតិចជាង ១៤ឆ្នាំ ជាអសមត្ថជន ។ ជនទាំងនេះមិនត្រូវទទួលខុសត្រូវចំពោះការខូចខាតដែលខ្លួនបានធ្វើអោយកើតឡើងដល់អ្នកដទៃឡើយ ។

**មាត្រា ១២៣.-**

ឪពុក ម្តាយ អ្នកអាណាព្យាបាល ព្រមទាំងជនផ្សេងៗ ទៀតដែលទទួលបន្ទុកត្រួតមើលអសមត្ថជន ត្រូវទទួលខុសត្រូវផ្ទាល់ខ្លួនចំពោះការខូចខាតដែលអសមត្ថជននោះបានធ្វើអោយកើតឡើង ។

**មាត្រា ១២៤.-**

អនីតិជនអាយុច្រើនជាង ១៤ឆ្នាំ ប៉ុន្តែមិនទាន់គ្រប់ ១៨ឆ្នាំ ត្រូវទទួលខុសត្រូវចំពោះការខូចខាតដែលខ្លួនបានធ្វើដល់អ្នកដទៃ ។ ការជួសជុលការខូចខាតត្រូវអនីតិជននេះ និង ឪពុក ម្តាយ ឬអ្នកអាណាព្យាបាលនៃអនីតិជននោះទទួលខុសត្រូវរួម ។ ក្នុងករណីដែលអនីតិជននេះគ្មានប្រាក់ ឬទ្រព្យសម្បត្តិដើម្បីជួសជុលការខូចខាតនោះ ឪពុក ម្តាយ ឬអ្នកអាណាព្យាបាលត្រូវសងជួស ។

**មាត្រា ១២៥.-**

អង្គការរដ្ឋ អង្គការសង្គម អង្គការសមូហភាព សហគ្រាស ត្រូវទទួលខុសត្រូវចំពោះការខូចខាតដែលកម្មាភិបាល បុគ្គលិក កម្មកររបស់ខ្លួន បានធ្វើអោយកើតឡើងក្នុងពេល ឬនៅពេលបំពេញភារកិច្ច របស់ជនទាំងនោះ ។

**មាត្រា ១២៦.-**

និយោជក ត្រូវទទួលខុសត្រូវចំពោះការខូចខាតដល់អ្នកដទៃ បណ្តាលមកពីនិយោជិតរបស់ខ្លួនក្នុងពេល ឬនៅពេលអនុវត្តការងារដែលនិយោជកបានប្រគល់អោយធ្វើ ។

**មាត្រា ១២៧.-**

កម្មសិទ្ធិករនៃសត្វ ឬជនដែលប្រើសត្វ ត្រូវទទួលខុសត្រូវចំពោះការខូចខាតដែលកើតឡើងដល់អ្នកដទៃដោយសារ

សត្វដែលនៅក្នុងការគ្រប់គ្រងរបស់ខ្លួន ទោះបីអន្តរាយកើតឡើងនៅពេលសត្វរត់រួចក្តី ឬនៅពេលសត្វវង្វេងខ្ចាត់ភ្លាត់ក្តី ។

**មាត្រា ១២៨.-**

កម្មសិទ្ធិករ ត្រូវទទួលខុសត្រូវចំពោះការខូចខាតដែលកើតឡើងដល់អ្នកដទៃដោយសារទ្រព្យរបស់ខ្លួន ប្រសិនបើការខូចខាតនោះបណ្តាលមកអំពីការខ្វះការថែទាំ ខ្វះការត្រួតពិនិត្យ ឬក៏ដោយសារសំណង់របស់ខ្លួនសង់មិនបានត្រឹមត្រូវល្អ ។

**មាត្រា ១២៩.-**

ប្រសិនបើការខូចខាតបណ្តាលមកពីជនប្រព្រឹត្តបទល្មើសច្រើននាក់ជនទាំងនេះត្រូវទទួលខុសត្រូវចំពោះជនរងគ្រោះ ។ ក្នុងករណីខ្លះតុលាការប្រជាជនអាចសំរេចសេចក្តីអោយបុគ្គលម្នាក់ៗ ដែលបានធ្វើអោយមានការខូចខាត សងទៅជនរងគ្រោះតាមសមាមាត្រនៃការចូលរួមប្រព្រឹត្តរបស់ខ្លួន ។

**មាត្រា ១៣០.-**

ជនដែលទទួលខុសត្រូវរួមជាមួយអ្នកទទួលខុសត្រូវឯទៀត ហើយបានសងជំនួសជនទាំងនេះ ជននោះមានសិទ្ធិទាមទារអោយជនទទួលខុសត្រូវឯទៀតសងមកខ្លួនវិញ ដោយគិតទៅតាមកំរិតនៃអំពើប្រព្រឹត្តដែលម្នាក់ៗ បានប្រព្រឹត្ត ។

**មាត្រា ១៣១.-**

អង្គការ ឬជនដែលបានទទួលខុសត្រូវចំពោះការខូចខាតដែលបណ្តាលមកពីកំហុសរបស់ជនម្នាក់ទៀត អង្គការ ឬជននោះមានសិទ្ធិប្តឹងទារសំណងពីជនខាងក្រោយនេះវិញ ។

**មាត្រា ១៣២.-**

ក្នុងករណីដែលការខូចខាត បណ្តាលមកពីកំហុសរបស់ជនរងគ្រោះផងដែរនោះ ជនរងគ្រោះត្រូវទទួលខុសត្រូវចំពោះចំណែកនៃការខូចខាតនោះដែរ

**មាត្រា ១៣៣.-**

ជនដែលធ្វើអោយមានការខូចខាតដល់អ្នកដទៃ នឹងអាចអោយរួចខ្លួនពីការទទួលខុសត្រូវបាន ប្រសិនបើ :

១-ការខូចខាតបានកើតឡើងក្នុងករណីប្រធានសក្តិ ។

២-ការខូចខាតបណ្តាលមកពីកំហុសទាំងស្រុងរបស់ជនរងគ្រោះ ។

**មាត្រា ១៣៤.-**

ប្រសិនបើការខូចខាតបានកើតឡើងដោយមានការព្រមព្រៀងពីជនរងគ្រោះហើយអំពើនោះគ្មានប៉ះពាល់ ឬគំរាមកំហែងដល់ប្រយោជន៏សង្គមទេនោះមិនត្រូវអោយមានការជួសជុលសំណងនៃការខូចខាតឡើយ ។

**មាត្រា ១៣៥.-**

បណ្តឹងសុំជួសជុលសំណងនៃការខូចខាត មានអាជ្ញាយុកាលកំណត់ ៣ឆ្នាំ ។

## ជំពូកទី ៤

## អំពីបទបញ្ញត្តិជាអន្តរកាល

**មាត្រា ១៣៦.-**

កិច្ចសន្យាទាំងឡាយណាដែលកើតឡើងមុនក្រឹត្យ-ច្បាប់នេះហើយមិនអាចដោះស្រាយតាមក្រឹត្យ-ច្បាប់នេះបាន នោះត្រូវដោះស្រាយតាមគោលនយោបាយរបស់បក្ស និងរដ្ឋ តាមសមធម៌ ឬតាមទំនៀមទំលាប់ និងប្រពៃណី ។

ដំណោះស្រាយនៃកិច្ចសន្យាខាងលើនេះមានកំណត់ ៥ឆ្នាំ គិតពីថ្ងៃដែលក្រឹត្យ-ច្បាប់នេះចូលជាធរមាន ។

**មាត្រា ១៣៧.-**

ក្រុមប្រឹក្សារដ្ឋមន្ត្រី តុលាការប្រជាជនកំពូល និងមហាអយ្យការ អមតុលាការប្រជាជនកំពូលត្រូវទទួលបន្ទុកអនុវត្ត ក្រឹត្យ-ច្បាប់នេះ តាមភារកិច្ចរៀង១ខ្លួន ។

**មាត្រា ១៣៨.-**

ក្រឹត្យ-ច្បាប់នេះ មានអានុភាពគតិយុត្តិចាប់ពីថ្ងៃប្រកាសផ្សាយ ជាសាធារណៈ ។

ធ្វើនៅភ្នំពេញ.ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៨៨

ជ.ក្រុមប្រឹក្សារដ្ឋ

ប្រធាន

ហត្ថលេខា និងត្រា

**ហេង សំរិន**

ទទួលបន្ទុកអនុវត្ត

ប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

# រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣

# នៃ

# ព្រះរាជាណាចក្រកម្ពុជា

## មុខកថា

## យើង ប្រជារាស្ត្រខ្មែរ

ដែលធ្លាប់មានអារ្យធម៌ឧត្តុង្គឧត្តម ប្រទេសជាតិស្តុកស្តម្ភធំទូលាយថ្កុំថ្កើងរុងរឿង កិត្យានុភាពខ្ពង់ខ្ពស់ ភ្លឺថ្លៃចែងចាំងដូចពេជ្រពណ្ណរាយ

បានធ្លាក់ខ្លួនដ៏សែនរន្ធត់ ក្នុងអំឡុងពីរទសវត្សចុងក្រោយនេះ ឆ្លងកាត់ទុក្ខសោកវិនាសអន្តរាយទ្រុឌទ្រោមឱនថយមហាសោកស្តាយ

បានភ្ញាក់រលឹក ក្រោកឈរឡើង ចងបាច់ឆន្ទៈ មោះមុត ប្តូរផ្តាច់ រួបរួមគ្នាពង្រឹងឯកភាពជាតិ រក្សាការពារទឹកដីកម្ពុជា អធិបតេយ្យថ្លៃថ្លា និងអារ្យធម៌អង្គរដ៏បវរ កសាងប្រទេសជាតិឱ្យទៅជា "កោះសន្តិភាព" ឡើងវិញផ្អែកលើប្រព័ន្ធប្រជាធិបតេយ្យ សេរីពហុបក្ស ធានាសិទ្ធិមនុស្ស គោរពច្បាប់ ទទួលខុសត្រូវខ្ពស់ ចំពោះវាសនាអនាគតជាតិ ឱ្យបានឈានឡើង រីកចំរើនលូតលាស់ សម្បូររុងរឿង ជានិច្ច និរន្តរ៍ ។

### ក្នុងឆន្ទៈមោះមុតនេះ

យើងសរសេរចារឹកក្នុងរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដូចតទៅ :

## ជំពូកទី ៣
## អំពី សិទ្ធិ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ

**មាត្រា ៣១.-**

ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញ នៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិ-នារី និងសិទ្ធិកុមារ ។

ប្រជាពលរដ្ឋខ្មែរ មានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រ-កាន់ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ ។ ការប្រើសិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ មិនត្រូវឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃឡើយ ។ ការប្រើសិទ្ធិសេរីភាពនេះ ត្រូវប្រព្រឹត្តតាមលក្ខខណ្ឌកំណត់ក្នុងច្បាប់ ។

**មាត្រា ៣២.-**

ជនគ្រប់រូប មានសិទ្ធិរស់រានមានជីវិត មានសេរីភាព និងមានសន្តិសុខផ្ទាល់ខ្លួន ។

ទោសប្រហារជីវិតមិនត្រូវឱ្យមានឡើយ ។

**មាត្រា ៣៣.-**

ប្រជាពលរដ្ឋខ្មែរមិនអាចត្រូវបានដកសញ្ជាតិ និរទេស ឬចាប់បញ្ជូនខ្លួនទៅឱ្យប្រទេសក្រៅណាមួយឡើយ លើក-លែងតែមានកិច្ចព្រមព្រៀងជាមួយគ្នាទៅវិញទៅមក ។

ប្រជាពលរដ្ឋខ្មែរដែលកំពុងរស់នៅឯបរទេសត្រូវបានរដ្ឋគាំពារ ។

ការទទួលសញ្ជាតិខ្មែរត្រូវកំណត់ក្នុងច្បាប់ ។

**មាត្រា ៣៤.- ថ្មី**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបោះឆ្នោត និងអាចឈរឈ្មោះឱ្យគេបោះឆ្នោត ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ១៨ ឆ្នាំ មានសិទ្ធិបោះឆ្នោត ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ២៥ ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំងជាតំណាងរាស្ត្រ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ៤០ ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំងជាសមា-ជិកព្រឹទ្ធសភា ។

បទប្បញ្ញត្តិបន្ថយសិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត ត្រូវចែងក្នុងច្បាប់បោះឆ្នោត ។

**មាត្រា ៣៥.-**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

របស់ប្រទេសជាតិ ។

សេចក្តីស្នើទាំងឡាយរបស់ប្រជាពលរដ្ឋ ត្រូវបានទទួលការពិនិត្យ និងដោះស្រាយយ៉ាងហ្មត់ចត់ ពីអង្គការរដ្ឋ ។

**មាត្រា ៣៦.-**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិជ្រើសរើសមុខរបរ សមស្របតាមសមត្ថភាពរបស់ខ្លួន តាមសេចក្តីត្រូវការរបស់សង្គម ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលប្រាក់បំណាច់ស្មើគ្នាចំពោះការងារដូចគ្នា ។

ការងារមេផ្ទះមានតម្លៃស្មើគ្នានឹងកំរៃដែលបានមកពីការងារធ្វើនៅក្រៅផ្ទះ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលការធានារ៉ាប់រងសង្គម និងអត្ថប្រយោជន៍ខាងសង្គមកិច្ច ដែលមានចែងក្នុងច្បាប់ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបង្កើតសហជីព និងចូលជាសមាជិកសហជីពនេះ ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃសហជីពនឹងមានកំណត់ក្នុងច្បាប់ ។

**មាត្រា ៣៧.-**

សិទ្ធិធ្វើកូដកម្ម និងធ្វើបាតុកម្មដោយសន្តិវិធី ត្រូវយកមកអនុវត្តនៅក្នុងក្របខ័ណ្ឌនៃច្បាប់ ។

**មាត្រា ៣៨.-**

ច្បាប់រ៉ាប់រង មិនឱ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយឡើយ ។

ច្បាប់ការពារជីវិត កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ ។

ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយ នឹងអាចធ្វើទៅកើត លុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់ ។

ការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយ ឬប្រព្រឹត្តិកម្មណាមួយដែលបន្ថែមទម្ងន់ទណ្ឌកម្ម អនុវត្តចំពោះជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារត្រូវហាមឃាត់មិនធ្វើឡើយ ។ អ្នកដៃដល់ អ្នករួមប្រព្រឹត្ត និងអ្នកសមគំនិតត្រូវទទួលទោសតាមច្បាប់ ។

ការទទួលសារភាពដែលកើតឡើងពីការបង្ខិតបង្ខំ តាមផ្លូវកាយក្តី តាមផ្លូវចិត្តក្តី មិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធ-ភាពទេ ។

វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ។

ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ ។

ជនគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ ។

**មាត្រា ៣៩.-**

ប្រជាពលរដ្ឋខ្មែរមានសិទ្ធិប្តឹងបរិហារ ប្តឹងតវ៉ា ឬប្តឹងទាមទារសំណងជួសជុលការខូចខាត ដែលបណ្តាលមកពីអំពើខុស

ច្បាប់របស់អង្គការរដ្ឋ របស់អង្គការសង្គម និងរបស់បុគ្គលិកនៃអង្គការទាំងនោះ ។ ការដោះស្រាយបណ្ដឹងតវ៉ា និងសំណង ជួសជុលការខូចខាតជាសមត្ថកិច្ចរបស់តុលាការ ។

**មាត្រា ៤០.-**

សេរីភាពក្នុងការធ្វើដំណើរ ធ្វើដំណើរឆ្ងាយជិត និងតាំងទីលំនៅក្នុងស្ថានភាពស្របច្បាប់ របស់ប្រជាពលរដ្ឋត្រូវបានគោរព ។

ប្រជាពលរដ្ឋខ្មែរអាចចេញទៅតាំងទីលំនៅ នៅប្រទេសក្រៅ ឬវិលត្រឡប់មកវិញបាន។

ការរក្សាសិទ្ធិមិនឱ្យរំលោភលើលំនៅឋាន និងអាថ៌កំបាំងនៃការឆ្លើយឆ្លងតាមលិខិត តាមសារទូរលេខ ទូរពុម្ព ទូរគមន៍ និងតាមទូរស័ព្ទត្រូវបានធានា ។

ការឆែកឆេរលំនៅឋាន សម្ភារៈវត្ថុ និងលើរូបបុគ្គលត្រូវធ្វើឱ្យស្របនឹងបញ្ញត្តិច្បាប់ ។

**មាត្រា ៤១.-**

ប្រជាពលរដ្ឋខ្មែរ មានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ ។ ជនណាក៏ដោយមិនអាចឆ្លៀតប្រើសិទ្ធិនេះ ដោយរំលោភ នាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទំលាប់ល្អរបស់សង្គម ដល់សណ្ដាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ ។

របបសារព័ត៌មាន ត្រូវរៀបចំឡើងដោយច្បាប់ ។

**មាត្រា ៤២.-**

ប្រជាពលរដ្ឋខ្មែរមានសិទ្ធិបង្កើតសមាគម និងគណបក្សនយោបាយ ។ សិទ្ធិនេះត្រូវកំណត់ក្នុងច្បាប់ ។

ប្រជាពលរដ្ឋខ្មែរទាំងឡាយ អាចចូលរួមក្នុងអង្គការមហាជនជួយគ្នាទៅវិញទៅមក ការពារសមិទ្ធផលជាតិ និងសណ្ដាប់ធ្នាប់សង្គម ។

**មាត្រា ៤៣.-**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិពេញទីខាងជំនឿ ។

សេរីភាពខាងជំនឿ និងការប្រតិបត្តិខាងផ្លូវសាសនាត្រូវបានរដ្ឋធានា ក្នុងលក្ខខណ្ឌដែលមិនប៉ះពាល់ដល់ជំនឿ ឬសាសនាដទៃទៀត ដល់សណ្ដាប់ធ្នាប់ និងសន្តិសុខសាធារណៈ ។

ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ។

**មាត្រា ៤៤.-**

ជនណាក៏ដោយ ទោះជាបុគ្គលក្ដី ជាសមូហភាពក្ដី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ ។ មានតែរូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានសញ្ជាតិជាខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី ។

កម្មសិទ្ធិឯកជនស្របច្បាប់ ឋិតនៅក្រោមការគាំពារនៃច្បាប់ ។

ដែលនឹងដកហូតកម្មសិទ្ធិអំពីជនណាមួយបាននោះ លុះត្រាតែប្រយោជន៍សាធារណៈតម្រូវឱ្យធ្វើ ក្នុងករណីដែលច្បាប់បានបញ្ញត្តិទុក ហើយត្រូវផ្ដល់សំណងជាមុនដោយសមរម្យ និងយុត្តិធម៌ ។

**មាត្រា ៤៥.-**

ការរើសអើងគ្រប់ប្រភេទប្រឆាំងនឹងស្ត្រីភេទ ត្រូវបំបាត់ចោល ។

ការធ្វើអាជីវកម្មលើការងាររបស់ស្ត្រីត្រូវហាមឃាត់ ។

បុរស និងស្ត្រី មានសិទ្ធិស្មើគ្នាក្នុងគ្រប់វិស័យទាំងអស់ ជាពិសេសក្នុងអាពាហ៍ពិពាហ៍ និងគ្រួសារ ។

អាពាហ៍ពិពាហ៍ ត្រូវធ្វើតាមលក្ខខណ្ឌ ដែលមានចែងក្នុងច្បាប់ និងតាមគោលការណ៍ស្ម័គ្រចិត្ត ប្តីមួយប្រពន្ធមួយ ។

**មាត្រា ៤៦.-**

អំពើលក់ដូរមនុស្ស អំពើធ្វើអាជីវកម្មផ្នែកពេស្យាកម្ម និងអំពើអាសអាភាស ដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់នារីត្រូវហាមឃាត់ ។

ត្រូវហាមឃាត់មិនឱ្យមានការបញ្ឈប់នារីពីការងារ ដោយមូលហេតុមានគភ៌ ។ នារីមានសិទ្ធិឈប់សំរាកនៅពេលសម្រាលកូន ដោយទទួលប្រាក់បៀវត្ស និងដោយមានការធានារក្សាសិទ្ធិអតីតភាពក្នុងការងារ និងអត្ថប្រយោជន៍សង្គមផ្សេងៗទៀត ។

រដ្ឋ និងសង្គមយកចិត្តទុកដាក់បង្កលក្ខណៈឱ្យនារី ជាពិសេសនារីនៅជនបទដែលគ្មានទីពឹង បានទទួលការឧបត្ថម្ភដើម្បីមានមុខរបរ មានលទ្ធភាពព្យាបាលជំងឺ ឱ្យកូនទៅរៀន និងមានជីវភាពរស់នៅសមរម្យ ។

**មាត្រា ៤៧.-**

មាតាបិតា មានកាតព្វកិច្ចចិញ្ចឹមថែរក្សា និងអប់រំកូនឱ្យទៅជាពលរដ្ឋល្អ ។

កូនមានករណីយកិច្ចចិញ្ចឹម និងបីបាច់ថែរក្សាមាតាបិតា ដែលចាស់ជរាតាមទំនៀមទំលាប់ខ្មែរ ។

**មាត្រា ៤៨.-**

រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារ ដែលមានចែងក្នុងអនុសញ្ញាស្តីពីកុមារ ជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលការអប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារក្នុងស្ថានការណ៍មានសង្គ្រាម និងការការពារប្រឆាំងនឹងអាជីវ-កម្មសេដ្ឋកិច្ច ឬកាមគុណលើកុមារ ។

រដ្ឋគាំពារប្រឆាំងនឹងការងារទាំងឡាយ ដែលអាចធ្វើឱ្យខូចដល់ការអប់រំ និងការរៀនសូត្ររបស់កុមារ ឬដែលនាំឱ្យអន្តរាយដល់សុខភាព ឬសុខុមាលភាពរបស់កុមារ ។

**មាត្រា ៤៩.-**

ប្រជាពលរដ្ឋខ្មែរគ្រប់រូបត្រូវគោរពរដ្ឋធម្មនុញ្ញ និងគោរពច្បាប់ ។

ប្រជាពលរដ្ឋខ្មែរគ្រប់រូប មានកាតព្វកិច្ចរួមចំណែកកសាងប្រទេសជាតិ និងការពារមាតុភូមិ ។

កាតព្វកិច្ចការពារមាតុភូមិត្រូវអនុវត្តតាមបញ្ញត្តិច្បាប់ ។

**មាត្រា ៥០.-**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ត្រូវគោរពគោលការណ៍អធិបតេយ្យជាតិ និងលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ត្រូវគោរពទ្រព្យសម្បត្តិសាធារណៈ និងកម្មសិទ្ធស្របច្បាប់របស់ឯកជន ។

# ច្បាប់
# ភូមិបាល

នស/រកម/០៨០១/១៤

# ព្រះរាជក្រម

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែង - តាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើត ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**ប្រកាសឱ្យប្រើ**

ច្បាប់ភូមិបាល ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៦ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៥ នីតិកាលទី ១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ :

## ជំពូកទី ១៣
## អំពីការបញ្ចាំអចលនវត្ថុ

### មាត្រា ២០៦.-

ការបញ្ចាំអចលនវត្ថុគឺជាកិច្ចសន្យាដែលតាមកិច្ចសន្យានោះ កូនបំណុលប្រគល់ឱ្យម្ចាស់បំណុលរបស់ខ្លួននូវទ្រព្យមួយដើម្បីធានាការសងបំណុល ។ ម្ចាស់បំណុលមានសិទ្ធិសុំឱ្យលក់ទ្រព្យនោះដើម្បីសងបំណុលតាមបុព្វសិទ្ធិ និងបុរិមាដែលខ្លួនមានជាងម្ចាស់បំណុលដទៃទៀត ។

ការប្រើប្រាស់ទ្រព្យដាក់បញ្ចាំដោយម្ចាស់បំណុលអាចជំនួសការសងបំណុលនេះជាការប្រាក់តែមួយមុខ ឬជាប្រាក់ដើម និងការប្រាក់ផងក៏បាន បើសិនមានចែងក្នុងកិច្ចសន្យាបញ្ចាំ ។

### មាត្រា ២០៧.-

កិច្ចសន្យាបញ្ចាំអចលនវត្ថុត្រូវធ្វើជាលាយលក្ខណ៍អក្សរតាមរូបមន្តលិខិតយថាភូតដោយអាជ្ញាធរមានសមត្ថកិច្ច ហើយត្រូវចុះបញ្ជីនៅអង្គភាពសុរិយោដី ។

### មាត្រា ២០៨.-

ការបញ្ចាំអចលនវត្ថុចាត់ទុកជាបានការ ហើយតតិយជនមិនអាចជំទាស់បាន លុះត្រាតែកិច្ចសន្យាបញ្ចាំនោះបានធ្វើតាមបញ្ញត្តិដូចមានចែងក្នុងមាត្រា ២០៧ នៃច្បាប់នេះ ។

ការមិនបានចុះបញ្ជីនៅអង្គភាពសុរិយោដីនូវកិច្ចសន្យាបញ្ចាំបណ្តាលឱ្យបាត់សិទ្ធិប្រាតិភោគភណ្ឌិក ហើយម្ចាស់បំណុល មានសិទ្ធិត្រឹមប្តឹងទារសំណងតាមច្បាប់ជាធរមានប៉ុណ្ណោះ ។

**មាត្រា ២០៩.-**

ទ្រព្យជាប់កិច្ចសន្យាបញ្ចាំអចលនវត្ថុនឹងត្រូវសងមកកូនបំណុលវិញជាចាំបាច់ ចាប់ពីពេលដែលកូនបំណុលបានសង-បំណុលទាំងស្រុងរួចហើយ ។

ចំពោះកិច្ចសន្យាដែលមិនបានបញ្ជាក់ពីកាលបរិច្ឆេទផុតកំណត់សងក្នុងរយៈពេល ១០ (ដប់) ឆ្នាំ គិតពីថ្ងៃដែលបានចុះកិច្ចសន្យាបញ្ចាំមក បើម្ចាស់បំណុលមិនបានដាក់ពាក្យប្តឹងទៅតុលាការដើម្បីទាមទារឱ្យសងបំណុលទេ ម្ចាស់បំណុលនោះត្រូវបាត់បង់ការធានានៃការដាក់បញ្ចាំ ។

ចំពោះកិច្ចសន្យាដែលបានបញ្ជាក់ថ្ងៃកំណត់ឱ្យសងក្នុងរយៈពេល ១០ (ដប់) ឆ្នាំ គិតពីថ្ងៃផុតរយៈពេលសងបំណុល បើម្ចាស់បំណុលមិនបានដាក់ពាក្យប្តឹងទៅតុលាការដើម្បីទាមទារអោយសងបំណុលទេ ម្ចាស់បំណុលនោះត្រូវបាត់បង់ការធានានៃការដាក់បញ្ចាំ ។

ការបាត់បង់ការធានានៃការដាក់បញ្ចាំនេះតម្រូវឱ្យម្ចាស់បំណុលប្រគល់អចលនវត្ថុ និងប័ណ្ណឱ្យកូនបំណុលវិញ តែកូនបំណុលពុំបានរួចពីការសងបំណុលឡើយ ហើយម្ចាស់បំណុលមានសិទ្ធិត្រឹមប្តឹងទារសំណងតាមច្បាប់ជាធរមានប៉ុណ្ណោះ ។

ការលើកលែងបញ្ចាំ ឬការលុបបន្ទុកបញ្ចាំត្រូវធ្វើលេខាចារិកក្នុងបញ្ជីសុរិយោដីតាមការស្នើសុំរបស់កូនបំណុល ឬដោយឯកឯង ។

**មាត្រា ២១០.-**

ក្នុងករណីណាក៏ដោយ ម្ចាស់បំណុលមិនអាចក្លាយជាកម្មសិទ្ធិករនៃទ្រព្យជាប់កិច្ចសន្យាបញ្ចាំបានឡើយ ។ ខសន្យា-ណាដែលផ្ទុយនឹងបទប្បញ្ញត្តិនេះត្រូវទុកជាមោឃៈ ។

**មាត្រា ២១១.-**

កិច្ចសន្យាបញ្ចាំអចលនវត្ថុអនុញ្ញាតឱ្យម្ចាស់បំណុលមានសិទ្ធិត្រឹមតែប្តឹងទៅតុលាការឱ្យដាក់លក់អចលនវត្ថុដោយបង្ខំប៉ុណ្ណោះ ដើម្បីសងខ្លួនជាអាទិភាព ដោយបុរិមា និងបុព្វសិទ្ធិមុនម្ចាស់បំណុលដទៃទៀត ។

បើសិនជាក្នុងរយៈពេលនៃកិច្ចសន្យាបញ្ចាំ ម្ចាស់បំណុលដែលទទួលបញ្ចាំទិញអចលនវត្ថុដែលដាក់បញ្ចាំ កិច្ចសន្យាទិញនេះត្រូវចុះបញ្ជីនៅអង្គភាពសុរិយោដី ពុំនោះទេនឹងត្រូវចាត់ទុកជាមោឃៈ ។

**មាត្រា ២១២.-**

ម្ចាស់បំណុលដែលបានកាន់កាប់ទ្រព្យដាក់បញ្ចាំអាចមានសិទ្ធិអាស្រ័យផលពីទ្រព្យនោះដូចជាផលុបភោគីដែរ លុះ-ត្រាតែមានចែងក្នុងកិច្ចសន្យាដាក់បញ្ចាំ ។ ម្ចាស់បំណុលមានកាតព្វកិច្ចថែទាំរក្សាទុកទ្រព្យនោះឱ្យដូចជាទ្រព្យរបស់ខ្លួន ។ បើទ្រព្យនោះខូចខាតដោយអំពើ ឬកំហុសណាមួយរបស់ខ្លួន ខ្លួនត្រូវសងតម្លៃខូចខាតនោះដោយកាត់ប្រាក់ក្នុងបំណុល-បាន ។

**មាត្រា ២១៣.-**

ការដាក់ធានាគឺជាកិច្ចសន្យាមួយដែលបានសម្រេចឡើងដើម្បីធានាការសងបំណុលដែលក្នុងនោះកូនបំណុលប្រគល់ទៅឱ្យម្ចាស់បំណុលរបស់ខ្លួន មិនមែនជាទ្រព្យទេតែជាប័ណ្ណកម្មសិទ្ធិនៃទ្រព្យនោះដែលបានចុះនិទ្ទេសក្នុងបញ្ជីសុរិយោដី ។

**មាត្រា ២២០.-**

កិច្ចសន្យាដាក់ធានាត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរតាមរូបមន្តយថាភូត និង ត្រូវចុះហត្ថលេខាចារិកក្នុងបញ្ជីសុរិយោដី ។

**មាត្រា ២២១.-**

ក្នុងករណីណាក៏ដោយ ម្ចាស់បំណុលមិនអាចក្លាយជាកម្មសិទ្ធិករនៃទ្រព្យជាប់កិច្ចសន្យាដាក់ធានាបានឡើយ ។ ខសន្យាណាដែលផ្ទុយនឹងបទប្បញ្ញត្តិនេះត្រូវទុកជាមោឃៈ ។

កិច្ចសន្យាដាក់ធានាអនុញ្ញាតឱ្យម្ចាស់បំណុលមានសិទ្ធិត្រឹមតែប្ដឹងទៅតុលាការឱ្យដាក់លក់អចលនវត្ថុដោយបង្ខំប៉ុណ្ណោះ ដើម្បីសងខ្លួនជាអាទិភាពដោយបុរិមា និងបុព្វសិទ្ធិមុនម្ចាស់បំណុលដទៃទៀត ។

**មាត្រា ២២២.-**

បើកូនបំណុលបានសងបំណុល និងការប្រាក់រួចហើយតាមពេលកំណត់ ឬមុនពេលកំណត់ ម្ចាស់បំណុលត្រូវបង្វិលប័ណ្ណកម្មសិទ្ធិមកកូនបំណុលវិញដោយធ្វើលេខាចារិក លើកលែងបន្ទុកក្នុងបញ្ជីសុរិយោដី ។

**មាត្រា ២២៣.-**

កូនបំណុលត្រូវរក្សាទុក គ្រប់គ្រង និងប្រើប្រាស់ទ្រព្យរបស់ខ្លួន ប៉ុន្តែមិនអាចធ្វើអ្វីដែលនាំឱ្យបន្ថយតម្លៃទ្រព្យនោះបានជាដាច់ខាត ។

**មាត្រា ២២៤.-**

សិទ្ធិវន្តនៃកូនបំណុល និងសិទ្ធិវន្តនៃម្ចាស់បំណុលមានកាតព្វកិច្ច និងសិទ្ធិដូចគ្នានឹងកូនបំណុល ឬម្ចាស់បំណុលរបស់ខ្លួនដែរ ។

**មាត្រា ២២៥.-**

ទាយាទ ឬប្រតិសិទ្ធិនៃកូនបំណុលព្រមទាំងសមាជិកទាំងឡាយនៃគ្រួសារដែលអាចប្រកាសថាជាសហកម្មសិទ្ធិករនៃទ្រព្យដាក់ធានា មានកាតព្វកិច្ច និងសិទ្ធិដូចគ្នានឹងកូនបំណុលដែរ ។

## មាតិកា ៦

## អំពីសុរិយោដី

## ជំពូកទី ១៥

## អំពីរដ្ឋបាលសុរិយោដី

**មាត្រា ២២៦.-**

# ច្បាប់
# ស្តីពី
# ប្រតិបត្តិការដែលមានកិច្ចធានា

# ព្រះរាជក្រម

នស/រកម/០៥០៧/០១២

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពី ប្រតិបត្តិការដែលមានកិច្ចធានា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៦ ខែ មេសា ឆ្នាំ ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី ៦ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៣ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

# ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.–**

១-ច្បាប់នេះមានគោលបំណងលើកស្ទួយសកម្មភាពសេដ្ឋកិច្ច តាមរយៈវិធានស្តីពីការប្រើប្រាស់ទ្រព្យធានា ដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះ ដើម្បីធានាកាតព្វកិច្ច ។

២-ក្នុងករណីមានភាពផ្ទុយគ្នា រវាងបទប្បញ្ញត្តិនៃច្បាប់នេះ និងបទប្បញ្ញត្តិនៃច្បាប់ដទៃទៀត ច្បាប់នេះត្រូវចាត់ទុកជាបញ្ញត្តិគោល លើកលែងតែច្បាប់ផ្សេងនោះចែងយោងជាក់លាក់ ឬធ្វើវិសោធនកម្មលើបទប្បញ្ញត្តិ ដែលផ្ទុយនឹងច្បាប់នេះ ។

ចំពោះបញ្ញត្តិដែលពុំមានចែងក្នុងច្បាប់នេះទេ ត្រូវអនុវត្តតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.–**

១-ច្បាប់នេះអនុវត្តចំពោះ :

ក-រាល់ប្រតិបត្តិការដែលមានអានុភាពលើការធានាកាតព្វកិច្ចដោយទ្រព្យធានា ដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះ រួមមានការបញ្ចាំចលនវត្ថុ ការផ្ទេរកម្មសិទ្ធិ បញ្ញើទុកលក់ អនុប្បទានសិទ្ធិជាដើម ។

ខ-ការលក់គណនី និងកិច្ចសន្យាលក់ដែលមានកិច្ចធានា ។

គ-ការជួលទំនិញសម្រាប់រយៈពេលលើសពីមួយឆ្នាំ ។

២-ការអនុវត្តន៍ចំពោះប្រតិបត្តិការ ដែលបានកំណត់ក្នុងចំណុចទី ១ ដោយមិនគិតពីទម្រង់ ឬពាក្យពេចន៍ ដែលប្រើក្នុងកិច្ចព្រមព្រៀងឡើយ ហើយទោះបីជាសិទ្ធិលើកម្មសិទ្ធិត្រូវបានកាន់កាប់ដោយម្ចាស់បំណុលដែលមានកិច្ចធានា ឬកូនបំណុលក៏ដោយ ។

៣-ច្បាប់ទាំងឡាយដែលចែងពីសមត្ថភាពចុះកិច្ចសន្យា ដូចជាច្បាប់ស្តីពីទីភ្នាក់ងារ ការឆបោក ការបង្ខិតបង្ខំ ការភ័ន្តច្រឡំនិងធនក្ស័យ ត្រូវបំពេញបន្ថែមលើច្បាប់នេះ ។

៤-ថ្វីបើមានចែងក្នុងចំណុចទី ១ និងចំណុចទី ២ នៃមាត្រានេះក្តី ច្បាប់នេះមិនអនុវត្ត

ក-ការផ្ទេរសិទ្ធិទាមទារប្រាក់បៀវត្សរបស់និយោជិត ។

ខ-ការលក់គណនី ឬកិច្ចសន្យាលក់ ដែលមានកិច្ចធានាដែលជាផ្នែកនៃការលក់អាជីវកម្មរួមទាំងគណនី ឬកិច្ចសន្យាលក់ដែលមានកិច្ចធានានេះ ។

គ-អនុប្បទានគណនី កិច្ចសន្យាលក់ដែលមានកិច្ចធានា ឬ លិខិតស្នាមដែលសម្រាប់តែគោលបំណងប្រមូលប្រាក់ដែលជំពាក់ ។

ឃ-ការផ្ទេរសិទ្ធិទទួលប្រាក់តាមកិច្ចសន្យាទៅអនុប្បទានិក ដែលមានកាតព្វកិច្ចអនុវត្តកិច្ចសន្យា ។

ង-ការប្រាក់លើប្រាក់បញ្ញើ គណនីមូលប្បទានប័ត្រ គណនីសញ្ជ័យ សៀវភៅធនាគារ ឬគណនីសាច់ប្រាក់ដទៃទៀត លើកលែងតែផលនៃទ្រព្យធានា ។

**មាត្រា ៣.–**

នៅក្នុងច្បាប់នេះពាក្យបច្ចេកទេសទាំងឡាយ ត្រូវមានន័យដូចកំណត់ខាងក្រោម :

១-"កសិផល" មានន័យថា ទំនិញរបស់កូនបំណុល ដែលបានពីមុខរបរកសិកម្ម លើកលែងតែឈើឈរ ។ កសិផលរួមមាន :

ក-ផលដំណាំដែលដាំដុះ កំពុងដុះលូតលាស់ ឬ ផលដំណាំដែលត្រូវដាំដុះ

ខ-ទំនិញជលផលដែលផលិតក្នុងប្រតិបត្តិការវារីវប្បកម្ម

គ-សត្វចិញ្ចឹមគ្រប់ប្រភេទ រាប់ទាំងកូនសត្វដែលកើតហើយ ឬ មិនទាន់កើតផងដែរ

ឃ-ទំនិញផ្គត់ផ្គង់ដែលប្រើ ឬផលិតក្នុងប្រតិបត្តិការកសិកម្ម

ង-ផលដំណាំដែលប្រមូលបាន ឬ ផលដែលបានមកពីសត្វចិញ្ចឹមគ្រប់ប្រភេទ ហើយមិនទាន់កែច្នៃ ។

២-"ការជួលទំនិញសម្រាប់រយៈពេលលើសពីមួយ(០១)ឆ្នាំ" មានន័យថា :

ក-ការជួលទំនិញដែលកំណត់រយៈពេលលើសពីមួយ(០១)ឆ្នាំ ។

ខ-ការជួលទំនិញដែលគ្មានកំណត់រយៈពេល ទោះបីជារយៈពេលនេះអាចត្រូវបានកំណត់ថាតិចជាងមួយឆ្នាំក៏ដោយ ។

គ-ការជួលទំនិញដែលកំណត់រយៈពេលដំបូងមួយឆ្នាំ ឬតិចជាងមួយឆ្នាំ បើអ្នកជួលបន្តកាន់កាប់ទំនិញដោយបានការឯកភាពពីអ្នកជួលឱ្យនិងគ្មានការអាក់ខាន ឬ គ្មានការអាក់ខានជាសារវន្ត ក្នុងរយៈពេលមួយ(០១)ឆ្នាំ បន្ទាប់ពីអ្នកជួលបានទទួលចលនវត្ថុនោះមក ប៉ុន្តែកិច្ចសន្យាជួលនេះ មិនក្លាយទៅជាមានរយៈពេលមួយ(០១)ឆ្នាំទេ លើកលែងតែអ្នកជួលបន្តការកាន់កាប់លើសពីមួយ(០១)ឆ្នាំ

ឃ-ការជួលទំនិញដែលកំណត់រយៈពេលមួយ(០១)ឆ្នាំ ឬ តិចជាងមួយ(០១)ឆ្នាំ កាលណាកិច្ចសន្យាជួលចែងថា អាចបន្តរយៈពេលលើសពីមួយ(០១)ឆ្នាំ ។

៣-"ការទិញ" ការទទួលបានវត្ថុក្នុងឋានៈជាអ្នកទិញ រាប់បញ្ចូលទាំងអ្នកទទួលអំណោយ អ្នកទទួលទ្រព្យធានា ម្ចាស់បំណុលដែលមានកិច្ចធានា ឬ ម្ចាស់បំណុលអ៊ីប៉ូតែក ឬ តាមប្រតិបត្តិការដោយស្ម័គ្រចិត្តដែលបង្កើតសិទ្ធិលើទ្រព្យ ។ បុគ្គលដែលទទួលបានចលនវត្ថុដោយការទិញហៅថា "អ្នកទិញ" ។

៤-"បញ្ជាក់ការឯកភាព" មានន័យថា ការចុះហត្ថលេខា ឬ ការឯកភាពលើឈ្មោះ ឬ និមិត្តសញ្ញាផ្សេងៗ ដែលធ្វើឡើងដោយផ្ទាល់ដៃ ឬ តាមវិធីផ្សេងៗ ហើយមានគោលបំណងបញ្ជាក់ពីអត្តសញ្ញាណរបស់ភាគីដែលឯកភាព ឬ ផ្តល់ការឯកភាព ឬ បញ្ជាក់ឱ្យកំណត់ត្រាមានតម្លៃតាមច្បាប់ ។

៥-"កិច្ចធានា" គឺជាកាតព្វកិច្ចគាំទ្រ ជាអាទិ៍មានកាតព្វកិច្ចបង់ប្រាក់ ឬកាតព្វកិច្ចបង់ប្រាក់របស់អ្នកចេញលិខិតឥណទាន និងដែលគាំទ្រការបង់ប្រាក់ ឬការបំពេញកាតព្វកិច្ចលើកណនី កិច្ចសន្យាលក់ដែលមានកិច្ចធានា ឯកសារ លិខិតស្នាម ឬ ទ្រព្យអរូបីដទៃទៀត ។

៦-"កិច្ចសន្យាលក់ដែលមានកិច្ចធានា" មានន័យថា កំណត់ត្រាដែលបង្កើតកាតព្វកិច្ចបង់ប្រាក់ និងសិទ្ធិប្រាតិភោគលើទំនិញ ឬ ការជួលទំនិញ ។

៧-"កិច្ចព្រមព្រៀងប្រាតិភោគ" គឺជាកិច្ចព្រមព្រៀងដែលបង្កើត ឬ ចែងពីសិទ្ធិប្រាតិភោគ ។

៨-"កូនបំណុល" មានន័យថា បុគ្គលដែលជំពាក់ប្រាក់ ឬកាតព្វកិច្ច ទោះបុគ្គលនេះជាកម្មសិទ្ធិករ ឬបុគ្គលដែលមានសិទ្ធិលើទ្រព្យធានាក៏ដោយ និងរាប់បញ្ចូលទាំងអ្នក

លក់គណនី ឬ កិច្ចសន្យាលក់ដែលមានកិច្ចធានា អ្នកទទួលទំនិញទុកលក់ អ្នកជួលចលន-វត្ថុតាមកិច្ចសន្យាជួលដែលកំណត់ក្នុងច្បាប់នេះ ។

៩-"កូនបំណុលគណនី" មានន័យថា បុគ្គលដែលជំពាក់កាតព្វកិច្ចក្នុងគណនី ក្នុងកិច្ចសន្យាលក់ដែលមានកិច្ចធានា ឬ ទ្រព្យអរូបីដទៃទៀត ។

១០-"កំណត់ត្រា" គឺជាព័ត៌មានដែលកត់ត្រាតាមមធ្យោបាយទាក់ទងរូបី ឬ ព័ត៌មានដែលរក្សាទុកក្នុងប្រព័ន្ធអេឡិចត្រូនិក ឬ មធ្យោបាយទាក់ទងផ្សេងទៀត និងអាចយកមកប្រើបានក្នុងទម្រង់ដែលអាចយល់ ឬដឹងខ្លឹមសារបាន ។ លិខិតជូនដំណឹង វិសោធ-នកម្ម លិខិតសុំបន្ត ឬ លិខិតសុំបញ្ឈប់ត្រូវចាត់ទុកជាកំណត់ត្រា បើបានប្រគល់ជូនការិយា-ល័យតម្កល់តាមមធ្យោបាយដែលការិយាល័យតម្កល់បានកំណត់ ។

១១-"គណនី" គឺជាសិទ្ធិទទួលការទូទាត់ថ្លៃទំនិញដែលបានលក់ ឬ បានជួល ឬ ថ្លៃសេវាកម្មដែលមិនមែនជាលិខិតស្នាម ឬ កិច្ចសន្យាលក់ដែលមានកិច្ចធានា ។

១២-"គាហកនៃសិទ្ធិឃាត់ទុក" មានន័យថា :

ក-បុគ្គលដែលទទួលបានសិទ្ធិ លើទ្រព្យធានារបស់ម្ចាស់បំណុលមានកិច្ចធានា ឬ មានសិទ្ធិរឹបអូសទ្រព្យធានារបស់ម្ចាស់បំណុល ដែលមានកិច្ចធានាតាមវិធីប្តឹងទៅមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ដូចជាមន្ត្រីតុលាការ អភិបាល ឬ អភិបាលបណ្តោះអាសន្នក្នុងរឿងក្តីក្ស័យធនជាដើម ។

ខ-បុគ្គលដែលមានឯកសិទ្ធិទូទៅ ឬ ឯកសិទ្ធិលើចលនវត្ថុពិសេសតាមច្បាប់ផ្សេងទៀត ។

១៣-"ចលនវត្ថុតាំងភ្ជាប់" គឺជាទំនិញដែលបានភ្ជាប់ទៅនឹងអចលនវត្ថុ ឬ មានគោលបំណងតាំងភ្ជាប់ទៅនឹងអចលនវត្ថុ តាមរបៀបមួយដែលនាំឱ្យមានសិទ្ធិប្រស៊ីក្សកើតឡើងតាមច្បាប់ភូមិបាលជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

១៤-"តម្លៃ" មានន័យថាតម្លៃដែលបានផ្តល់សម្រាប់សិទ្ធិក្នុងករណីដែលបុគ្គលបានទទួលសិទ្ធិ :

ក-ជាថ្នូរនឹងការសន្យាមានសុពលភាពក្នុងការផ្តល់ឥណទាន ទោះបីជាការសន្យាដែលអាចដកវិញបាន ឬ មិនអាចដកវិញបានក៏ដោយ ។

ខ-ជាទ្រព្យធានា ឬ ការទូទាត់ទាំងស្រុង ឬ មួយភាគចំពោះការទាមទារពីមុន ។

គ-ដោយការទទួលការប្រគល់ អនុលោមតាមកិច្ចសន្យាទិញដែលមានស្រាប់ ។

ឃ-ជាថ្នូរនឹងអ្វីដែលត្រូវបានផ្តល់ក្នុងការដោះដូរ ឬជាថ្នូរនឹងការសន្យា។

១៥-"ទំនិញ" គឺជាវត្ថុដែលជាចលនវត្ថុក្នុងពេលដែលសិទ្ធិប្រាតិភោគភ្ជាប់ទៅនឹងវត្ថុនេះ ។ ក្នុងនេះពាក្យថា ទំនិញសំដៅផលផលិតផលរ៉ែ ដែលត្រូវភ្ជាប់សិទ្ធិប្រាតិភោគនៅពេលជីកបាន ឈើឈរដែលបំរុងនឹងកាប់ កូនសត្វចិញ្ចឹមគ្រប់ប្រភេទមិនទាន់កើតនិងផលដំណាំដែលបានដាំដុះ កំពុងលូតលាស់ ឬដែលត្រូវដាំដុះ រាប់បញ្ចូលទាំងផលដំណាំនៅជាប់នឹងដើម ប្រេង ជ័រ ឬរុក្ខជាតិផងដែរ ។ ពាក្យថា ទំនិញនេះមិនរាប់បញ្ចូលនូវគណនីកិច្ចសន្យាលក់ដែលមានកិច្ចធានា រូបិយវត្ថុ ឯកសារ ឬ លិខិតស្នាមឡើយ ។

១៦-"ទំនិញប្រើប្រាស់" គឺទំនិញដែលបានប្រើប្រាស់ ឬទិញសម្រាប់ប្រើប្រាស់ជាចម្បងសម្រាប់គោលបំណងផ្ទាល់ខ្លួន សមាជិកគ្រួសារ ឬសម្រាប់គោលបំណងគ្រួសារ ទំនិញទាំងនេះ មិនអាចជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគបានទេ លើកលែងតែយានយន្តមានលេខសេរី ។

១៧-"ទំនិញបញ្ចូលគ្នា" មានន័យថាទំនិញដែលបានលាយបញ្ចូលជាមួយទំនិញដទៃតាមរបៀបមួយដែលអត្តសញ្ញាណនៃទំនិញនេះត្រូវបាត់បង់និងចូលក្នុងទំនិញថ្មី ឬក្នុងសមាសធាតុរួម ។

១៨-"ទ្រព្យអរូបីដទៃទៀត" មានន័យថារាល់ចលនវត្ថុ ឬសិទ្ធិដែលក្រៅពីទំនិញ គណនី កិច្ចសន្យាលក់ដែលមានកិច្ចធានា ឯកសារ លិខិតស្នាម និងរូបិយវត្ថុ ។

១៩-"បញ្ញើទុកលក់" គឺជាប្រតិបត្តិការដែលបុគ្គលម្នាក់(អ្នកផ្ញើទំនិញទុកលក់) ប្រគល់ទំនិញឱ្យទៅពាណិជ្ជករ(អ្នកទទួលទំនិញទុកលក់) ដើម្បីលក់ដោយមិនគិតពីទម្រង់នៃកិច្ចសន្យា ឬពាក្យពេចន៍ដែលប្រើក្នុងកិច្ចសន្យាហើយ :

ក-ពាណិជ្ជករទិញនិងលក់ទំនិញប្រភេទនេះ ប្រើឈ្មោះផ្សេងពីឈ្មោះអ្នកផ្ញើទំនិញទុកលក់ ។

ខ-ពាណិជ្ជករមិនមែនជាអ្នកលក់ដេញថ្លៃ ។

គ-ទំនិញមិនមែនជាទំនិញប្រើប្រាស់ មុនពេលប្រគល់ឱ្យទៅពាណិជ្ជករ ។

ឃ-ប្រតិបត្តិការនេះមិនបង្កើតសិទ្ធិប្រាតិភោគ ដែលធានាកាតព្វកិច្ច នោះទេ ។

២០-"បុគ្គល" មានន័យថារូបវន្តបុគ្គល ឬនីតិបុគ្គលដែលច្បាប់កម្ពុជាទទួលស្គាល់ ។

២១-"អ្នកទិញក្នុងអាជីវកម្មធម្មតា" មានន័យថា បុគ្គលដែលទិញទំនិញពីបុគ្គលដែលប្រកបអាជីវកម្មលក់ទំនិញ ក្នុងប្រភេទទំនិញដែលបានទិញ បើអ្នកទិញបានទិញដោយសុចរិត ហើយមិនបានដឹងថាការលក់នេះបំពានលើសិទ្ធិរបស់បុគ្គលផ្សេងទេ ។

២២-"ផលនៃទ្រព្យធានា" មានន័យថា អ្វីដែលទទួលបាននៅពេលលក់ ជួល ឬផ្តល់អាជ្ញាប័ណ្ណ ដោះដូរ ឬការជម្រះចោលទ្រព្យធានាតាមវិធីផ្សេងពីនេះ ។ គឺអ្វីៗដែលប្រមូលបានពីទ្រព្យធានា អ្វីៗត្រូវបានបែងចែកពីទ្រព្យធានា ដូចជាសិទ្ធិដែលផុសចេញពីទ្រព្យធានា បណ្តឹងទាមទារដែលកើតចេញពីការខាតបង់ ការមិនគោរពតាមវិការៈ ឬការខូចខាតទ្រព្យធានា ទៅតាមកំរិតតម្លៃនៃទ្រព្យធានា ថ្លៃធានារ៉ាប់រងដែលត្រូវសងដោយសារការខាតបង់ ឬ ការមិនគោរពតាមវិការៈ ឬការខូចខាតទ្រព្យធានា ទៅតាមកំរិតតម្លៃទ្រព្យធានា និងតាមកំរិតដែលត្រូវចេញសងកូនបំណុល ឬម្ចាស់បំណុលដែលមានកិច្ចធានា ។ "ផលជារូបិយវត្ថុ" មានន័យថា ផលជាសាច់ប្រាក់ មូលប្បទានប័ត្រ មូលនិធិដែលផ្ញើក្នុងធនាគារ និងផលនៃទ្រព្យធានា ដែលមានលក្ខណៈដូចគ្នានេះ ។

២៣-"ម្ចាស់បំណុលដែលមានកិច្ចធានា" មានន័យថា អ្នកឱ្យខ្ចី អ្នកលក់ ឬបុគ្គលដែលទទួលសិទ្ធិប្រាតិភោគ តាមកិច្ចសន្យាប្រាតិភោគ រាប់បញ្ចូលទាំងបុគ្គលដែលបានទិញគណនី ឬកិច្ចសន្យាលក់ដែលមានកិច្ចធានា អ្នកផ្ញើទំនិញទុកលក់ និងអ្នកជួលឱ្យដែលជួលទំនិញតាមការកំណត់នៃច្បាប់នេះ ។

២៤-"ម្ចាស់បំណុលក្នុងលិខិតជូនដំណឹង" គឺជាបុគ្គលដែលដាក់ឈ្មោះជាម្ចាស់បំណុលដែលមានកិច្ចធានា ឬ តំណាងរបស់ម្ចាស់បំណុលមានកិច្ចធានា ក្នុងលិខិតជូនដំណឹងដំបូង ឬវិសោធនកម្មដែលបានតម្កល់ ។ បុគ្គលនេះមានឋានៈជាម្ចាស់បំណុលដែលមានកិច្ចធានាក្នុងលិខិតជូនដំណឹង ក្នុងរយៈពេលតម្កល់ ឬរហូតដល់ពេលបានតម្កល់វិសោធនកម្មដែលលុបឈ្មោះម្ចាស់បំណុលនេះ ឬ រហូតដល់ពេលលិខិតសុំបញ្ចប់សិទ្ធិប្រាតិភោគ

របស់ម្ចាស់បំណុលក្នុងលិខិតជូនដំណឹង ឬ រហូតដល់ពេលដែលលិខិតជូនដំណឹងទាក់ទិននឹងម្ចាស់បំណុលមានកិច្ចធានា ផុតរយៈពេលកំណត់ ។

២៥-"យានយន្តមានលេខស៊េរី" មានន័យថា យានយន្ត រថសណ្តោង អាកាសយាន កាណូត ឬទូកដែលមានម៉ាស៊ីន បើយានយន្តទាំងនេះមិនមែនជាសារពើភណ្ឌរបស់កូនបំណុល ។

២៦-"លិខិតស្នាម" គឺជាកំណត់ត្រាដែលបង្ហាញភស្តុតាងពីសិទ្ធិទទួលប្រាក់ដែលមិនមែនជាកិច្ចព្រមព្រៀងប្រាតិភោគ ឬ កិច្ចសន្យាជួល និងការផ្ទេរមួយប្រភេទដែលកើតឡើងតាមការប្រគល់ក្នុងអាជីវកម្មធម្មតាដោយមានបិដ្ឋិលេខចំណារខ្នង ឬ អនុប្បទានសិទ្ធិ ។ ពាក្យនេះរាប់បញ្ចូលទាំងភស្តុតាងនៃសិទ្ធិប្រាតិភោគផងដែរ ។

២៧-"លិខិតជូនដំណឹង" គឺជាកំណត់ត្រាដែលបានតម្កល់ ឬ ដាក់ជូនដើម្បីតម្កល់នៅការិយាល័យតម្កល់ ។ ពាក្យនេះរាប់បញ្ចូលទាំងវិសោធនកម្ម លិខិតសុំបន្ត និងលិខិតសុំបញ្ចប់ដែលបានតម្កល់ ឬ ដាក់ជូនដើម្បីតម្កល់ ។

២៨-"វត្ថុចំណុះ" សំដៅដល់ចលនទ្រព្យដែលបានផ្តុំបញ្ចូលជាមួយចលនវត្ថុផ្សេង តាមរបៀបដែលមិនធ្វើឱ្យ បាត់បង់អត្តសញ្ញាណនៃចលនវត្ថុចម្បងនោះទេ ។

២៩-"សារពើភណ្ឌ" គឺជាទំនិញដែលបុគ្គលកាន់កាប់សម្រាប់លក់ ជួល ឬ ជាវត្ថុធាតុដើម គំរោងដែលកំពុងដំណើរការ សម្ភារៈដែលប្រើប្រាស់ក្នុងអាជីវកម្ម ។

៣០-"សិទ្ធិប្រាតិភោគលើប្រាក់ខ្ចីទិញ" មានន័យថាសិទ្ធិប្រាតិភោគដែល ៖

ក-ត្រូវបានយក ឬ រក្សាទុកដោយអ្នកលក់ទំនិញដើម្បីធានាតម្លៃទំនិញនោះទាំងស្រុង ឬ មួយផ្នែក

ខ-ត្រូវបានយកដោយបុគ្គល ក្រៅពីអ្នកលក់ដែលបានបង់តម្លៃ ដើម្បីឱ្យកូនបំណុលទទួលបានសិទ្ធិ ឬការប្រើប្រាស់ទំនិញតាមរយៈការបង្កើតកាតព្វកិច្ច បើតម្លៃនោះ បានប្រើតាមគោលបំណងនេះប្រាកដមែន ។

៣១-"អនុប្បទានសិទ្ធិ" គឺជាការផ្ទេរពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់នូវសិទ្ធិទាំងស្រុង ឬ មួយផ្នែកលើគណនី កិច្ចសន្យាលក់ដែលមានកិច្ចធានា ឯកសារ លិខិតស្នាម ឬសិទ្ធិទទួលការបង់ប្រាក់ផ្សេងទៀត ។

[stamp]

បុគ្គលដែលផ្ទេរសិទ្ធិនេះហៅថា អនុប្បទាយី និងបុគ្គលដែលទទួលសិទ្ធិផ្ទេរហៅថា អនុប្បទានិក ។

៣២-"អ្នកជួលក្នុងអាជីវកម្មធម្មតា" គឺជាបុគ្គលដែលបានជួលទំនិញតាមប្រភេទនៃទំនិញក្នុងអាជីវកម្មពីបុគ្គលដែលមានអាជីវកម្មលក់ ឬ ជួលទំនិញធម្មតាដោយសុចរិតនិងមិនដឹងថាការជួលនេះបំពានលើសិទ្ធិកម្មសិទ្ធិ ឬ សិទ្ធិប្រាតិភោគ ឬ សិទ្ធិរបស់តតិយជនលើទំនិញនេះឡើយ ។ "កិច្ចសន្យាលក់បណ្តាក់" អាចធ្វើឡើងជាថ្នូរនឹងរូបិយវត្ថុ ឬទ្រព្យផ្សេងទៀត ។

៣៣-"ឧបករណ៍" មានន័យថា ទំនិញ លើកលែងតែកសិផល សារពើភណ្ឌ ទំនិញប្រើប្រាស់ ឬយានយន្តមានលេខសេរី ។

៣៤-"ឯកសារ" មានន័យថា ប័ណ្ណកម្មសិទ្ធិ ឬបង្កាន់ដៃ ជាអាទិ៍មានប័ណ្ណដឹកជញ្ជូន សក្ខីប័ត្រកំពង់ផែ បង្កាន់ដៃឃ្លាំង ដែលចេញដោយបុគ្គលដែលធ្វើអាជីវកម្មដឹកជញ្ជូន ឬ ស្តុកទំនិញ ។

**មាត្រា ៤.-**

១-សិទ្ធិប្រាតិភោគ គឺជាសិទ្ធិប្រត្យ័ក្សលើទ្រព្យធានា ដែលដាក់ធានាការបំពេញកាតព្វកិច្ច ។

២-បុគ្គលគ្រប់រូបអាចផ្តល់ ឬ ទទួលសិទ្ធិប្រាតិភោគ ដែលមានចែងក្នុងច្បាប់នេះ លើកលែងតែប្រការដែលមានចែងក្នុងចំណុចទី ៣ នៃមាត្រានេះ ។

៣-មិនអាចបង្កើតសិទ្ធិប្រាតិភោគលើទំនិញប្រើប្រាស់បានទេ លើកលែងតែសិទ្ធិប្រាតិភោគលើប្រាក់ខ្ចីទិញលើទំនិញរបស់កូនបំណុល ។

៤-មិនអាចចាត់ទុកថា សិទ្ធិប្រាតិភោគគ្មានសុពលភាពទេ បើកូនបំណុលមានសិទ្ធិប្រើប្រាស់ កាន់កាប់ លក់ ដោះដូរ បញ្ចូលេប្លា ឬ ជម្រះចោលទ្រព្យធានា ។

**មាត្រា ៥.-**

១-សិទ្ធិប្រាតិភោគអាចធានាកាតព្វកិច្ចមួយ ឬ ច្រើន ដែលចែងជាក់លាក់ ឬ ប្រើពាក្យទូទៅបាន ។

២-កាតព្វកិច្ចប្រាតិភោគជាកាតព្វកិច្ចជារូបិយវត្ថុ ឬ មិនមែនជារូបិយវត្ថុ ។

៣-កាតព្វកិច្ចប្រាតិភោគ ត្រូវគ្រប់គ្រងដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ឬ ច្បាប់របស់បរទេស ទោះបីជាក្នុងករណីណាមួយក៏ដោយ បទប្បញ្ញត្តិនៃច្បាប់នេះក៏ត្រូវអនុវត្តផងដែរ ។

៤-សិទ្ធិប្រាតិភោគអាចធានាកាតព្វកិច្ចអនាគតបាន ទោះបីជាកាតព្វកិច្ចជាក់លាក់ ឬកាតព្វកិច្ចមានលក្ខខណ្ឌ និងកាតព្វកិច្ចតាមជំរើសក៏ដោយ ។

៥-តាមការព្រមព្រៀងរបស់ភាគី សិទ្ធិប្រាតិភោគអាចធានាបុរេកាតព្វកិច្ចបាន ។

មាត្រា ៦.-

១-ទ្រព្យធានាអាចជាទំនិញ និងចលនវត្ថុគ្រប់ប្រភេទបាន ។

២-ទ្រព្យធានាអាចជាទ្រព្យអរូបី ជាអាទិ៍មានសិទ្ធិប្រស៊ុក្ស សិទ្ធិលើបំណុលនិងទ្រព្យអរូបីដទៃទៀត ។

៣-ទ្រព្យធានាអាចជាចលនវត្ថុតាំងភ្ជាប់ ។

៤-ទ្រព្យធានាអាចជាទ្រព្យដែលមានក្នុងពេលបច្ចុប្បន្ន ឬ អាចកើតឡើងនាពេលអនាគត ។

៥-ទ្រព្យធានាអាចស្ថិតនៅទីណាក៏បាន ទោះបីនៅក្នុង ឬនៅក្រៅព្រះរាជាណាចក្រកម្ពុជាក៏ដោយ ។

៦-ទ្រព្យធានាអាចជាគណនី និងកិច្ចសន្យាលក់ដែលមានកិច្ចធានាដែលបានលក់ទំនិញដែលបានផ្ញើទុកលក់ ទំនិញដែលបានផ្តល់ហើយនិងផលនៃទ្រព្យធានា ។

៧-សេចក្តីអធិប្បាយពីទ្រព្យធានាត្រូវចាត់ទុកថាគ្រប់គ្រាន់ បើក្នុងសេចក្តីអធិប្បាយនោះមានបញ្ជាក់សមស្របពីអត្តសញ្ញាណទ្រព្យធានា ។ សេចក្តីអធិប្បាយពីទ្រព្យធានាអាចចែងជាពាក្យទូទៅបាន លើកលែងតែយានយន្តមានលេខស៊េរី ។ សេចក្តីអធិប្បាយថា "ទ្រព្យសកម្មទាំងអស់" ឬ "ចលនទ្រព្យទាំងអស់" របស់កូនបំណុលត្រូវចាត់ទុកជាសេចក្តីអធិប្បាយគ្រប់គ្រាន់ លើកលែងតែសេចក្តីអធិប្បាយពីទំនិញប្រើប្រាស់ ។

មាត្រា ៧.-

១-កិច្ចព្រមព្រៀងប្រាតិភោគ ត្រូវតែធ្វើឡើងតាមទម្រង់កំណត់ត្រាជាលាយលក្ខណ៍អក្សរ ។ កិច្ចព្រមព្រៀងប្រាតិភោគ អាចកើតឡើងពីកំណត់ត្រាច្រើនដែលដាក់បញ្ចូលគ្នា ។

២-កិច្ចព្រមព្រៀងប្រាតិភោគ ត្រូវមានប្រសិទ្ធភាពស្របតាមលក្ខខណ្ឌរវាងភាគី និងមានប្រសិទ្ធភាពចំពោះអ្នកទិញទ្រព្យធានានិងម្ចាស់បំណុល លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងក្នុងច្បាប់នេះ ។

៣-កិច្ចព្រមព្រៀងប្រាតិភោគអាចចែងពីសិទ្ធិប្រាតិភោគច្រើនជាងមួយបាន ។

មាត្រា ៨.-

១-ម្ចាស់បំណុលដែលមានកិច្ចធានា ត្រូវយកចិត្តទុកដាក់ក្នុងការឃុំគ្រង និងថែរក្សាទ្រព្យធានាដែលខ្លួនកាន់កាប់ឱ្យបានគង់វង់ ។

២-លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះ បើទ្រព្យធានាស្ថិតក្នុងការកាន់កាប់របស់ម្ចាស់បំណុល :

ក-ចំណាយសមស្របត្រូវចេញដោយកូនបំណុល និងធានាដោយទ្រព្យធានារាប់បញ្ចូលទាំងថ្លៃធានារ៉ាប់រង ពន្ធអាករនិងថ្លៃចំណាយទាក់ទិននឹងទ្រព្យធានា ។

ខ-ហានិភ័យនៃការបាត់បង់ ឬ ការខូចខាតដោយគ្រោះថ្នាក់ គឺជាបន្ទុករបស់កូនបំណុលចំពោះតែប្រាក់ ដែលលើសពីថ្លៃសំណងធានារ៉ាប់រង ។

គ-ម្ចាស់បំណុលដែលមានកិច្ចធានា អាចរក្សាទុកផលនៃទ្រព្យធានាជាសិទ្ធិប្រាតិភោគបន្ថែម លើកលែងតែផលជារូបិយវត្ថុ ហើយបើមានផលជារូបិយវត្ថុ ត្រូវប្រើដើម្បីទូទាត់កាតព្វកិច្ចប្រាតិភោគ លើកលែងតែផលជារូបិយវត្ថុនោះត្រូវបានផ្ទេរឱ្យទៅកូនបំណុលរួចហើយ ។

មាត្រា ៩.-

១-សិទ្ធិប្រាតិភោគភ្ជាប់ទៅនឹងទ្រព្យធានា ហើយអាចបង្ខំឱ្យកូនបំណុលនិងភាគីទីបី[illegible]បានចំពោះទ្រព្យធានា តែក្នុងករណីដែល :

ក-កូនបំណុលបានបញ្ជាក់ការឯកភាព លើកិច្ចព្រមព្រៀងប្រាតិភោគដែល

ចែងពីទ្រព្យធានា

ខ-ម្ចាស់បំណុលបានផ្តល់តម្លៃឱ្យទៅកូនបំណុល

គ-កូនបំណុលមានសិទ្ធិលើទ្រព្យធានា ឬ អំណាចផ្ទេរសិទ្ធិលើទ្រព្យធានាឱ្យទៅម្ចាស់បំណុលដែលមានកិច្ចធានា ។

២-លើកលែងតែភាគីបានព្រមព្រៀងផ្សេងពីនេះ ការភ្ជាប់សិទ្ធិប្រាតិភោគទៅនឹងទ្រព្យធានាផ្តល់ឱ្យម្ចាស់បំណុល មានកិច្ចធានានូវសិទ្ធិលើផលនៃទ្រព្យធានាដូចមានចែងក្នុងច្បាប់នេះ ។

## ជំពូកទី ២

## សុក្រឹតកម្ម និង អាទិភាព

**មាត្រា ១០.-**

១-សិទ្ធិប្រាតិភោគមានសុក្រឹតភាព កាលណាសិទ្ធិប្រាតិភោគនេះបានភ្ជាប់ទៅនឹងទ្រព្យធានា និងបានបំពេញតាមលក្ខខណ្ឌទាំងអស់នៃមាត្រានេះ ។

២-ដើម្បីឱ្យសិទ្ធិប្រាតិភោគមានសុក្រឹតភាព ត្រូវតែតម្កល់លិខិតជូនដំណឹងតាមច្បាប់នេះ លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងក្នុងច្បាប់នេះ ។

៣-សិទ្ធិប្រាតិភោគលើប្រាក់ខ្ចីទិញទំនិញប្រើប្រាស់ មានសុក្រឹតភាពនៅពេលដែលសិទ្ធិប្រាតិភោគភ្ជាប់នឹងទំនិញនោះ ហើយមិនចាំបាច់តម្កល់លិខិតជូនដំណឹងដើម្បីធ្វើសុក្រឹតកម្មឡើយ ។

៤-សិទ្ធិប្រាតិភោគលើទំនិញ លិខិតស្នាម ឯកសារ ឬ កិច្ចសន្យាលក់ដែលមានកិច្ចធានាអាចមានសុក្រឹតភាព ដោយការតម្កល់លិខិតជូនដំណឹង ឬ ដោយម្ចាស់បំណុលមានកិច្ចធានាកាន់កាប់ទ្រព្យធានា ។

៥-សិទ្ធិប្រាតិភោគបន្តមានសុក្រឹតភាពដោយការកាន់កាប់ គិតចាប់ពីពេលកាន់កាប់ហើយសុក្រឹតភាពនេះ ត្រូវបន្តអនុភាពតែក្នុងពេលមានការកាន់កាប់ប៉ុណ្ណោះ ។

៦-សិទ្ធិប្រាតិភោគលើរូបិយវត្ថុ អាចមានសុក្រឹតភាពតែក្នុងករណីដែលម្ចាស់បំណុលដែលមានកិច្ចធានាបានកាន់កាប់រូបិយវត្ថុ លើកលែងតែផលទ្រព្យធានាដែលជារូបិយវត្ថុ ។

៧-សិទ្ធិប្រាតិភោគលើយានយន្តមានលេខស៊េរី អាចត្រូវធ្វើសុក្រឹតកម្មដោយការតម្កល់លិខិតជូនដំណឹងដែលពណ៌នាជាទូទៅ ឬ បញ្ជាក់ពីលេខស៊េរីនៃយានយន្តនោះ ។

៨-សិទ្ធិប្រាតិភោគក្រៅពីសិទ្ធិប្រាតិភោគលើវិបិយវត្ថុ អាចត្រូវធ្វើសុក្រឹតកម្មមុន ឬ ក្នុងពេល ឬ បន្ទាប់ពីរយៈពេលដែលម្ចាស់បំណុលដែលមានកិច្ចធានាបានកាន់កាប់ទ្រព្យធានា ។

៩-មិនចាំបាច់តម្កល់លិខិតជូនដំណឹង ដើម្បីធ្វើសុក្រឹត្យកម្មសិទ្ធិប្រាតិភោគលើផលនៃទ្រព្យធានាឡើយ ។

១០-កាលណាទំនិញស្ថិតក្នុងការកាន់កាប់របស់អ្នកទទួលបញ្ញើ ដែលបានចេញឯកសារបញ្ជាក់ពីទំនិញនេះ សិទ្ធិប្រាតិភោគលើទំនិញអាចមានសុក្រឹតភាព ដោយការធ្វើសុក្រឹតកម្មសិទ្ធិប្រាតិភោគលើឯកសារនោះ ។ សិទ្ធិប្រាតិភោគដែលត្រូវបានធ្វើសុក្រឹតកម្មតាមមធ្យោបាយផ្សេង ក្នុងអំឡុងពេលដែលអ្នកទទួលបញ្ញើកាន់កាប់ទំនិញ ត្រូវមានអាទិភាពក្នុងលំដាប់ បន្ទាប់ពីសិទ្ធិប្រាតិភោគដែលត្រូវធ្វើសុក្រឹតកម្មលើឯកសារ ។

១១-ការធ្វើសុក្រឹតកម្មសិទ្ធិប្រាតិភោគលើទ្រព្យធានា នាំឱ្យសិទ្ធិប្រាតិភោគលើកិច្ចធានាដែលគាំទ្រទ្រព្យធានានេះត្រូវមានសុក្រឹតភាពផងដែរ ។ ភាគីមិនចាំបាច់តម្កល់លិខិតជូនដំណឹង ដើម្បីធ្វើសុក្រឹត្យកម្មសិទ្ធិប្រាតិភោគលើកិច្ចធានានេះឡើយ ។

១២-ការធ្វើសុក្រឹតកម្មសិទ្ធិប្រាតិភោគលើសិទ្ធិទទួលប្រាក់ ឬ ការបំពេញកាតព្វកិច្ចនាំឱ្យសិទ្ធិប្រាតិភោគលើកិច្ចសន្យាអ៊ីប៉ូតែកស្តីពីអចលនទ្រព្យ ដែលធានាសិទ្ធិទទួលប្រាក់នោះមានសុក្រឹតភាពផងដែរ ។

មាត្រា ១១.–

១-សិទ្ធិប្រាតិភោគត្រូវមានសុក្រឹតភាពជាបន្ត បើដំបូងត្រូវធ្វើសុក្រឹតកម្មតាមរបៀបមួយ ហើយក្រោយមកមានសុក្រឹតភាពតាមរបៀបផ្សេង បើគ្មានចន្លោះរយៈពេលដែលគ្មានសុក្រឹតភាពរវាងចំណុចទាំងពីរនេះទេ ។

២-ក្នុងករណីដែលម្ចាស់បំណុលដែលមានកិច្ចធានា ផ្ទេរសិទ្ធិប្រាតិភោគដែលមានសុក្រឹតភាព មិនចាំបាច់តម្កល់លិខិតជូនដំណឹងតាមច្បាប់នេះ ដើម្បីបន្តសុក្រឹតភាពសិទ្ធិ-

ប្រាតិភោគចំពោះម្ចាស់បំណុលរបស់កូនបំណុល និងបុគ្គលដែលទទួលទ្រព្យធានាពីកូនបំណុលឡើយ ។

**មាត្រា ១២.-**

១-សិទ្ធិប្រាតិភោគច្រើនលើទ្រព្យធានាតែមួយ ត្រូវមានអាទិភាពអនុលោមតាមពេលនៃការតម្កល់ ឬ ការធ្វើសុក្រឹតកម្ម លើកលែងតែច្បាប់នេះចែងផ្សេងពីនេះ ។

២-អាទិភាពត្រូវគិតចាប់ពីកាលបរិច្ឆេទនៃការតម្កល់លិខិតជូនដំណឹងពីទ្រព្យធានា ឬ ពីពេលដែលសិទ្ធិប្រាតិភោគមានសុក្រឹតភាព គឺយកកាលបរិច្ឆេទណាមួយ ដែលកើតឡើងមុន បើគ្មានចន្លោះរយៈពេលដែលគ្មានការតម្កល់និងគ្មានសុក្រឹតភាពក្រោយពីនេះទេ ។

៣-សិទ្ធិប្រាតិភោគដែលត្រូវភ្ជាប់នឹងទ្រព្យធានាមុនគេ ត្រូវមានអាទិភាពលើសិទ្ធិ-ប្រាតិភោគផ្សេងទៀត ដែលមិនបានតម្កល់ ឬមិនបានធ្វើសុក្រឹត្យកម្ម ។

៤-កាលបរិច្ឆេទនៃការតម្កល់ ឬសុក្រឹតកម្មសម្រាប់ទ្រព្យធានា ត្រូវចាត់ទុកជាកាល-បរិច្ឆេទនៃការតម្កល់ ឬ សុក្រឹតកម្មសម្រាប់ផលនៃទ្រព្យធានានេះផងដែរ ។

**មាត្រា ១៣.-**

សិទ្ធិប្រាតិភោគមានអាទិភាពលើសិទ្ធិរបស់គាហកនៃសិទ្ធិឃាត់ទុក លើកលែងតែគាហកនៃសិទ្ធិឃាត់ទុកបានតម្កល់លិខិតជូនដំណឹងពីសិទ្ធិរបស់ខ្លួនតាមច្បាប់នេះ :

១-មុនពេលសិទ្ធិប្រាតិភោគមានសុក្រឹត្យភាព

២-មុនពេលម្ចាស់បំណុលតម្កល់លិខិតជូនដំណឹងពីទ្រព្យធានា ។

**មាត្រា ១៤.-**

១-បុគ្គលត្រូវទទួលទ្រព្យធានាដោយគ្មានជាប់សិទ្ធិប្រាតិភោគ បើបុគ្គលបានទិញនិងផ្តល់តម្លៃដោយមិនបានដឹងថាមានសិទ្ធិប្រាតិភោគ និងមុនពេលដែលសិទ្ធិប្រាតិភោគមានសុក្រឹតភាព ។ ក្នុងករណីទ្រព្យធានាជាទ្រព្យរូបី បុគ្គលនឹងទទួលបានទ្រព្យធានាដោយគ្មានជាប់សិទ្ធិប្រាតិភោគ បើបុគ្គលបានទិញផ្តល់តម្លៃ និងទទួលទ្រព្យធានាដោយមិនបានដឹងថាមានសិទ្ធិប្រាតិភោគ និងមុនពេលដែលសិទ្ធិប្រាតិភោគមានសុក្រឹតភាព ។

២-ថ្វីបើមានចែងក្នុងចំណុចទី ១ ក្ដី អ្នកទិញក្នុងអាជីវកម្មធម្មតាត្រូវទទួលកម្មសិទ្ធិដោយគ្មានជាប់សិទ្ធិប្រាតិភោគលើទំនិញឡើយ ទោះបីសិទ្ធិប្រាតិភោគមានសុក្រឹតភាពក៏ដោយ និងទោះបីជាអ្នកទិញបានដឹងថា មានជាប់សិទ្ធិប្រាតិភោគក៏ដោយ ។

៣-ថ្វីបើមានចែងក្នុងចំណុចទី ១ ក្ដី អ្នកទិញទំនិញប្រើប្រាស់នឹងទទួលបានកម្មសិទ្ធិដោយគ្មានជាប់សិទ្ធិប្រាតិភោគលើទំនិញ ទោះបីសិទ្ធិប្រាតិភោគមាន ឬ គ្មានសុក្រឹតភាពក៏ដោយ បើអ្នកទិញបានទិញដោយមិនដឹងថាមានសិទ្ធិប្រាតិភោគ និងមុនពេលមានការតម្កល់លិខិតជូនដំណឹងពីទំនិញប្រើប្រាស់នេះ ។

៤-ថ្វីបើមានចែងក្នុងចំណុចទី ១ ក្ដី អ្នកទិញយានយន្តមានលេខស៊េរី ត្រូវទទួលយានយន្តមានលេខស៊េរី ដោយគ្មានជាប់សិទ្ធិប្រាតិភោគ តែក្នុងករណីដែលអ្នកទិញបានទិញដោយមិនបានដឹងថាមានសិទ្ធិប្រាតិភោគ ហើយលិខិតជូនដំណឹងដែលតម្កល់មិនបានពណ៌នាពីយានយន្តមានលេខស៊េរីនេះ ឬ លិខិតជូនដំណឹងដែលតម្កល់នោះបានចុះលេខស៊េរីមិនត្រឹមត្រូវ ។

៥-ថ្វីបើមានចែងក្នុងចំណុចទី ១ ក្ដី អ្នកទិញកសិផលត្រូវទទួលបាន :

ក-កសិផលដោយគ្មានជាប់សិទ្ធិប្រាតិភោគ បើអ្នកទិញយកកសិផលទៅប្រើជាទំនិញប្រើប្រាស់ ។

ខ-កសិផលដោយគ្មានជាប់សិទ្ធិប្រាតិភោគ បើអ្នកទិញយកកសិផលទៅប្រើក្នុងគោលបំណងក្រៅពីទំនិញប្រើប្រាស់ ហើយអ្នកទិញបានផ្ដល់តម្លៃ និងបានទទួលកសិផលដោយមិនបានដឹងថាមានសិទ្ធិប្រាតិភោគ និងមុនពេលសិទ្ធិប្រាតិភោគមានសុក្រឹតភាព ។

៦-អ្នកទទួលប្រាក់ផ្ទេរត្រូវទទួលប្រាក់ដោយគ្មានជាប់សិទ្ធិប្រាតិភោគ លើកលែងតែអ្នកទទួលបានស៊ុំគ្រលំជាមួយកូនបំណុលដោយបំពានលើសិទ្ធិរបស់ម្ចាស់បំណុលដែលមានកិច្ចធានា ។

៧-អ្នកទទួលផលនៃទ្រព្យធានាដែលជាមូលនិធិក្នុងគណនីប្រាក់បញ្ញើ គណនីមូលប្បទានប័ត្រ គណនីសញ្ជ័យ សៀវភៅធនាគារ ឬ គណនីសាច់ប្រាក់ដទៃទៀត ត្រូវទទួលបានមូលនិធិដោយគ្មានជាប់សិទ្ធិប្រាតិភោគ លើកលែងតែអ្នកទទួលបានស៊ុំគ្រលំជាមួយកូនបំណុលដោយបំពានលើសិទ្ធិរបស់ម្ចាស់បំណុលដែលមានកិច្ចធានា ។

**មាត្រា ១៥.-**

១-អ្នកជួលទ្រព្យធានាត្រូវទទួលបានសិទ្ធិ ដោយគ្មានជាប់សិទ្ធិប្រាតិភោគ បើអ្នកជួលបានទទួលទំនិញ ដោយមិនបានដឹងថាមានសិទ្ធិប្រាតិភោគ និងមុនពេលដែលសិទ្ធិប្រាតិភោគមានសុក្រឹតភាព ។

២-ថ្វីបើមានចែងក្នុងចំណុចទី ១ ក្ដី អ្នកជួលទំនិញក្នុងអាជីវកម្មធម្មតាត្រូវទទួលបានសិទ្ធិដោយគ្មានជាប់សិទ្ធិប្រាតិភោគលើទំនិញ ទោះបីសិទ្ធិប្រាតិភោគមានសុក្រឹតភាព និងទោះបីជាអ្នកជួលបានដឹងថាមានសិទ្ធិប្រាតិភោគក៏ដោយ ។

៣-ថ្វីបើមានចែងក្នុងចំណុចទី ១ ក្ដី អ្នកជួលត្រូវទទួលបានយានយន្តមានលេខស៊េរីដោយគ្មានជាប់សិទ្ធិប្រាតិភោគ តែក្នុងករណីដែលអ្នកជួលបានជួលដោយមិនបានដឹងថាមានសិទ្ធិប្រាតិភោគ ហើយលិខិតជូនដំណឹងដែលតម្កល់មិនបានពណ៌នាត្រឹមត្រូវពីយានយន្តមានលេខស៊េរីនេះ ។

**មាត្រា ១៦.-**

បើបុគ្គលតម្កល់លិខិតជូនដំណឹងពីសិទ្ធិប្រាតិភោគលើប្រាក់ខ្ចីទិញមុនពេល ឬ ក្នុងអំឡុងពេលប្រាំ(០៥)ថ្ងៃ បន្ទាប់ពីកូនបំណុលបានទទួលទំនិញ សិទ្ធិប្រាតិភោគនេះមានអាទិភាពលើសិទ្ធិរបស់អ្នកទិញ អ្នកជួល ឬគាហកនៃសិទ្ធិឃាត់ទុកដែលកើតឡើងក្នុងចន្លោះពេលដែលសិទ្ធិប្រាតិភោគភ្ជាប់នឹងទំនិញ និងពេលនៃការតម្កល់លិខិតជូនដំណឹង ។

**មាត្រា ១៧.-**

១-សិទ្ធិប្រាតិភោគត្រូវបន្តភ្ជាប់នឹងទ្រព្យធានា ថ្វីបើមានការលក់ ការជួល ការផ្ដល់អាជ្ញាប័ណ្ណ ការដូរ ឬការជម្រះចោលទ្រព្យធានាក្ដី លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងក្នុងច្បាប់នេះ ឬភាគីបានព្រមព្រៀងផ្សេងពីនេះ ។

២-នៅពេលជម្រះចោលទ្រព្យធានា សិទ្ធិប្រាតិភោគត្រូវបន្តភ្ជាប់នឹងផលនៃទ្រព្យធានា លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងក្នុងច្បាប់នេះ ឬភាគីបានព្រមព្រៀងផ្សេងនេះ ។

៣-សិទ្ធិប្រាតិភោគលើផលនៃទ្រព្យធានា គឺជាសិទ្ធិប្រាតិភោគមានសុក្រឹតភាពជាបន្តក្នុងករណីដែលសិទ្ធិប្រាតិភោគលើទ្រព្យធានាដើម ត្រូវបានធ្វើសុក្រឹតកម្ម ប៉ុន្តែសិទ្ធិនេះក្លាយ

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

ទៅជាគ្មានសុក្រឹតភាពក្នុងរយៈពេលម្ភៃ(២០)ថ្ងៃ បន្ទាប់ពីកូនបំណុលទទួលផលនៃទ្រព្យធានានេះ លើកលែងតែ :

- បានតម្កល់លិខិតជូនដំណឹងសម្រាប់ទ្រព្យធានាដើម ហើយផលនៃទ្រព្យធានាជារូបិយវត្ថុ ឬផលនៃទ្រព្យធានាមានលក្ខណៈដូចបញ្ជាក់ក្នុងលិខិតជូនដំណឹង ឬ
- សិទ្ធិប្រាតិភោគលើផលនៃទ្រព្យធានា ត្រូវបានធ្វើសុក្រឹតកម្មមុនផុតរយៈពេលម្ភៃ (២០)ថ្ងៃ ។

មាត្រា ១៨.–

១-សិទ្ធិប្រាតិភោគលើប្រាក់ខ្ចីទិញឧបករណ៍ ដែលមានសុក្រឹតភាពត្រូវមានអាទិភាពលើសិទ្ធិប្រាតិភោគឯទៀតលើឧបករណ៍តែមួយ និងមានអាទិភាពលើផលនៃឧបករណ៍ផងដែរ បើសិទ្ធិប្រាតិភោគលើប្រាក់ខ្ចីទិញត្រូវបានធ្វើសុក្រឹតកម្មនៅពេលដែលកូនបំណុលបានកាន់កាប់ឧបករណ៍ ឬក្នុងរយៈពេលប្រាំ(០៥)ថ្ងៃ បន្ទាប់ពីការកាន់កាប់ ។

២-សិទ្ធិប្រាតិភោគលើប្រាក់ខ្ចីទិញសារពើភណ្ឌ ឬសត្វចិញ្ចឹមគ្រប់ប្រភេទ ត្រូវមានអាទិភាពលើសិទ្ធិប្រាតិភោគផ្សេងទៀតលើសារពើភណ្ឌ ឬសត្វចិញ្ចឹមប្រភេទតែមួយ ប្រសិនបើ :

ក-សិទ្ធិប្រាតិភោគលើប្រាក់ខ្ចីទិញ ត្រូវបានធ្វើសុក្រឹតកម្មនៅពេលដែលកូនបំណុលបានកាន់កាប់សារពើភណ្ឌ ឬសត្វចិញ្ចឹមគ្រប់ប្រភេទ និង

ខ-ម្ចាស់បំណុលដែលមានកិច្ចធានាពីប្រាក់ខ្ចីទិញ ជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អ្នកកាន់កាប់សិទ្ធិប្រាតិភោគផ្សេងទៀត បើអ្នកកាន់កាប់នោះបានតម្កល់លិខិតជូនដំណឹងសម្រាប់សារពើភណ្ឌ ឬ សត្វចិញ្ចឹមប្រភេទដូចគ្នា មុនពេលដែលម្ចាស់បំណុលមានកិច្ចធានាពីប្រាក់ខ្ចីទិញបានតម្កល់លិខិតជូនដំណឹង ។ លិខិតជូនដំណឹងត្រូវតែអធិប្បាយអំពីសារពើភណ្ឌ ឬសត្វចិញ្ចឹមគ្រប់ប្រភេទ និងបញ្ជាក់ថាបុគ្គលដែលផ្តល់លិខិតជូនដំណឹងបានទទួល ឬនឹងបានទទួលសិទ្ធិប្រាតិភោគលើប្រាក់ខ្ចីទិញសារពើភណ្ឌ ឬ សត្វចិញ្ចឹមរបស់កូនបំណុល ។

**មាត្រា ១៩.–**

សិទ្ធិឃាត់ទុកទំនិញដែលបង្កើតឡើងដោយច្បាប់ត្រូវមានអាទិភាពលើសិទ្ធិប្រាតិភោគដែលមានសុក្រឹតភាព ប្រសិនបើ :

១-សិទ្ធិឃាត់ទុកត្រូវបង្កើតជាផលប្រយោជន៍របស់បុគ្គល ដែលកាន់កាប់ទំនិញសម្រាប់ធានាការទូទាត់ថ្លៃសម្ភារៈ ឬសេវាកម្មដែលទាក់ទិននឹងទំនិញ និង

២-សម្ភារៈ ឬសេវាកម្មនោះត្រូវបានផ្តល់ក្នុងដំណើរការអាជីវកម្មធម្មតា ។

**មាត្រា ២០.–**

១-សិទ្ធិប្រាតិភោគអាចបង្កើតលើទំនិញដែលជាចលនវត្ថុតាំងភ្ជាប់ ហើយអាចបន្តភ្ជាប់នឹងទំនិញដែលក្លាយទៅជាចលនវត្ថុតាំងភ្ជាប់ ។

២-សិទ្ធិប្រាតិភោគ លើសម្ភារៈសំណង់ធម្មតាត្រូវបញ្ចប់នៅពេលសម្ភារៈនោះត្រូវបានបញ្ចូលទៅក្នុងអចលនវត្ថុ ។

៣-ម៉ាស៊ីននៃរោងចក្រ ម៉ាស៊ីនប្រើក្នុងការិយាល័យដែលអាចរុះរើបានដោយងាយស្រួល បរិក្ខារក្នុងផ្ទះ ឬវត្ថុដទៃទៀត ដែលអាចយកទៅប្រើដាច់ដោយឡែកពីដី និងអាគារបាន មិនចាត់ទុកជាចលនវត្ថុតាំងភ្ជាប់ឡើយ ។ អាទិភាពលើចលនវត្ថុទាំងនេះមិនត្រូវកំណត់តាមមាត្រានេះទេ ហើយមិនរងឥទ្ធិពលពីសិទ្ធិរបស់ម្ចាស់អចលវត្ថុ ឬម្ចាស់បំណុលអ៊ីប៉ូតែកលើដីឡើយ ។

៤-សិទ្ធិប្រាតិភោគលើចលនវត្ថុតាំងភ្ជាប់ ត្រូវមានអាទិភាពបន្ទាប់ពីសិទ្ធិប្រស៊ុំក្បលើអចលនវត្ថុ លើកលែងតែសិទ្ធិដែលមានចែងក្នុងច្បាប់នេះ ។

៥-សិទ្ធិប្រាតិភោគលើចលនវត្ថុតាំងភ្ជាប់ដែលមានសុក្រឹតភាព មានអាទិភាពលើសិទ្ធិរបស់ម្ចាស់អចលនវត្ថុ គាហកនៃសិទ្ធិឃាត់ទុក ឬ ម្ចាស់បំណុលអ៊ីប៉ូតែក នោះបីជាខបញ្ញត្តិនៃកិច្ចសន្យាអ៊ីប៉ូតែកចែងផ្សេងពីនេះក្តី ប្រសិនបើ :

ក-លិខិតជូនដំណឹង ត្រូវបានតម្កល់មុនការតម្កល់លិខិតជូនដំណឹងពីសិទ្ធិរបស់គាហកនៃសិទ្ធិឃាត់ទុកដែលច្បាប់នេះតម្រូវ ឬមុនពេលចុះបញ្ជីកិច្ចសន្យាអ៊ីប៉ូតែក ឬមុនពេលចុះបញ្ជីសិទ្ធិរបស់ម្ចាស់អចលនវត្ថុ នៅការិយាល័យចុះបញ្ជីអចលនវត្ថុដែលមានសមត្ថកិច្ច

ខ-សិទ្ធិប្រាតិភោគជាសិទ្ធិប្រាតិភោគលើប្រាក់ខ្ចីទិញ ដែលកូនបំណុលបានផ្តល់មុនពេលទំនិញក្លាយទៅជាចលនវត្ថុតាំងភ្ជាប់ ហើយលិខិតជូនដំណឹងត្រូវបានតម្កល់មុនពេលទំនិញក្លាយទៅជាចលវត្ថុតាំងភ្ជាប់ ឬប្រាំ(១៥)ថ្ងៃ បន្ទាប់ពីទំនិញនេះក្លាយទៅជាចល-នវត្ថុតាំងភ្ជាប់ ។

អាទិភាពដែលបង្កើតក្នុងចំណុច ខ នៃវាក្យខណ្ឌនេះ មិនមានប្រសិទ្ធភាពលើអ៊ីប៉ូតែកធានាការសាងសង់ឡើយ ។ ត្រូវចាត់ទុកជាអ៊ីប៉ូតែកធានាការសាងសង់ រាល់អ៊ីប៉ូតែកដែលធានាកាតព្វកិច្ចបង់ប្រាក់ថ្លៃសាងសង់ ដើម្បីកែលំអលើអចលនទ្រព្យ ហើយអចលនទ្រព្យដែលបានដាក់អ៊ីប៉ូតែកធានាកាតព្វកិច្ចនេះ ត្រូវបានចុះបញ្ជីតាមច្បាប់ភូមិបាលជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

៦- ម្ចាស់បំណុលមានកិច្ចធានា ដែលមានអាទិភាពតាមមាត្រានេះ អាចដក ឬរុះរើយកចលនវត្ថុតាំងភ្ជាប់វិញនៅពេលកូនបំណុលមិនសងបំណុល ។

ក-ម្ចាស់បំណុលដែលមានកិច្ចធានាដែលដក ឬរុះរើយកចលនវត្ថុតាំងភ្ជាប់ត្រូវតែចេញថ្លៃជួសជុលការខូចខាតលើអចលនទ្រព្យភ្លាមៗ ឱ្យទៅម្ចាស់បំណុលអ៊ីប៉ូតែកដែលមិនមែនជាកូនបំណុល ។

ខ-ម្ចាស់បំណុលដែលមានកិច្ចធានា មិនចាំបាច់ចេញសំណងជូនម្ចាស់បំណុលអ៊ីប៉ូតែក ឬ កម្មសិទ្ធិករចំពោះការចុះតម្លៃដោយសារគ្មានទំនិញដែលបានយកចេញ ឬដោយភាពចាំបាច់នៃការដាក់ជំនួសវិញឡើយ ។

គ-បុគ្គលដែលមានសិទ្ធិទារសំណងនេះអាចបដិសេធការយកចេញ ឬការរុះរើ រហូតទាល់តែម្ចាស់បំណុល ដែលមានកិច្ចធានាផ្តល់ការធានាគ្រប់គ្រាន់ក្នុងការបំពេញកាតព្វកិច្ចចេញសំណងនេះ ។

មាត្រា ២១.-

សិទ្ធិប្រាតិភោគលើផលដំណាំដែលដាំដុះលើអចលនទ្រព្យ មានអាទិភាពលើសិទ្ធិរបស់កម្មសិទ្ធិករ ឬ ម្ចាស់បំណុលអ៊ីប៉ូតែក បើកូនបំណុលបានកាន់កាប់អចលនទ្រព្យ ឬមានសិទ្ធិលើអចលនទ្រព្យ ដែលបានចុះបញ្ជីតាមច្បាប់ភូមិបាលជាធរមាននៃព្រះរាជាណាចក្រ

មាត្រា ២២.–

១-សិទ្ធិប្រាតិភោគអាចបង្កើតលើវត្ថុចំណុះ ហើយសិទ្ធិប្រាតិភោគនេះបន្តអានុភាពលើទ្រព្យធានាដែលក្លាយទៅជាវត្ថុចំណុះ ។ បើសិទ្ធិប្រាតិភោគត្រូវធ្វើសុក្រឹតកម្មនៅពេលដែលទ្រព្យធានាក្លាយទៅជាវត្ថុចំណុះសិទ្ធិប្រាតិភោគត្រូវបន្តសុក្រឹតភាពលើវត្ថុចំណុះនោះ ។

២-នៅពេលកូនបំណុលមិនសងបំណុល ម្ចាស់បំណុលដែលមានកិច្ចធានាអាចដកយកវត្ថុចំណុះនោះចេញពីចលនវត្ថុផ្សេងនោះបាន បើសិទ្ធិប្រាតិភោគលើវត្ថុចំណុះមានអាទិភាពលើការទាមទាររបស់បុគ្គលផ្សេងទៀត ដែលមានសិទ្ធិលើចលនវត្ថុទាំងមូល ។

៣-ភាគីដែលដកយកវត្ថុចំណុះត្រូវសងថ្លៃចំណាយជួសជុល ឬ ការខូចខាតជាក់ស្តែងលើចលនវត្ថុទាំងមូលឱ្យទៅអ្នកកាន់កាប់ដែលមិនមែនជាកូនបំណុលនូវផលប្រយោជន៍លើចលនវត្ថុទាំងមូល ឬចលនវត្ថុផ្សេងនោះ ដែលសិទ្ធិនៃអ្នកកាន់កាប់នេះមានអាទិភាពលើសិទ្ធិរបស់ម្ចាស់បំណុលដែលមានកិច្ចធានា ហើយ :

ក-ម្ចាស់បំណុលដែលមានកិច្ចធានា មិនចាំបាច់ចេញសងការចុះតម្លៃចលនវត្ថុទាំងមូលដែលបណ្តាលឡើងដោយសារគ្មានវត្ថុចំណុះ ឬភាពចាំបាច់នៃការដាក់ជំនួសវិញឡើយ ។

ខ-បុគ្គលដែលមានសិទ្ធិទារសំណងនេះ អាចបដិសេធមិនអនុញ្ញាតឱ្យរុះរើយកវត្ថុចំណុះ លុះត្រាតែម្ចាស់បំណុលដែលមានកិច្ចធានាផ្តល់ការធានាច្បាស់ពីការបំពេញកាតព្វកិច្ចចេញសំណងនេះ ។

មាត្រា ២៣.–

១-សិទ្ធិប្រាតិភោគមិនអាចបង្កើតលើទំនិញនីមួយៗ ដែលលាយបញ្ចូលគ្នាឡើយ ។

២-ប្រសិនបើទ្រព្យធានាក្លាយទៅជាទំនិញបញ្ចូលគ្នា សិទ្ធិប្រាតិភោគត្រូវភ្ជាប់នឹងផលិតផល ឬ សមាសធាតុរួម ។

៣-បើសិទ្ធិប្រាតិភោគមានសុក្រឹតភាព មុនពេលទ្រព្យធានាក្លាយទៅជាទំនិញបញ្ចូលគ្នា សិទ្ធិប្រាតិភោគដែលភ្ជាប់ទៅនឹងផលិតផល ឬសមាសធាតុរួមត្រូវមានសុក្រឹតភាពដោយមិនចាំបាច់ផ្តល់លិខិតជូនដំណឹងឡើយ ។ អាទិភាពនៃសិទ្ធិប្រាតិភោគលើផលិតផល ឬ

សមាសធាតុរួម ត្រូវគិតចាប់ពីពេលធ្វើសុក្រឹតកម្មសិទ្ធិប្រាតិភោគលើទ្រព្យធានាដែលបាន ក្លាយទៅជាទំនិញបញ្ចូលគ្នា ។

៤- ក្នុងករណីមានសិទ្ធិប្រាតិភោគលើសពីមួយភ្ជាប់ទៅនឹងផលិតផល ឬសមាសធាតុរួម អាទិភាពត្រូវកំណត់តាមវិធានខាងក្រោមនេះ :

ក- សិទ្ធិប្រាតិភោគដែលមានសុក្រឹតភាព ត្រូវមានអាទិភាពលើសិទ្ធិប្រាតិភោគ ដែលគ្មានសុក្រឹតភាពក្នុងពេលដែលទ្រព្យធានាក្លាយទៅជាទំនិញបញ្ចូលគ្នា ។

ខ- សិទ្ធិដែលត្រូវភ្ជាប់នឹងផលិតផល ឬសមាសធាតុរួមមុនគេត្រូវមានអាទិភាព លើសិទ្ធិដែលគ្មានសុក្រឹតភាព ។

គ- បើមានសិទ្ធិប្រាតិភោគលើសពីមួយ ត្រូវបានធ្វើសុក្រឹតកម្មសិទ្ធិប្រាតិភោគ ត្រូវមានលំដាប់អាទិភាពស្មើគ្នាតាមសមាមាត្រនៃតម្លៃទ្រព្យធានា នៅពេលទ្រព្យនេះបាន ក្លាយទៅជាទំនិញបញ្ចូលគ្នា ។

មាត្រា ២៤.-

អ្នកទិញកិច្ចសន្យាលក់ដែលមានកិច្ចធានា ឬ លិខិតស្នាម មានអាទិភាពលើសិទ្ធិប្រា- តិភោគផ្សេងលើកិច្ចសន្យាលក់ដែលមានកិច្ចធានា ឬលិខិតស្នាមហើយក៏មានអាទិភាពលើ ផលនៃកិច្ចសន្យាលក់ ដែលមានកិច្ចធានាឬលិខិតស្នាមផងដែរ ប្រសិនបើ :

-អ្នកទិញបានផ្តល់តម្លៃថ្មីនិងកាន់កាប់កិច្ចសន្យាលក់ដែលមានកិច្ចធានា ឬ លិខិតស្នាមក្នុងដំណើរការអាជីវកម្មធម្មតារបស់ខ្លួន និង

-កិច្ចសន្យាលក់ដែលមានកិច្ចធានា ឬលិខិតស្នាម មិនបានបញ្ជាក់ថាបានផ្ទេរ ឱ្យទៅភាគីដែលកាន់កាប់សិទ្ធិប្រាតិភោគដែលប្រជែងគ្នា ។

មាត្រា ២៥.-

១- បុគ្គលអាចធ្វើអនុប្បទានសិទ្ធិរបស់ខ្លួនទាំងអស់ ឬ មួយផ្នែកលើគណនី កិច្ចសន្យា លក់ដែលមានកិច្ចធានា ឬលិខិតស្នាម និងសិទ្ធិលើទ្រព្យអរូបីផ្សេងៗទៀតបាន ។

២- អនុប្បទានសិទ្ធិអាចមានលក្ខណៈជាការធ្វើអនុប្បទានសិទ្ធិទូទៅ ដូចជាសិទ្ធិទទួល ប្រាក់ឈ្នួលនៅអនាគត កិច្ចសន្យាលក់ដែលមានកិច្ចធានា លិខិតស្នាម និងទ្រព្យអរូបីដទៃ

៣-អនុប្បទានិកត្រូវគោរពតាមលក្ខខណ្ឌក្នុងកិច្ចព្រមព្រៀងរវាងកូនបំណុលតណានី និងអនុប្បទាយី ។

៤-មិនចាំបាច់ជូនដំណឹងពីការភ្ជាប់សិទ្ធិប្រាតិភោគ សុក្រឹតកម្មសិទ្ធិប្រាតិភោគ ឬការអនុវត្តសិទ្ធិប្រាតិភោគដែលកើតចេញពីអនុប្បទានសិទ្ធិដល់កូនបំណុលតណានីឡើយ ។ ការមិនបានជូនដំណឹងដល់កូនបំណុលតណានី មានអនុភាពចំពោះតែករណីដូចបានចែងក្នុងមាត្រានេះប៉ុណ្ណោះ ។

៥-ក្នុងករណីដែលតម្រូវឱ្យមានការជូនដំណឹងដល់កូនបំណុលតណានី ការផ្តល់ពត៌មាននោះត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ដោយកំណត់ពីសិទ្ធិដែលបានផ្ទេរ ហើយត្រូវមានហត្ថលេខារបស់អនុប្បទាយី ឬអនុប្បទានិក ប៉ុន្តែមិនចាំបាច់រៀបរាប់ពីខ្លឹមសារ ឬលក្ខខណ្ឌនៃអនុប្បទានសិទ្ធិឡើយ ។

៦-កូនបំណុលតណានី ត្រូវបំពេញកាតព្វកិច្ចរបស់ខ្លួន ដោយការបង់ប្រាក់ជូនអនុប្បទាយីរហូតដល់ពេលដែលខ្លួនបានទទួលដំណឹងថាប្រាក់ដែលត្រូវបង់ ឬដល់កាលកំណត់សងត្រូវបានផ្ទេរ ហើយមានការណែនាំឱ្យបង់ជូនអនុប្បទានិក ។

៧-ក្រោយពីបានទទួលការជូនដំណឹងពីអនុប្បទានសិទ្ធិនេះ កូនបំណុលតណានីត្រូវបំពេញកាតព្វកិច្ចរបស់ខ្លួន ដោយបង់ប្រាក់ជូនអនុប្បទានិក ហើយមិនត្រូវបង់ប្រាក់ឱ្យអនុប្បទាយីទៀតទេ ។ ប៉ុន្តែក្នុងករណីមានការស្នើសុំពីកូនបំណុលតណានី អនុប្បទានិកត្រូវផ្តល់ភស្តុតាងគ្រប់គ្រាន់និងទាន់ពេលវេលាថាតណានីនេះត្រូវបានធ្វើអនុប្បទាន ហើយបើអនុប្បទានិកមិនបានធ្វើដូច្នេះទេ កូនបំណុលតណានីអាចបំពេញកាតព្វកិច្ចរបស់ខ្លួនដោយបន្តបង់ប្រាក់ជូនអនុប្បទាយី ទោះបីជាកូនបំណុលតណានី បានទទួលលិខិតជូនដំណឹងពីអនុប្បទានសិទ្ធិនេះក៏ដោយ ។

**មាត្រា ២៦.-**

កិច្ចព្រមព្រៀងរវាងម្ចាស់បំណុលដែលមានកិច្ចធានា និងកូនបំណុលមិនអាចដាក់ឱ្យប្រតិបត្តិតាមបានទេ បើកិច្ចព្រមព្រៀងនេះហាមប្រាម ឬដាក់កំរិតលើការលក់ ឬការផ្ទេរតណានី កិច្ចសន្យាជួល ឬ កិច្ចសន្យាលក់ដែលមានកិច្ចធានា ។

ä

**មាត្រា ២៧.-**

១-កាលណាសិទ្ធិប្រាតិភោគត្រូវបានធ្វើសុក្រឹតកម្មដើម្បីធានាកាតព្វកិច្ច ដោយម្ចាស់បំណុលដែលមានកិច្ចធានា ដើម្បីផ្តល់បុរេប្រទាននាពេលអនាគត សិទ្ធិរបស់គាហកនៃសិទ្ធិឃាត់ទុកមានអាទិភាពលើទ្រព្យធានានេះ ចំពោះតែសិទ្ធិប្រាតិភោគធានាបុរេប្រទានដែលបានផ្តល់បន្ទាប់ពីម្ចាស់បំណុលដែលមានកិច្ចធានាបានដឹងថា មានសិទ្ធិរបស់គាហកនៃសិទ្ធិឃាត់ទុក ឬលើសពីម្ភៃ(២០)ថ្ងៃ បន្ទាប់ពីគាហកនៃសិទ្ធិឃាត់ទុកបានតម្កល់លិខិតជូនដំណឹងពីសិទ្ធិរបស់ខ្លួននៅការិយាល័យតម្កល់លិខិតជូនដំណឹង គឺយកកាលបរិច្ឆេទណាមួយដែលកើតឡើងមុន ។

២-បើលិខិតជូនដំណឹងចែងពីទ្រព្យធានា ដែលកូនបំណុលនឹងមានសិទ្ធិលើទ្រព្យធានាក្នុងពេលអនាគត លិខិតជូនដំណឹងនេះមិនត្រូវមានប្រសិទ្ធភាពលើសិទ្ធិរបស់អភិបាល ឬ អភិបាលបណ្តោះអាសន្ន ដែលតែងតាំងតាមច្បាប់ក្ស័យធនទេ អាទិភាពនេះមានចំពោះតែទ្រព្យធានាដែលបានទទួលក្រោយពេលតម្កល់លិខិតជូនដំណឹង នៅការិយាល័យតម្កល់តាមបទប្បញ្ញត្តិច្បាប់ស្តីពីក្ស័យធន ។

**មាត្រា ២៨.-**

បុគ្គលដែលមានអាទិភាពតាមច្បាប់នេះ អាចយល់ព្រមកែប្រែ ឬលុបចោលអាទិភាពនេះបាន ។ ភាគីមិនចាំបាច់តម្កល់លិខិតជូនដំណឹងពីការព្រមព្រៀងកែប្រែ ឬ លុបចោលអាទិភាពនេះឡើយ ។

## ជំពូកទី ៣
## ការតម្កល់លិខិតជូនដំណឹង

**មាត្រា ២៩.-**

ការិយាល័យតម្កល់លិខិតជូនដំណឹងនៃប្រតិបត្តិការ ដែលមានកិច្ចធានាត្រូវបង្កើតនៅក្រសួងពាណិជ្ជកម្ម ។

ROYAUME DU CAMBODGE • LE MINISTÈRE DU PALAIS ROYAL

4

មាត្រា ៣០.-

ការិយាល័យនេះជាទីកន្លែងដែលត្រូវតម្កល់ :

១-លិខិតជូនដំណឹងដើម្បីធ្វើសុក្រឹតកម្មសិទ្ធិប្រាតិភោគលើទ្រព្យធានាដែលចែងក្នុងច្បាប់នេះ លើកលែងតែទ្រព្យធានាដូចបានកំណត់ក្នុងមាត្រា ៤៤ នៃច្បាប់នេះនិង

២-លិខិតជូនដំណឹងពីសិទ្ធិរបស់គាហកនៃសិទ្ធិឃាត់ទុក ។

មាត្រា ៣១.-

១-ក្រសួងពាណិជ្ជកម្ម មានអំណាចចេញលិខិតបទដ្ឋានទាំងឡាយដែលមានចែងក្នុងច្បាប់នេះ ។

២-លិខិតបទដ្ឋានរបស់ក្រសួងពាណិជ្ជកម្ម មិនត្រូវផ្ទុយពីបទប្បញ្ញត្តិនៃច្បាប់នេះ ឬគោលបំណងលើកស្ទួយសកម្មភាពពាណិជ្ជកម្មដែលចែងក្នុងច្បាប់នេះឡើយ ។

៣-លិខិតបទដ្ឋានអាចចែងពីវិធីបង់ថ្លៃសេវាកម្ម ដែលកំណត់ដោយច្បាប់នេះ ។

៤-ក្រសួងពាណិជ្ជកម្មត្រូវអនុញ្ញាតឱ្យមានការតម្កល់លិខិតជូនដំណឹង និងការស្រាវជ្រាវរកកំណត់ត្រាតាមមធ្យោបាយអេឡិចត្រូនិក ។ ប៉ុន្តែក្រសួងពាណិជ្ជកម្មអាចចេញលិខិតបទដ្ឋានសម្រាប់អនុញ្ញាតឱ្យដាក់ជូនលិខិតជូនដំណឹង និងការស្នើសុំស្រាវជ្រាវរកកំណត់ត្រាតាមមធ្យោបាយផ្សេងពីនេះ ដែលអាចបំប្លែងទៅជាកំណត់ត្រាអេឡិចត្រូនិកបាន ។ កំណត់ត្រាអេឡិចត្រូនិករបស់ការិយាល័យតម្កល់ ត្រូវចាត់ទុកជាកំណត់ត្រាផ្លូវការនៃការតម្កល់ ។

៥-បើក្រសួងពាណិជ្ជកម្មចេញលិខិតបទដ្ឋានសម្រាប់អនុញ្ញាតការដាក់ជូនលិខិតជូនដំណឹងនិងការស្នើសុំស្រាវជ្រាវរកកំណត់ត្រា តាមមធ្យោបាយផ្សេងពីមធ្យោបាយអេ-ឡិចត្រូនិក ក្រសួងពាណិជ្ជកម្មអាចកំណត់នូវទម្រង់បែបបទសម្រាប់ដាក់ជូនលិខិតជូនដំណឹងនិងការស្នើសុំស្រាវជ្រាវរកកំណត់ត្រា ។

មាត្រា ៣២.-

១-ព័ត៌មានដែលចែងក្នុងលិខិតជូនដំណឹង ដែលតម្កល់តាមច្បាប់នេះជាកំណត់ត្រាសាធារណៈ ។

២-ឧបសម្ព័ន្ធ និងកំណត់ត្រាផ្សេងទៀត ដែលបង្កើតឡើងដោយការិយាល័យតម្កល់ ហើយពាក់ព័ន្ធនឹងលិខិតជូនដំណឹងនេះត្រូវចាត់ទុកជាកំណត់ត្រាសាធារណៈ ។

៣-បុគ្គលគ្រប់រូបមានសិទ្ធិពិនិត្យមើល និងថតចម្លងកំណត់ត្រាសាធារណៈដែលតម្កល់នៅការិយាល័យតម្កល់ដោយគ្មានការរើសអើងអ្វីឡើយ ។

មាត្រា ៣៣.-

១-ត្រូវចាត់ទុកថាលិខិតជូនដំណឹងដំបូងមានលក្ខណៈគ្រប់គ្រាន់ បើលិខិតជូនដំណឹងនេះ :

ក-កំណត់អត្តសញ្ញាណនិងចែងពីអាសយដ្ឋានរបស់កូនបំណុល ។

ខ-កំណត់អត្តសញ្ញាណម្ចាស់បំណុលដែលមានកិច្ចធានា ឬភ្នាក់ងាររបស់ម្ចាស់បំណុលដែលមានកិច្ចធានា និងអាសយដ្ឋានរបស់ម្ចាស់បំណុល ។

គ-ពណ៌នាអំពីទ្រព្យធានាដែលចុះក្នុងលិខិតជូនដំណឹងជាអក្សរខ្មែរ និងអក្សរឡាតាំង និងលេខអារ៉ាប់ ។ ក្រៅពីនេះលិខិតជូនដំណឹងត្រូវតែអធិប្បាយពីអចលនវត្ថុដែលពាក់ព័ន្ធ បើលិខិតជូនដំណឹងនេះចែងពីឈើឈរដែលត្រូវកាប់ ឬ រ៉ែដែលត្រូវជីកយក ឬ បើទ្រព្យធានាជាចលនវត្ថុតាំងភ្ជាប់ ។

២-បុគ្គលមានសិទ្ធិតម្កល់លិខិតជូនដំណឹងដំបូង តែក្នុងករណីដែលកូនបំណុលអនុញ្ញាតឱ្យតម្កល់ដូចបានបញ្ជាក់ក្នុងកំណត់ត្រា ដែលកូនបំណុលបានបញ្ជាក់ការឯកភាព ។ កំណត់ត្រាបញ្ជាក់ការឯកភាព មិនចាំបាច់ចែងក្នុងលិខិតជូនដំណឹងឡើយ ។

៣-ការដែលកូនបំណុលចុះហត្ថលេខាលើកិច្ចព្រមព្រៀងប្រាតិភោគ មានន័យថាកូនបំណុលអនុញ្ញាតឱ្យតម្កល់លិខិតជូនដំណឹងដំបូង ឬ វិសោធនកម្មដែលចែងពីទ្រព្យធានាដែលរៀបរាប់ក្នុងកិច្ចសន្យា និងផលនៃទ្រព្យធានា ទោះបីជាកិច្ចព្រមព្រៀងប្រាតិភោគចែងច្បាស់ ឬមិនបានចែងច្បាស់ពីផលនៃទ្រព្យធានាក្តី ។

៤-លិខិតជូនដំណឹងអាចត្រូវបានតម្កល់មុនចុះកិច្ចព្រមព្រៀងប្រាតិភោគ ឬមុនសិទ្ធិប្រាតិភោគភ្ជាប់ទៅនឹងទ្រព្យធានា ។

៥-លិខិតជូនដំណឹងដែលគោរពតាមលក្ខខណ្ឌតម្រូវភាគច្រើននៃមាត្រានេះត្រូវចាត់ទុកថាមានប្រសិទ្ធភាព ទោះបីជាមិនបានបំពេញលក្ខខណ្ឌទាំងស្រុងនៃមាត្រានេះក៏ដោយ

លើកលែងតែវិការៈនោះបង្កឱ្យ មានការភ័ន្តច្រឡំខ្លាំង ។ លិខិតជូនដំណឹងដែលមិនបាន ចែងពីឈ្មោះកូនបំណុល ត្រូវចាត់ទុកថាជាលិខិតជូនដំណឹងដែលបង្កឱ្យ មានការភ័ន្តច្រឡំ ខ្លាំង ។

មាត្រា ៣៤.-

១-ត្រូវចាត់ទុកថាលិខិតជូនដំណឹងចែងគ្រប់គ្រាន់ពីឈ្មោះ ឬនាមករណ៍របស់កូន បំណុលជាអក្សរខ្មែរ និងអក្សរឡាតាំង និងលេខអារ៉ាប់ កាលណា :

ក-កូនបំណុលជារូបវន្តបុគ្គលដែលមានឈ្មោះក្នុងកំណត់ត្រារបស់ក្រសួង មហាផ្ទៃ ហើយលិខិតជូនដំណឹងមានចុះអត្តលេខប្រាំបួនខ្ទង់ ដែលបោះពុម្ពលើអត្តសញ្ញា-ណប័ណ្ណសញ្ជាតិខ្មែររបស់សាមីជន ។

ខ-កូនបំណុលជារូបវន្តបុគ្គល ហើយមិនមែនជាពលរដ្ឋខ្មែរ លិខិតជូនដំណឹង ត្រូវចុះឈ្មោះរបស់បុគ្គល ដូចដែលបោះពុម្ពលើលិខិតឆ្លងដែនរបស់សាមីជន និងឈ្មោះ ប្រទេសដែលចេញលិខិតឆ្លងដែននោះ ។

គ-កូនបំណុលជានីតិបុគ្គលដែលបង្កើតឡើង ឬ ទទួលស្គាល់តាមច្បាប់នៃ ព្រះរាជាណាចក្រកម្ពុជា លិខិតជូនដំណឹងត្រូវចុះនាមករណ៍របស់កូនបំណុលដែលបានចុះ ក្នុងបញ្ជីពាណិជ្ជកម្ម ឬ នាមករណ៍ដែលច្បាប់ទទួលស្គាល់ ។

ឃ-កូនបំណុលជានីតិបុគ្គលបរទេស ដែលបង្កើតឡើងក្រៅព្រះរាជាណាចក្រ កម្ពុជា ហើយមានសមត្ថភាពធ្វើអាជីវកម្មតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា បើលិខិត ជូនដំណឹងបានចុះនាមករណ៍របស់កូនបំណុល ដូចបានចុះក្នុងបញ្ជីពាណិជ្ជកម្មនៃព្រះរាជា-ណាចក្រកម្ពុជា ។

ង-កូនបំណុលជានីតិបុគ្គលបរទេស ដែលមិនបានចុះក្នុងបញ្ជីពាណិជ្ជកម្មនៃ ព្រះរាជាណាចក្រកម្ពុជា ហើយលិខិតជូនដំណឹងនេះត្រូវចុះនាមករណ៍របស់កូនបំណុល ដូចចុះក្នុងបញ្ជីពាណិជ្ជកម្មនៃប្រទេសកំណើតរបស់នីតិបុគ្គលបរទេសដែរ ។

២-លិខិតជូនដំណឹងដែលចែងគ្រប់គ្រាន់ពីឈ្មោះរបស់កូនបំណុល មិនអាចក្លាយ ទៅជាអាត់ប្រសិទ្ធភាពដោយសារការចែង ឬ មិនបានចែងពីពាណិជ្ជនាម ឬ ឈ្មោះផ្សេងទៀត

LE MINISTRE du PALAIS ROYAL

របស់កូនបំណុលឡើយ ។ លិខិតជូនដំណឹងដែលចែងតែពីពាណិជ្ជនាមរបស់កូនបំណុល មិនចាត់ទុកថាបានចែងគ្រប់គ្រាន់ពីឈ្មោះរបស់កូនបំណុលឡើយ ។

៣-លិខិតជូនដំណឹង អាចចែងពីឈ្មោះកូនបំណុលនិងម្ចាស់បំណុលមានកិច្ចធានា លើសពីមួយបាន ។

៤-ក្នុងករណីដែលលិខិតជូនដំណឹង មិនបានបញ្ជាក់ថាបុគ្គលជាភ្នាក់ងាររបស់ម្ចាស់បំណុលដែលមានកិច្ចធានា មិនប៉ះពាល់ដល់ភាពគ្រប់គ្រាន់នៃលិខិតជូនដំណឹងឡើយ ។

មាត្រា ៣៥.–

១-លិខិតជូនដំណឹងដែលបានតម្កល់ ត្រូវបន្តមានប្រសិទ្ធភាពលើទ្រព្យធានាដែលត្រូវបានលក់ ដោះដូរ ជួល ឬជម្រះចោលតាមវិធីដែលសិទ្ធិប្រាតិភោគបន្តមានអត្ថិភាព ទោះបីម្ចាស់បំណុលមានកិច្ចធានាបានដឹង ឬ យល់ព្រមនឹងការជម្រះចោលនេះក៏ដោយ ។

២-បើកូនបំណុលប្តូរឈ្មោះដែលធ្វើឱ្យលិខិតជូនដំណឹង ដែលបានតម្កល់បង្កការភ័ន្តច្រឡំខ្លាំង លិខិតជូនដំណឹងនេះមានប្រសិទ្ធភាព ដើម្បីបន្តសុក្រឹតភាពសិទ្ធិប្រាតិភោគលើទ្រព្យធានាដែលកូនបំណុលទទួលបានមុន ឬ ក្នុងរយៈពេលបួន(០៤)ខែ បន្ទាប់ពីការប្តូរឈ្មោះនេះ ។ លិខិតជូនដំណឹងនេះមានប្រសិទ្ធភាព ដើម្បីបន្តសុក្រឹតភាពសិទ្ធិប្រាតិភោគលើទ្រព្យធានាដែលកូនបំណុលទទួលបាន ក្នុងរយៈពេលលើសពីបួន(០៤)ខែ ក្រោយពីការប្តូរឈ្មោះនេះ តែក្នុងករណីដែលបានតម្កល់វិសោធនកម្មលើលិខិតជូនដំណឹង ដើម្បីកែតម្រូវឈ្មោះក្នុងរយៈពេលបួន(០៤)ខែបន្ទាប់ពីការប្តូរឈ្មោះនេះ ។

៣-លើកលែងតែប្រការដែលចែងពីការប្តូរឈ្មោះកូនបំណុលក្នុងចំណុចទី ២ ខាងលើ លិខិតជូនដំណឹងនេះបន្តមានប្រសិទ្ធភាព ទោះបីជាកាលៈទេសៈបានកែប្រែ និងបណ្តាលឱ្យលិខិតជូនដំណឹងបង្កការភ័ន្តច្រឡំខ្លាំង បន្ទាប់ពីការតម្កល់លិខិតជូនដំណឹងក៏ដោយ ។

មាត្រា ៣៦.–

១-លិខិតជូនដំណឹងមានប្រសិទ្ធភាព សម្រាប់រយៈពេលប្រាំ(០៥)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការតម្កល់ ។

២-លិខិតជូនដំណឹងដែលបានតម្កល់ត្រូវអស់ប្រសិទ្ធភាព នៅពេលដែលផុតរយៈពេលប្រាំ(០៥)ឆ្នាំ លើកលែងតែបុគ្គលបានតម្កល់លិខិតសុំបន្តមុនផុតរយៈពេលប្រាំ(០៥)ឆ្នាំ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

៣-លិខិតជូនដំណឹងក្លាយទៅជាគ្មានប្រសិទ្ធភាព នៅពេលផុតរយៈពេលប្រាំ(០៥) ឆ្នាំ ហើយរាល់សិទ្ធិប្រាតិភោគដែលមានសុក្រឹតភាព តាមលិខិតជូនដំណឹងនេះក៏ក្លាយទៅជាគ្មានសុក្រឹតភាពដែរ លើកលែងតែសិទ្ធិប្រាតិភោគដែលមានប្រសិទ្ធភាពដោយមិនចាំបាច់តម្កល់លិខិតជូនដំណឹង ។

៤-បើសិទ្ធិប្រាតិភោគក្លាយទៅជាគ្មានសុក្រឹតភាពនៅពេលផុតរយៈពេល ត្រូវចាត់ទុកថាមិនដែលបានធ្វើសុក្រឹតកម្ម ចំពោះអ្នកទិញទ្រព្យធានាពីមុន ឬ អ្នកទិញទ្រព្យធានាបន្តបន្ទាប់ដែលបានបង់តម្លៃឡើយ ។

**មាត្រា ៣៧.-**

១-លិខិតជូនដំណឹងដំបូងអាចត្រូវកែប្រែដោយវិសោធនកម្មម្តង ឬ ច្រើនដង ។ វិសោធនកម្មត្រូវតែ :

ក-បញ្ជាក់ពីលិខិតជូនដំណឹងដំបូងតាមលេខតម្កល់ ។

ខ-បញ្ជាក់ពីម្ចាស់បំណុលដែលមានកិច្ចធានា ក្នុងលិខិតជូនដំណឹងដែលអនុញ្ញាតឱ្យមានវិសោធនកម្មនេះ ។

គ-បញ្ជាក់ថានេះជាវិសោធនកម្មលើលិខិតជូនដំណឹង ។

ឃ-ចែងពីព័ត៌មានចាំបាច់ទាំងអស់ ក្នុងលិខិតជូនដំណឹងដំបូងដោយចែងឆ្លុះបញ្ចាំងពីលិខិតជូនដំណឹងនេះទាំងស្រុងឡើងវិញ ។

២-បើវិសោធនកម្មដាក់បន្ថែមទ្រព្យធានា ដែលចែងក្នុងលិខិតជូនដំណឹង ឬ បន្ថែមកូនបំណុលទៅក្នុងលិខិតជូនដំណឹង លិខិតជូនដំណឹងនេះមានប្រសិទ្ធភាព បើកូនបំណុលអនុញ្ញាតឱ្យតម្កល់តាមកំណត់ត្រាដែលកូនបំណុលបានឯកភាព ។ ការដែលកូនបំណុលចុះហត្ថលេខាលើកិច្ចព្រមព្រៀងប្រាតិភោគមានន័យថា កូនបំណុលអនុញ្ញាតឱ្យតម្កល់វិសោធនកម្មចែងពីទ្រព្យធានាដែលចុះក្នុងកិច្ចព្រមព្រៀងប្រាតិភោគនិងផលនៃទ្រព្យធានា ទោះបីជាកិច្ចព្រមព្រៀងប្រាតិភោគចែងជាក់លាក់ ឬ មិនជាក់លាក់ពីផលនៃទ្រព្យធានាក៏ដោយ ។

៣-បើលិខិតជូនដំណឹងចែងពីម្ចាស់បំណុលដែលមានកិច្ចធានាលើសពីមួយ វិសោធនកម្មមិនមានប្រសិទ្ធភាព ចំពោះតែម្ចាស់បំណុល ដែលមានកិច្ចធានាដែលអនុញ្ញាតឱ្យតម្កល់តាមកំណត់ត្រាដែលកូនបំណុលបានឯកភាពប៉ុណ្ណោះ ។

៤-វិសោធនកម្មបន្ថែមទ្រព្យធានា មានប្រសិទ្ធភាពលើទ្រព្យធានាដែលបន្ថែមនោះ គិតចាប់ពីកាលបរិច្ឆេទនៃការតម្កល់វិសោធនកម្ម ។

៥-វិសោធនកម្មបន្ថែមកូនបំណុល មានប្រសិទ្ធភាពលើកូនបំណុលដែលបន្ថែមនោះ គិតចាប់ពីកាលបរិច្ឆេទនៃការតម្កល់វិសោធនកម្ម ។

៦-វិសោធនកម្មក្រៅពីវិសោធនកម្មបន្ថែមទ្រព្យធានា ឬ បន្ថែមកូនបំណុលមាន ប្រសិទ្ធភាពតែក្នុងករណីដែលម្ចាស់បំណុលដែលមានកិច្ចធានា អនុញ្ញាតឱ្យតម្កល់តាម កំណត់ត្រាដែលកូនបំណុលបានឯកភាព ។

៧-វិសោធនកម្មគ្មានប្រសិទ្ធភាពទេ បើវិសោធនកម្មនេះចែងលុបចោលម្ចាស់បំណុល ដែលមានកិច្ចធានាទាំងអស់ ដោយមិនបានចែងពីឈ្មោះម្ចាស់បំណុល ដែលមានកិច្ចធានា ថ្មី ឬ ចែងលុបឈ្មោះកូនបំណុលទាំងអស់ និងមិនបានចែងពីឈ្មោះកូនបំណុល ដែលមិន បានបញ្ជាក់ក្នុងលិខិតជូនដំណឹងពីមុន ។

៨-បើមានម្ចាស់បំណុលដែលមានកិច្ចធានាលើសពីមួយ ក្នុងលិខិតជូនដំណឹងម្ចាស់ បំណុលដែលមានកិច្ចធានាម្នាក់ៗ អាចអនុញ្ញាតឱ្យតម្កល់វិសោធនកម្មបាន ។

៩-វិសោធនកម្មដែលអនុញ្ញាតដោយម្ចាស់បំណុលដែលមានកិច្ចធានាម្នាក់ មិនប៉ះ ពាល់ដល់សិទ្ធិរបស់ម្ចាស់បំណុលដែលមានកិច្ចធានាផ្សេងទៀត ដែលមានឈ្មោះក្នុងលិខិត ជូនដំណឹងឡើយ ។

១០-ការតម្កល់វិសោធនកម្ម មិនធ្វើឱ្យរយៈពេលប្រសិទ្ធភាពនៃលិខិតជូនដំណឹងត្រូវ កើនឡើងទេ ។

មាត្រា ៣៨.-

១-រយៈពេលប្រសិទ្ធភាពនៃលិខិតជូនដំណឹង អាចត្រូវបន្តដោយតម្កល់លិខិតស៊ីបន្ត ដែល :

ក-បញ្ជាក់ពីលេខតម្កល់នៃលិខិតជូនដំណឹងដំបូង ។

ខ-បញ្ជាក់ពីម្ចាស់បំណុលដែលមានកិច្ចធានា ក្នុងលិខិតជូនដំណឹងដែលអនុ- ញ្ញាតឱ្យមានលិខិតស៊ីបន្តនេះ ។

គ-បញ្ជាក់ថាលិខិតជូនដំណឹងត្រូវបន្តប្រសិទ្ធភាព ចំពោះម្ចាស់បំណុលដែល

មានកិច្ចធានាដែលអនុញ្ញាតឱ្យតម្កល់ ។

២-ភាគីអាចតម្កល់លិខិតសុំបន្តសុពលភាព ក្នុងរយៈពេលប្រាំមួយ(០៦)ខែ មុនផុតរយៈពេលប្រាំ(០៥)ឆ្នាំ ដែលលិខិតជូនដំណឹងមានសុពលភាព ។

ក-ចាប់ពីពេលតម្កល់លិខិតសុំបន្ត លិខិតជូនដំណឹងត្រូវបន្តសុពលភាពនិងមានប្រសិទ្ធភាពសម្រាប់រយៈពេលប្រាំ(០៥)ឆ្នាំទៀត គិតចាប់ពីថ្ងៃដែលលិខិតជូនដំណឹងដំបូងត្រូវអស់ប្រសិទ្ធភាព ។

ខ-ប្រសិទ្ធភាពនេះត្រូវបន្តចំពោះតែម្ចាស់បំណុលដែលមានកិច្ចធានាដែលអនុញ្ញាតឱ្យតម្កល់លិខិតសុំបន្តប៉ុណ្ណោះ ។

គ-នៅពេលផុតរយៈពេលប្រាំ(០៥)ឆ្នាំ លិខិតជូនដំណឹងត្រូវអស់សុពលភាពចំពោះម្ចាស់បំណុលដែលមានកិច្ចធានា លើកលែងតែលិខិតសុំបន្តដែលអនុញ្ញាតដោយម្ចាស់បំណុលដែលមានកិច្ចធានាត្រូវបានតម្កល់មុនផុតរយៈពេលនេះ ។ ដើម្បីបន្តប្រសិទ្ធភាពលិខិតជូនដំណឹងតទៅទៀត ភាគីអាចតម្កល់លិខិតសុំបន្តសុពលភាពជាបន្តបន្ទាប់តាមរបៀបដូចបានចែងខាងលើនេះ ។

**មាត្រា ៣៩.–**

១-ប្រសិទ្ធភាពនៃលិខិតជូនដំណឹង អាចត្រូវបញ្ចប់ដោយការតម្កល់លិខិតសុំបញ្ចប់ដែល :

ក-បញ្ជាក់ពីលិខិតជូនដំណឹងដំបូងតាមលេខតម្កល់ ។

ខ-បញ្ជាក់ពីម្ចាស់បំណុលដែលមានកិច្ចធានា ក្នុងលិខិតជូនដំណឹងដែលអនុញ្ញាតឱ្យបញ្ចប់នេះ ។

គ-បញ្ជាក់ថាលិខិតជូនដំណឹងគ្មានប្រសិទ្ធភាព ចំពោះផលប្រយោជន៍របស់ម្ចាស់បំណុលដែលមានកិច្ចធានាដែលអនុញ្ញាតឱ្យបញ្ចប់ ។

២-ក្នុងរយៈពេលម្ភៃ(២០)ថ្ងៃ បន្ទាប់ពីម្ចាស់បំណុលដែលមានកិច្ចធានា បានទទួលការទាមទារជាលាយលក្ខណ៍អក្សរពីកូនបំណុល ម្ចាស់បំណុលដែលមានកិច្ចធានាត្រូវតម្កល់លិខិតសុំបញ្ចប់ ប្រសិនបើ :

មានជំពាក់កាតព្វកិច្ចព្រាតិភោគនិងគ្មានការសន្យាផ្តល់បុរេប្រទាន ការបង្កើត

កាតព្វកិច្ច ឬ ការផ្តល់តម្លៃតាមវិធីក្រៅពីនេះទេ ឬ

-កូនបំណុលមិនបានអនុញ្ញាតឱ្យតម្កល់លិខិតជូនដំណឹងដំបូង ឬ

-លិខិតជូនដំណឹងដែលចែងពីគណនី ឬ កិច្ចសន្យាលក់ដែលមានកិច្ចធានាដែលត្រូវបានលក់ ប៉ុន្តែកូនបំណុលគណនី ឬ បុគ្គលដែលជំពាក់កាតព្វកិច្ច បានរំលត់កាតព្វកិច្ចរបស់ខ្លួនសព្វគ្រប់អស់ហើយ ។

៣-លិខិតសុំបញ្ចប់ អាចបញ្ចប់សិទ្ធិរបស់ម្ចាស់បំណុលដែលមានកិច្ចធានាក្នុងលិខិតជូនដំណឹង តែក្នុងករណីដែលម្ចាស់បំណុលមានកិច្ចធានាបានអនុញ្ញាតតាមរយៈកំណត់ត្រាដែលមានបញ្ជាក់ការឯកភាព ។ នៅពេលតម្កល់លិខិតសុំបញ្ចប់ ដែលមានប្រសិទ្ធភាព លិខិតជូនដំណឹងដែលពាក់ព័ន្ធនឹងលិខិតសុំបញ្ចប់នេះ ក្លាយទៅជាគ្មានប្រសិទ្ធភាពចំពោះម្ចាស់បំណុលដែលមានកិច្ចធានាដែលបានអនុញ្ញាតឱ្យតម្កល់ ។

មាត្រា ៤០.-

១-ការប្រគល់លិខិតជូនដំណឹងដំបូង វិសោធនកម្ម លិខិតសុំបន្ត ឬ លិខិតសុំបញ្ចប់ និងការស្នើសុំបង់ថ្លៃតម្កល់ ឬ ការទទួលកំណត់ត្រាដោយការិយាល័យតម្កល់ ត្រូវចាត់ទុកជាការតម្កល់ លើកលែងតែប្រការដែលមានចែងក្នុងវាក្យខណ្ឌទី ២ ខាងក្រោមនេះ ។

២-មិនចាត់ទុកថាមានការតម្កល់លិខិតជូនដំណឹងទេ បើកំណត់ត្រានេះត្រូវបានការិយាល័យតម្កល់បដិសេធ ក្នុងករណីដែល :

ក-លិខិតជូនដំណឹងដំបូងមិនបានផ្តល់ព័ត៌មានតាមច្បាប់តម្រូវ ។

ខ-វិសោធនកម្ម មិនបានផ្តល់ព័ត៌មានតាមច្បាប់តម្រូវ ឬវិសោធនកម្មបញ្ជាក់ពីលិខិតជូនដំណឹងដំបូងដែលផុតរយៈពេលមានប្រសិទ្ធភាព ។

គ-លិខិតសុំបន្តមិនបានបញ្ជាក់ពីលេខនៃលិខិតជូនដំណឹងដំបូង ឬ មិនបានប្រគល់ជូនក្នុងរយៈពេលប្រាំមួយ(០៦)ខែ ដែលច្បាប់នេះបានអនុញ្ញាត ឬ

ឃ-លិខិតសុំបញ្ចប់មិនបានបញ្ជាក់ពីលេខនៃលិខិតជូនដំណឹងដំបូង ។

៣-ការិយាល័យតម្កល់ មិនអាចបដិសេធមិនតម្កល់លិខិតជូនដំណឹងក្រៅពីមូលហេតុដែលចែងក្នុងវាក្យខណ្ឌទី ២ នៃមាត្រានេះឡើយ លើកលែងតែមានការស្នើសុំបង់ថ្លៃតម្កល់ដែលមិនបានបង់តាមច្បាប់កំណត់ ទើបការិយាល័យតម្កល់អាចបដិសេធបាន ។

ក-កំណត់ត្រារួមជាមួយថ្លៃសេវាតម្កល់ ដែលដាក់ជូនការិយាល័យតម្កល់ ប៉ុន្តែបើការិយាល័យតម្កល់បានបដិសេធ ដោយផ្អែកលើមូលហេតុក្រៅពីមូលហេតុដែលចែងក្នុងមាត្រានេះ ត្រូវចាត់ទុកថាកំណត់ត្រាដែលបានតម្កល់នោះមានប្រសិទ្ធភាព ប៉ុន្តែគ្មានអនុភាពលើអ្នកទិញទ្រព្យធានា ដែលបានបង់ថ្លៃដោយមានការជឿជាក់សមហេតុផលថាគ្មានកំណត់ត្រាណាតម្កល់ពីមុនទេ ។

ខ-បើការិយាល័យតម្កល់បដិសេធការទទួលតម្កល់ ការិយាល័យនេះត្រូវតែបញ្ជូនអង្គហេតុ និងមូលហេតុនៃការបដិសេធរបស់ខ្លួនភ្លាមៗជូនទៅបុគ្គលដែលបានដាក់ជូនកំណត់ត្រានេះ ។

៤-លិខិតជូនដំណឹងដែលបានតម្កល់ មានប្រសិទ្ធភាពតែក្នុងករណីដែលបានតម្កល់ដោយបុគ្គលដែលច្បាប់នេះអនុញ្ញាតឱ្យតម្កល់ ។

៥-ការជូនដំណឹងដែលអនុញ្ញាតដោយម្ចាស់បំណុលដែលមានកិច្ចធានាម្នាក់ ដែលមានឈ្មោះក្នុងលិខិតជូនដំណឹង មិនប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បំណុលមានកិច្ចធានាផ្សេងទៀត ដែលបញ្ជាក់ក្នុងលិខិតជូនដំណឹងឡើយ ។

៦-ការចម្លងនិទ្ទេសមិនបានត្រឹមត្រូវដោយការិយាល័យតម្កល់ មិនប៉ះពាល់ប្រសិទ្ធ-ភាពនៃកំណត់ត្រាឡើយ ។

មាត្រា ៤១.—

១-បុគ្គលពាក់ព័ន្ធនៅក្នុងការតម្កល់លិខិតជូនដំណឹង អាចតម្កល់លិខិតសុំកែតម្រូវនៅការិយាល័យតម្កល់ ដើម្បីកែតម្រូវលិខិតជូនដំណឹងដែលមានចុះឈ្មោះរបស់ខ្លួន បើខ្លួនជឿថាកំណត់ត្រានោះមានកំហុស ឬ បានតម្កល់ដោយមិនត្រឹមត្រូវ ។

២-លិខិតសុំកែតម្រូវត្រូវតែ :

ក-បញ្ជាក់ពីកំណត់ត្រាដែលត្រូវកែតម្រូវ ដោយកំណត់ពីលេខតម្កល់នៃលិខិតជូនដំណឹងដំបូង ។

ខ-បញ្ជាក់ថាលិខិតនេះជាលិខិតសុំកែតម្រូវ ។



គ-បញ្ជាក់ពីមូលហេតុដែលបុគ្គលសាមីជឿថា កំណត់ត្រានេះមិនត្រឹមត្រូវនិងចង្អុលបង្ហាញពីវិធីដែលត្រូវកែតម្រូវកំហុស ឬបញ្ជាក់ពីមូលហេតុ ដែលខ្លួនជឿថាកំណត់ត្រានោះបានតម្កល់ដោយមិនត្រឹមត្រូវ ។

៣-ការតម្កល់លិខិតសុំកែតម្រូវ មិនប៉ះពាល់ដល់ប្រសិទ្ធភាពនៃលិខិតជូនដំណឹងឡើយ ។

**មាត្រា ៤២.-**

១-រាល់លិខិតជូនដំណឹងដែលខ្លួនទទួលតម្កល់ ការិយាល័យតម្កល់ត្រូវតែ :

ក-ដាក់លេខកូដពិសេសលើកំណត់ត្រាដែលបានតម្កល់ ។

ខ-បង្កើតសំណុំកំណត់ត្រាដែលមានចុះលេខកូដពិសេស កាលបរិច្ឆេទ និងពេលវេលានៃការតម្កល់ ។

គ-រក្សាទុកកំណត់ត្រាដែលបានតម្កល់សម្រាប់សាធារណជនពិនិត្យ ។

២-ការិយាល័យតម្កល់ត្រូវតែកត់ត្រាលិខិតជូនដំណឹងដំបូង ដោយចុះឈ្មោះកូនបំណុល និងត្រូវចុះកំណត់ត្រាទាំងអស់ ដែលពាក់ព័ន្ធនឹងលិខិតជូនដំណឹងដំបូង តាមរបៀបដែលយោងទៅរកលិខិតជូនដំណឹងដំបូង ។ ចំពោះលិខិតជូនដំណឹងដែលមានចែងពីលេខសេរីនៃយានយន្តមានលេខសេរី ការិយាល័យតម្កល់ត្រូវរក្សាទុកនិទ្ទេសលេខសេរីនោះ ។

៣-ការិយាល័យតម្កល់ត្រូវសម្រួលដល់ការស្វែងរកកំណត់ត្រាដោយប្រើឈ្មោះ និងលេខកូដរបស់កូនបំណុល ដែលបានចុះលើលិខិតជូនដំណឹងដំបូង ដែលពាក់ព័ន្ធនឹងកំណត់ត្រានេះនិងឯកសារតម្កល់ទាំងអស់ ដែលទាក់ទងគ្នានឹងលិខិតជូនដំណឹងដំបូង ។ ចំពោះលិខិតជូនដំណឹងដែលមានចែងពីលេខសេរីនៃយានយន្តដែលមានលេខសេរី ការិយាល័យតម្កល់ ត្រូវផ្តល់លទ្ធភាពដល់ការទាញកំណត់ត្រាមកប្រើតាមរយៈលេខសេរីនៃយានយន្តមានលេខសេរីនោះ ។

៤-ការិយាល័យតម្កល់ត្រូវរក្សាទុកកំណត់ត្រា ដែលអស់ប្រសិទ្ធភាពក្នុងរយៈពេលដប់ (១០)ឆ្នាំ បន្ទាប់ពីកាលបរិច្ឆេទផុតរយៈពេល ។

ROYAUME DU CAMBODGE MINISTÈRE DU PALAIS ROYAL

៥-សិទ្ធិនៃការិយាល័យតម្កល់មានអំណាចតែលើកិច្ចការរដ្ឋបាលប៉ុណ្ណោះ ។ មាតិកានៃលិខិតជូនដំណឹងត្រូវដកស្រង់ចេញពីកិច្ចព្រមព្រៀងឯកជនដែលច្បាប់នេះអនុញ្ញាតនិង

ច្បាប់ដទៃទៀតនៃព្រះរាជាណាចក្រកម្ពុជា ដែលមិនតម្រូវឱ្យមានការឯកភាព ឬការយល់ព្រមពីបុគ្គលណាក្រៅពីភាគីនៃកិច្ចព្រមព្រៀងឡើយ ។ ការិយាល័យតម្កល់មិនមានអំណាចក្នុងការពិនិត្យលិខិតជូនដំណឹង ដើម្បីកំណត់ពីភាពគ្រប់គ្រាន់សុពលភាព ឬបញ្ជាក់ថាមានតម្លៃតាមច្បាប់ឡើយ ។

## មាត្រា ៤៣.-

១-ការិយាល័យតម្កល់ត្រូវតែផ្តល់ជូនបុគ្គលដែលស្នើសុំ នូវព័ត៌មានដូចខាងក្រោមនេះ :

ក-រាល់លិខិតជូនដំណឹងដែលចែងពីកូនបំណុល នឹងនៅមានប្រសិទ្ធភាពចំពោះម្ចាស់បំណុលដែលមានកិច្ចធានាទាំងអស់ ទោះបីជាការិយាល័យនេះមាន ឬ នឹងទទួលបានព័ត៌មាននោះនាកាលបរិច្ឆេទ និងពេលវេលាដែលការិយាល័យតម្កល់បានកំណត់ក៏ដោយ ។

ខ-លេខកូដឯកសារ កាលបរិច្ឆេទ និងពេលវេលានៃការតម្កល់លិខិតជូនដំណឹងនីមួយៗ ។

គ-ឈ្មោះ និងអាសយដ្ឋានរបស់ម្ចាស់បំណុល ដែលមានកិច្ចធានាដែលចុះលើលិខិតជូនដំណឹងនីមួយៗ ។

ឃ-សេចក្តីអធិប្បាយពីទ្រព្យធានាក្នុងលិខិតជូនដំណឹងឬវិសោធនកម្មនីមួយៗ។

ង-លេខកូដឯកសារ កាលបរិច្ឆេទ និងពេលនៃការតម្កល់កំណត់ត្រានីមួយៗ ដែលពាក់ព័ន្ធនឹងលិខិតជូនដំណឹងនីមួយៗ និងកំណត់ត្រាដែលជាលិខិតសុំបន្ត លិខិតសុំកែតម្រូវ ឬ លិខិតសុំបញ្ចប់ ។

២-បុគ្គលអាចស្នើសុំរកកំណត់ត្រានៅការិយាល័យតម្កល់ តាមលក្ខណៈវិនិច្ឆ័យណាមួយដូចខាងក្រោមនេះ :

-លេខតម្កល់នៃលិខិតជូនដំណឹង ឬ

-លេខស៊េរីនៃយានយន្តមានលេខស៊េរី ឬ

-លេខអត្តសញ្ញាណប័ណ្ណរបស់កូនបំណុលជារូបវន្តបុគ្គល ដែលមានសញ្ជាតិ

ឈ្មោះរបស់កូនបំណុលដែលជានីតិបុគ្គល ដែលមានសញ្ជាតិខ្មែរ ។

៣-ការិយាល័យតម្កល់ អាចផ្តល់កំណត់ត្រាតាមគ្រប់មធ្យោបាយ ដើម្បីអនុវត្តភារកិច្ចរបស់ខ្លួន ។ ប៉ុន្តែបើមានការស្នើសុំការិយាល័យតម្កល់ ត្រូវផ្តល់កំណត់ត្រាដោយចេញលិខិតបញ្ជាក់ដែលអាចប្រើជាភស្តុតាង ក្នុងតុលាការនៃព្រះរាជាណាចក្រកម្ពុជា ដោយមិនចាំបាច់មានភស្តុតាងក្រៅពីឯកសារផ្ទាល់មកបញ្ជាក់បន្ថែមឡើយ ។

**មាត្រា ៤៤.-**

១-ថ្វីបើមានបទប្បញ្ញត្តិក្នុងមាត្រា ៣០ ក៏ដោយ បើទ្រព្យធានាជាចលនវត្ថុតាំងភ្ជាប់រ៉ែដែលនឹងត្រូវជីកយក ឬឈើឈរដែលនឹងត្រូវកាប់ ត្រូវតម្កល់លិខិតជូនដំណឹង ដើម្បីធ្វើសុក្រឹតកម្មសិទ្ធិប្រាតិភោគនៅការិយាល័យចុះបញ្ជី ដែលបានបង្កើតឡើងតាមច្បាប់ភូមិបាលជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

២-លិខិតជូនដំណឹងដែលតម្កល់តាមវាក្យខណ្ឌនេះ ត្រូវអនុលោមតាមវិធានដែលកំណត់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

**មាត្រា ៤៥.-**

១-ថ្លៃសេវាសម្រាប់ការតម្កល់លិខិតជូនដំណឹងដំបូង លិខិតសុំបន្ត លិខិតសុំបញ្ចប់ ឬ លិខិតសុំកែតម្រូវ ថ្លៃសេវារៀបចំរបាយការណ៍ស្រាវជ្រាវដែលមានការបញ្ជាក់ ឬសេវាផ្សេងៗទៀត ត្រូវបង់តាមការកំណត់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម ។

២-ទោះបីមានបញ្ញត្តិក្នុងចំណុចទី ១ ក៏ដោយ ច្បាប់នេះមិនតម្រូវឱ្យមានថ្លៃសេវាកម្មសម្រាប់របាយការណ៍ស្រាវជ្រាវរក ដែលបុគ្គលគ្រប់រូបទទួលបានពីការប្រើប្រាស់សេវាកម្មអេឡិចត្រូនិករបស់ការិយាល័យតម្កល់ឡើយ ។

៣-ច្បាប់នេះមិនតម្រូវឱ្យមានថ្លៃសេវាកម្មណាផ្សេងពីថ្លៃសេវាកម្មដែលកំណត់ខាងលើនេះឡើយ ។

## ជំពូកទី ៤

## ការអនុវត្ត

**មាត្រា ៤៦.-**

១-ភាគីនៃកិច្ចព្រមព្រៀងប្រាតិភោគ មានសេរីភាពក្នុងការកំណត់ពីការមិនសងបំណុលក្នុងកិច្ចសន្យារបស់ខ្លួន ។

២-នៅពេលកូនបំណុលមិនសងបំណុល ម្ចាស់បំណុលដែលមានកិច្ចធានាត្រូវមាន :

ក-សិទ្ធិកាន់កាប់ ឬ គ្រប់គ្រងទ្រព្យធានាតាមសិទ្ធិរបស់ខ្លួន ទោះបីជាកិច្ចព្រមព្រៀងប្រាតិភោគគ្មានចែងពីការកាន់កាប់ ឬការត្រួតត្រាក៏ដោយ ។

ខ-សិទ្ធិ និងដំណោះស្រាយដែលមានចែងក្នុងច្បាប់នេះ ។

គ-សិទ្ធិ និងដំណោះស្រាយដែលមានចែងក្នុងកិច្ចព្រមព្រៀងប្រាតិភោគ ។

ឃ-សិទ្ធិ និងដំណោះស្រាយដែលមានចែងក្នុងច្បាប់ផ្សេងទៀត ។

៣-ម្ចាស់បំណុលដែលមានកិច្ចធានាអាចប្រើសិទ្ធិណាមួយ ឬ ទាំងអស់ដែលខ្លួនមានក្នុងពេលជាមួយគ្នាបាន ។

៤-បើទ្រព្យធានាជាគណនីឬទ្រព្យអរូបីផ្សេងទៀត ម្ចាស់បំណុលដែលមានកិច្ចធានាអាចប្រើសិទ្ធិលើគណនី ឬទ្រព្យអរូបីនោះដោយមិនចាំបាច់ប្តឹងទៅតុលាការ ប៉ុន្តែត្រូវគោរពតាមបទប្បញ្ញត្តិនៃច្បាប់នេះ ដែលចែងពីអនុប្បទានសិទ្ធិឬសិទ្ធិប្រមូលបំណុល ។

៥-បើទ្រព្យធានាជាឯកសារ ម្ចាស់បំណុលដែលមានកិច្ចធានាអាចប្រើសិទ្ធិលើឯកសារ ឬ ចំពោះទំនិញដែលបានចែងក្នុងឯកសារក៏បាន ។

៦-នៅពេលកូនបំណុលមិនសងបំណុល ម្ចាស់បំណុលដែលមានកិច្ចធានាមានសិទ្ធិសុំសេចក្តីសម្រេចកិច្ចការប្រញាប់ពីតុលាការ ដែលអនុញ្ញាតឱ្យ ម្ចាស់បំណុលមានកិច្ចធានាកាន់កាប់ ឬ គ្រប់គ្រងលើទ្រព្យធានា ។

៧-កាលណាម្ចាស់បំណុលមានកិច្ចធានា បានទទួលសេចក្តីសម្រេចឱ្យកាន់កាប់អាទិភាពនៃការអនុវត្តសេចក្តីសម្រេចនេះ ត្រូវគិតចាប់ពីកាលបរិច្ឆេទតម្កល់លិខិតជូនដំណឹង ឬ ស្របកម្មនៃសិទ្ធិប្រាតិភោគ គឺយកកាលបរិច្ឆេទណាមួយដែលកើតឡើងមុន ។

៨-ម្ចាស់បំណុលដែលមានកិច្ចធានា អាចទិញទ្រព្យធានាដែលប្រកាសលក់ដេញថ្លៃបាន ។

មាត្រា ៤៧.-

១-នៅពេលកូនបំណុលមិនសងបំណុលក្នុងគណនី ឬ សិទ្ធិទទួលការបង់ប្រាក់ផ្សេងទៀត ម្ចាស់បំណុលដែលមានកិច្ចធានា អាចប្រើសិទ្ធិរបស់ខ្លួនបានដោយផ្ទាល់ចំពោះគណនី ។

២-នៅពេលកូនបំណុលមិនសងបំណុលក្នុងគណនី កិច្ចសន្យាលក់ដែលមានកិច្ចធានា ឬសិទ្ធិទទួលការបង់ប្រាក់ផ្សេងទៀត ឬ នៅពេលដែលកូនបំណុលបានឯកភាព ម្ចាស់បំណុលដែលមានកិច្ចធានា មានសិទ្ធិជូនដំណឹងអំពីសិទ្ធិរបស់ខ្លួន ទៅកូនបំណុលនៃគណនី ឬ ភាគីកូនបំណុល ដើម្បីឱ្យបង់ប្រាក់ជូនម្ចាស់បំណុលដែលមានកិច្ចធានា និងគ្រប់គ្រងលើផលនៃទ្រព្យធានា ។

៣-បើសិទ្ធិប្រាតិភោគធានានូវបំណុល ម្ចាស់បំណុលដែលមានកិច្ចធានាត្រូវប្រគល់ទឹកប្រាក់ដែលប្រមូលបានដែលលើសពីបំណុលឱ្យទៅកូនបំណុល ។ កូនបំណុលត្រូវទទួលខុសត្រូវសងប្រាក់សមតុល្យរវាងប្រាក់បំណុលនិងប្រាក់ដែលប្រមូលបាន លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះ ។

៤-បើប្រតិបត្តិការជាការលក់គណនី ឬ កិច្ចសន្យាលក់ដែលមានកិច្ចធានាកូនបំណុលគ្មានសិទ្ធិលើទឹកប្រាក់ដែលលើសពីបំណុល និងគ្មានការទទួលខុសត្រូវចំពោះទឹកប្រាក់ដែលនៅខ្វះទេ លើកលែងតែកិច្ចព្រមព្រៀងប្រាតិភោគចែងផ្ទុយពីនេះ ។

៥-ម្ចាស់បំណុលដែលមានកិច្ចធានា អាចអនុវត្តតាមមាត្រានេះដោយមិនចាំបាច់ប្រើនីតិវិធីតុលាការក៏បាន ។

មាត្រា ៤៨.-

១-នៅពេលកូនបំណុលមិនសងបំណុល ម្ចាស់បំណុលមានកិច្ចធានាមានសិទ្ធិកាន់កាប់ ឬគ្រប់គ្រងទ្រព្យធានាដោយមិនចាំបាច់ប្តឹងទៅតុលាការ បើកូនបំណុលបានឯកភាពជាលាយលក្ខណ៍អក្សរបន្ទាប់ពីកូនបំណុលមិនបានសងបំណុល ។

២-នៅពេលកូនបំណុលមិនសងបំណុល ម្ចាស់បំណុលមានកិច្ចធានាមានសិទ្ធិប្តឹងសុំសេចក្តីសម្រេចកិច្ចការប្រញាប់ ឬ ការបញ្ជាពិសេសពីតុលាការដែលអនុញ្ញាតឱ្យម្ចាស់បំ-ណុលមានកិច្ចធានាកាន់កាប់ ឬ គ្រប់គ្រងទ្រព្យធានា ។

ក-សវនាការត្រូវផ្តោតតែលើបញ្ហាដែលពាក់ព័ន្ធ នឹងកិច្ចព្រមព្រៀងប្រាតិ-ភោគដែលចែងពីទ្រព្យធានា ហើយត្រូវមានការខកខានមិនបានសងបំណុលយ៉ាងតិចមួយលើក ។

ខ-ក្នុងករណីដែលត្រូវការសេវាកម្មរបស់អាជ្ញាសាលា ឬ មន្ត្រីដទៃទៀតជាចាំបាច់ ដើម្បីដកហូតទ្រព្យធានាពីកូនបំណុល ម្ចាស់បំណុលត្រូវបង់ថ្លៃសេវាជាប្រាក់រៀលតាមការកំណត់រួមរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងយុត្តិធម៌ ។

៣-បើមានចែងក្នុងកិច្ចព្រមព្រៀងប្រាតិភោគ ម្ចាស់បំណុលមានកិច្ចធានាអាចតម្រូវឱ្យកូនបំណុលផ្តុំតម្លើងទ្រព្យធានា និងរៀបចំឱ្យហើយស្រេចសម្រាប់ម្ចាស់បំណុលមានកិច្ចធានានៅកន្លែងដែលសមស្រប និងងាយស្រួលដល់ភាគីទាំងពីរដែលម្ចាស់បំណុលមានកិច្ចធានាជាអ្នកកំណត់ ។

៤- ម្ចាស់បំណុលមានកិច្ចធានា អាចទុកដាក់ឧបករណ៍មិនឱ្យអ្នកផ្សេងប្រើប្រាស់បានដោយគ្មានផ្លាស់ប្តូរទីតាំងរបស់វា ហើយអាចជម្រះចោលទ្រព្យធានានេះនៅមណ្ឌលអាជីវ-កម្ម ឬ លំនៅស្ថានរបស់កូនបំណុល ឬទីកន្លែងផ្សេងទៀតដែលរកឃើញទ្រព្យធានា ។

មាត្រា ៤៩.-

១-បន្ទាប់ពីកូនបំណុលមិនសងបំណុល ម្ចាស់បំណុលមានកិច្ចធានាអាចលក់ ជួល ផ្តល់តាមអាជ្ញាប័ណ្ណ ឬ ជម្រះចោលទ្រព្យធានាណាមួយ ឬ ទាំងអស់ក៏បាន ។

២-ការជម្រះចោលទ្រព្យធានា អាចធ្វើឡើងជាសាធារណៈ ឬ ជាឯកជន ហើយអាចធ្វើឡើងតាមកិច្ចសន្យាមួយ ឬ ច្រើនក៏បាន ។

៣-ការជម្រះចោលនេះអាចធ្វើឡើងតាមឯកតា ឬ ជាកញ្ចប់ និងនៅពេលវេលាទីកន្លែង និងតាមលក្ខខណ្ឌដែលស្របតាមកាតព្វកិច្ចរបស់ម្ចាស់បំណុលមានកិច្ចធានាដែលកំណត់ក្នុងច្បាប់នេះ ។

៤- ម្ចាស់បំណុលមានកិច្ចធានា ត្រូវផ្តល់ជូនកូនបំណុលនូវដំណឹងសមស្របអំពីពេលវេលា និងទីកន្លែងនៃការលក់ឡាយឡុងជាសាធារណៈ ឬ ពេលវេលាដែលត្រូវលក់ជាឯកជន ឬការជម្រះចោលដែលបានគ្រោងទុក លើកលែងតែទ្រព្យធានាដែលងាយផុយរលួយ ឬ បង្ហាញពីការធ្លាក់ចុះតម្លៃយ៉ាងឆាប់រហ័ស ។ កូនបំណុលអាចលះបង់សិទ្ធិក្នុងការទទួលព័ត៌មាននេះបាន ។

៥- ម្ចាស់បំណុលដែលមានកិច្ចធានា ត្រូវជូនដំណឹងដល់ម្ចាស់បំណុលដែលមានកិច្ចធានាផ្សេងទៀត ដែលបានធ្វើកំណត់ត្រាជាលាយលក្ខណ៍អក្សរ ដែលបញ្ជាក់ពីសិទ្ធិរបស់គេលើទ្រព្យធានាមកឱ្យម្ចាស់បំណុលដែលមានកិច្ចធានា ។

៦- ម្ចាស់បំណុលដែលមានកិច្ចធានា អាចទិញទ្រព្យធានាដែលលក់ឡាយឡុងជាសាធារណៈ ឬ ជាឯកជនបាន ។

មាត្រា ៥០.-

១- ផលនៃការជម្រះទ្រព្យធានា ត្រូវយកមកប្រើប្រាស់តាមលំដាប់ដូចខាងក្រោមនេះ :

ក- សងថ្លៃចំណាយសមស្រប ដែលកើតឡើងពីការទទួលយកការកាន់កាប់ ការរៀបចំជម្រះទ្រព្យធានា និងការជម្រះទ្រព្យធានា រាប់បញ្ចូលទាំងថ្លៃចំណាយសមស្របសម្រាប់មេធាវី និងថ្លៃចំណាយរឿងក្តី ដែលម្ចាស់បំណុលមានកិច្ចធានាបានចំណាយ ។

ខ- ទូទាត់បំណុលដែលធានាដោយសិទ្ធិប្រាតិភោគ ។

គ- ទូទាត់បំណុលដែលធានាដោយសិទ្ធិប្រាតិភោគ ក្នុងលំដាប់បន្ទាប់លើទ្រព្យធានា បើមានការទាមទារជាលាយលក្ខណ៍អក្សរ មុនពេលបញ្ចប់ការបែងចែកផលនៃទ្រព្យធានា ហើយអ្នកកាន់កាប់សិទ្ធិប្រាតិភោគបន្ទាប់នេះ បានផ្តល់ភស្តុតាងសមស្របពីផលប្រយោជន៍របស់ខ្លួន ។

ឃ- ទូទាត់បំណុលគ្មានទ្រព្យធានាដែលបានទទួលស្គាល់ ។

២- ម្ចាស់បំណុលដែលមានកិច្ចធានា ត្រូវប្រគល់ទឹកប្រាក់ដែលលើសពីបំណុលទៅឱ្យកូនបំណុល ហើយកូនបំណុលត្រូវទទួលខុសត្រូវសងទឹកប្រាក់ដែលខ្វះ លើកលែងតែមានកិច្ចព្រមព្រៀងផ្សេងពីនេះ ។

៣-កាលណាទ្រព្យធានា ត្រូវបានជម្រះចោលដោយម្ចាស់បំណុលដែលមានកិច្ចធានា បន្ទាប់ពីកូនបំណុលមិនសងបំណុល ៖

ក-ការជម្រះចោលនេះជាការផ្ទេរសិទ្ធិទាំងអស់ លើទ្រព្យធានាឱ្យទៅអ្នកទិញ ដែលបានបង់ថ្លៃ ហើយរំលត់សិទ្ធិប្រាតិភោគ និងសិទ្ធិប្រាតិភោគបន្ទាប់ ឬ ឯកសិទ្ធិផ្សេងទៀត បើអ្នកទិញបានទិញដោយសុចរិត និង

ខ-មន្ត្រីចុះបញ្ជីនៃការិយាល័យចុះបញ្ជី ដែលរក្សាទុកកំណត់ត្រាកម្មសិទ្ធិលើទ្រព្យធានាដូចជាមន្ត្រីចុះបញ្ជីសិទ្ធិកម្ម សិទ្ធិយានយន្តដែលមានលេខស៊េរី ត្រូវចេញប័ណ្ណកម្មសិទ្ធិថ្មីជូនអ្នកទិញដែលបានបង់តម្លៃ ហើយបើមានការស្នើសុំពីមន្ត្រីចុះបញ្ជី ម្ចាស់បំណុលដែលមានកិច្ចធានា ត្រូវផ្តល់ការអនុញ្ញាតឱ្យចេញប័ណ្ណកម្មសិទ្ធិថ្មី តាមរយៈសេចក្តីសម្រេចរបស់តុលាការដែលបង្គាប់ឱ្យម្ចាស់បំណុលកាន់កាប់ ឬកិច្ចព្រមព្រៀងលាយលក្ខណ៍អក្សររបស់កូនបំណុលដែលប្រគល់ ទ្រព្យធានាឱ្យម្ចាស់បំណុលកាន់កាប់ ដែលកូនបំណុលចុះហត្ថលេខា បន្ទាប់ពីការមិនសងបំណុល ។

**មាត្រា ៥១.-**

១-បន្ទាប់ពីការមិនសងបំណុល ម្ចាស់បំណុលមានកិច្ចធានា អាចស្នើសុំឃាត់ទុកទ្រព្យធានា ដើម្បីឱ្យមានការទូទាត់កាតព្វកិច្ចមួយផ្នែក ឬ ទាំងស្រុងបាន ។

២-ម្ចាស់បំណុលមានកិច្ចធានាត្រូវធ្វើការស្នើសុំនេះទៅកូនបំណុល និង ម្ចាស់បំណុលដែលមានកិច្ចធានាផ្សេងទៀត ដែលបានធ្វើការទាមទារជាលាយលក្ខណ៍អក្សរមកម្ចាស់បំណុលដែលមានកិច្ចធានា ហើយបញ្ជាក់ថាខ្លួនមានផលប្រយោជន៍ក្នុងទ្រព្យធានានេះ ។

៣-បើម្ចាស់បំណុលដែលមានកិច្ចធានា បានទទួលការជំទាស់ជាលាយលក្ខណ៍អក្សរពីបុគ្គលដែលមានសិទ្ធិទទួលលិខិតជូនដំណឹងក្នុងរយៈពេលម្ភៃ(២០)ថ្ងៃបន្ទាប់ពីបានធ្វើលិខិតជូនដំណឹង ម្ចាស់បំណុលដែលមានកិច្ចធានាត្រូវតែជម្រះចោលទ្រព្យធានាតាមបទ-ប្បញ្ញត្តិនៃជំពូកនេះ ។

៤-បើគ្មានការជំទាស់ក្នុងរយៈពេលម្ភៃ(២០)ថ្ងៃទេ ម្ចាស់បំណុលដែលមានកិច្ចធានាអាចរក្សាទុកទ្រព្យធានា ដើម្បីទូទាត់កាតព្វកិច្ចរបស់កូនបំណុលស្របតាមការស្នើសុំ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា ៥២.-**

១-លើកលែងតែមានការព្រមព្រៀងលាយលក្ខណ៍អក្សរផ្ទុយពីនេះ បន្ទាប់ពីការមិនសងបំណុល កូនបំណុលឬម្ចាស់បំណុលដែលមានកិច្ចធានាផ្សេងទៀត អាចលោះយកទ្រព្យធានាដោយអនុវត្តកាតព្វកិច្ចទាំងអស់ ដែលធានាដោយទ្រព្យធានានេះ និងចេញថ្លៃចំណាយសមស្របដែលម្ចាស់បំណុលដែលមានកិច្ចធានាបានចាយក្នុងការកាន់កាប់ និង ផ្គួសផ្គុលទ្រព្យធានាសម្រាប់ជម្រះចោល រួមបញ្ចូលទាំងថ្លៃសេវាមេធាវី និងចំណាយសមស្របក្នុងរឿងក្តី ។

២-ការលោះយកទ្រព្យធានា ត្រូវតែធ្វើឡើងមុនពេលម្ចាស់បំណុលដែលមានកិច្ចធានាជម្រះចោលទ្រព្យធានា ឬ មុនពេលម្ចាស់បំណុលដែលមានកិច្ចធានាចុះកិច្ចសន្យាដើម្បីជម្រះចោលទ្រព្យធានា ឬ មុនពេលដែលកាតព្វកិច្ចត្រូវបានរំលត់ ។

**មាត្រា ៥៣.-**

១-បើម្ចាស់បំណុលមានកិច្ចធានា មិនគោរពតាមលក្ខខណ្ឌតម្រូវនៃជំពូកនេះ តុលាការអាចបង្គាប់ ឬ ហាមឃាត់ការជម្រះចោលទ្រព្យធានាដោយអនុលោមតាមបញ្ញត្តិ និងលក្ខខណ្ឌសមស្រប ។

២-ម្ចាស់បំណុលមានកិច្ចធានាត្រូវតែអនុវត្តតាមគោលការណ៍ពាណិជ្ជកម្ម ដែលសមស្របជានិច្ចក្នុងការជម្រះចោលទ្រព្យធានា ។

៣-បើទ្រព្យធានាត្រូវបានជម្រះចោលរួចហើយ កូនបំណុល ឬ បុគ្គលដែលមានសិទ្ធិទទួលព័ត៌មាន ឬបុគ្គលដែលបានជូនដំណឹងពីសិទ្ធិប្រាតិភោគរបស់ខ្លួនទៅម្ចាស់បំណុលដែលមានកិច្ចធានាមុនការជម្រះចោលទ្រព្យនេះ មានសិទ្ធិទារសំណងពីម្ចាស់បំណុលដែលមានកិច្ចធានាចំពោះការខាតបង់ ដែលបណ្តាលមកពីការមិនគោរពច្បាប់នេះ ។

៤-មិនត្រូវចាត់ទុកថា ការលក់មិនស្របតាមគោលការណ៍ពាណិជ្ជកម្មឡើយ បើគ្រាន់តែដោយសារការលក់នេះអាចនឹងទទួលតម្លៃខ្ពស់ជាង បើលក់នៅពេលវេលាផ្សេង ឬតាមវិធីផ្សេងពីវិធីដែលកំណត់ដោយម្ចាស់បំណុលដែលមានកិច្ចធានា ។

៥- ការលក់នឹងត្រូវចាត់ទុកថាស្របតាមគោលការណ៍ពាណិជ្ជកម្ម បើម្ចាស់បំណុលដែលមានកិច្ចធានា បានជម្រះចោលទ្រព្យធានាស្របតាមទម្លាប់ពាណិជ្ជកម្មរវាងពាណិជ្ជ-ករ ដែលធ្វើអាជីវកម្មទ្រព្យដែលមានប្រភេទដូចគ្នានឹងទ្រព្យធានា ។

៦- បើវិធីជម្រះចោលទ្រព្យធានាត្រូវបានឯកភាពដោយតុលាការ ការជម្រះចោលត្រូវចាត់ទុកថា ស្របតាមគោលការណ៍ពាណិជ្ជកម្មទាំងស្រុង ប៉ុន្តែច្បាប់នេះមិនតម្រូវឱ្យមានការឯកភាពនេះជាចាំបាច់ឡើយ ។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**មាត្រា ៥៤.-**

បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥៥.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០០៧

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នស/រកម.០៥០៥.០២១

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
ហត្ថលេខា
ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
ហត្ថលេខា
ចម ប្រសិទ្ធ

លេខៈ ៥០៨ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ឃុន ជិនកេន

# ច្បាប់

# ស្ដីពី

# ភតិសន្យាហិរញ្ញវត្ថុ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ព្រះរាជក្រម

នស/រកម/០៦០៩/០០៩

## យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្ដិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានទ្រង់យល់ សេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ ស្ដីពីភតិសន្យាហិរញ្ញវត្ថុ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៧ ខែឧសភា ឆ្នាំ ២០០៩ នាសម័យប្រជុំ រដ្ឋសភាលើកទី ២ នីតិកាលទី ៤ និងដែលព្រឹទ្ធសភាបាន យល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ២០០៩ នាសម័យប្រជុំវិសាមញ្ញ ហើយដែលមានសេចក្ដីទាំងស្រុង ដូចតទៅនេះ ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.–**

ច្បាប់នេះមានគោលដៅកំណត់សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីពាក់ព័ន្ធនឹងប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ និងដាក់ចេញនូវវិធានការ ដើម្បីការពារសិទ្ធិទាំងនោះ ។

**មាត្រា ២.–**

ច្បាប់នេះមានគោលបំណងអភិវឌ្ឍប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ និងសហគ្រាស ដើម្បីបង្កលក្ខណៈធ្វើប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុដោយស្មើភាព សុវត្ថិភាព ប្រសិទ្ធភាព និងផលិតភាព ស្របតាមការវិវត្តនៃសេដ្ឋកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣.–**

ច្បាប់នេះមានវិសាលភាព គ្របដណ្តប់លើភតិសន្យាហិរញ្ញវត្ថុនៃចលនវត្ថុក្នុងព្រះរាជាណាចក្រកម្ពុជាប៉ុណ្ណោះ ។

**មាត្រា ៤.–**

ពាក្យបច្ចេកទេសដែលប្រើក្នុងច្បាប់នេះ មាននិយមន័យដូចតទៅ :

- **ភតិបតី** :សំដៅដល់រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលផ្ទេរសិទ្ធិកាន់កាប់ និងសិទ្ធិប្រើប្រាស់ចលនវត្ថុទៅឱ្យភតិកៈ ។

- **ភតិកៈ** :សំដៅដល់រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលទទួលសិទ្ធិកាន់កាប់ និងសិទ្ធិប្រើប្រាស់ចលនវត្ថុពីភតិបតី ។

- **ចលនវត្ថុ** : សំដៅដល់ទ្រព្យសម្បត្តិ គ្រឿងចក្រ និងឧបករណ៍ទាំងអស់ លើកលែងតែដី និងអគារ ។

- **រយៈពេល** : សំដៅដល់រយៈពេលដែលមានចែងក្នុងកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ដែលក្នុងរយៈពេលនោះភតិកៈត្រូវបានអនុញ្ញាតឱ្យកាន់កាប់ និងប្រើប្រាស់ចលនវត្ថុដែលបានជួល ។

- **ភតិសន្យា** : សំដៅដល់ប្រតិបត្តិការដែលភតិបតីចុះកិច្ចព្រមព្រៀងជាមួយ

4/17

ភតិកៈ ក្នុងនោះភតិកៈត្រូវបានផ្តល់សិទ្ធិឱ្យកាន់កាប់ និងប្រើប្រាស់ចលនវត្ថុក្នុងរយៈពេលមួយ ដោយការបង់ថ្លៃឈ្នួលតាមគ្រា ឬ តាមតម្លៃសមមូល ។ ភតិសន្យា ត្រូវរួមបញ្ចូលទាំងភតិសន្យាបន្តផងដែរ ។

- **ភតិសន្យាបន្ត** : សំដៅដល់ប្រតិបត្តិការដែលចលនវត្ថុ ត្រូវបានជួលដោយភតិកៈដំបូង ត្រូវបានជួលបន្តឱ្យភាគីផ្សេងទៀត ហើយកិច្ចព្រមព្រៀងភតិសន្យារវាងគូភាគីដំបូង នៅមានសុពលភាពដដែល ។

- **ភតិសន្យាហិរញ្ញវត្ថុ** : សំដៅដល់ភតិសន្យាសម្រាប់រយៈពេលដំបូងមួយឆ្នាំ ឬ ច្រើនជាងដែលរយៈពេលនោះមិនអាចកែប្រែបាន ក្នុងនោះ :

ក-ភតិកៈបញ្ជាក់ច្បាស់លាស់នូវចលនវត្ថុ និងជ្រើសរើសអ្នកផ្គត់ផ្គង់ ដោយមិនផ្អែកសំខាន់លើជំនាញ និងការវិនិច្ឆ័យរបស់ភតិបតីឡើយ

ខ-ភតិបតីទិញចលនវត្ថុតាមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ដើម្បីជួលឱ្យភតិកៈ ។

ក៏ប៉ុន្តែ បើមានការជួលបន្តនូវចលនវត្ថុដែលបានជួលពីមុនពីភតិបតីដដែល ការជួលបន្តនោះអាចនៅតែជាភតិសន្យាហិរញ្ញវត្ថុដដែល ។

ភតិសន្យាអាចជាភតិសន្យាហិរញ្ញវត្ថុ ដោយមិនគិតដល់ :

ក-ការបង់ថ្លៃឈ្នួលភតិសន្យាត្រូវបាន ឬ មិនត្រូវបានគណនាបញ្ចូលនូវការរំលស់ទាំងមូល ឬ ការរំលស់មួយផ្នែកធំនៃតម្លៃចលនវត្ថុ ឬ

ខ-ភតិកៈមាន ឬ ពុំមានជម្រើស ឬ ក្រោយមកទទួលយកជម្រើសថាទិញ ឬ បន្តជួលចលនវត្ថុ មួយរយៈពេលបន្ថែមទៀត ។

- **ការបង់ថ្លៃឈ្នួលជាមុន** : សំដៅដល់ចំនួននៃការបង់ថ្លៃឈ្នួលតាមគ្រាដោយភតិកៈ នៅពេល ឬ មុនពេលចាប់ផ្តើមជួល ។ ការបង់ថ្លៃឈ្នួលជាមុន មិនមែនជាប្រាក់ប្រាតិភោគទេ ។

- **ប្រាក់ប្រាតិភោគ** : សំដៅដល់ចំនួនប្រាក់ដែលត្រូវបានបង់ដោយភតិកៈនិងត្រូវបានកាន់កាប់ដោយភតិបតី ដើម្បីធានាកាតព្វកិច្ច សម្រាប់ឱ្យភតិកៈអនុវត្តតាមភតិសន្យាហិរញ្ញវត្ថុ ដោយពេញលេញ និងទៀងទាត់ ។

- **អ្នកផ្គត់ផ្គង់** : សំដៅដល់រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលភតិបតីទទួលចលន-

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

វត្ថុដែលត្រូវជួលឱ្យភតិកៈ ។ លទ្ធកម្មរបស់ភតិបតីអាចប្រព្រឹត្តទៅតាមរយៈការទិញ ការជួល ការប្រគល់សិទ្ធិឱ្យទិញ ឬ ឱ្យជួល រួមទាំងការប្រគល់សិទ្ធិពីភតិកៈផងដែរ ។ នៅក្នុងប្រតិបត្តិការលក់ហើយជួលមកវិញ ភតិកៈអាចជាអ្នកផ្គត់ផ្គង់ ។

- **កិច្ចព្រមព្រៀងផ្គត់ផ្គង់** : សំដៅដល់កិច្ចព្រមព្រៀងដែលភតិបតីទិញចលនវត្ថុដែលត្រូវជួលឱ្យភតិកៈ ។

- **កិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ** : សំដៅដល់កិច្ចព្រមព្រៀងដែលភតិបតីទិញចលនវត្ថុ ដែលភតិកៈបានជ្រើសរើសពីអ្នកផ្គត់ផ្គង់ ហើយជួលចលនវត្ថុនេះទៅឱ្យភតិកៈ និងអនុញ្ញាតឱ្យភតិកៈបង់ថ្លៃឈ្នួលតាមកាលកំណត់ ។

## ជំពូកទី ២

## កិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ

**មាត្រា ៥.–**

កិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុត្រូវតែសរសេរជាលាយលក្ខណ៍អក្សរ ចុះហត្ថលេខាដោយភតិបតីនិងភតិកៈ ហើយត្រូវកំណត់រយៈពេល និងលក្ខខណ្ឌនៃគ្រប់ភាគីទាក់ទងនឹងចលនវត្ថុដែលបានជួល ។ កិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុមិនចាំបាច់មានការបញ្ជាក់ពីសារការីក៏បានដែរ លើកលែងតែមានច្បាប់ណាមួយតម្រូវ ។

**មាត្រា ៦.–**

កិច្ចព្រមព្រៀងមួយដែលពេញលក្ខណៈជាកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ លុះត្រាតែកិច្ចព្រមព្រៀងនោះ មានចែងចំណុចសំខាន់ៗយ៉ាងតិច ដូចខាងក្រោម :

ក-ការពណ៌នាពីចលនវត្ថុដែលបានជួល

ខ-ចំនួនប្រាក់ ការកំណត់គ្រា និងរយៈពេលនៃការបង់ថ្លៃឈ្នួល

គ-កាលបរិច្ឆេទចាប់ផ្តើមភតិសន្យាហិរញ្ញវត្ថុ និង

ឃ-ហត្ថលេខារបស់ភតិបតី និងភតិកៈ ។

**មាត្រា ៧.–**

កិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុអាចមានចែងអំពីប្រាក់ប្រាតិភោគ ឬ ការបង់ថ្លៃឈ្នួលជាមុន ឬ ទាំងពីរ ។ សម្រាប់ភតិកៈ ប្រាក់ប្រាតិភោគ អាច ឬ មិនអាចទទួលបាននូវ

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

ចំណូលការប្រាក់ ហើយអាចត្រូវបានបង្វិលឱ្យភតិកៈវិញ ឬ អាចប្រើប្រាស់ ដោយភតិបតី ដូចមានចែងក្នុងកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ។

ក្នុងករណីដែលកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ មិនមានចែងអំពីការប្រើប្រាក់ប្រា-តិភោគទេ ប្រាក់ប្រាតិភោគនោះ មិនត្រូវទទួលការប្រាក់ឡើយ និងត្រូវបង្វិលទៅឱ្យភតិកៈវិញ ក្រោយពេលដែលភតិកៈបានបំពេញកាតព្វកិច្ចភតិសន្យាហិរញ្ញវត្ថុបានពេញលេញនិងតាមពេលកំណត់ហើយ ។ ការបង់ថ្លៃឈ្នួលជាមុនមិនត្រូវទទួលបានការប្រាក់ទេ ។ ប្រាក់ប្រាតិភោគ និងការបង់ថ្លៃឈ្នួលជាមុន អាចជាចំនួនប្រាក់ដែលបានព្រមព្រៀងគ្នារវាងភាគីទាំងពីរ ។

**មាត្រា ៨.–**

បើកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុមានចែងថា ចលនវត្ថុត្រូវបិទស្លាកសម្គាល់ជាកម្មសិទ្ធិរបស់ភតិបតី ឬ ជាកម្មវត្ថុនៃភតិសន្យាពីភតិបតី ស្លាកសម្គាល់ទាំងនោះមិនត្រូវដកចេញ ឬ ធ្វើឱ្យមើលមិនស្គាល់ ដោយជនណាម្នាក់ ក្រៅពីភតិបតី ឬ អ្នកតំណាងរបស់ភតិបតីនោះឡើយ ។

នៅពេលបានរកឃើញការខូចខាតណាមួយនៃស្លាកសម្គាល់ដែលបណ្តាលឱ្យមើលមិនស្គាល់ ភតិកៈត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាបន្ទាន់ទៅឱ្យភតិបតី ឬ បើពុំដូច្នោះទេ ភតិកៈត្រូវទទួលខុសត្រូវក្នុងកម្រិតដូចដែលភតិកៈបានដកស្លាកសម្គាល់ចេញដោយគ្មានការអនុញ្ញាត ។ ភតិកៈមិនត្រូវទទួលខុសត្រូវក្រោមមាត្រានេះឡើយ ប្រសិនបើភតិបតីខកខានមិនបានផ្លាស់ប្តូរស្លាកសម្គាល់នោះ ក្រោយពីភតិកៈបានជូនដំណឹងទាន់ពេលវេលាឱ្យទៅភតិបតីរួចហើយ ។

**មាត្រា ៩.–**

បើភតិបតី និងភតិកៈព្រមព្រៀងគ្នាសងតាមវិធីមិនមែនរូបិយវត្ថុ ដូចជាផលិតផលសេវាកម្ម ការដោះដូរជាវត្ថុ តម្លៃនៃការទូទាត់សង ក្នុងទម្រង់មិនមែនរូបិយវត្ថុនោះ ត្រូវគិតតាមតម្លៃទីផ្សារ លើកលែងតែភាគីទាំងពីរ បានចែងក្នុងកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញ-វត្ថុ ឬ កិច្ចសន្យាណាមួយផ្សេងពីនេះ ។

**មាត្រា ១០.-**

នៅក្រោមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ភតិកៈទទួលយកការប្រើប្រាស់ចលនវត្ថុ ក្នុងរយៈពេលយ៉ាងតិចបំផុត ០១ (មួយ) ឆ្នាំ ។ នៅចុងបញ្ចប់នៃកិច្ចព្រមព្រៀងនោះ ភតិកៈអាច ឬ មិនអាចទិញផ្តាច់នូវចលនវត្ថុនោះ ។ ភតិបតីផ្តល់ហិរញ្ញប្បទានសម្រាប់ឱ្យភតិកៈប្រើប្រាស់ចលនវត្ថុ មិនមែនឱ្យធ្វើជាម្ចាស់កម្មសិទ្ធិលើចលនវត្ថុនោះទេ ។

## ជំពូកទី ៣
## សិទ្ធិ និងកាតព្វកិច្ចរបស់ភតិបតី

**មាត្រា ១១.-**

នៅក្នុង និងក្រោយរយៈពេលនៃភតិសន្យាហិរញ្ញវត្ថុ ភតិបតីនៅតែជាម្ចាស់កម្មសិទ្ធិលើចលនវត្ថុដែលបានជួល លើកលែងតែកម្មសិទ្ធិត្រូវបានផ្ទេរទៅឱ្យភតិកៈ ឬ ទៅឱ្យភាគីផ្សេងទៀត ។

**មាត្រា ១២.-**

ភតិបតីត្រូវទទួលខុសត្រូវបង់ពន្ធនាំចូល និងកាតព្វកិច្ចសារពើពន្ធផ្សេងៗទៀត តាមច្បាប់កំណត់ និងសោហ៊ុយចុះបញ្ជីលើចលនវត្ថុដែលបានជួល លើកលែងតែកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុមានចែងផ្សេងពីនេះ ។

**មាត្រា ១៣.-**

ភតិបតីត្រូវទូទាត់សងថ្លៃទិញចលនវត្ថុទៅឱ្យអ្នកផ្គត់ផ្គង់ នៅពេលដែលភតិកៈបានយល់ព្រមទទួលចលនវត្ថុនោះ ដោយគ្មានលក្ខខណ្ឌ ។

**មាត្រា ១៤.-**

ភតិបតីត្រូវធានាយ៉ាងណាឱ្យភតិកៈបានប្រើប្រាស់ និងកាន់កាប់ចលនវត្ថុ ដែលបានជួលដោយគ្មានការរំខាន នៅក្នុងរយៈពេលអនុវត្តភតិសន្យាហិរញ្ញវត្ថុ ដរាបណាភតិកៈអនុវត្តតាមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ។

**មាត្រា ១៥.-**

ភតិបតីមិនទទួលខុសត្រូវចំពោះភតិកៈលើចលនវត្ថុឡើយ លើកលែងតែក្នុងករណីដែលភតិកៈបានទទួលរងការខាតបង់ ដោយសារការធ្វើអន្តរាគមន៍របស់ភតិបតី ក្នុងការជ្រើសរើស ឬ ក្នុងការកំណត់យថាប្រភេទនៃចលនវត្ថុ ។

**មាត្រា ១៦.-**

ក្នុងអំឡុងពេលនៃការអនុវត្តកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ភតិបតីមិនទទួលខុសត្រូវសងការខូចខាត ដែលបង្កដល់តតិយជន ដោយសារចលនវត្ថុដែលខ្លួនបានជួលឡើយ ។

**មាត្រា ១៧.-**

ក្នុងករណីដែលភតិកៈមិនគោរពតាមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ភតិបតីត្រូវមានសិទ្ធិបន្ថែមពីលើសិទ្ធិ ដែលមានចែងក្នុងកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ដូចតទៅ :

ក-ភតិបតីអាចទាមទារឱ្យភតិកៈបង់ថ្លៃឈ្នួលដែលមិនទាន់បានសង រួមទាំងការប្រាក់ និងការខូចខាត

ខ-ភតិបតីក៏អាចទាមទារឱ្យពន្លឿនការបង់ថ្លៃឈ្នួលនាអនាគតបាន អាចរំលាយកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ និងអាចទាមទារយកចលនវត្ថុដែលបានជួលមកវិញ បើមានករណីណាមួយ ដូចខាងក្រោម :

-ភតិកៈមិនបានបង់ថ្លៃឈ្នួលតាមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ក្នុងរយៈពេលពីរគ្រាជាបន្តបន្ទាប់

-ភតិកៈបំពានខណាមួយផ្សេងទៀតនៃកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ និងខកខានមិនបានដោះស្រាយបញ្ហា ក្នុងរយៈពេលដប់ (១០) ថ្ងៃ បន្ទាប់ពីបានទទួលសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរពីភតិបតី

-ភតិកៈមានអ្នកធានាដែលគ្មានសាធនភាព ក្ស័យធន ឬ ត្រូវបានរំលាយ ហើយភតិកៈមិនបានរកអ្នកធានាជំនួសណាម្នាក់ ដែលភតិបតីអាចទទួលយកបាន ក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ តាមការស្នើសុំឱ្យរកអ្នកធានាជំនួសជាលាយលក្ខណ៍អក្សរពី

-ភតិកៈគ្មានសាធនភាព ក្ស័យធន ត្រូវបានរំលាយ ឬ ទទួលមរណភាព ហើយពុំមានអ្នកស្នងបន្ត ។

គ-ទោះបីជាកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ត្រូវបាន ឬ មិនត្រូវបានរំលាយ នៅមុនពេលផុតរយៈពេលក៏ដោយ ភតិបតីអាច :

-ទាមទារយកចលនវត្ថុដែលបានជួលមកកាន់កាប់វិញ ដោយមិនចាំបាច់ប្តឹងទៅតុលាការ ប្រសិនបើការទាមទារនោះធ្វើឡើង ដោយគ្មានអំពើហិង្សា និង

-ទាមទារសំណងការខូចខាត ដែលភតិបតីត្រូវទទួលបានរាប់ទាំងចំណាយបន្ថែម បណ្តាលមកពីកំហុសរបស់ភតិកៈផង ។ កិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ អាចចែងអំពីវិធីគណនាការខូចខាត ហើយវិធីគណនានេះ អាចអនុវត្តបានដោយភាគីទាំងពីរ លើកលែងតែវិធីគណនានេះ បណ្តាលឱ្យមានវិការៈធ្ងន់ធ្ងរលើសពីសំណងការខូចខាត ដែលភតិបតីអាចនឹងទទួលបាន ប្រសិនបើភតិកៈអនុវត្តតាមកិច្ចព្រមព្រៀងភតិសន្យាហិរ-ញ្ញវត្ថុ ។

ឃ-បើចាំបាច់ ភតិបតីអាចដាក់ពាក្យស្នើសុំដីកាសម្រេចពីតុលាការឱ្យភតិកៈប្រគល់ចលនវត្ថុជួលនោះមកភតិបតីវិញ ដោយភ្ជាប់ជាមួយនូវរាល់ឯកសារភស្តុតាងដែលបង្ហាញថា ភតិកៈមិនបានគោរពតាមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ។ ប៉ុន្តែ ភតិបតីនៅតែត្រូវទទួលខុសត្រូវចំពោះការខូចខាតទាំងឡាយដែលកើតឡើងដល់ភតិកៈ បើនៅពេលក្រោយមកមានភស្តុតាងបង្ហាញថា ការទាមទារចលនវត្ថុដែលបានជួលមកវិញដោយភតិបតីនោះ ជាការរំលោភលើកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ។

**មាត្រា ១៨.–**

ភតិបតីមានសិទ្ធិតម្រូវឱ្យភតិកៈសងការខាតបង់ បំណុល ការខូចខាត ឬ ផលវិបាកផ្សេងៗណាមួយ ឬ ទាំងអស់ ដែលកើតឡើងពី ឬ ពាក់ព័ន្ធទៅនឹងការប្រើប្រាស់ និងការកាន់កាប់របស់ភតិកៈលើចលនវត្ថុដែលបានជួល ។

**មាត្រា ១៩.–**

ភតិបតីអាចទាមទារឱ្យភតិកៈទិញ និងបង់ថ្លៃធានារ៉ាប់រងលើចលនវត្ថុ ដែលបានជួលនៅគ្រប់អំឡុងពេលដែលភតិកៈកាន់កាប់ ឬ គ្រប់គ្រងចលនវត្ថុនោះ ទោះបីជារយៈ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ពេលអនុវត្តភតិសន្យាហិរញ្ញវត្ថុ បានឈានដល់ទីបញ្ចប់ហើយ ឬ កិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ត្រូវបានរំលាយមុនពេលក៏ដោយ រហូតដល់ពេលដែលចលនវត្ថុនោះ ត្រូវបានប្រគល់ឱ្យភតិបតីកាន់កាប់ និងគ្រប់គ្រងវិញ ។

ប្រសិនបើភតិកៈត្រូវទិញ និងបង់ថ្លៃបានារ៉ាប់រងហើយបែរជាខកខានទៅវិញ ភតិបតីមានសិទ្ធិទិញ តែមិនមានភារកិច្ចត្រូវទិញបានារ៉ាប់រងនេះទេ ហើយភតិកៈត្រូវសងរាល់ការចំណាយទៅឱ្យភតិបតីវិញភ្លាម ប្រសិនបើភតិបតីបានចំណាយរួចហើយ ។

**មាត្រា ២០.-**

ចលនវត្ថុដែលបានជួល មិនមែនជាចំណែកនៃទ្រព្យសម្បត្តិរបស់ភតិកៈទេ ក្នុងន័យនេះ នៅពេលដែលភតិកៈក្ស័យធន ម្ចាស់បំណុលទាំងឡាយរបស់ភតិកៈ រួមទាំងម្ចាស់បំណុលដែលបានទទួលសិទ្ធិរឹបអូសទ្រព្យសម្បត្តិភតិកៈ តាមសេចក្តីសម្រេចរបស់តុលាការផង គ្មានសិទ្ធិទាមទារយកចលនវត្ថុដែលបានជួលនោះទេ ។

**មាត្រា ២១.-**

ភតិបតីអាចចាត់ចែង ផ្ទេរ ឬ ម្យ៉ាងទៀតបែងចែកសិទ្ធិទាំងអស់ ឬ សិទ្ធិណាមួយរបស់ខ្លួនលើចលនវត្ថុដែលបានជួល ឬ តាមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ទៅឱ្យភាគីណាមួយ ដោយមិនចាំបាច់មានការយល់ព្រមពីភតិកៈ ។ ការផ្ទេរបែបនេះ មិនត្រូវធ្វើឱ្យភតិបតីរួចផុតពីកាតព្វកិច្ចណាមួយ ឬ ផ្លាស់ប្តូរភាពដើមនៃកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុទេ ។ កិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុអាចចែងថា ភតិកៈយល់ព្រមមិនទាមទារកាត់កងការពារ ឬ ទាមទារប្រឆាំងនឹងអ្នកដែលត្រូវបានប្រគល់សិទ្ធិ ឬ អនុប្បទានិករបស់ភតិបតីឡើយ ។

**មាត្រា ២២.-**

ក្នុងករណី ភតិបតីក្ស័យធន ឥណទាយករបស់ភតិបតី និងភាគីពាក់ព័ន្ធផ្សេងទៀត មិនមានសិទ្ធិច្រើនជាងសិទ្ធិដែលភតិបតីមាន តាមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុនោះ

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

Kol

# ជំពូកទី ៤

## សិទ្ធិ និងភារកិច្ចរបស់ភតិកៈ

**មាត្រា ២៣.-**

ភតិកៈមានភារកិច្ចយល់ព្រមទទួលចលនវត្ថុដែលបានជួល បើចលនវត្ថុនោះ ត្រូវបានប្រគល់ទាន់ពេលវេលាកំណត់ និងត្រឹមត្រូវតាមកិច្ចព្រមព្រៀងផ្គត់ផ្គង់ ។ បើចលនវត្ថុដែលបានជួលមិនត្រូវបានប្រគល់ ឬ ប្រគល់យឺតពេល ឬ មិនត្រូវតាមកិច្ចព្រមព្រៀងផ្គត់ផ្គង់ទេនោះ នៅពេលយល់ព្រម ឬ មុនពេលយល់ព្រម ប៉ុន្តែពុំមែនក្រោយពេលយល់ព្រមទទួលនោះទេ ភតិកៈមានសិទ្ធិបដិសេធចលនវត្ថុនោះ ហើយទាមទារភ្លាមឱ្យអ្នកផ្គត់ផ្គង់ជួសជុលវិការៈនោះ ឬ រំលាយភតិសន្យាហិរញ្ញវត្ថុ ប៉ុន្តែគ្មានសិទ្ធិរំលាយ ដកហូត ឬ កែប្រែកិច្ចព្រមព្រៀងផ្គត់ផ្គង់ ដោយពុំមានការយល់ព្រមពីភតិបតីឡើយ ។

ភតិបតីមានសិទ្ធិឱ្យអ្នកផ្គត់ផ្គង់ប្រគល់ចលនវត្ថុ ស្របតាមកិច្ចព្រមព្រៀងផ្គត់ផ្គង់ តែមិនមានភារកិច្ចទទួលខុសត្រូវលើការខូចខាត ដោយសារការខកខានរបស់អ្នកផ្គត់ផ្គង់ឡើយ ។

**មាត្រា ២៤.-**

ការយល់ព្រមទទួលចលនវត្ថុ អាចជាឯកសារឬអាចតាមរយៈមធ្យោបាយផ្សេងៗទៀត ដូចខាងក្រោម :

ក-ក្រោយពេលដែលភតិកៈបានពិនិត្យចលនវត្ថុ ដែលត្រូវជួលនោះរួចហើយ ហើយបានបញ្ជាក់ថា អាចទទួលយកបាន ទោះបីជាចលនវត្ថុនោះស្រប ឬ មិនស្រប តាមកិច្ចព្រមព្រៀងផ្គត់ផ្គង់ក៏ដោយ

ខ-ភតិកៈមិនបានជូនដំណឹងទាន់ពេលវេលាដែលបានកំណត់ក្នុងកិច្ចព្រមព្រៀងផ្គត់ផ្គង់ ពីភាពមិនស្របតាមកិច្ចព្រមព្រៀងផ្គត់ផ្គង់ទៅភតិបតី និងអ្នកផ្គត់ផ្គង់ ដើម្បីឱ្យអ្នកផ្គត់ផ្គង់ ឬ ភតិបតីអាចដោះស្រាយទាន់ពេលវេលា ក្រោយពេលបានទទួលដំណឹងនោះ

គ-កិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុអាចចែងថា ភតិកៈត្រូវបានចាត់ទុកថា

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

បានយល់ព្រមទទួលចលនវត្ថុ លើកលែងតែភតិបតីបានទទួលសេចក្ដីជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការបដិសេធរបស់ភតិកៈ ដែលមានរាយលម្អិតពីមូលហេតុច្បាស់លាស់ ក្នុងរយៈពេលកំណត់ដប់ (១០) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីភតិកៈបានទទួលចលនវត្ថុនោះ ។

**មាត្រា ២៥._**

តាមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ភតិកៈមានកាតព្វកិច្ចបង់ថ្លៃឈ្នួលតាមកិច្ចព្រមព្រៀងដោយមិនអាចបដិសេធបាន នៅពេលដែលភតិកៈ បានយល់ព្រមទទួលចលន-វត្ថុជាផ្លូវការហើយ ។

**មាត្រា ២៦._**

ភតិកៈ ត្រូវប្រើប្រាស់ចលនវត្ថុឱ្យ បានត្រឹមត្រូវ តាមមុខសញ្ញាប្រើប្រាស់ស្របតាមច្បាប់ វិធាន និងបទបញ្ញាជាធរមាន និងតាមលក្ខណៈបច្ចេកទេស ។ ភតិកៈក៏ត្រូវចំណាយលើការថែទាំ និងជួសជុលចលនវត្ថុឱ្យនៅល្អ និងអាចប្រើប្រាស់បាន លើកលែងតែកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុមានចែងផ្សេងពីនេះ ។

**មាត្រា ២៧._**

នៅដំណាក់កាលផុតរយៈពេល ឬ នៅពេលរំលាយកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ និងក្នុងករណីមិនបានទិញ ឬ មិនបានជួលបន្តទេនោះ ភតិកៈត្រូវប្រគល់ចលនវត្ថុដែលបានជួលទៅឱ្យភតិបតីវិញ ដោយរក្សាលក្ខណៈដូចដើម លើកលែងតែការសឹករេចរឹលធម្មតា ។

**មាត្រា ២៨._**

ភតិកៈ ត្រូវទទួលខុសត្រូវចំពោះការបាត់បង់ចលនវត្ថុ ដែលបានជួល ចាប់ពីពេលទទួលរហូតដល់ពេលប្រគល់ចលនវត្ថុទៅភតិបតីវិញ ។

**មាត្រា ២៩._**

ភតិកៈមិនត្រូវដាក់ជាហ៊ីប៉ូតែក ដាក់បញ្ចាំ ទាមទារឱ្យឃាត់ទុក ចលនវត្ថុដែលបានជួល [illegible]មានបន្ទុកផ្សេងទៀតទៅលើចលនវត្ថុដែលបានជួលឡើយ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា ៣០.-**

ភតិកៈ មានកាតព្វកិច្ចផ្តល់ព័ត៌មានជាលាយលក្ខណ៍អក្សរទៅភតិបតី អំពីទីតាំងបច្ចុប្បន្ន និងការប្តូរទៅទីតាំងថ្មីនៃចលនវត្ថុដែលបានជួល លើកលែងតែកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុមានចែងផ្សេងពីនេះ ។

**មាត្រា ៣១.-**

កាតព្វកិច្ចរបស់អ្នកផ្គត់ផ្គង់ តាមកិច្ចព្រមព្រៀងផ្គត់ផ្គង់ ក៏ត្រូវពាក់ព័ន្ធជាមួយភតិកៈផងដែរ ប្រៀបដូចជាភតិកៈជាភាគីមួយនៃកិច្ចព្រមព្រៀងផ្គត់ផ្គង់ ហើយចលនវត្ថុដែលបានជួល ហាក់ដូចជាត្រូវបានផ្គត់ផ្គង់ផ្ទាល់ទៅឱ្យភតិកៈ ។ ប៉ុន្តែអ្នកផ្គត់ផ្គង់មិនទទួលខុសត្រូវលើការៈមួយចំពោះភតិកៈផង និងភតិបតីផងនោះទេ ។

សិទ្ធិរបស់ភតិកៈ នៅក្នុងកិច្ចព្រមព្រៀងផ្គត់ផ្គង់ដែលភតិកៈបានយល់ព្រម ហើយមិនត្រូវបានប៉ះពាល់ ដោយសារតែការកែប្រែលក្ខខណ្ឌណាមួយនៃកិច្ចព្រមព្រៀងផ្គត់ផ្គង់ទេ លើកលែងតែភតិកៈបានយល់ព្រមលើការកែប្រែនោះ ។

**មាត្រា ៣២.-**

ភតិកៈមិនត្រូវជួលបន្ត ចាត់ចែង ឬ ផ្ទេរសិទ្ធិកាន់កាប់ ឬ ប្រើប្រាស់ចលនវត្ថុ ដែលបានជួល ឬ សិទ្ធិណាមួយផ្សេងទៀត ក្រោមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីភតិបតី និងមិនត្រូវចំណុះសិទ្ធិរបស់តតិយភាគីឡើយ ។ ការជួលបន្ត ការចាត់ចែង ឬ ការផ្ទេរ ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីភតិបតី ត្រូវចាត់ទុកជាមោឃៈ និងត្រូវបានចាត់ទុកថា ល្មើសច្បាប់នេះ និងច្បាប់ផ្សេងទៀត ។

## ជំពូកទី ៥

## អាជ្ញាធរអាណាព្យាបាល និងអំណាចចេញបទបញ្ញា

**មាត្រា ៣៣.-**

ធនាគារជាតិនៃកម្ពុជា បំពេញតួនាទីជាអាជ្ញាធរអាណាព្យាបាលលើគ្រឹះស្ថាន ភតិសន្យាហិរញ្ញវត្ថុ ដែលក្នុងតួនាទីនេះ ធនាគារជាតិនៃកម្ពុជា :

១-ចេញ ល្វែរ ឬ ដកហូតអាជ្ញាបណ្ណធ្វើប្រតិបត្តិការ ភតិសន្យាហិរញ្ញវត្ថុ និង កំណត់នីតិវិធីនិងបែបបទនានាអំពីការចេញអាជ្ញាបណ្ណនេះ ។

២-ចេញបទបញ្ជា ដើម្បីអនុវត្តច្បាប់នេះ ដែលអនុញ្ញាតឱ្យកំណត់ច្បាស់ជា អាទិ៍នូវ :

ក-កម្រិតដើមទុនអប្បបរមា

ខ-អនុបាតប្រុងប្រយ័ត្នផ្សេងៗ

គ-ចំណាត់ថ្នាក់ប្រភេទឥណទាន និងការធ្វើសំវិធានធន

ឃ-ប្រព័ន្ធគណនេយ្យ និងបទដ្ឋានដែលពាក់ព័ន្ធ ។

៣-ត្រួតពិនិត្យ តាមវិធីពិនិត្យផ្ទៀងផ្ទាត់ ជាអចិន្ត្រៃយ៍លើឯកសារ និងតាម វិធីត្រួតពិនិត្យតាមកាលវេលាចាំបាច់ ដល់ទីកន្លែងនៃគ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ។

៤-អាចសម្រេចដាក់ទណ្ឌកម្មខាងវិន័យ ក្នុងលក្ខខណ្ឌដែលមានចែងក្នុង មាត្រា ៣៥ នៃច្បាប់នេះ ។

**មាត្រា ៣៤.–**

ប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ អាចអនុវត្តបានដោយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលទទួលបានអាជ្ញាបណ្ណប្រកបមុខរបរធនាគារពីធនាគារជាតិនៃកម្ពុជា ។

ប្រតិបត្តិការទាំងនេះក៏អាចអនុវត្តបានផងដែរ ដោយគ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ដែលត្រូវបានបង្កើតឡើង ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ត្រូវសុំអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា ដើម្បីប្រកប អាជីវកម្មភតិសន្យាហិរញ្ញវត្ថុ ។

គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ មិនត្រូវបានអនុញ្ញាតឱ្យធ្វើប្រតិបត្តិការផ្សេងទៀតរបស់ ធនាគារ ក្រៅពីប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុឡើយ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

## ជំពូកទី ៦
## ទណ្ឌកម្ម

**មាត្រា ៣៥.-**

ប្រសិនបើគ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ បានប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់ ឬ នៃបទបញ្ជាពាក់ព័ន្ធនឹងសកម្មភាពរបស់ខ្លួន ឬ មិនបានធ្វើតាមការដាស់តឿន ឬ មិនបានធ្វើតាមអធិបញ្ជា អាជ្ញាធរអាណាព្យាបាល អាចដាក់ទណ្ឌកម្មខាងវិន័យណាមួយដូចខាងក្រោមនេះ :

-ព្រមាន

-ស្តីបន្ទោស

-ហាមធ្វើប្រតិបត្តិការមួយចំនួន និងកំណត់ព្រំដែនសកម្មភាព

-ព្យួរមុខងារបណ្តោះអាសន្ន ចំពោះអ្នកដឹកនាំម្នាក់ ឬ ច្រើននាក់ ដោយមាន ឬ គ្មានការតែងតាំងអភិបាលបណ្តោះអាសន្ន

-តម្រូវឱ្យលាឈប់ពីការងារជាស្វ័យប្រវត្តិចំពោះអ្នកដឹកនាំម្នាក់ ឬ ច្រើននាក់ ដោយមាន ឬ គ្មានការតែងតាំងអភិបាលបណ្តោះអាសន្ន

-ដាក់ឱ្យស្ថិតនៅក្រោមការអភិបាលបណ្តោះអាសន្ន ជាបន្តបន្ទាប់

-ដកហូតអាជ្ញាបណ្ណជាស្ថាពរ និងការដាក់ឱ្យជម្រះបញ្ជីជាបន្ទាន់ ។

## ជំពូកទី ៧
## អន្តរប្បញ្ញត្តិ

**មាត្រា ៣៦.-**

គ្រឹះស្ថានណាដែលកំពុងធ្វើប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ ដោយគ្មានធីតិសម្បទា ត្រូវដាក់ពាក្យសុំអាជ្ញាបណ្ណ ទៅអាជ្ញាធរអាណាព្យាបាល ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ក្នុងរយៈពេល ១២ (ដប់ពីរ) ខែ បន្ទាប់ពីច្បាប់នេះចូលជាធរមាន ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**មាត្រា ៣៧.-**

ច្បាប់នេះត្រូវមានអាទិភាព ប្រសិនបើមានបទប្បញ្ញត្តិនៃច្បាប់ផ្សេងទៀត មិនស្របគ្នានឹងបទប្បញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ៣៨.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៩

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

នស/រកម.០៦០៩.០១០ **នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា

**ហត្ថលេខា**

**ជា ចាន់តូ**

លេខ : ៦៣៥ ច.ល

[illegible] ចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៩

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**[illegible] ជិនកេន**

17/12

# អនុក្រ-១១៤
# ស្ដីពី
# ការដាក់បញ្ចាំ-ផ្ទេរ-នូវសិទ្ធិជួល
# រយៈពេលវែង-ឬសិទ្ធិលើដីសម្បទាន
# សេដ្ឋកិច្ច

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ** ១១៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការដាក់បញ្ចាំ ~ ការផ្ទេរ

## នូវសិទ្ធិលើការជួលរយៈពេលវែង ឬសិទ្ធិលើសម្បទានដីសេដ្ឋកិច្ច

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៤/នស/៩៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/០៥ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែសីហា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី ២៤ ខែ មិនា ឆ្នាំ ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញអនុក្រឹត្យ លេខ ៤៦ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី
- បានឃើញអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០០២ ស្តីពីការចុះបញ្ជីដីធ្លីដែលមានលក្ខណៈដាច់ដោយដុំ
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី ០៧ ខែតុលា ឆ្នាំ ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១៤៦ អនក្រ.បក ចុះថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញអនុក្រឹត្យលេខ ១១១ អនក្រ.បក ចុះថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ ២០០៥ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិនិយោគ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## ស ម្រេ ច

**មាត្រា ១ ._**

អនុក្រឹត្យនេះមានគោលដៅកំណត់គោលការណ៍ និងលក្ខខណ្ឌតម្រូវទាំងឡាយក្នុងការផ្តល់សិទ្ធិដល់អ្នកវិនិយោគក្នុងការដាក់បញ្ចាំសម្រាប់ធានា និងការផ្ទេរនូវសិទ្ធិលើការជួលរយៈពេលវែង ឬ សិទ្ធិលើសម្បទានដី ក្នុងរយៈពេលមិនលើសពីរយៈពេល ដែលមានកំណត់ក្នុងកិច្ចសន្យាជួលរយៈពេលវែង ឬកិច្ចសន្យាសម្បទានដី ។

**មាត្រា ២ ._**

ក្នុងន័យនៃអនុក្រឹត្យនេះ វាក្យស័ព្ទ ÷

- **ការផ្ទេរសិទ្ធិ** សំដៅដល់ការផ្ទេរនូវសិទ្ធិទាំងឡាយ ដែលមានចែងក្នុងកិច្ចសន្យាសម្បទានដី ឬកិច្ចសន្យាជួលដីរយៈពេលវែង ។
- **ការដាក់បញ្ចាំ** សំដៅដល់ការយកសិទ្ធិលើការជួលរយៈពេលវែង ឬសិទ្ធិលើសម្បទានដីទៅដាក់ធានាការសងបំណុល ។
- **ការជួលរយៈពេលវែង** សំដៅដល់ការជួលអចលវត្ថុដោយរូបវន្តបុគ្គល នីតិបុគ្គល ឬរាជរដ្ឋាភិបាល អនុលោមទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។ ការជួលរយៈពេលវែងនេះ មានរយៈពេល ១៥ (ដប់ប្រាំ) ឆ្នាំ ឬលើស ។
- **សម្បទានដី** សំដៅដល់សម្បទានដីសេដ្ឋកិច្ច ដែលផ្តល់ដោយរដ្ឋដល់វិនិយោគិន ដែលបានបំពេញលក្ខខណ្ឌស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។
- **ភតិសន្យា** សំដៅដល់កិច្ចសន្យាជួលអចលនវត្ថុ ដែលធ្វើឡើងរវាងម្ចាស់ទ្រព្យ និងអ្នកជួលទ្រព្យនោះ ។
- **ភតិបតី** សំដៅដល់ម្ចាស់ទ្រព្យ ឬកម្មសិទ្ធិករ ដែលបានជួលទ្រព្យទៅឱ្យអ្នកដទៃ ។
- **ភតិកៈ** សំដៅដល់អ្នកទទួលជួលទ្រព្យពីម្ចាស់ទ្រព្យ ឬ ពីកម្មសិទ្ធិករ ។
- **លេខាចារឹក** សំដៅដល់ការកត់ត្រារឿងហេតុអ្វីមួយចូលក្នុងសៀវភៅ ឬបញ្ជី តាមរូបមន្តដែលបានកំណត់ដើម្បីគ្រប់គ្រងអចលនវត្ថុឱ្យបានត្រឹមត្រូវតាមច្បាប់ ។
- **បុព្វសិទ្ធិ** សំដៅដល់សិទ្ធិជាពិសេស ដែលឱ្យដាច់ទៅលើមុខងារ ឬទៅលើក្រុមនីមួយៗលើសពីអ្នកដទៃ ។

- **បុរិមា** សំដៅដល់សិទ្ធិដែលបើកឱ្យជនណាម្នាក់បានអ្វីមួយមុនជនឯទៀត ។
- **មតកជន** សំដៅដល់ជនដែលបានស្លាប់ហើយ ។

**មាត្រា ៣ .-**

រាល់ការដាក់បញ្ចាំ ឬ ការផ្ទេរនូវសិទ្ធិលើការជួលរយៈពេលវែង ឬលើសម្បទានដី មិនមែនជាការដាក់បញ្ចាំដី ឬការផ្ទេរដី ដែលអ្នកវិនិយោគបានទទួលសម្បទានដីពីរដ្ឋ ឬបានជួលរយៈពេលវែងឡើយ ។

ចំពោះដីសម្បទានណាដែលពុំទាន់បានដំណើរការស្របតាមលក្ខខណ្ឌនៃកិច្ចសន្យា អ្នកវិនិយោគមិនអាចផ្ទេរ ឬបញ្ចាំបន្តទៀតជាដាច់ខាត ។

**មាត្រា ៤ .-**

សម្បទានដីជាសិទ្ធិស្របច្បាប់ដែលបានចែងក្នុងឯកសារគតិយុត្ត ចេញដោយអាជ្ញាធរមានសមត្ថកិច្ច តាមអំណាចឆន្ទានុសិទ្ធិឱ្យរូបវន្តបុគ្គល ឬនីតិបុគ្គល ឬក្រុមមនុស្ស ដើម្បីកាន់កាប់ដី និងសិទ្ធិប្រើប្រាស់ដីតាមលក្ខខណ្ឌកំណត់ជាក់លាក់ ។

សម្បទានដីអាចបង្កើតបានតែសិទ្ធិក្នុងរយៈពេលមួយជាកំណត់តាមកិច្ចសន្យា ដែលបានបង្កើតសម្បទាននោះ ។ សិទ្ធិសម្បទានដីមិនអាចឈានដល់ការបង្កើតនូវសិទ្ធិកម្មសិទ្ធិលើដី ដែលបានផ្តល់ជាសម្បទាន ជាប្រយោជន៍ដល់សាមីជននោះទេ ។

**មាត្រា ៥ .-**

មានតែអចលនវត្ថុ ដែលបានចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីដីធ្លីទេ ទើបអាចជាកម្មវត្ថុនៃការធ្វើសម្បទាន ឬការជួលរយៈពេលវែងបាន ។

ក្នុងករណីនៃការជួលដែលផ្តល់ដោយរាជរដ្ឋាភិបាល ហើយដីជាកម្មវត្ថុនៃការជួលនៅពុំទាន់មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុនៅឡើយនោះ កិច្ចសន្យាជួលត្រូវចុះហត្ថលេខាដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រី ឬប្រធានស្ថាប័ន ឬអភិបាលខេត្ត ក្រុងពាក់ព័ន្ធ។

**មាត្រា ៦ .-**

សម្បទានដី ឬការជួលរយៈពេលវែង ត្រូវធ្វើលេខាចារឹកនៅលើប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬ លើវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវចេញវិញ្ញាបត្រសម្គាល់សិទ្ធិជួលរយៈពេលវែង ឬ វិញ្ញាបនបត្រសម្គាល់សិទ្ធិសម្បទានដីសេដ្ឋកិច្ច ។

រាល់ការដាក់បញ្ចាំ ឬការផ្ទេរនូវសិទ្ធិលើសម្បទានដី ឬលើការជួលរយៈពេលវែង ត្រូវធ្វើលេខាចារឹកលើវិញ្ញាបនបត្រសម្គាល់សិទ្ធិជួលរយៈពេលវែង ឬលើវិញ្ញាបនបត្រសម្គាល់សិទ្ធិសម្បទានដីសេដ្ឋកិច្ច។

**មាត្រា ៧ ._**

ភតិក: ឬសម្បទានិក មានសិទ្ធិក្នុងការដាក់បញ្ចាំ ឬការផ្ទេរនូវសិទ្ធិលើការជួលរយ:ពេលវែង ឬសិទ្ធិលើសម្បទានដី ព្រមជាមួយនឹងអគារ ឬ/និងអចលនវត្ថុដទៃទៀត ដែលខ្លួនបានវិនិយោគលើដី លើកលែងតែមានការចែងផ្សេងពីនេះនៅក្នុងកិច្ចសន្យាជួល ឬកិច្ចសន្យាសម្បទាន ឬការកំណត់នៃច្បាប់។

**មាត្រា ៨ ._**

នៅពេលដែលភតិក: ឬសម្បទានិកស្លាប់ ទាយាទរបស់មតកជន អាចបន្តសិទ្ធិក្នុងកិច្ចសន្យាជួល ឬសម្បទានដី បានត្រឹមតែក្នុងរយ:ពេលនៃកិច្ចសន្យាជួលរយ:ពេលវែង ឬកិច្ចសន្យាសម្បទានដីតែប៉ុណ្ណោះ។

រូបវន្តបុគ្គល ឬនីតិបុគ្គល ឬក្រុមមនុស្សដែលបានទទួលការអនុញ្ញាតិឱ្យជួលដីពីរដ្ឋ អាចធ្វើការជួលបន្តទៅឱ្យតតិយជនបាន បើមានការអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ចជាមុន។

**មាត្រា ៩ ._**

ក្នុងករណីណាក៏ដោយ ម្ចាស់បំណុលមិនអាចក្លាយជាកម្មសិទ្ធិករ និងគ្មានសិទ្ធិទាមទារសិទ្ធិកម្មសិទ្ធិលើអចលនទ្រព្យ ដែលកូនបំណុលរបស់ខ្លួនបានជួល ឬបានទទួលសម្បទាន ហើយបានវិនិយោគ និងយកសិទ្ធិជួល ឬសម្បទាននេះទៅដាក់បញ្ចាំបានឡើយ។ កិច្ចសន្យាទាំងឡាយដែលចែងផ្ទុយពីនេះ ត្រូវទុកជាមោឃ:។

ម្ចាស់បំណុលមានសិទ្ធិប្តឹងកូនបំណុលដែលបានដាក់បញ្ចាំសិទ្ធិ ទៅតុលាការដើម្បីដោះស្រាយស្របតាមច្បាប់ និងនីតិវិធីជាធរមាន យកមកសងបំណុលតាមបុព្វសិទ្ធិ និងបរិមាដែលខ្លួនមានជាងម្ចាស់បំណុលដទៃទៀត ត្រឹមតែក្នុងអំឡុងពេលដែលមានចែងនៅក្នុងកិច្ចសន្យាជួល ឬ កិច្ចសន្យាសម្បទានប៉ុណ្ណោះ។

ម្ចាស់បំណុលគ្មានសិទ្ធិទាមទារនូវសិទ្ធិចាត់ចែងលើអចលនទ្រព្យ ដែលកូនបំណុលរបស់ខ្លួនបានទទួលជួល ឬសម្បទានពីភាគីទីបីបានឡើយ។

**មាត្រា ១០ ._**

វិញ្ញាបនបត្រសម្គាល់សិទ្ធិជួលរយ:ពេលវែង និងវិញ្ញាបនបត្រសម្គាល់សិទ្ធិសម្បទានដីសេដ្ឋកិច្ច មានកំណត់អំពីប្រភេទអចលនវត្ថុ ទំហំ ទីតាំង អត្តសញ្ញាណនៃកម្មសិទ្ធិករ អត្តសញ្ញាណភតិក: ឬសម្បទានិក និងរយ:ពេលនៃការជួល ឬសម្បទាន។ គំរូនៃវិញ្ញាបនបត្រសម្គាល់សិទ្ធិជួលរយ:ពេលវែង និងវិញ្ញាបនប័ត្រសម្គាល់សិទ្ធិសម្បទានដីសេដ្ឋកិច្ច ជាឧបសម្ព័ន្ធទី ១ និងទី២ នៃអនុក្រឹត្យនេះ។

សោហ៊ុយសេវាចេញវិញ្ញាបនបត្រសម្គាល់សិទ្ធិជួលរយ:ពេលវែង វិញ្ញាបនបត្រសម្គាល់សិទ្ធិសម្បទានដីសេដ្ឋកិច្ច និងការធ្វើលេខាចារឹក ត្រូវកំណត់ដោយប្រកាសរួមរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា ១១ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អភិបាលគ្រប់ខេត្ត ក្រុង គ្រប់ប្រធានស្ថាប័ន អង្គភាពដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ , ថ្ងៃទី ២៩ ខែសីហា ឆ្នាំ ២០០៧

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**<u>កន្លែងទទួល:</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១២
-រាជកិច្ច
- ឯកសារ-កាលប្បវត្តិ